ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានរតនាគារជាតិ

# គោលការណ៍ណែនាំ
# ស្តីពី
# កិច្ចបញ្ជិកាគណនេយ្យនៃប្រតិបត្តិការថវិកា
# ក្នុងគណនេយ្យថវិកា

២០២៤

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៩៩០ សហវ.ប្រក.អសគន

# ប្រកាស
## ស្តីពី
## ការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពី
## កិច្ចបញ្ជិកាគណនេយ្យនៃប្រតិបត្តិការថវិកាក្នុងគណនេយ្យថវិកា

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០០១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៥ ស្ដីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៨/៥៩០ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៨ ស្ដីពីការកែសម្រួលមាត្រាមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៥ ស្ដីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ ស្ដីពីការកែសម្រួលមាត្រា៥០ មាត្រា៥១ មាត្រា៥២ និងមាត្រា៥៣នៃអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៣ ស្ដីពីការបង្កើតនិងការបំពេញបន្ថែមអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថលឱ្យស្ថិតនៅក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៥៨ អនក្រ.បក ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការបង្កើតនិងការបំពេញបន្ថែមអគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៨ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សានីតិកម្មនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២២ ស្ដីពីការបង្កើតវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២៣ ស្ដីពីការបង្កើតមជ្ឈមណ្ឌលបណ្ដុះធុរកិច្ចថ្មី "តេជោ" ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ២៧១ អនក្រ.បក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការរៀបចំនិងប្រព្រឹត្តទៅនៃមជ្ឈមណ្ឌលបណ្ដុះធុរកិច្ចថ្មី "តេជោ"
- បានឃើញអនុក្រឹត្យលេខ ២៨៩ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្ដីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២៥៩ អនក្រ.បក ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្ដីពីការគ្រប់គ្រងថវិកាគណនេយ្យ និងទ្រព្យសម្បត្តិរដ្ឋ នៃគ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.-**

ត្រូវបានដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្ដីពីកិច្ចបញ្ជិកាគណនេយ្យនៃប្រតិបត្តិការថវិកាក្នុងគណនេយ្យថវិកា ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ នៃប្រកាសនេះ។



ឋ

**ប្រការ២.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះគ្រប់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែលរដ្ឋបាលថ្នាក់ក្រោមជាតិ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងនីតិបុគ្គលដទៃទៀតដែលទទួលផលប្រយោជន៍ពីថវិការដ្ឋ។

ប្រកាសនេះ ពុំមានវិសាលភាពអនុវត្តចំពោះសហគ្រាសសាធារណៈឡើយ។

**ប្រការ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ [illegible] ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# គោលការណ៍ណែនាំ

# ស្តីពី

# កិច្ចបញ្ជិកាគណនេយ្យនៃប្រតិបត្តិការថវិកាក្នុងគណនេយ្យថវិកា

ជាឧបសម្ព័ន្ធនៃប្រកាសលេខ ៩៩០........ សហវ.ប្រក ចុះថ្ងៃទី ៣១... ខែ ធ្នូ.......... ឆ្នាំ២០២៤
ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីកិច្ចបញ្ជិកាគណនេយ្យនៃប្រតិបត្តិការថវិកាក្នុងគណនេយ្យថវិកា

# មាតិកានុក្រម


**បញ្ជីអក្សរកាត់** ........ ១

**សេចក្តីផ្តើម** ........ ២

**ជំពូកទី១**

**បទប្បញ្ញត្តិទូទៅ**

**១.១ គោលបំណង** ........ ៤

**១.២ វិសាលភាព** ........ ៤

**១.៣ និយមន័យ** ........ ៤

**ជំពូកទី២**

**គោលការណ៍ទូទៅនៃគណនេយ្យថវិកា**

**២.១ គោលការណ៍គ្រឹះ** ........ ៥

២.១.១ និយមន័យនៃគណនេយ្យថវិកា ........ ៥

២.១.២ មូលដ្ឋាននៃកិច្ចបញ្ជិកាគណនេយ្យថវិកា ........ ៥

២.១.៣ គោលការណ៍ឯកភាគ ........ ៦

២.១.៤ ការិយបរិច្ឆេទគណនេយ្យថវិកា ........ ៦

២.១.៥ រយៈពេលបំពេញបន្ថែម ........ ៦

២.១.៦ ការរៀបចំគណនេយ្យថវិកាតាមអង្គភាពសាធារណៈនីមួយៗ ........ ៦

២.១.៧ រូបិយបណ្ណនិងភាសាសម្រាប់ការកត់ត្រានិងរាយការណ៍ ........ ៦

២.១.៨ ការប្រើប្រាស់មាតិកាថវិកា ........ ៧

២.១.៩ គុណភាពនៃគណនេយ្យថវិកា ........ ៧

**២.២ សមាសធាតុនៃគណនេយ្យថវិកា** ........ ៧

២.២.១ គណនេយ្យចំណូលថវិកា ........ ៧

២.២.២ គណនេយ្យចំណាយថវិកា ........ ៧

**២.៣ តួអង្គពាក់ព័ន្ធនឹងការងារគណនេយ្យថវិកា** ........ ៨

២.៣.១ តួអង្គពាក់ព័ន្ធផ្ទាល់ ........ ៨

២.៣.១.១ អាណាប័ក ........ ៨

២.៣.១.២ អ្នកត្រួតពិនិត្យថវិកា ........ ៩

២.៣.១.៣ គណនេយ្យករសាធារណៈ ........ ១០

២.៣.១.៤ មន្ត្រីគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ........ ១០

២.៣.២ តួអង្គពាក់ព័ន្ធដោយប្រយោល ........ ១១

២.៣.២.១ សវនករ ........ ១១

២.៣.២.២ អង្គនីតិប្បញ្ញត្តិ ........ ១១

២.៣.២.៣ ដៃគូអភិវឌ្ឍន៍ ........ ១១

២.៣.២.៤ សាធារណជន ..... ១១
**២.៤ រំហូរការងារគណនេយ្យថវិកា** ..... ១២
**២.៥ ឯកសារគណនេយ្យថវិកា** ..... ១២
២.៥.១ សក្ខីបត្រដើម ..... ១២
២.៥.២ បញ្ជីគណនេយ្យ ..... ១៣
២.៥.៣ របាយការណ៍ថវិកា ..... ១៣
២.៥.៤ ការរក្សាទុកដាក់ឯកសារគណនេយ្យថវិកា ..... ១៣
**២.៦ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការអនុវត្តគណនេយ្យថវិកា** ..... ១៣
គំនូសបំព្រួញទូទៅនៃរំហូរឯកសារគណនេយ្យថវិកា ..... ១៣

## ជំពូកទី៣
## ចំណាត់ថ្នាក់នៃមាតិកាថវិការដ្ឋ

**៣.១ គោលការណ៍គ្រឹះ** ..... ១៤
**៣.២ ការចាត់ថ្នាក់ថវិកា** ..... ១៥
៣.២.១ ចំណូលថវិកា ..... ១៥
៣.២.២ ចំណាយថវិកា ..... ១៥
**៣.៣ ប្រភេទចំណាត់ថ្នាក់នៃមាតិកាថវិការដ្ឋ** ..... ១៦
៣.៣.១ ចំណាត់ថ្នាក់សេដ្ឋកិច្ច ..... ១៦
៣.៣.២ ចំណាត់ថ្នាក់កម្មវិធី ..... ១៦
៣.៣.៣ ចំណាត់ថ្នាក់រដ្ឋបាល ..... ១៧
៣.៣.៤ ចំណាត់ថ្នាក់ភូមិសាស្ត្រ ..... ១៧
៣.៣.៥ ចំណាត់ថ្នាក់មុខងារ ..... ១៨
៣.៣.៦ ចំណាត់ថ្នាក់គម្រោង ..... ១៨
៣.៣.៧ ចំណាត់ថ្នាក់មូលនិធិ ..... ១៩
**៣.៤ ភាពប្រទាក់ក្រឡាគ្នារវាងថវិកានិងចំណាត់ថ្នាក់នៃមាតិកាថវិការដ្ឋ** ..... ១៩
**៣.៥ មាតិកាគណនី** ..... ១៩
**៣.៦ ប្លង់គណនេយ្យនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** ..... ២០
**៣.៧ ការកំណត់មាតិកាថវិកា** ..... ២០

## ជំពូកទី៤
## កិច្ចប្រតិបត្តិការថវិកា

**៤.១ កិច្ចប្រតិបត្តិការចំណូលថវិកា** ..... ២១
៤.១.១ លក្ខខណ្ឌទូទៅនៃការទទួលស្គាល់ចំណូលថវិកា ..... ២២
៤.១.២ លក្ខខណ្ឌដោយឡែកនៃការទទួលស្គាល់ចំណូលថវិកា ..... ២៣

៤.១.២.១ ប្រតិបត្តិការសាច់ប្រាក់បានទទួលនៅក្នុងឆ្នាំអនុវត្តថវិកា ប៉ុន្តែពុំទាន់ដឹងច្បាស់អំពីមុខសញ្ញាចំណូលថវិកា ........ ២៣
៤.១.២.២ ប្រតិបត្តិការចំណូលព្រម-ចំណាយព្រម (ករណីទូទាត់រង្វាន់) ........ ២៥
៤.១.២.៣ ចំណូលពីការកាត់ពន្ធលើអាណត្តិបើកប្រាក់ ........ ២៧
៤.១.២.៤ ចំណូលឧបត្ថម្ភធនពីរដ្ឋបាលសាធារណៈ ឬប្រភពផ្សេងៗទៀត ........ ២៨
៤.១.២.៥ ចំណូលពីដៃគូអភិវឌ្ឍន៍ ឬ ពីសប្បុរសជន ........ ២៩
៤.១.២.៦ ការបង់ភាគលាភ ឬ អតិរេកចូលថវិកាជាតិ ........ ៣០
៤.១.២.៧ ការបង្វែរប្រាក់ពីគណនីប្រាក់បញ្ញើ បង់ចូលជាចំណូលថវិកា ........ ៣១
៤.១.២.៨ ចំណូលថវិការដ្ឋពីកម្រៃរតនាគារ ........ ៣៣
៤.១.២.៩ ចំណេញពិតពីអត្រាប្តូរប្រាក់ ........ ៣៤
៤.១.២.១០ ចំណូលមិនឆ្លងកាត់រតនាគារជាតិ ........ ៣៥
៤.១.២.១១ បុរេប្រទានបានទទួល ........ ៣៥
៤.១.២.១២ ប្រតិបត្តិការចំណូលផ្សេងទៀត ........ ៣៥
៤.១.៣ ធនធានហិរញ្ញប្បទាន ........ ៣៥
៤.១.៤ រយៈពេលនៃការទទួលសលាកបត្របង្វែរចំណូល សម្រាប់ការទទួលស្គាល់ចំណូលថវិកា ........ ៣៦
៤.១.៥ ការសងប្រាក់ចំណូល ........ ៣៧
**៤.២ កិច្ចប្រតិបត្តិការចំណាយថវិកា** ........ ៣៧
៤.២.១ លក្ខខណ្ឌទូទៅនៃការទទួលស្គាល់ចំណាយថវិកា ........ ៣៨
៤.២.២ លក្ខខណ្ឌដោយឡែកនៃការទទួលស្គាល់ចំណាយថវិកា ........ ៣៩
៤.២.២.១ ប្រតិបត្តិការចំណាយកើតមាននៅក្នុងឆ្នាំអនុវត្តថវិកា ប៉ុន្តែសាច់ប្រាក់ចំណាយត្រូវបានទូទាត់នៅក្នុងឆ្នាំបន្ទាប់ ........ ៣៩
៤.២.២.២ ប្រតិបត្តិការសាច់ប្រាក់បានចំណាយមុន និងដឹងច្បាស់ថាមានជាមុខសញ្ញាចំណាយថវិកា នៅក្នុងឆ្នាំអនុវត្ត ........ ៤០
៤.២.២.៣ ប្រតិបត្តិការរំហូរសាច់ប្រាក់ចេញ មុនពេលមានឥណទានថវិកា និងដឹងច្បាស់ថាជាមុខសញ្ញាចំណាយថវិកា នៅពេលក្រោយ ........ ៤១
៤.២.២.៤ ប្រតិបត្តិការចំណូលព្រម-ចំណាយព្រម (ករណីទូទាត់រង្វាន់) ........ ៤៣
៤.២.២.៥ ការកាត់ពន្ធលើអាណត្តិបើកប្រាក់ ........ ៤៤
៤.២.២.៦ ការទូទាត់ទឹកប្រាក់តម្កល់ធានាសុពលភាព ........ ៤៥
៤.២.២.៧ ចំណាយឧបត្ថម្ភធនទៅរដ្ឋបាលផ្សេងៗ ........ ៤៥
៤.២.២.៨ ការទូទាត់ចំណាយចូលគណនីប្រាក់បញ្ញើ ........ ៤៨
៤.២.២.៩ ចំណាយថវិកាប្រភពពីដៃគូអភិវឌ្ឍន៍ ឬ ថវិកាសប្បុរសជន ........ ៤៨
៤.២.២.១០ ខាតពិតពីអត្រាប្តូរប្រាក់ ........ ៥០
៤.២.២.១១ ចំណាយមិនឆ្លងកាត់រតនាគារជាតិ ........ ៥១
៤.២.២.១២ ប្រតិបត្តិការចំណាយផ្សេងទៀត ........ ៥២

៤.២.៣ បន្ទុកហិរញ្ញប្បទាន ........................................ ៥២

៤.២.៤ រយៈពេលនៃការទទួលអាណត្តិបើកប្រាក់ សម្រាប់ការទទួលស្គាល់ចំណាយថវិកា ........................................ ៥៣

៤.២.៥ សំណៃសចំណាយ ........................................ ៥៣

**៤.៣ ការចុះកិច្ចបញ្ជិកាគណនេយ្យថវិកា ........................................ ៥៣**

៤.៣.១ ការកត់ត្រាប្រតិបត្តិការចំណូលនិងចំណាយថវិកា ........................................ ៥៤

៤.៣.២ ការកែតម្រូវលើកិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិកា ........................................ ៥៤

៤.៣.៣ រយៈពេលបំពេញបន្ថែម សម្រាប់ការអនុវត្តចំណូលនិងចំណាយថវិកា ........................................ ៥៤


## ជំពូកទី៥

## ការបិទបញ្ជីគណនេយ្យថវិកា និងការរៀបចំរបាយការណ៍ថវិកា


**៥.១ ការត្រៀមលក្ខណៈមុននឹងបិទបញ្ជីគណនេយ្យថវិកានៅចុងការិយបរិច្ឆេទថវិកា ........ ៥៥**

៥.១.១ ក្របខ័ណ្ឌពេលវេលា ........................................ ៥៥

៥.១.២ ការគ្រប់គ្រងឥណទានថវិកា ........................................ ៥៦

៥.១.៣ ការកែប្រែចំណាត់ថ្នាក់ថវិកា ........................................ ៥៦

៥.១.៤ ការផ្ទៀងផ្ទាត់ប្រតិបត្តិការថវិកា ........................................ ៥៦

៥.១.៥ ការកំណត់អំពីទឹកប្រាក់ត្រូវទូទាត់នៅឆ្នាំបន្ទាប់ ........................................ ៥៧

**៥.២ ការបិទបញ្ជីគណនេយ្យថវិកា ........................................ ៥៨**

៥.២.១ ក្របខ័ណ្ឌពេលវេលា ........................................ ៥៨

៥.២.២ កិច្ចដំណើរការបិទបញ្ជីគណនេយ្យថវិកា ........................................ ៥៨

៥.២.៣ តួអង្គពាក់ព័ន្ធ ........................................ ៥៩

**៥.៣ ការរៀបចំរបាយការណ៍ថវិកា ........................................ ៥៩**

៥.៣.១ មូលដ្ឋាននៃការរៀបចំរបាយការណ៍ថវិកា ........................................ ៥៩

៥.៣.២ ប្រភេទរបាយការណ៍ថវិកា ........................................ ៦០

៥.៣.៣ អ្នករៀបចំរបាយការណ៍ថវិកា ........................................ ៦០

៥.៣.៤ កាលកំណត់នៃការរៀបចំរបាយការណ៍ថវិកា ........................................ ៦០

៥.៣.៥ ការបញ្ជូនរបាយការណ៍ថវិកា ........................................ ៦០

**៥.៤ ការគណនាលទ្ធផល ........................................ ៦០**

៥.៤.១ លទ្ធផលថវិកា ........................................ ៦១

៥.៤.២ លទ្ធផលសាច់ប្រាក់ ........................................ ៦១

៥.៤.៣ លទ្ធផលគណនេយ្យ ........................................ ៦១

៥.៤.៤ អតិរេកដែលអាចប្រើប្រាស់បាន ........................................ ៦១

## ជំពូកទី៦
## ការត្រួតពិនិត្យនិងសវនកម្ម


**៦.១ តួអង្គពាក់ព័ន្ធ** ............ ៦៣

**៦.២ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន** ............ ៦៣


## ឧបសម្ព័ន្ធ


**ឧបសម្ព័ន្ធ១៖ សទ្ទានុក្រម** ............ ៦៤

**ឧបសម្ព័ន្ធ២៖ ទម្រង់ឯកសារគណនេយ្យថវិកា** ............ ៦៦

២.១. គំរូសលាកបត្របង្វែរចំណូល ............ ៦៦

២.២. គំរូអាណត្តិបើកប្រាក់ចំណាយថវិកា ............ ៦៧

២.៣. គំរូសលាកបត្រតាមដានចំណូលថវិកា ............ ៦៩

២.៤. គំរូសលាកបត្រតាមដានចំណាយថវិកា ............ ៧០

២.៥. គំរូសលាកបត្របង់សំណៃសចំណាយ ............ ៧១

**ឧបសម្ព័ន្ធ៣៖ ទម្រង់របាយការណ៍ថវិកា** ............ ៧២

៣.១. ទម្រង់របាយការណ៍ចំណូលថវិកា ............ ៧២

៣.២. ទម្រង់របាយការណ៍ចំណាយថវិកា ............ ៧៦

# បញ្ជីអក្សរកាត់

| | | |
|---|---|---|
| ADB | Asian Development Bank | ធនាគារអភិវឌ្ឍន៍អាស៊ី |
| AFD | Agence Française de Développement | ទីភ្នាក់ងារបារាំងសម្រាប់អភិវឌ្ឍន៍ |
| ASYCUDA | Automated System for Customs Data | ប្រព័ន្ធស្វ័យប្រវត្តិកម្មទិន្នន័យគយ |
| EU | European Union | សហភាពអឺរ៉ុប |
| FMIS | Financial Management Information System | ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| IMF | International Monetary Fund | មូលនិធិរូបិយវត្ថុអន្តរជាតិ |
| NRMIS | Non-tax Revenue Management Information System | ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ |
| UNICEF | United Nations Children's Fund | មូលនិធិកុមាររបស់អង្គការសហប្រជាជាតិ |
| WB | World Bank | ធនាគារពិភពលោក |
| ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធាណៈឆ្នាំ២០២៣ | | ព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ស្តីពីច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ |
| អនុក្រឹត្យស្តីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ | | អនុក្រឹត្យលេខ ២៨៩ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងថវិកា និងគណនេយ្យសាធារណៈ |

## សេចក្តីផ្តើម

"កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ" គឺជាកម្មវិធីកែទម្រង់ស្នូលមួយ ក្នុងចំណោមកម្មវិធីកែទម្រង់សំខាន់ៗនៃវិស័យសាធារណៈ របស់រាជរដ្ឋាភិបាលកម្ពុជា ដែលត្រូវបានដាក់ឱ្យអនុវត្តក្នុងគោលបំណងលើកកម្ពស់ប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព ពង្រឹងគណនេយ្យភាព និងបង្ហាញអំពីតម្លាភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីធានាបាននូវការផ្តល់សេវាសាធារណៈទាន់ពេល ចំទិសដៅ និងចំមនុស្សគោលដៅ។ ជាមួយគ្នានេះ ផែនទីចង្អុលផ្លូវនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក៏ត្រូវបានរៀបចំជាកំណត់របៀបវារៈគ្រប់ជ្រុងជ្រោយ ដែលសំដៅទៅរកភាពច្បាស់លាស់ ភាពងាយស្រួល ភាពប្រសើរឡើង និងភាពសុខដុមនៃដំណើរការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមរយៈការបង្កើតនិងដាក់ឱ្យដំណើរការនូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលប្រព័ន្ធរួមថ្មីនេះនឹងគ្របដណ្តប់រាល់ប្រតិបត្តិការរបស់រាជរដ្ឋាភិបាល ដើម្បីធានាបាននូវការអនុវត្តស្តង់ដាដូចគ្នា សម្រាប់គ្រប់ក្រសួង ស្ថាប័នទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ កម្មវិធីកែទម្រង់នេះ ត្រូវបានប្រកាសដាក់ឱ្យអនុវត្តជាបន្តបន្ទាប់ចាប់ពីចុងឆ្នាំ២០០៤ សម្រាប់ដំណាក់កាលទី១ "ភាពជឿទុកចិត្តនៃថវិកា" និងរហូតមកដល់ដំណាក់កាលទី៤ "ការបង្កើនគណនេយ្យភាពសមិទ្ធកម្ម"ដែលជាគោលដៅចម្បងនៃដំណាក់កាលចុងក្រោយ និងត្រូវសម្រេចឱ្យបាននៅឆ្នាំ២០២៧ ខាងមុខនេះ។ សមិទ្ធផលនៃការអនុវត្តកម្មវិធីកែទម្រង់នេះ បាននិងកំពុងប្រែក្លាយប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា ជាជំហានៗ ឱ្យទៅជាប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមួយ ស្របតាមបទដ្ឋាននិងឧត្តមានុវត្តន៍ជាអន្តរជាតិ។ ជាលទ្ធផល ឱនភាពសាច់ប្រាក់បានប្រែទៅជាអតិរេកសាច់ប្រាក់, បំណុលកកស្ទះត្រូវបានលុបបំបាត់, ការប្រើប្រាស់ប្រព័ន្ធធនាគារ (រដ្ឋនិងឯកជន) ត្រូវបានពង្រីក, អង្គភាពសវនកម្មផ្ទៃក្នុងត្រូវបានបង្កើតតាមក្រសួង ស្ថាប័ន, និងក្របខ័ណ្ឌច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ(មួយចំនួនថ្មី) រួមមានទាំងបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការត្រួតពិនិត្យថវិកានិងគណនេយ្យសាធារណៈ ត្រូវបានពិនិត្យឡើងវិញ និងអនុម័តដាក់ឱ្យប្រើប្រាស់, ក៏ដូចជានីតិវិធីលម្អិតសម្រាប់អនុវត្តថវិកានឹងត្រូវបានរៀបចំឡើងវិញ, អង្គភាពថវិកា/ថវិកាកម្មវិធីត្រូវបានរៀបចំនិងដាក់ឱ្យដំណើរការ, ចំណាត់ថ្នាក់នៃមាតិកាថវិកាថ្មី និងប្លង់គណនេយ្យថ្មីត្រូវបានរៀបចំ, ប្រព័ន្ធ FMIS ត្រូវបានដាក់ឱ្យអនុវត្ត ២ដំណាក់កាល, សមត្ថភាពធនធានមនុស្សនិងស្ថាប័នត្រូវបានពង្រឹងជាបណ្តើរៗ, និងវិមជ្ឈការហិរញ្ញវត្ថុត្រូវបានរៀបចំនិងដាក់ឱ្យអនុវត្តជាជំហានៗ ជាដើម។

ជាមួយគ្នានេះ រាជរដ្ឋាភិបាលក៏បានដាក់ចេញនូវ "យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥" ដែលជាឯកសារតម្រង់ទិសនៃការកែទម្រង់គ្រប់ជ្រុងជ្រោយរយៈពេលវែង ក្នុងការកំណត់យកការកែទម្រង់ប្រព័ន្ធថវិការបស់កម្ពុជាឈានឆ្ពោះទៅលើកកម្ពស់ប្រសិទ្ធភាពនៃការវិភាជថវិកា តាមរយៈការប្រើប្រាស់សូចនាករសមិទ្ធកម្ម ឬហៅថាលទ្ធផលការងារជាមូលដ្ឋានក្នុងក្របខ័ណ្ឌថវិកាសមិទ្ធកម្ម និងប្រសិទ្ធភាពនៃការអនុវត្តថវិកាតាមរយៈការកាត់បន្ថយនីតិវិធីចំណាយ ការផ្ទេរសិទ្ធិអំណាច និងការទទួលខុសត្រូវកាន់តែច្រើន ដល់ក្រសួង ស្ថាប័ន ជាពិសេសអង្គភាពប្រតិបត្តិផ្ទាល់ ស្របជាមួយនឹងការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈផងដែរ។ ជាលទ្ធផលច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០២៣ និងអនុក្រឹត្យស្តីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈឆ្នាំ២០២៣ ត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្ត។ តាមរយៈច្បាប់និងអនុក្រឹត្យថ្មីនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវរៀបចំក្របខ័ណ្ឌគតិយុត្តនានា ដែលក្នុងនោះរួមមាន ប្រកាសសម្រាប់ដាក់ឱ្យអនុវត្តនូវវិធាននិងគោលការណ៍ណែនាំដែលពាក់ព័ន្ធនឹងកិច្ចបញ្ជិកាគណនេយ្យថវិកា ដែលនឹងត្រូវចាប់ផ្តើមអនុវត្តនៅឆ្នាំ២០២៥តទៅ ដើម្បីឈានទៅអនុវត្តជាមូលដ្ឋាននូវប្រព័ន្ធគណនេយ្យថវិកា មូលដ្ឋានសាច់ប្រាក់ សម្រាប់ការគាំទ្រដល់ការអនុវត្តពេញលេញនៃប្រព័ន្ធគណនេយ្យសាធារណៈកម្ពុជា ដែលរួមមាន គណនេយ្យថវិកា គណនេយ្យទូទៅ និងគណនេយ្យវិភាគ ព្រមទាំងការរៀបចំជាមូលដ្ឋាននូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីគាំទ្រការអនុវត្តគណនេយ្យសាធារណៈទាំងបីនេះ។ គោលការណ៍ណែនាំស្តីពីកិច្ចបញ្ជិកាគណនេយ្យនៃប្រតិបត្តិការថវិកាក្នុងគណនេយ្យថវិកានឹងក្លាយជាឧបករណ៍មួយដ៏សំខាន់សម្រាប់តួអង្គអនុវត្តថវិកា ដើម្បីគ្រប់គ្រង កត់ត្រា តាមដាន និងរាយការណ៍អំពីការអនុវត្តថវិការបស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ គ្រឹះស្ថានសាធារណៈរដ្ឋបាល និង

នីតិបុគ្គលដទៃទៀតដែលទទួលផលប្រយោជន៍ពីថវិការដ្ឋ ព្រមទាំងអាចចាត់ទុកជាក្របខ័ណ្ឌគតិយុត្តថ្មីមួយទៀតសម្រាប់បម្រើដល់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជា និងសម្រាប់ការរៀបចំជាមូលដ្ឋាននូវទិន្នន័យចំណូលនិងចំណាយថវិការបស់រដ្ឋ ប្រកបដោយភាពពេញលេញ ភាពគ្រប់ជ្រុងជ្រោយ និងមានតម្លាភាព បម្រើដល់ការវិភាគនិងការធ្វើសេចក្តីសម្រេចចិត្តលើការគ្រប់គ្រងថវិកានិងហិរញ្ញវត្ថុរបស់អ្នកគ្រប់គ្រងនិងអ្នកពាក់ព័ន្ធដទៃទៀត។

គោលការណ៍ណែនាំនេះ ត្រូវបានរៀបចំឡើងដោយផ្អែកលើបទពិសោធន៍ជាក់ស្តែងនៃការអនុវត្តល្អនាពេលកន្លងមករបស់កម្ពុជា និងផ្អែកលើក្របខ័ណ្ឌនិងបទពិសោធន៍នៃការអនុវត្តគណនេយ្យថវិការបស់ប្រទេសបារាំង ព្រមទាំងឧត្តមានុវត្តន៍អន្តរជាតិ ដោយបានផ្សារភ្ជាប់ទៅនឹងបរិបទកម្ពុជាផងដែរ។ គោលការណ៍ណែនាំនេះជាកម្មវត្ថុនៃការធ្វើបច្ចុប្បន្នភាពជាបណ្តើរៗ ស្របតាមការប្រែប្រួលនៃស្ថានការណ៍គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជានិងអន្តរជាតិ។ គោលការណ៍ណែនាំនេះចែកចេញជាជំពូក ជាផ្នែកតូចៗ និងមានជាតារាងឧបសម្ព័ន្ធ ឯកសារសម្រាប់គាំទ្រដល់ការអនុវត្តគណនេយ្យថវិកា។

# ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

ជំពូកទី១នេះនឹងកំណត់អំពីគោលបំណងនៃគណនេយ្យថវិកា វិសាលភាពនៃការអនុវត្តគណនេយ្យថវិកា និងផ្តល់នូវនិយមន័យលើពាក្យបច្ចេកទេសគន្លឹះៗសម្រាប់ជាមូលដ្ឋានក្នុងការស្វែងយល់គណនេយ្យថវិកា។

### ១.១ គោលបំណង

គោលការណ៍ណែនាំនេះ មានគោលបំណងកំណត់នូវគោលការណ៍ វិធាន នីតិវិធី និងបទបញ្ញាជាមូលដ្ឋាន នៃគណនេយ្យថវិកា ព្រមទាំងកិច្ចបញ្ជិកាគណនេយ្យនិងការរាយការណ៍ថវិកា ដើម្បីធានាឱ្យបាននូវប្រសិទ្ធភាព គណនេយ្យភាព និងតម្លាភាព នៃការអនុវត្តថវិកា ស្របតាមក្របខ័ណ្ឌនៃការកែទម្រង់ហិរញ្ញវត្ថុសាធារណៈកម្ពុជា ដូចមានកំណត់ក្នុងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០២៣ និងអនុក្រឹត្យស្តីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ។

គោលការណ៍ណែនាំនេះ នឹងជួយជំរុញដល់ការកត់ត្រា តាមដាន និងរាយការណ៍ ឱ្យបានត្រឹមត្រូវ ទាន់ពេល ប្រកបដោយគុណភាព និងស្របតាមឧត្តមានុវត្តន៍អន្តរជាតិ អំពីការប្រើប្រាស់ឥណទានថវិកា ទាំងចំណូលនិងចំណាយថវិការដ្ឋ ដែលបានអនុញ្ញាតដោយច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំនីមួយៗ ព្រមទាំងអាចឆ្លើយតបទៅនឹងតម្រូវការនៃទិន្នន័យថវិកាដែលត្រូវរាយការណ៍ក្នុងច្បាប់ទូទាត់ថវិកាប្រចាំឆ្នាំនីមួយៗ។ ទន្ទឹមនេះ គោលការណ៍ណែនាំនេះ ផ្តល់ភាពងាយស្រួលដល់តួអង្គពាក់ព័ន្ធនឹងការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ ក្នុងការសិក្សា ស្វែងយល់ និងយកទៅអនុវត្តលើការងារគ្រប់គ្រងហិរញ្ញវត្ថុរបស់អង្គភាពសាមី ដោយសារតែគោលការណ៍ណែនាំនេះ គឺជាបណ្តុំនៃគោលការណ៍គ្រឹះទាំងឡាយសម្រាប់អនុវត្តគណនេយ្យថវិកា ដោយបង្ហាញទាំងគោលការណ៍ ទ្រឹស្តី និងឧទាហរណ៍ សម្រាប់ជាមូលដ្ឋានយកទៅអនុវត្ត។

គោលការណ៍ណែនាំនេះត្រូវបានរៀបចំឡើងដោយផ្អែកលើបទពិសោធន៍នៃការអនុវត្តរបស់កម្ពុជា និងអន្តរជាតិ ព្រមទាំងអាចធានាបាននូវអនុលោមភាពមាត្រា៨៧នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០២៣ និងមាត្រា១១៦នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ។

គោលការណ៍ណែនាំនេះ ជាកម្មវត្ថុនៃការធ្វើបច្ចុប្បន្នភាពជាបន្តបន្ទាប់ ទៅតាមការប្រែប្រួលនៃបរិការណ៍សង្គម-សេដ្ឋកិច្ច ទាំងកម្រិតជាតិទាំងអន្តរជាតិ។ ជាមួយគ្នានេះ គោលការណ៍ណែនាំនេះ អាចត្រូវបានបំពេញបន្ថែមដោយសេចក្តីណែនាំបច្ចេកទេសលម្អិត ឬ លិខិតបទដ្ឋានគតិយុត្តផ្សេងទៀត សម្រាប់អនុវត្តការងារគណនេយ្យថវិកា ឱ្យទទួលបានប្រសិទ្ធភាពខ្ពស់និងលទ្ធផលល្អប្រសើរ។

### ១.២ វិសាលភាព

គោលការណ៍ណែនាំនេះមានវិសាលភាពអនុវត្តចំពោះគ្រប់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែលរដ្ឋបាលថ្នាក់ក្រោមជាតិ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងនីតិបុគ្គលដទៃទៀតដែលទទួលផលប្រយោជន៍ពីថវិការដ្ឋ។

គោលការណ៍ណែនាំនេះ មិនអនុវត្តចំពោះសហគ្រាសសាធារណៈឡើយ។

គោលការណ៍ណែនាំនេះ អនុវត្តចំពោះកិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិការដ្ឋ ដែលកើតចេញពីការអនុវត្តច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំនីមួយៗ។

### ១.៣ និយមន័យ

និយមន័យនៃវាក្យសព្ទដែលប្រើប្រាស់ក្នុងគោលការណ៍ណែនាំស្តីពីកិច្ចបញ្ជិកាគណនេយ្យនៃប្រតិបត្តិការថវិកាក្នុងគណនេយ្យថវិកា ត្រូវបានកំណត់ក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃគោលការណ៍ណែនាំនេះ។

# ជំពូកទី២

## គោលការណ៍ទូទៅនៃគណនេយ្យថវិកា

គណនេយ្យថវិកា គឺជាប្រភេទមួយក្នុងគណនេយ្យសាធារណៈ ដែលបានកំណត់ឱ្យប្រើប្រាស់ក្នុងប្រព័ន្ធគណនេយ្យសាធារណៈរបស់កម្ពុជាទន្ទឹមគ្នានឹងគណនេយ្យទូទៅនិងគណនេយ្យវិភាគ និងត្រូវបានអនុញ្ញាតដោយច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០២៣ ត្រង់មាត្រា៨៧។ គណនេយ្យថវិកាត្រូវបានប្រើប្រាស់ទូលំទូលាយនៅក្នុងប្រទេសបស្ចិមលោក ឧទាហរណ៍ ប្រទេសបារាំង អង់គ្លេស អាល្លឺម៉ង់ អ៊ីតាលី ជាដើម និងប្រទេសមួយចំនួននៅអាស៊ី ដូចជាប្រទេសកូរ៉េខាងត្បូង ម៉ាឡេស៊ី ជាដើម ហើយត្រូវបានប្រើប្រាស់ជាឧបករណ៍វាស់វែងមួយដ៏មានប្រសិទ្ធភាពសម្រាប់វាស់ស្ទង់កម្រិតការអនុវត្តថវិការបស់អង្គភាពសាធារណៈ។ គណនេយ្យថវិកាមិនត្រឹមតែអាចឆ្លុះបញ្ចាំងអំពីលទ្ធផលនៃការអនុវត្តថវិកាប្រចាំឆ្នាំនោះទេ ប៉ុន្តែ អាចជាឧបករណ៍បន្ថែមសម្រាប់អ្នកគ្រប់គ្រងថវិកាប្រើប្រាស់ដើម្បីវិភាគនិងគ្រប់គ្រងលើសមិទ្ធកម្មប្រចាំឆ្នាំ ផងដែរ។ ទន្ទឹមនេះ ទិន្នន័យនិងព័ត៌មានពីគណនេយ្យថវិកាត្រូវបានទាញចេញសម្រាប់រាយការណ៍ជូនរដ្ឋសភានិងសាធារណជនទូទៅ។ ជារួម គណនេយ្យថវិកាមានគោលបំណងបង្ហាញអំពីលទ្ធផលនៃការអនុវត្តថវិកាប្រចាំឆ្នាំដែលបានអនុញ្ញាតដោយរដ្ឋសភាតាមរយៈច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ។

ដើម្បីបានជាមូលដ្ឋានរឹងមាំក្នុងការស្វែងយល់ឱ្យបានច្បាស់លាស់អំពីគណនេយ្យថវិកា ជំពូកទី២នេះនឹងរំលេចឱ្យឃើញអំពីគោលការណ៍គ្រឹះសំខាន់ៗនៃគណនេយ្យថវិកា, កំណត់អំពីប្រភេទនៃគណនេយ្យថវិកា, បង្ហាញអំពីតួអង្គដែលពាក់ព័ន្ធនឹងគណនេយ្យថវិកា, វិហ្វនីតិវិធីការងារ និងឯកសារតម្រូវពាក់ព័ន្ធនឹងគណនេយ្យថវិកា ព្រមទាំងផ្សារភ្ជាប់គណនេយ្យថវិកាទៅនឹងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជា។

## ២.១ គោលការណ៍គ្រឹះ

គណនេយ្យថវិកាត្រូវបានរៀបចំ អនុវត្ត និងគ្រប់គ្រង ដោយផ្អែកលើគោលការណ៍គ្រឹះនៃថវិកាមួយចំនួនជាសារវន្តដូចមានកំណត់ក្នុងឧបសម្ព័ន្ធនៃច្បាប់ស្តីពីហិរញ្ញវត្ថុសាធារណៈឆ្នាំ២០២៣ ដែលរួមមាន៖ គោលការណ៍ភាពជាអាជ្ញា, ភាពជឿទុកចិត្តបាន, ឯកត្តភាព, សកលភាព, វិសេសភាព, ចីរភាព, គណនេយ្យភាព, ប្រសិទ្ធភាព, តម្លាភាព និងសមិទ្ធកម្ម។

ទន្ទឹមនេះ គណនេយ្យថវិកាត្រូវផ្អែកលើគោលការណ៍ប្រចាំឆ្នាំនៃថវិកា ដូចមានកំណត់ក្នុងមាត្រា១១នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០២៣ ដែលចាប់ផ្តើមនៅថ្ងៃទី១ ខែមករា ហើយបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ។

### ២.១.១ និយមន័យនៃគណនេយ្យថវិកា

គណនេយ្យថវិកាកត់ត្រា តាមដាន និងរាយការណ៍អំពីការប្រើប្រាស់ឥណទានថវិកា ទាំងចំណូលនិងចំណាយថវិកា ដែលបានអនុញ្ញាតដោយច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ។

គណនេយ្យថវិកាត្រូវកត់ត្រាឆ្លុះបញ្ចាំងអំពីការគ្រោងនិងការប្រើប្រាស់ឥណទានភ្ជាប់សន្យានិងឥណទានទូទាត់និងឥណទានថវិកានៃចំណាយចរន្ត ព្រមទាំងកត់ត្រានូវចំណូលដែលបានប្រមូល។

គណនេយ្យថវិកាអនុញ្ញាតឱ្យតួអង្គមានសមត្ថកិច្ចពាក់ព័ន្ធអាចទទួលបានព័ត៌មាននិងទិន្នន័យស្តីពីការប្រើប្រាស់ឥណទានថវិកាដែលបានផ្តល់ជូនអាណាប័ក។

### ២.១.២ មូលដ្ឋាននៃកិច្ចបញ្ជិកាគណនេយ្យថវិកា

កិច្ចបញ្ជិកាគណនេយ្យថវិកាត្រូវធ្វើឡើងដោយផ្អែកលើមូលដ្ឋានសាច់ប្រាក់ មានន័យថា ការកត់ត្រាទទួលស្គាល់ប្រតិបត្តិការចំណូលនិងចំណាយថវិកា គឺអាស្រ័យផ្ទាល់ទៅនឹងវិហ្វរចូលឬចេញនៃសាច់ប្រាក់។ ក្នុងន័យនេះ ចំណូលថវិកាត្រូវបានទទួលស្គាល់ជាស្ថាពរ នៅក្នុងឆ្នាំអនុវត្តថវិកា នៅពេលដែលចំណូលទាំងនោះត្រូវបានទទួលជាសាច់ប្រាក់រួចរាល់ដោយគណនេយ្យករសាធារណៈ។ ចំណែកឯចំណាយថវិកាត្រូវបានទទួលស្គាល់ជាស្ថាពរ នៅក្នុងឆ្នាំអនុវត្តថវិកា នៅពេលដែលចំណាយទាំងនោះត្រូវបានទូទាត់ជាសាច់ប្រាក់រួចរាល់ ដោយគណនេយ្យករសាធារណៈ។ ពាក្យ "សាច់ប្រាក់" ដែលប្រើប្រាស់នៅក្នុងគោលការណ៍ណែនាំនេះ សំដៅដល់សាច់ប្រាក់និងសាច់ប្រាក់សមមូល ដូចមានកំណត់ក្នុងនិយមន័យក្នុងគោលការណ៍ណែនាំនេះ និងមិនសំដៅតែទៅលើសាច់ប្រាក់សុទ្ធ តែម្យ៉ាងនោះទេ។ សាច់ប្រាក់ អាចមានរូបភាពជា

មូលប្បទានបត្រ, គណនីចរន្តនៅធនាគារ, គណនីប្រាក់បញ្ញើដែលបានដាក់នៅធនាគារ ឬ រតនាគារជាតិ, ឬ ឧបករណ៍ហិរញ្ញវត្ថុផ្សេងៗទៀត ដែលអាចប្តូរជាសាច់ប្រាក់បានភ្លាមដោយពុំមានហានិភ័យ និង/ឬ អាចទទួលស្គាល់ជាមធ្យោបាយទូទាត់ដោយធនាគារជាតិនៃកម្ពុជា។ កាលបរិច្ឆេទនៃការទទួលសាច់ប្រាក់ (ផ្នែកចំណូល) និងកាលបរិច្ឆេទនៃការទូទាត់សាច់ប្រាក់ (ផ្នែកចំណាយ) នៅក្នុងប្រព័ន្ធ FMIS គឺជាមធ្យោបាយក្នុងការកំណត់ថ្ងៃខែឆ្នាំនៃលំហូរសាច់ប្រាក់ ដែលជាមូលដ្ឋានក្នុងការកត់ត្រានិងទទួលស្គាល់ជាចំណូលនិងចំណាយថវិកា។

មូលដ្ឋានសាច់ប្រាក់នៃគណនេយ្យថវិកាដែលបានកំណត់នេះ ឆ្លើយតបនឹងមូលដ្ឋាននៃការរៀបចំគម្រោងថវិកាដែលផ្អែកលើមូលដ្ឋានសាច់ប្រាក់ដូចគ្នា ព្រមទាំងឆ្លុះបញ្ចាំងអំពីសង្គតិភាពនិងភាពស៊ីសង្វាក់គ្នាទៅវិញទៅមករវាងទិដ្ឋភាពថវិកានិងទិដ្ឋភាពគណនេយ្យ ដើម្បីធានាឱ្យបាននូវសុខដុមនីយកម្មនៃប្រព័ន្ធថវិកានិងប្រព័ន្ធគណនេយ្យនៅកម្ពុជា។

### ២.១.៣ គោលការណ៍ឯកភាគ

ការចុះកិច្ចបញ្ជិកាគណនេយ្យថវិកាមិនអនុលោមតាមគោលការណ៍ទ្វេភាគ ដូចគណនេយ្យទូទៅទេ។ គណនេយ្យថវិកាពុំមានការកត់ត្រាក្នុងគណនីមួយដោយត្រូវបដិភាគទៅនឹងគណនីមួយទៀតឬគណនីច្រើននោះទេ។ គណនេយ្យថវិកាគ្រាន់តែជាការកត់ត្រាតាមដានការអនុវត្តឥណទានថវិកាតាមបែបសាមញ្ញតែប៉ុណ្ណោះ ប៉ុន្តែស្ថិតក្រោមគោលការណ៍ណែនាំច្បាស់លាស់។ ការកត់ត្រាធ្វើឡើងដោយប្រើប្រាស់សញ្ញា បូក (+) ឬ ដក (-) លើសលាកបត្រតាមដានចំណូលនិងចំណាយថវិកា ដែលឆ្លុះបញ្ចាំងអំពីការប្រើប្រាស់ឥណទានថវិកា ឬ កត់ត្រានៅក្នុងប្រព័ន្ធ FMIS ដើម្បីឱ្យដឹងអំពីឥណទានអនុញ្ញាត ប្រើប្រាស់ និងសល់ ព្រមទាំងផ្អែកលើមូលដ្ឋាន ដូចមានកំណត់ក្នុងជំពូកទី៤ស្តីពីកិច្ចប្រតិបត្តិការថវិកា។

### ២.១.៤ ការិយបរិច្ឆេទគណនេយ្យថវិកា

ការិយបរិច្ឆេទនៃគណនេយ្យថវិកាត្រូវកំណត់រយៈពេលចំនួន១២(ដប់ពីរ)ខែ ដោយគិតចាប់ពីថ្ងៃទី១ ខែមករា រហូតដល់ថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំដដែល ដូចបានកំណត់នៅក្នុងមាត្រា៨៦នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០២៣។

### ២.១.៥ រយៈពេលបំពេញបន្ថែម

សលាកបត្របង្វែរចំណូល និងអាណត្តិបើកប្រាក់ ក្នុងការិយបរិច្ឆេទនៃឆ្នាំអនុវត្តថវិកា អាចត្រូវបន្តទទួលយ៉ាងយូរត្រឹមថ្ងៃទី៣១ ខែមករា នៃឆ្នាំបន្ទាប់ ដោយត្រូវកត់ត្រាលេខនាបន្ថែមនៅត្រឹមថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំអនុវត្ត។

ក្នុងករណីដែលមានច្បាប់ហិរញ្ញវត្ថុកែតម្រូវត្រូវបានអនុម័តនៅក្នុងឆ្នាំអនុវត្តថវិកាឬមានអនុក្រឹត្យបន្ថែមឥណទានថវិកា ស្របតាមមាត្រា៧១នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០២៣ ចំណូលនិងចំណាយថវិកាដែលបានគ្រោងក្នុងច្បាប់ហិរញ្ញវត្ថុកែតម្រូវ ឬអនុក្រឹត្យនេះ អាចអនុវត្តបានក្នុងអំឡុងនៃរយៈពេលបំពេញបន្ថែម និងត្រូវចុះកិច្ចបញ្ជិកាគណនេយ្យនៅក្នុងការិយបរិច្ឆេទអនុវត្តថវិកាប្រចាំឆ្នាំ។ រយៈពេលបំពេញបន្ថែមនៃការអនុវត្តថវិកាសម្រាប់ករណីនេះត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

### ២.១.៦ ការរៀបចំគណនេយ្យថវិកាតាមអង្គភាពសាធារណៈនីមួយៗ

គណនេយ្យថវិកាត្រូវរៀបចំឡើងទៅតាមក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងនីតិបុគ្គលដទៃទៀតដែលទទួលផលប្រយោជន៍ពីថវិការដ្ឋ ដែលអនុញ្ញាតឱ្យធ្វើការប្រៀបធៀបរវាងឥណទានអនុម័តនិងឥណទានអនុវត្ត។

### ២.១.៧ រូបិយបណ្ណនិងភាសាសម្រាប់ការកត់ត្រានិងរាយការណ៍

ការកាន់បញ្ជីគណនេយ្យថវិកា និងការរៀបចំរបាយការណ៍ចំណូលនិងចំណាយថវិការដ្ឋ ត្រូវធ្វើឡើងជាភាសាខ្មែរនិងជាប្រាក់រៀល។

ក្នុងករណីដែលមានការប្រើប្រាស់រូបិយបណ្ណបរទេស អាណាប័កនិងគណនេយ្យករសាធារណៈត្រូវប្រើប្រាស់អត្រាប្តូរប្រាក់របស់ធនាគារជាតិនៃកម្ពុជា ឬ ធនាគារពាណិជ្ជដៃគូ អាស្រ័យទៅតាមប្រភេទនៃកិច្ចប្រតិបត្តិការ សម្រាប់

ជាមូលដ្ឋានដល់ការកត់ត្រានិងរាយការណ៍អំពីប្រតិបត្តិការថវិកា នៅក្នុងគណនេយ្យថវិកា។ ការប្រើប្រាស់អត្រាប្តូរប្រាក់នៅក្នុងគណនេយ្យថវិកាត្រូវអនុវត្តជាគោលការណ៍ តាមអត្រាប្តូរប្រាក់ដែលបានកំណត់នៅក្នុងគណនេយ្យទូទៅ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងកំណត់គោលការណ៍ណែនាំដោយឡែក ក្នុងក្របខ័ណ្ឌគណនេយ្យទូទៅ សម្រាប់ចុះកិច្ចបញ្ជិកាគណនេយ្យនៃប្រតិបត្តិការចំណូលនិងចំណាយថវិកាដែលពាក់ព័ន្ធនឹងការប្រែប្រួលនៃអត្រាប្តូរប្រាក់។

### ២.១.៨ ការប្រើប្រាស់មាតិកាថវិកា

គណនេយ្យថវិកាត្រូវបានចុះកិច្ចបញ្ជិកាដោយប្រើប្រាស់មាតិកាថវិការដ្ឋ ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចមានពន្យល់ជាខ្លឹមសារលម្អិតក្នុងជំពូកទី៣ស្តីពីចំណាត់ថ្នាក់នៃមាតិកាថវិការដ្ឋនៃគោលការណ៍ណែនាំនេះ។

រាល់ប្រតិបត្តិការចំណូលនិងចំណាយថវិកាដែលកើតចេញពីប្រតិបត្តិការសាច់ប្រាក់ ត្រូវកត់ត្រាទៅតាមមុខសញ្ញាចំណូលនិងចំណាយថវិកា ស្របតាមលក្ខខណ្ឌនៃការទទួលស្គាល់ដូចមានកំណត់ក្នុងជំពូកទី៤ស្តីពីកិច្ចប្រតិបត្តិការថវិកា និងត្រូវប្រើប្រាស់មាតិកាថវិការដ្ឋ ដូចមានកំណត់ក្នុងជំពូកទី៣ស្តីពីចំណាត់ថ្នាក់នៃមាតិកាថវិការដ្ឋ។

### ២.១.៩ គុណភាពនៃគណនេយ្យថវិកា

តួអង្គដែលចូលរួមអនុវត្តផ្ទាល់លើការងារគណនេយ្យថវិកា រួមមាន អាណាប័ក អ្នកត្រួតពិនិត្យថវិកា និង គណនេយ្យករសាធារណៈ ត្រូវធានាឱ្យបាននូវគុណភាពនៃទិន្នន័យនិងព័ត៌មានថវិកា សម្រាប់ជាមូលដ្ឋានក្នុងការរៀបចំរបាយការណ៍ចំណូលនិងចំណាយថវិការដ្ឋ។ ក្នុងន័យនេះ តួអង្គអនុវត្តទាំងអស់ត្រូវធ្វើការផ្ទៀងផ្ទាត់កិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិកានីមួយៗ តាមឋានានុក្រម និងនីតិវិធីការងារដែលបានកំណត់ដោយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ព្រមទាំងផ្ទៀងផ្ទាត់ទិន្នន័យនិងព័ត៌មានថវិកាជាមួយគ្នាទៅវិញទៅមក ដើម្បីធានាឱ្យបាននូវទិន្នន័យមួយប្រកបដោយភាពជឿទុកចិត្តបាន វាយតម្លៃបាន មានគុណភាព និងទាន់ពេល សម្រាប់ជាកម្មវត្ថុនៃការរាយការណ៍និងធ្វើសវនកម្ម។

## ២.២ សមាសធាតុនៃគណនេយ្យថវិកា

គណនេយ្យថវិកាកត់ត្រា តាមដាន និងរាយការណ៍អំពីការប្រើប្រាស់ឥណទានថវិកា ទាំងចំណូលនិងចំណាយថវិកា។ ក្នុងន័យនេះ គណនេយ្យថវិកាមានសមាសធាតុផ្សំ ដូចខាងក្រោម៖

### ២.២.១ គណនេយ្យចំណូលថវិកា

ការកត់ត្រា តាមដាន និងរាយការណ៍អំពីចំណូលថវិកាដែលបានប្រមូល ត្រូវផ្អែកតាមមូលដ្ឋានសាច់ប្រាក់ចូលក្នុងគណនីធនាគារឬបេឡារបស់គណនេយ្យករសាធារណៈ ព្រមទាំងគោរពតាមលក្ខខណ្ឌនៃការទទួលស្គាល់ជាចំណូលថវិកា ដូចមានកំណត់ក្នុងជំពូកទី៤ ផ្នែកកិច្ចប្រតិបត្តិការចំណូលថវិកា។ គណនេយ្យករសាធារណៈ ជាអ្នកទទួលបន្ទុកលើកិច្ចបញ្ជិកាគណនេយ្យនៃប្រតិបត្តិការចំណូលថវិកានេះ។ ជាមួយគ្នានេះ អាណាប័កនិងអ្នកពាក់ព័ន្ធត្រូវសហការរៀបចំរំហូរការងារ នៅក្នុងប្រព័ន្ធ FMIS និងប្រព័ន្ធគាំទ្រផ្នែកចំណូល ដើម្បីពិនិត្យនិងតាមដានអំពីរំហូរនៃប្រតិបត្តិការចំណូលថវិកា សម្រាប់ជាមូលដ្ឋានក្នុងការអនុវត្តកិច្ចប្រតិបត្តិការចំណូល ការផ្ទៀងផ្ទាត់ និងការរាយការណ៍អំពីទិន្នន័យផ្នែកចំណូល ជាមួយនឹងគណនេយ្យករសាធារណៈ។

### ២.២.២ គណនេយ្យចំណាយថវិកា

ក្នុងក្របខ័ណ្ឌនៃចំណាយ ឥណទានថវិកាត្រូវបានអនុម័តសម្រាប់ធានាដល់ការចំណាយមូលធននិងចំណាយចរន្ត។ ការកត់ត្រា តាមដាន និងរាយការណ៍អំពីឥណទានថវិកាក៏ត្រូវប្រព្រឹត្តទៅតាមប្រភេទនៃចំណាយថវិកាទាំងនេះដែរ។ ដូច្នេះ គណនេយ្យថវិកាសម្រាប់ផ្នែកចំណាយ ត្រូវរៀបចំឡើង៖

- **សម្រាប់តាមដានឥណទានថវិកានៃចំណាយមូលធន**

ឥណទានថវិកានៃចំណាយមូលធន រួមមានឥណទានភ្ជាប់សន្យានិងឥណទានទូទាត់។

អាណាប័កត្រូវកត់ត្រា តាមដាន និងរាយការណ៍អំពីការប្រើប្រាស់ឥណទានភ្ជាប់សន្យា ដែលបានកើតមានឡើងនៅពេលដែលអាណាប័កបានចុះកិច្ចសន្យាផ្គត់ផ្គង់ទំនិញនិងសេវាកម្ម ឬកិច្ចព្រមព្រៀងអនុវត្តគម្រោងវិនិយោគណាមួយជាមួយអ្នកផ្គត់ផ្គង់ ក្នុងក្របខ័ណ្ឌឥណទានដែលបានអនុញ្ញាតដោយច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ និងក្នុងទំហំទឹកប្រាក់ដែលបានព្រមព្រៀងគ្នា។ ទន្ទឹមនេះ អ្នកត្រួតពិនិត្យថវិកាក៏ត្រូវ ពិនិត្យនិងតាមដានលើការប្រើប្រាស់ឥណទានភ្ជាប់សន្យារបស់អាណាប័កផងដែរ។ ជាមួយគ្នានេះ អាណាប័កនិង/ឬអ្នកត្រួតពិនិត្យថវិកាត្រូវសហការរៀបចំនីតិវិធីរហូរការងារនៅក្នុងប្រព័ន្ធ FMIS ជាមួយអគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីអាចពិនិត្យ តាមដាន និងរាយការណ៍អំពីការប្រើប្រាស់ឥណទានភ្ជាប់សន្យា។

វិធាននិងនីតិវិធីនៃការកត់ត្រាតាមដានការប្រើប្រាស់ឥណទានភ្ជាប់សន្យា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈនាយកដ្ឋានវិនិយោគនៃអគ្គនាយកដ្ឋានថវិកា និងអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល។

ចំពោះឥណទានទូទាត់នៃចំណាយមូលធន អាណាប័កនិង/ឬអ្នកត្រួតពិនិត្យថវិកាត្រូវពិនិត្យនិងតាមដានលើការប្រើប្រាស់ឥណទានទូទាត់ ទៅតាមដំណាក់កាលចំណាយមូលធនដែលមានការពាក់ព័ន្ធ ស្របតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈនាយកដ្ឋានវិនិយោគនៃអគ្គនាយកដ្ឋានថវិកា។ ទន្ទឹមនេះ គណនេយ្យករសាធារណៈត្រូវកត់ត្រា តាមដាន និងរាយការណ៍អំពីការប្រើប្រាស់ឥណទានទូទាត់នៃចំណាយមូលធន ស្របតាមលក្ខខណ្ឌនៃការទទួលស្គាល់ជាចំណាយថវិកា ដូចមានកំណត់ក្នុងចំណុចទី៤.២ នៃជំពូកទី៤ស្តីពីកិច្ចប្រតិបត្តិការថវិកា។

**- សម្រាប់តាមដានឥណទានថវិកានៃចំណាយចរន្ត**

អាណាប័ក និង/ឬអ្នកត្រួតពិនិត្យថវិកាត្រូវពិនិត្យនិងតាមដានលើការប្រើប្រាស់ឥណទានថវិកា ទៅតាមដំណាក់កាលចំណាយចរន្តដែលមានការពាក់ព័ន្ធ ស្របតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ទន្ទឹមនេះ គណនេយ្យករសាធារណៈត្រូវកត់ត្រា តាមដាន និងរាយការណ៍អំពីការប្រើប្រាស់ឥណទានថវិកានៃចំណាយចរន្ត ស្របតាមលក្ខខណ្ឌនៃការទទួលស្គាល់ជាចំណាយថវិកា ដូចមានកំណត់ក្នុងជំពូកទី៤ ផ្នែកកិច្ចប្រតិបត្តិការចំណាយថវិកា។

## ២.៣ តួអង្គពាក់ព័ន្ធនឹងការងារគណនេយ្យថវិកា

តាមរយៈច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ ឬតាមរយៈការអនុញ្ញាតឱ្យប្រមូលចំណូលនិងចំណាយ, ការរៀបចំនិងអនុវត្តគណនេយ្យថវិកាប្រចាំឆ្នាំនីមួយៗត្រូវអនុលោមទៅតាមគោលការណ៍ណែនាំនេះ ដែលត្រូវបានរៀបចំ សម្របសម្រួល គាំទ្រ និងដាក់ឱ្យអនុវត្តគណនេយ្យថវិកា ទាំងទិដ្ឋភាពគតិយុត្តនិងបច្ចេកទេស ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកដ្ឋានថវិកា អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ និងអគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាសេនាធិការ។ ក្នុងករណីសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ មិនត្រូវបានអនុម័តមុនថ្ងៃទី១ ខែមករា នៃឆ្នាំការិយបរិច្ឆេទ ការអនុវត្តថវិកាត្រូវអនុលោមតាមមាត្រា៦១ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០២៣ដោយតួអង្គអនុវត្តថវិកា ត្រូវមានភាពកិច្ចនិងការទទួលខុសត្រូវក្នុងការរៀបចំឱ្យមានគណនេយ្យថវិកាទៅតាមអង្គភាពសាធារណៈនីមួយៗ ត្រូវធ្វើការកត់ត្រាតាមដាន និងរាយការណ៍អំពីការអនុវត្តថវិកា ប្រចាំឆ្នាំនីមួយៗ តាមបទប្បញ្ញត្តិជាធរមាន។ ភារកិច្ចផ្ទាល់របស់តួអង្គអនុវត្តនីមួយៗ ក្នុងការអនុវត្តគណនេយ្យថវិកា រួមមាន៖

### ២.៣.១ តួអង្គពាក់ព័ន្ធផ្ទាល់

#### ២.៣.១.១ អាណាប័ក

អាណាប័ក គឺជាអ្នកបញ្ជាចំណូលនិងចំណាយថវិកា ក្នុងវង្ង់ឥណទានថវិការបស់ខ្លួននិងក្នុងនាមជាម្ចាស់ថវិកា។

អគ្គនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវបញ្ចូលឥណទានថវិការបស់ក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល ទៅក្នុងប្រព័ន្ធ FMIS យ៉ាងយូរបំផុតត្រឹមថ្ងៃទី៣១ ខែធ្នូ មុនចាប់ផ្តើមឆ្នាំអនុវត្តថវិកា ដើម្បី

ជាមូលដ្ឋានក្នុងការកត់ត្រា តាមដាន និងអនុវត្តគណនេយ្យថវិកា។ ការបញ្ចូលនេះ ត្រូវធ្វើលម្អិតដល់អង្គភាពប្រតិបត្តិ ឬ អង្គភាពថវិកាទៅតាមចំណាត់ថ្នាក់នៃមាតិកាថវិកាជាតិ។

អាណាប័ក ត្រូវតាមដានការប្រើប្រាស់ឥណទានថវិកា ដោយត្រូវប្រើប្រាស់សលាកបត្រកត់ត្រាចំណាយថវិកា និងត្រួតពិនិត្យហិរញ្ញវត្ថុ ក្នុងករណីមិនទាន់ប្រើប្រាស់ប្រព័ន្ធ FMIS។ ក្នុងករណីប្រើប្រាស់ប្រព័ន្ធ FMIS ទាំងស្រុង ត្រូវប្រើប្រាស់ព័ត៌មានពីក្នុងប្រព័ន្ធ FMIS ជាមូលដ្ឋាន ដោយត្រូវធ្វើការកត់ត្រានិងតាមដានការប្រើប្រាស់ឥណទានថវិកាខាងលើ នៅពេលដែលប្រតិបត្តិការកើតមានឡើង ជាពិសេសនៅដំណាក់កាលដែលជាសមត្ថកិច្ចរបស់អាណាប័ក និងត្រូវធ្វើឱ្យបានទៀងទាត់ជាប្រចាំ សម្រាប់ជាមូលដ្ឋានដល់ការផ្ទៀងផ្ទាត់តួលេខជាមួយនឹងអ្នកត្រួតពិនិត្យថវិកានិង/ឬគណនេយ្យករសាធារណៈ។

អាណាប័ក ត្រូវអនុវត្តកិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិកា តាមរយៈប្រព័ន្ធ FMIS ទៅតាមដំណាក់កាលនីមួយៗ ស្របតាមបទប្បញ្ញត្តិជាធរមាន។

អាណាប័ក ត្រូវប្រមូលសក្ខីបត្រដើម និងឯកសារពាក់ព័ន្ធនឹងកិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិកានីមួយៗ ដែលអាចមានទម្រង់ជាឯកសាររឹងឬទន់ រួចបញ្ជូនទៅអ្នកត្រួតពិនិត្យថវិកា ដើម្បីពិនិត្យនិងយល់ព្រម ស្របតាមបទប្បញ្ញត្តិជាធរមាន មុននឹងបញ្ជូនបន្តទៅគណនេយ្យករសាធារណៈ ដើម្បីធ្វើការទូទាត់។

អាណាប័ក ត្រូវចុះកិច្ចបញ្ជិកាគណនេយ្យថវិកានៃប្រតិបត្តិការចំណូលនិងចំណាយថវិកានីមួយៗ ទៅក្នុងប្រព័ន្ធ FMIS ឬប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដទៃទៀត ដោយត្រូវបំពេញមាតិកាថវិកា ទៅតាមចំណាត់ថ្នាក់នីមួយៗ ស្របតាមការតម្រូវដាក់ឱ្យអនុវត្តចំណាត់ថ្នាក់នៃមាតិកាថវិកាជាតិ និងត្រូវធ្វើការផ្ទៀងផ្ទាត់ការចុះបញ្ជីនេះឱ្យបានត្រឹមត្រូវ គត់មត់ ប្រុងប្រយ័ត្នខ្ពស់ និងគ្រប់ជ្រុងជ្រោយ ព្រមទាំងឱ្យស្របតាមការណែនាំរបស់មន្ត្រីគ្រប់គ្រងប្រព័ន្ធ FMIS មុននឹងធ្វើការអនុម័តប្រតិបត្តិការ ឬ មុននឹងបញ្ជូនបន្តទៅអ្នកពាក់ព័ន្ធ។ ការចុះបញ្ជិកានេះនឹងក្លាយជាមូលដ្ឋានដ៏សំខាន់នៃទិន្នន័យថវិកា ក៏ដូចជាការរាយការណ៍អំពីព័ត៌មានថវិកានិងហិរញ្ញវត្ថុ។ អាណាប័កត្រូវទទួលខុសត្រូវខ្ពស់ចំពោះការបញ្ចូលទិន្នន័យនៃប្រតិបត្តិការចំណូលនិងចំណាយថវិកាទៅក្នុងប្រព័ន្ធ FMIS។

អាណាប័ក ត្រូវធានាឱ្យបាននូវប្រសិទ្ធភាពខ្ពស់លើការគ្រប់គ្រងប្រតិបត្តិការចំណូលនិងចំណាយថវិកានីមួយៗ ក្នុងប្រព័ន្ធ FMIS ដោយសហការជាមួយនឹងភាគីពាក់ព័ន្ធ ជាពិសេស អង្គភាពគ្រប់គ្រងប្រព័ន្ធ FMIS ដើម្បីបង្ការហានិភ័យនៃការបាត់បង់ទិន្នន័យនិងព័ត៌មានថវិកា ការចុះប្រតិបត្តិការខុសឬលើស ការបង្កើត លុប ឬកែតម្រូវប្រតិបត្តិការដោយគ្មានការទទួលខុសត្រូវ និងការបិទឬបើកប្រតិបត្តិការនិងអនុម័តដោយគ្មានការអនុញ្ញាត និងការមិនគោរពតាមក្រមប្រតិបត្តិការងារ ជាដើម។

អាណាប័ក ត្រូវបញ្ជាក់ទទួលស្គាល់លើរបាយការណ៍អនុវត្តចំណូលនិងចំណាយថវិកា ទាំងទិដ្ឋភាពគ្រប់គ្រងឥណទានថវិកា និងទិដ្ឋភាពលទ្ធផលអនុវត្តថវិកា ដោយត្រូវប្រើប្រាស់ទិន្នន័យពីប្រព័ន្ធ FMIS ជាមូលដ្ឋាន និងផ្តល់ជូនអ្នកពាក់ព័ន្ធ ស្របតាមបទប្បញ្ញត្តិជាធរមាន។

អាណាប័ក ត្រូវតែងតាំងប្រធានអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ ឬ មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុមួយរូប អមដោយជំនួយការមួយចំនួន តាមតម្រូវការចាំបាច់ ដែលត្រូវដើរតួនាទីជាសេនាធិការផ្ទាល់លើការងារហិរញ្ញវត្ថុរបស់អាណាប័ក ដូចបានរៀបរាប់ខាងលើនេះ។

អាណាប័ក ត្រូវសហការជាមួយសវនកម្មផ្ទៃក្នុងនិងផ្ទៃក្រៅ ក្នុងការផ្តល់ព័ត៌មានថវិកានិងព័ត៌មានផ្សេងទៀត ដែលពាក់ព័ន្ធទៅនឹងសមត្ថកិច្ចនិងការទទួលខុសត្រូវរបស់ខ្លួន។

**២.៣.១.២ អ្នកត្រួតពិនិត្យថវិកា**

អ្នកត្រួតពិនិត្យថវិកា ដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួម ត្រួតពិនិត្យ តាមដាន វាយតម្លៃ និងជំរុញការអនុវត្តថវិកាជាតិ។ ក្នុងន័យនេះ អ្នកត្រួតពិនិត្យថវិកា ត្រូវកត់ត្រាតាមដានការប្រើប្រាស់ឥណទានថវិកា ដែលមានការពាក់ព័ន្ធផ្ទាល់ទៅនឹងឥណទានសម្រាប់ការទូទាត់។

អ្នកត្រួតពិនិត្យថវិកា ត្រូវប្រើប្រាស់សលាកបត្រកត់ត្រាចំណាយថវិកានិងត្រួតពិនិត្យហិរញ្ញវត្ថុ ស្របតាមបទប្បញ្ញត្តិជាធរមាន ក្នុងករណីមិនទាន់ប្រើប្រាស់ប្រព័ន្ធ FMIS សម្រាប់កត់ត្រា តាមដានការអនុវត្តឥណទានថវិការបស់អាណាប័ក។ ក្នុងករណីប្រើប្រាស់ប្រព័ន្ធ FMIS ទាំងស្រុង ត្រូវប្រើប្រាស់ព័ត៌មានពីក្នុងប្រព័ន្ធ FMIS ជាមូលដ្ឋាន។

អ្នកត្រួតពិនិត្យថវិកា ត្រូវសហការជាមួយសវនកម្មផ្ទៃក្នុងនិងផ្ទៃក្រៅ ក្នុងការផ្តល់ព័ត៌មានថវិកានិងព័ត៌មានផ្សេងទៀត ដែលពាក់ព័ន្ធទៅនឹងសមត្ថកិច្ចនិងការទទួលខុសត្រូវរបស់ខ្លួន។

**២.៣.១.៣ គណនេយ្យករសាធារណៈ**

គណនេយ្យករសាធារណៈ ដើរតួនាទីយ៉ាងសំខាន់ក្នុងការទទួលនិងគ្រប់គ្រងចំណូល ទូទាត់ចំណាយ រក្សាទុកដាក់និងគ្រប់គ្រងសាច់ប្រាក់ កាន់បញ្ជីគណនេយ្យ និងរៀបចំរបាយការណ៍ថវិកានិងរបាយការណ៍ហិរញ្ញវត្ថុរបស់រដ្ឋ ដោយធានាឱ្យបាននូវការគោរពគោលការណ៍និងបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ ព្រមទាំងធានាឱ្យបាននូវភាពស្មោះត្រង់នៃកិច្ចបញ្ជិកាគណនេយ្យ និងការគោរពតាមនីតិវិធីហិរញ្ញវត្ថុជាធរមានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ក្នុងន័យនេះ គណនេយ្យករសាធារណៈត្រូវកាន់គណនេយ្យថវិកា ដែលពាក់ព័ន្ធនឹងឥណទានសម្រាប់ទូទាត់ និងត្រូវចុះកិច្ចបញ្ជិកាគណនេយ្យថវិកានៃកិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិកា ទៅក្នុងប្រព័ន្ធ FMIS ស្របតាមគោលការណ៍ណែនាំនេះ។

គណនេយ្យករសាធារណៈ ត្រូវពិនិត្យនិងអនុម័តលើកិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិកា នៅក្នុងប្រព័ន្ធ FMIS ដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ខ្លួន ស្របតាមបទប្បញ្ញត្តិជាធរមាន ដែលការណ៍នេះនឹងនាំឱ្យមានដល់ការកត់ត្រាតាមដានការប្រើប្រាស់ឥណទានថវិកានៅក្នុងគណនេយ្យថវិកា ជាពិសេស ក្នុងដំណាក់កាលការប្រមូលចំណូលនៃកិច្ចប្រតិបត្តិការចំណូល និងក្នុងដំណាក់កាលទូទាត់នៃកិច្ចប្រតិបត្តិការចំណាយ។

គណនេយ្យករសាធារណៈ ត្រូវកាន់បញ្ជីគណនេយ្យថវិកា និងត្រូវរៀបចំរបាយការណ៍ថវិកា ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ដោយត្រូវប្រើប្រាស់ទិន្នន័យពីប្រព័ន្ធ FMIS ជាមូលដ្ឋាន ព្រមទាំងត្រូវផ្ទៀងផ្ទាត់តួលេខថវិកាជាមួយនឹងអាណាប័ក និងអ្នកត្រួតពិនិត្យថវិកា ដើម្បីបញ្ជាក់ទទួលស្គាល់ ឬសម្រេចទូទាត់។

គណនេយ្យករសាធារណៈ ត្រូវសហការជាមួយសវនកម្មផ្ទៃក្នុងនិងផ្ទៃក្រៅ ក្នុងការផ្តល់ព័ត៌មានថវិកានិងព័ត៌មានផ្សេងទៀត ដែលពាក់ព័ន្ធទៅនឹងសមត្ថកិច្ចនិងការទទួលខុសត្រូវរបស់ខ្លួន។

**២.៣.១.៤ មន្ត្រីគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

មន្ត្រីគ្រប់គ្រងប្រព័ន្ធ FMIS ដើរតួនាទីយ៉ាងសំខាន់ក្នុងការកសាងប្រព័ន្ធ FMIS និងចូលរួមក្នុងការគាំទ្រការអនុវត្តនីតិវិធីនិងវំហូរការងារដើម្បីធានាដល់ប្រសិទ្ធភាពនៃការអនុវត្តកិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិកា ស្របតាមបទប្បញ្ញត្តិជាធរមាន។ ទន្ទឹមនេះ មន្ត្រីគ្រប់គ្រងប្រព័ន្ធ FMIS ត្រូវផ្តល់ការបណ្តុះបណ្តាលដល់អ្នកប្រើប្រាស់ប្រព័ន្ធ និងចូលរួមគាំទ្រនិងដោះស្រាយបញ្ហាប្រឈមដែលកើតចេញពីការអនុវត្តប្រព័ន្ធ FMIS។

មន្ត្រីគ្រប់គ្រងប្រព័ន្ធ FMIS ត្រូវរៀបចំនិងកសាងប្រព័ន្ធ FMIS ដែលគាំទ្រ ទាំងទិដ្ឋភាពកិច្ចបញ្ជិកាទាំងការរៀបចំរបាយការណ៍ថវិកា ស្របតាមគោលការណ៍ណែនាំនេះ ដើម្បីអាចឆ្លើយតបទៅនឹងតម្រូវការនៃការអនុវត្តគណនេយ្យថវិកា ស្របតាមមាត្រា៨៧នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០២៣ ដោយត្រូវសហការជាមួយនឹងអគ្គនាយកដ្ឋានថវិកា អគ្គនាយកដ្ឋានរតនាគារជាតិ និងអគ្គនាយកដ្ឋានពាក់ព័ន្ធផ្សេងទៀត។

មន្ត្រីគ្រប់គ្រងប្រព័ន្ធ FMIS ត្រូវបង្កើតឱ្យមាននូវយន្តការគាំទ្រនិងដោះស្រាយបញ្ហាប្រឈមជាប្រចាំ ដល់អ្នកអនុវត្តគណនេយ្យថវិកា (អាណាប័ក អ្នកត្រួតពិនិត្យថវិកា និងគណនេយ្យករសាធារណៈ)។

មន្ត្រីគ្រប់គ្រងប្រព័ន្ធ FMIS ត្រូវធ្វើសន្ទានកម្មប្រព័ន្ធគ្រប់គ្រងចំណូលថវិកាដទៃទៀត ដូចជាប្រព័ន្ធ NRMIS, ប្រព័ន្ធ ASYCUDA, ប្រព័ន្ធ Tax, ជាដើម ជាមួយនឹងប្រព័ន្ធ FMIS ដើម្បីមានលទ្ធភាពទទួលស្គាល់ចំណូលថវិកាប្រកបដោយតម្លាភាព និងទាន់ពេល។ ការធ្វើសន្ទានកម្មនេះតម្រូវឱ្យមានការចូលរួមខ្ពស់ពីអង្គភាពពាក់ព័ន្ធទៅនឹងប្រព័ន្ធទាំងអស់នេះ។

មន្ត្រីគ្រប់គ្រងប្រព័ន្ធ FMIS ត្រូវសហការរៀបចំទិន្នន័យ ព័ត៌មាន និងរបាយការណ៍ថវិកា ដែលពាក់ព័ន្ធនឹងគណនេយ្យថវិកា សម្រាប់ផ្តល់ជូនថ្នាក់ដឹកនាំនិងតួអង្គអនុវត្តពាក់ព័ន្ធ ព្រមទាំងត្រូវរក្សាទុកនិងធានាឱ្យបាននូវសុវត្ថិភាពពេញលេញនៃទិន្នន័យ ព័ត៌មាន និងរបាយការណ៍ថវិកាទាំងនោះ នៅក្នុងប្រព័ន្ធ FMIS។

**២.៣.២ តួអង្គពាក់ព័ន្ធដោយប្រយោល**

ក្រៅពីតួអង្គពាក់ព័ន្ធផ្ទាល់នឹងការរៀបចំនិងអនុវត្តគណនេយ្យថវិកាខាងលើ ទិន្នន័យ ព័ត៌មាន និងរបាយការណ៍ថវិកា ដែលពាក់ព័ន្ធនឹងគណនេយ្យថវិកាអាចត្រូវបានស្នើសុំពិនិត្យឬយកទៅប្រើប្រាស់ដោយភាគីខាងក្រៅ ក្នុងគោលដៅពិនិត្យនិងវាយតម្លៃអំពីប្រសិទ្ធភាពនៃកិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិកា និងក្នុងក្របខ័ណ្ឌនៃតម្លាភាពនិងគណនេយ្យភាពថវិកា ដែលរួមមាន៖

**២.៣.២.១ សវនករ**

សវនករដើរតួនាទីយ៉ាងសំខាន់ក្នុងការធានាអនុលោមភាព និងប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់អង្គភាព ព្រមទាំងជួយបង្ការហានិភ័យដែលអាចកើតមានឡើងក្នុងការអនុវត្តគណនេយ្យថវិកា។ ក្នុងគោលដៅនេះ សវនករមានតម្រូវការស្វែងរកទិន្នន័យ ព័ត៌មាន និងរបាយការណ៍ថវិកា ពីគណនេយ្យថវិកា ព្រមទាំងត្រូវការសិក្សាអំពីវិធាននិងនីតិវិធីការងារនៃការអនុវត្តគណនេយ្យថវិកា ដើម្បីអាចពិនិត្យ វាយតម្លៃ និងផ្តល់អនុសាសន៍កែលម្អវិធាននិងនីតិវិធីនៃការអនុវត្តគណនេយ្យថវិកា។ សវនករអាចជាសវនករផ្ទៃក្នុងរបស់អង្គភាពសាធារណៈ ដូចជា អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាស្រ័យទៅតាមរចនាសម្ព័ន្ធផ្ទៃក្នុងរបស់អង្គភាពនីមួយៗ ឬ ជាសវនករផ្ទៃក្រៅរបស់អង្គភាព ដូចជា អគ្គាធិការដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាជ្ញាធរសវនកម្មជាតិ ក្រសួងអធិការកិច្ចជាដើម។ ចំពោះអង្គភាពមួយចំនួនដែលទទួលថវិកាពីដៃគូអភិវឌ្ឍន៍សម្រាប់អនុវត្តការងាររបស់ខ្លួន នោះសវនករអាចមកពីក្រុមហ៊ុនឯកជន។ ការធ្វើសវនកម្មទាំងនេះអាចប្រព្រឹត្តទៅក្រោមរូបភាពផ្ទាល់ឬឌីជីថល និងត្រូវអនុវត្តការងារឱ្យស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

**២.៣.២.២ អង្គនីតិប្បញ្ញត្តិ**

រដ្ឋសភានិងព្រឹទ្ធសភា ដើរតួនាទីយ៉ាងសំខាន់ក្នុងការពិនិត្យនិងអនុម័តលើលទ្ធផលនៃការអនុវត្តថវិការបស់រដ្ឋ ដែលទិន្នន័យ ព័ត៌មាន និងរបាយការណ៍ស្តីពីការអនុវត្តថវិកា គឺទទួលបានពីគណនេយ្យថវិកា នៅក្នុងប្រព័ន្ធ FMIS។ ក្នុងគោលដៅសម្រេចឱ្យបានកិច្ចការនេះ តំណាងរាស្ត្រត្រូវការជាចាំបាច់ពីតួអង្គអនុវត្តពាក់ព័ន្ធ នូវព័ត៌មានហិរញ្ញវត្ថុនិងមិនមែនហិរញ្ញវត្ថុ សេចក្តីពន្យល់អំពីសភាពការណ៍នានា តួលេខថវិកា និងកិច្ចដំណើរការនៃការអនុវត្តថវិកា ដើម្បីពិនិត្យពិច័យលើការអនុវត្តថវិកា ព្រមទាំងក្នុងករណីចាំបាច់ តំណាងរាស្ត្រអាចចុះត្រួតពិនិត្យផ្ទាល់លើការងារអនុវត្តថវិកានិងគណនេយ្យរបស់អង្គភាពសាធារណៈណាមួយ។

**២.៣.២.៣ ដៃគូអភិវឌ្ឍន៍**

ដៃគូអភិវឌ្ឍន៍ មួយចំនួន ទាំងពហុភាគី ដូចជា EU, IMF, ADB, WB, AFD, UNICEF ជាដើម ទាំងទ្វេភាគី ដូចជា ប្រទេសចិន, ជប៉ុន, បារាំង, សហរដ្ឋអាមេរិក ជាដើមអាចមានតម្រូវការព័ត៌មានស្តីពីការអនុវត្តថវិកា សម្រាប់ធ្វើការវិភាគ វាយតម្លៃ និងផ្តល់មតិយោបល់នានា ជាគុណប្រយោជន៍ដល់ការកែលម្អយន្តការឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់បន្ថែមទៀត។

**២.៣.២.៤ សាធារណជន**

សាធារណជន ដែលសំដៅដល់ប្រជាពលរដ្ឋទូទៅ សង្គមស៊ីវិល អ្នកសារព័ត៌មាន ឬក្រុមមនុស្សដទៃទៀត អាចមានតម្រូវការព័ត៌មានអំពីការអនុវត្តថវិការបស់រដ្ឋ សម្រាប់ជាចំណេះដឹងផ្ទាល់ខ្លួន ឬ ធ្វើការផ្សព្វផ្សាយជាសាធារណៈជាដើម។ ជាមួយគ្នានេះ ក្នុងក្របខ័ណ្ឌនៃថវិកាពលរដ្ឋ (Citizen Budget) ទិន្នន័យ ព័ត៌មាន និងរបាយការណ៍ថវិកា ដែលទាញចេញពីគណនេយ្យថវិកា ត្រូវបានបង្ហាញជាសាធារណៈ សម្រាប់ជាព័ត៌មានអំពីការប្រើប្រាស់ថវិការដ្ឋ។

## ២.៤ វិហ្វភាការងារគណនេយ្យថវិកា

ការងារគណនេយ្យថវិកាមានការពាក់ព័ន្ធផ្ទាល់ទៅនឹងការអនុវត្តកិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិកា ដែលវិហ្វភាការងារត្រូវចាប់ផ្តើមពីសក្ខីបត្រដើមដែលអាណាប័កត្រូវរៀបចំ និងត្រូវបន្តធ្វើកិច្ចបញ្ជិកាគណនេយ្យថវិកាទៅក្នុងប្រព័ន្ធ FMIS។ អាណាប័កត្រូវបញ្ជូនឯកសារទៅអ្នកត្រួតពិនិត្យថវិកា ស្របតាមបទប្បញ្ញត្តិជាធរមាន ដើម្បីធ្វើការត្រួតពិនិត្យនិងផ្តល់ទិដ្ឋាការ មុននឹងបញ្ជូនទៅគណនេយ្យករសាធារណៈ ដើម្បីធ្វើការអនុម័តនិងទទួលស្គាល់ជាចំណូលនិងចំណាយថវិកា និងកត់ត្រាក្នុងសលាកបត្រតាមដានចំណូលនិង/ឬចំណាយថវិកាសម្រាប់ជាមូលដ្ឋានដល់ការរាយការណ៍ថវិកា។ ក្នុងករណីដែលប្រព័ន្ធ FMIS ពុំទាន់រៀបចំទៅដល់ទីតាំងរបស់អាណាប័ក ផ្អែកលើសក្ខីបត្រដើម អាណាប័កនិងគណនេយ្យករសាធារណៈត្រូវប្រើប្រាស់ឯកសារគណនេយ្យថវិកា ដូចមានកំណត់ក្នុងចំណុចទី២.៥ ខាងក្រោម ដើម្បីធ្វើការកត់ត្រានិងតាមដានការប្រើប្រាស់ឥណទានថវិកានិងចំណូលថវិកា។

*ចំពោះកិច្ចប្រតិបត្តិការចំណូលថវិកា*

កិច្ចប្រតិបត្តិការចំណូលថវិកាឆ្លងកាត់២ដំណាក់កាល គឺការជម្រះបញ្ជីនិងការប្រមូលឥណទេយ្យ។ ផ្អែកលើសក្ខីបត្រដើម អាណាប័កត្រូវរៀបចំសលាកបត្របង្វែចំណូលនិងចុះកិច្ចបញ្ជិកាក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ឬ ដោយដៃ មុននឹងបញ្ជូនឯកសារទៅគណនេយ្យករសាធារណៈ ដើម្បីពិនិត្យ អនុម័ត និងទទួលស្គាល់កិច្ចបញ្ជិកាជាចំណូលថវិកា។

*ចំពោះកិច្ចប្រតិបត្តិការចំណាយថវិកា*

ក្រោយពីបានធ្វើកិច្ចបញ្ជិកាក្នុងប្រព័ន្ធ ឬដោយដៃ អាណាប័កត្រូវបញ្ជូនអាណត្តិបើកប្រាក់អមដោយសក្ខីបត្រគាំទ្រទៅអ្នកត្រួតពិនិត្យថវិកា ស្របតាមបទប្បញ្ញត្តិជាធរមាន ដើម្បីពិនិត្យនិងផ្តល់ទិដ្ឋាការ មុននឹងបញ្ជូនបន្តទៅគណនេយ្យករសាធារណៈ ដើម្បីពិនិត្យនិងបើកផ្តល់សាច់ប្រាក់ ព្រមទាំងចុះកិច្ចបញ្ជិកាទទួលស្គាល់ជាចំណាយថវិកា។

ក្រៅពីវិហ្វភាការងារដែលពាក់ព័ន្ធផ្ទាល់នឹងការអនុវត្តកិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិកា ការគ្រប់គ្រងចលនាឥណទានថវិកាឬការស្នើសុំនិយ័តភាពឥណទានថវិការបស់អាណាប័កត្រូវមានការពាក់ព័ន្ធផ្ទាល់ជាមួយនឹងអ្នកត្រួតពិនិត្យថវិកា ឬអគ្គនាយកដ្ឋានថវិកា ឬអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ និងអគ្គនាយកដ្ឋានពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមានវិហ្វភាការងារដោយឡែក ស្របតាមបទប្បញ្ញត្តិជាធរមាន។ ចលនាឥណទានថវិកានេះក៏ត្រូវធ្វើការកត់ត្រាក្នុងគណនេយ្យថវិកា និងប្រព័ន្ធ FMIS ផងដែរ និងត្រូវគោរពតាមវិធាននិងនីតិវិធីហិរញ្ញវត្ថុជាធរមាន។

## ២.៥ ឯកសារគណនេយ្យថវិកា

ដើម្បីអាចចុះកិច្ចបញ្ជិកាគណនេយ្យថវិកាបាន អាណាប័កនិងគណនេយ្យករសាធារណៈត្រូវមានឯកសារមួយចំនួន ដូចខាងក្រោម៖

### ២.៥.១ សក្ខីបត្រដើម

- សក្ខីបត្រដើមសម្រាប់គាំទ្រដល់ការរៀបចំសលាកបត្របង្វែចំណូល មានដូចជា លិខិតស្នើសុំបង្វែចំណូល, វិក្កយបត្រ, ប័ណ្ណបង់ប្រាក់, របាយការណ៍ធនាគារ, កិច្ចសន្យា ជាដើម អាស្រ័យទៅតាមមុខសញ្ញាចំណូលថវិកានីមួយៗ និង
- សក្ខីបត្រដើមសម្រាប់គាំទ្រដល់ការរៀបចំអាណត្តិបើកប្រាក់ឬសំណើសុំទូទាត់ចំណាយថវិកា មានដូចជា វិក្កយបត្រ, កិច្ចសន្យា, ដីកាបញ្ចេញលិខិតយុត្តិការ, ដីកាអមបញ្ចេញអាណត្តិបើកប្រាក់, លិខិតស្នើសុំគោលការណ៍ ជាដើម អាស្រ័យទៅតាមមុខសញ្ញាចំណាយថវិកា និងនីតិវិធីពាក់ព័ន្ធដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវកំណត់អំពីមាតិកាឯកសារឬលិខិតយុត្តិការគាំទ្រនៃប្រតិបត្តិការចំណូលនិងចំណាយថវិកានីមួយៗ សម្រាប់ជាមូលដ្ឋានក្នុងការអនុវត្តថវិការបស់រដ្ឋ។

### ២.៥.២ បញ្ជីគណនេយ្យ

- សលាកបត្រតាមដានចំណូលថវិកា
- សលាកបត្របង្វែរចំណូល
- អាណត្តិបើកប្រាក់ ឬ សំណើសុំទូទាត់ចំណាយថវិកា
- សលាកបត្រតាមដានចំណាយថវិកា និង
- សលាកបត្របង់សំណែសចំណាយ។

នៅពេលប្រព័ន្ធ FMIS ត្រូវបានដាក់ឱ្យអនុវត្តដល់អង្គភាពសាធារណៈនីមួយៗ បញ្ជីគណនេយ្យខាងលើ អាចមានជាទម្រង់ឌីជីថល ក្នុងប្រព័ន្ធ FMIS សម្រាប់ប្រើប្រាស់ជាផ្លូវការ។ គណនេយ្យករសាធារណៈត្រូវពិនិត្យភាពត្រឹមត្រូវនៃបញ្ជីគណនេយ្យទាំងនេះ ក្នុងប្រព័ន្ធ FMIS។

### ២.៥.៣ របាយការណ៍ថវិកា

- របាយការណ៍ចំណូលថវិកា និង
- របាយការណ៍ចំណាយថវិកា។

### ២.៥.៤ ការរក្សាទុកដាក់ឯកសារគណនេយ្យថវិកា

ឯកសារគណនេយ្យថវិកាអាចរក្សាទុកជាទម្រង់ឯកសាររឹង ឬ ឌីជីថល ដើម្បីការធ្វើសវនកម្ម និងរក្សាទុកយ៉ាងហោចណាស់១០ឆ្នាំ ក្រោយថ្ងៃបង្កើតឯកសារទាំងនោះ មុននឹងធ្វើការជម្រះចោលតាមនីតិវិធីជាធរមាន។ គណនេយ្យករសាធារណៈមានភារកិច្ចក្នុងការរក្សាទុកដាក់ឯកសារគណនេយ្យថវិកា ឱ្យបានត្រឹមត្រូវនិងគត់មត់ ព្រមទាំងងាយស្រួលសម្រាប់ការធ្វើសវនកម្ម តាមតម្រូវការចាំបាច់។ ក្នុងករណីដែលមានការអនុញ្ញាតឱ្យអាណាប័កជាអ្នកទុកដាក់ឯកសារគណនេយ្យថវិកា ស្របតាមបទប្បញ្ញត្តិជាធរមាន អាណាប័កត្រូវទទួលខុសត្រូវលើឯកសារគណនេយ្យថវិកាដែលបានរៀបចំហើយ រីឯគណនេយ្យករសាធារណៈមានសិទ្ធិត្រួតពិនិត្យលើឯកសារគណនេយ្យថវិកាដែលបានទូទាត់រួចរាល់។

## ២.៦ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការអនុវត្តគណនេយ្យថវិកា

គណនេយ្យថវិកាត្រូវអនុវត្តតាមរយៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ FMIS។ ប្រព័ន្ធ FMIS គឺជាប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានតែមួយគត់ សម្រាប់កត់ត្រា តាមដាន និងរាយការណ៍អំពីការអនុវត្តគណនេយ្យថវិកានៅកម្ពុជា។ រាល់ប្រតិបត្តិការទាំងអស់ដែលមានការពាក់ព័ន្ធនឹងគណនេយ្យថវិកា ត្រូវឆ្លុះបញ្ចាំងនិង/ឬលាតត្រដាងនៅក្នុងប្រព័ន្ធ FMIS។ ប្រតិបត្តិការថវិកាទាំងអស់ត្រូវប្រើប្រាស់ប្រព័ន្ធ FMIS ជាគោល សម្រាប់ការទាញយកទិន្នន័យ ការរាយការណ៍ និងការរៀបចំរបាយការណ៍និងព័ត៌មានថវិកា។ កិច្ចបញ្ជិកាគណនេយ្យថវិកាក្នុងប្រព័ន្ធ FMIS ជាកម្មវត្ថុនៃការត្រួតពិនិត្យនិងធ្វើសវនកម្ម ដោយតួអង្គពាក់ព័ន្ធ ស្របតាមបទប្បញ្ញត្តិជាធរមាន។

<u>**គំនូសបំព្រួញទូទៅនៃលំហូរឯកសារគណនេយ្យថវិកា**</u>

<u>ផ្នែកចំណូលថវិកា</u>

សក្ខីបត្រដើម ⇨ សលាកបត្របង្វែរចំណូល ⇨ សលាកបត្រតាមដានចំណូលថវិកា ⇨ របាយការណ៍ចំណូលថវិកា

<u>ផ្នែកចំណាយថវិកា</u>

សក្ខីបត្រដើម ⇨ អាណត្តិបើកប្រាក់ ⇨ សលាកបត្រតាមដានចំណាយថវិកា ⇨ របាយការណ៍ចំណាយថវិកា

# ជំពូកទី៣

## ចំណាត់ថ្នាក់នៃមាតិកាថវិការដ្ឋ

មាតិកាថវិការដ្ឋ គឺជាឧបករណ៍មួយដ៏សំខាន់ក្នុងការគ្រប់គ្រងថវិកានិងហិរញ្ញវត្ថុសាធារណៈរបស់រដ្ឋ។ មាតិកាថវិកាត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការរៀបចំគម្រោងថវិកា ការអនុវត្តថវិកា និងការរាយការណ៍អំពីព័ត៌មានថវិកា និងហិរញ្ញវត្ថុ ព្រមទាំងជាឧបករណ៍មួយដែលមិនអាចខ្វះបានក្នុងការរៀបចំប្រព័ន្ធ FMIS និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដទៃទៀត។ ជាមួយគ្នានេះ មាតិកាថវិកាក៏ជាឧបករណ៍សម្រាប់ចុះកិច្ចបញ្ជិកាគណនេយ្យនៃគណនេយ្យថវិកាដែរ។ មាតិកាថវិកា គឺជាបណ្តុំនៃលេខកូដសម្គាល់នៃវត្ថុធាតុដែលមានការពាក់ព័ន្ធទៅនឹងការអនុវត្តចំណូលនិងចំណាយថវិកា។ មាតិកាថវិកាត្រូវបានប្រមូលផ្តុំនិងចាត់ថ្នាក់ទៅតាមគោលបំណង គោលដៅ ឬមុខសញ្ញា ដែលអាចបម្រើដល់ការបែងចែកថវិកា ការអនុវត្តថវិកា និងការវិភាគលើការអនុវត្តថវិកា។ ទិន្នន័យដែលទាញចេញពីមាតិកាថវិកាត្រូវបានយកទៅប្រមូលផ្តុំ វិភាគ និងប្រើប្រាស់ជាមូលដ្ឋានក្នុងការសម្រេចចិត្តលើការគ្រប់គ្រងថវិកា។

ដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់លាស់អំពីមាតិកាថវិការដ្ឋ ជំពូកទី៣នេះនឹងកំណត់អំពីគោលការណ៍គ្រឹះមួយចំនួនក្នុងការរៀបចំមាតិកាថវិកា, គោលការណ៍តម្រូវមួយចំនួនដែលពាក់ព័ន្ធនឹងមាតិកាថវិកា, ប្រភេទនៃចំណាត់ថ្នាក់នៃមាតិកាថវិកា និងភាពប្រទាក់ក្រឡាគ្នានៃមាតិកាថវិកានៃគណនេយ្យថវិកា មូលដ្ឋានសាច់ប្រាក់ ទៅនឹងមាតិកាគណនីនៃគណនេយ្យទូទៅ មូលដ្ឋានបង្គរ។

### ៣.១ គោលការណ៍គ្រឹះ

មាតិកាថវិការដ្ឋត្រូវបានរៀបចំឡើងដោយផ្អែកលើគោលការណ៍គ្រឹះមួយចំនួន ដូចខាងក្រោម៖

- ភាពប្រហាក់ប្រហែលឬស្រដៀងគ្នានៃធាតុដែលត្រូវប្រមូលផ្តុំគ្នា និងអាចឆ្លើយតបទៅនឹងគោលដៅឬគោលបំណងរួមនៃធាតុទាំងនោះ
- ភាពប្រើប្រាស់ពិតប្រាកដនៃមាតិកាថវិការដ្ឋ បម្រើប្រយោជន៍ដល់ការកត់ត្រានិងរាយការណ៍អំពីព័ត៌មានថវិកា និងហិរញ្ញវត្ថុ
- ភាពអាចអនុវត្តបាន និងការរៀបចំក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និង
- ការថ្លឹងថ្លែងរវាងបន្ទុកនៃការរៀបចំនិងដាក់ឱ្យមានចំណាត់ថ្នាក់ថ្មី និងផលប្រយោជន៍នៃការប្រើប្រាស់ចំណាត់ថ្នាក់ថ្មី។

ផ្អែកលើគោលការណ៍ទាំងនេះ មាតិកាថវិការដ្ឋត្រូវបានប្រមូលផ្តុំនិងចាត់ថ្នាក់ឱ្យចេញជាចំណាត់ថ្នាក់ ដែលអនុញ្ញាតឱ្យកត់ត្រានិងផ្ទុកទិន្នន័យនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រដ្ឋ ប្រកបដោយលក្ខណៈគ្រប់ជ្រុងជ្រោយ ភាពពេញលេញ គណនេយ្យភាព និងតម្លាភាព។ មាតិកាថវិការដ្ឋត្រូវបានប្រើប្រាស់នៅក្នុងក្របខ័ណ្ឌនៃគណនេយ្យថវិកាមូលដ្ឋានសាច់ប្រាក់។

ទន្ទឹមនេះ តួអង្គអនុវត្តថវិកាត្រូវគោរពតាមគោលការណ៍មួយចំនួនដែលពាក់ព័ន្ធនឹងមាតិកាថវិការដ្ឋ ដូចជា៖

- ថវិកាត្រូវធ្វើចំណាត់ថ្នាក់ទៅតាមមាតិកាថវិការដ្ឋ។ ការធ្វើចំណាត់ថ្នាក់ថវិកានេះ គឺអាស្រ័យទៅតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន តម្រូវការជាក់ស្តែង និងបរិបទកម្ពុជា និង
- រាល់ការកត់ត្រាចំណូលនិងចំណាយថវិការដ្ឋត្រូវគោរពទៅតាមមាតិកាថវិការដ្ឋនិងប្លង់គណនេយ្យសាធារណៈ ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ក្នុងន័យនេះ អាណាប័ក តាមរយៈប្រធានអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ ឬមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុ ត្រូវធ្វើការបែងចែកនិងកត់ត្រាចំណូលនិងចំណាយថវិកា ទៅតាមចំណាត់ថ្នាក់នៃមាតិកាថវិការដ្ឋ ព្រមទាំងការបញ្ចូលទិន្នន័យទៅក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ជាពិសេសពាក់ព័ន្ធនឹងចំណាត់ថ្នាក់ផ្សេងទៀត ក្រៅពីចំណាត់ថ្នាក់សេដ្ឋកិច្ច រដ្ឋបាល និងកម្មវិធី។ អគ្គនាយកដ្ឋានថវិកាត្រូវពិនិត្យនិងអនុម័តលើព័ត៌មានថវិកាដែលអាណាប័កបានបញ្ចូលទៅក្នុងប្រព័ន្ធ FMIS ទៅតាមចំណាក់ថ្នាក់នៃមាតិកាថវិការដ្ឋ។ អាណាប័កត្រូវរៀបចំប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ខ្លួន ដើម្បីធានាដល់ភាព

ត្រឹមត្រូវនិងគុណភាពនៃការបញ្ចូលទិន្នន័យចំណូលនិងចំណាយថវិកាទៅតាមចំណាត់ថ្នាក់ នៅក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។

ចំណាត់ថ្នាក់នីមួយៗនៃមាតិកាថវិការដ្ឋ ត្រូវបានដាក់ចេញឱ្យអនុវត្តដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ការកែសម្រួលខ្លឹមសារនៃចំណាត់ថ្នាក់នីមួយៗត្រូវបានពិនិត្យនិងសម្រេចដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ក្នុងករណីដែលមានតម្រូវការចាំបាច់និងបន្ទាន់ក្នុងការកត់ត្រាប្រតិបត្តិការថវិកា គណនេយ្យករសាធារណៈអាចចាត់ចែងរៀបចំ បង្កើត និងដាក់ឱ្យអនុវត្តមាតិកានៃចំណាត់ថ្នាក់ទាំងនោះ ដោយសហការជាមួយតួអង្គពាក់ព័ន្ធទៅក្នុងប្រព័ន្ធ FMIS និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដទៃទៀត។ មាតិកានៃចំណាត់ថ្នាក់ដែលបានបង្កើតថ្មីនោះ ជាកម្មវត្ថុនៃការពិនិត្យនិងសម្រេចដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅចុងការិយបរិច្ឆេទថវិកានីមួយៗ។

ប្រព័ន្ធ FMIS និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដទៃទៀត ត្រូវប្រើប្រាស់ចំណាត់ថ្នាក់នៃមាតិកាថវិការដ្ឋ សម្រាប់ជាមូលដ្ឋានក្នុងការគ្រប់គ្រងថវិកា ការកត់ត្រាកិច្ចប្រតិបត្តិការថវិកា ហិរញ្ញវត្ថុ និងគណនេយ្យ និងរាយការណ៍អំពីរបាយការណ៍ថវិកានិងហិរញ្ញវត្ថុ។

## ៣.២ ការចាត់ថ្នាក់ថវិកា

ថវិការួមមានចំណូលនិងចំណាយថវិកា។

### ៣.២.១ ចំណូលថវិកា

ផ្អែកតាមមាត្រា២៤នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០២៣ ចំណូលថវិកា រួមមាន៖

១-ចំណូលសារពើពន្ធ រួមមាន ចំណូលសារពើពន្ធក្នុងស្រុក ចំណូលសារពើពន្ធលើពាណិជ្ជកម្មអន្តរជាតិ និងចំណូលសារពើពន្ធដទៃទៀត។

២-ចំណូលមិនមែនសារពើពន្ធ រួមមាន ចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ ចំណូលពីសហគ្រាសសាធារណៈ ភាគកម្មសាធារណៈនិងអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត ចំណូលពីសេវាសាធារណៈ ចំណូលពីការពិន័យនិងការដាក់ទណ្ឌកម្ម និងចំណូលមិនមែនសារពើពន្ធផ្សេងទៀត ដែលកំណត់ដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

៣-ចំណូលផ្សេងៗ រួមបញ្ចូលទាំងចំណូលបានមកពីទ្រព្យសកម្មហិរញ្ញវត្ថុរយៈពេលវែង ហិរញ្ញប្បទានឥតសំណង ការសងវិញនូវប្រាក់ឱ្យគេខ្ចី និងចំណូលផ្សេងៗដទៃទៀត។

ចំណូលថវិកានីមួយៗត្រូវធ្វើចំណាត់ថ្នាក់ជាជំពូក គណនី អនុគណនី និងអាចលម្អិតជាងនេះទៀត ដោយប្រើប្រាស់ចំណាត់ថ្នាក់នៃមាតិកាថវិការដ្ឋ។

### ៣.២.២ ចំណាយថវិកា

ផ្អែកតាមមាត្រា៣២នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០២៣ ចំណាយថវិកា រួមមានចំណាយចរន្ត និងចំណាយមូលធន ដែលត្រូវបែងចែកជា៦ប្រភេទ ដូចខាងក្រោម៖

១-បន្ទុកបុគ្គលិក រួមមាន ចំណាយលើបៀវត្ស ប្រាក់បំណាច់និងប្រាក់ឧបត្ថម្ភផ្សេងៗ ប្រាក់វិភាជន៍សង្គម វិភាគទានសង្គម និងប្រាក់អត្ថប្រយោជន៍ផ្សេងៗ។

២-ចំណាយប្រតិបត្តិការ រួមមាន ចំណាយលើការទិញទំនិញ ការជួសជុលថែទាំ និងការជួលសេវា ដើម្បីទទួលបាននូវមធ្យោបាយនិងសេវាផ្សេងៗ បម្រើឱ្យសកម្មភាពរបស់រដ្ឋ។

៣-បន្ទុកហិរញ្ញវត្ថុ រួមមាន ចំណាយលើការប្រាក់និងបន្ទុកពាក់ព័ន្ធផ្សេងៗនៃបំណុលសាធារណៈក្នុងប្រទេស និងក្រៅប្រទេស។

៤- ចំណាយវិនិយោគ រួមមាន ចំណាយលើការទទួលបាននូវទ្រព្យសកម្មរយៈពេលវែងទាំងរូបីនិងអរូបី ព្រមទាំងទ្រព្យសកម្មហិរញ្ញវត្ថុរយៈពេលវែង។

៥-ការផ្ទេរ៖

- ចំណាយអន្តរាគមន៍ រួមមាន ចំណាយលើការផ្តល់អត្ថប្រយោជន៍សង្គម ចំណាយអន្តរាគមន៍ផ្នែកសង្គមសេដ្ឋកិច្ច និងវប្បធម៌
- ចំណាយឧបត្ថម្ភធន ដោយមានភ្ជាប់លក្ខខណ្ឌនិងគ្មានភ្ជាប់លក្ខខណ្ឌទៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- ចំណាយឧបត្ថម្ភធនទៅគ្រឹះស្ថានសាធារណៈរដ្ឋបាល
- ចំណាយឧបត្ថម្ភធនទៅសហគ្រាសសាធារណៈ
- ការផ្តល់អំណោយ
- ចំណាយឧបត្ថម្ភធនផ្សេងៗ។

៦- ចំណាយផ្សេងៗ រួមមាន ចំណាយលើពន្ធនិងអាករដែលបង់ដោយរដ្ឋ ចំណាយមិនទាន់បែងចែកមានមុខសញ្ញា ចំណាយមិនបានគ្រោងទុក និងចំណាយដទៃទៀត។

ប្រភេទចំណាយថវិកានីមួយៗត្រូវធ្វើចំណាត់ថ្នាក់ជាជំពូក គណនី អនុគណនី និងអាចលម្អិតជាងនេះទៀត ដោយប្រើប្រាស់ចំណាត់ថ្នាក់នៃមាតិកាថវិការដ្ឋ។

## ៣.៣ ប្រភេទចំណាត់ថ្នាក់នៃមាតិកាថវិការដ្ឋ

យោងតាមមាត្រា២២នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០២៣ ចំណាត់ថ្នាក់នៃមាតិកាថវិការដ្ឋ រួមមាន ចំណាត់ថ្នាក់សេដ្ឋកិច្ច ចំណាត់ថ្នាក់កម្មវិធី ចំណាត់ថ្នាក់រដ្ឋបាល ចំណាត់ថ្នាក់ភូមិសាស្ត្រ ចំណាត់ថ្នាក់មុខងារ ចំណាត់ថ្នាក់គម្រោង និងចំណាត់ថ្នាក់មូលនិធិ។

### ៣.៣.១ ចំណាត់ថ្នាក់សេដ្ឋកិច្ច

ចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការដ្ឋ មានគោលបំណងបង្ហាញអំពីមុខសញ្ញាចំណូលនិងចំណាយថវិកាលម្អិត ទៅតាមសារជាតិឬចរិតលក្ខណៈនៃចំណូលនិងចំណាយថវិកាជាក់ស្តែង តាមរយៈការកំណត់លេខកូដសម្គាល់នៃមុខសញ្ញាចំណូលនិងចំណាយថវិកានីមួយៗ ដើម្បីអាចប្រមូលផ្តុំទិន្នន័យចំណូលនិងចំណាយថវិកាទៅតាមប្រភេទនៃចំណូលនិងចំណាយថវិកានិងអាចឆ្លើយតបទៅនឹងតម្រូវការព័ត៌មានអនុវត្តជាក់ស្តែងអំពីការប្រើប្រាស់ថវិកានិងការប្រមូលចំណូលថវិកា។

ចំណាត់ថ្នាក់សេដ្ឋកិច្ច ចែកចេញជាចំណាត់ថ្នាក់ចំណូលនិងចំណាយ និងត្រូវបានបែងចែកជាក្រុមនិងប្រភេទទៅតាមចំណូលនិងចំណាយថវិការបស់រដ្ឋ ស្របតាមខ្លឹមសារនៃមាត្រា២៤អំពីធនធានថវិកា និងមាត្រា៣២អំពីបន្ទុកថវិកា នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០២៣។ ចំណាត់ថ្នាក់សេដ្ឋកិច្ចមានលេខសម្គាល់ចំនួន៥ខ្ទង់ ដែលត្រូវបានបែងចែកជាជំពូក (២ខ្ទង់) គណនី (៤ខ្ទង់) និងអនុគណនី (៥ខ្ទង់)។ ចំណាត់ថ្នាក់សេដ្ឋកិច្ចអាចបែងចែកលម្អិតជាងនេះ រហូតដល់អនុគណនីរង ឬ អនុអនុគណនីរង ជាដើម អាស្រ័យទៅតាមតម្រូវការព័ត៌មានលម្អិតរបស់អង្គភាពប្រើប្រាស់និងលទ្ធភាពគាំទ្របានរបស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងត្រូវស្នើសុំការពិនិត្យនិងសម្រេចពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ចំណាត់ថ្នាក់សេដ្ឋកិច្ចត្រូវបានដាក់ឱ្យអនុវត្តតាមរយៈប្រកាសលេខ ៥២៣ សហវ.ប្រក ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ និងត្រូវបានកែសម្រួលជាបន្តបន្ទាប់ តាមរយៈប្រកាសបំពេញបន្ថែមគណនី ឬ លុបគណនី ឬ កែប្រែគណនីថ្មី របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាស្រ័យទៅតាមតម្រូវការចាំបាច់នៃការកត់ត្រាប្រតិបត្តិការចំណូលនិងចំណាយថវិកា។ ចំណាត់ថ្នាក់សេដ្ឋកិច្ចជាកម្មវត្ថុនៃការធ្វើបច្ចុប្បន្នភាព ស្របតាមការប្រែប្រួលនៃបរិការណ៍គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

### ៣.៣.២ ចំណាត់ថ្នាក់កម្មវិធី

ចំណាត់ថ្នាក់កម្មវិធីនៃមាតិកាថវិការដ្ឋ មានគោលបំណងបង្ហាញអំពីរចនាសម្ព័ន្ធលម្អិតនៃកម្មវិធីរបស់រដ្ឋ ទៅតាមប្រភេទនិងមុខសញ្ញានៃកម្មវិធីនីមួយៗ ដែលកំណត់ដោយអង្គភាពសាធារណៈ និងអាចឆ្លើយតបទៅនឹងគោលបំណង និងអាទិភាពនៃគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ចំណាត់ថ្នាក់កម្មវិធីត្រូវបានប្រើប្រាស់ជាមធ្យោបាយក្នុងការរៀបចំ

ថវិកាបស់អង្គភាពសាធារណៈ ដើម្បីវាស់វែងអំពីប្រសិទ្ធភាពនៃការប្រើប្រាស់ថវិកាទៅតាមកម្មវិធីនីមួយៗ ដោយប្រៀបធៀបជាមួយនឹងសូចនាករវាស់វែងលទ្ធផលនៃកម្មវិធីនីមួយៗ។

ចំណាត់ថ្នាក់កម្មវិធី ចែកចេញជាកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព អមដោយការបរិយាយអំពីកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពទាំងនោះ។ ចំណាត់ថ្នាក់កម្មវិធី ត្រូវប្រើប្រាស់លេខសម្គាល់ចំនួន៧ខ្ទង់ សម្រាប់សម្គាល់កម្មវិធី (៣ខ្ទង់) អនុកម្មវិធី (៥ខ្ទង់) និងចង្កោមសកម្មភាព (៧ខ្ទង់)។ ចំណាត់ថ្នាក់កម្មវិធីអាចបែងចែកលម្អិតជាងនេះ ហូតដល់សកម្មភាព ឬ អនុសកម្មភាព ជាដើម និងត្រូវមានលេខកូដសម្គាល់បន្ថែម (អាចមានច្រើនខ្ទង់ អាស្រ័យទៅតាមចំនួនសកម្មភាព ឬអនុសកម្មភាព) អាស្រ័យទៅតាមតម្រូវការព័ត៌មានលម្អិតរបស់អង្គភាពប្រើប្រាស់ និងលទ្ធភាពគាំទ្របានរបស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងត្រូវស្នើសុំការពិនិត្យនិងសម្រេចពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ចំណាត់ថ្នាក់កម្មវិធីត្រូវបានដាក់ឱ្យអនុវត្តតាមរយៈប្រកាសលេខ ១០២២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់កម្មវិធីនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ និងត្រូវបានកែសម្រួលជាបន្តបន្ទាប់ តាមរយៈប្រកាសបំពេញបន្ថែម ឬលុប ឬកែប្រែថ្មី នូវលេខកូដចំណាត់ថ្នាក់កម្មវិធី ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាស្រ័យទៅតាមតម្រូវការចាំបាច់នៃការកត់ត្រាកម្មវិធីរបស់រដ្ឋ។ ចំណាត់ថ្នាក់កម្មវិធី ជាកម្មវត្ថុនៃការធ្វើបច្ចុប្បន្នភាព ស្របតាមការប្រែប្រួលនៃបរិការណ៍គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

### ៣.៣.៣ ចំណាត់ថ្នាក់រដ្ឋបាល

ចំណាត់ថ្នាក់រដ្ឋបាលនៃមាតិកាថវិការដ្ឋ មានគោលបំណងបង្ហាញអំពីរចនាសម្ព័ន្ធលម្អិតនៃរដ្ឋបាលសាធារណៈ តាមរយៈការកំណត់លេខកូដសម្គាល់នៃរដ្ឋបាលសាធារណៈទាំងនោះ ដែលឆ្លុះបញ្ចាំងអំពីរចនាសម្ព័ន្ធរបស់រាជរដ្ឋាភិបាល។ ចំណាត់ថ្នាក់រដ្ឋបាលត្រូវបានប្រើប្រាស់ជាមធ្យោបាយក្នុងការបែងចែកថវិកាដល់រដ្ឋបាលសាធារណៈ និងអាចបង្ហាញអំពីគណនេយ្យភាព ការទទួលខុសត្រូវ និងតម្លាភាពនៃការប្រើប្រាស់ថវិការបស់អ្នកគ្រប់គ្រងនៅរដ្ឋបាលសាធារណៈ។

ចំណាត់ថ្នាក់រដ្ឋបាលត្រូវបានលម្អិតទៅតាមថ្នាក់របស់រដ្ឋបាល (រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ) និងកំណត់លេខកូដសម្គាល់ទៅតាមរដ្ឋបាលសាធារណៈនីមួយៗ អាស្រ័យទៅតាមតម្រូវការព័ត៌មានលម្អិតរបស់អង្គភាពប្រើប្រាស់ និងលទ្ធភាពគាំទ្របានរបស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងត្រូវស្នើសុំការពិនិត្យនិងសម្រេចពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ចំណាត់ថ្នាក់រដ្ឋបាល ត្រូវបានដាក់ឱ្យអនុវត្តតាមរយៈប្រកាសលេខ ៧៧២ សហវ.ប្រក ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់រដ្ឋបាលនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ និងត្រូវបានកែសម្រួលជាបន្តបន្ទាប់ តាមរយៈប្រកាសបំពេញបន្ថែម ឬលុប ឬកែប្រែថ្មី នូវលេខកូដចំណាត់ថ្នាក់រដ្ឋបាល ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាស្រ័យទៅតាមតម្រូវការចាំបាច់នៃការកត់ត្រាថវិកាទៅតាមរដ្ឋបាលសាធារណៈនីមួយៗ។ ចំណាត់ថ្នាក់រដ្ឋបាល ជាកម្មវត្ថុនៃការធ្វើបច្ចុប្បន្នភាព ស្របតាមការប្រែប្រួលនៃបរិការណ៍គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

### ៣.៣.៤ ចំណាត់ថ្នាក់ភូមិសាស្ត្រ

ចំណាត់ថ្នាក់ភូមិសាស្ត្រ មានគោលបំណងបង្ហាញអំពីទីតាំងភូមិសាស្ត្រដែលថវិកាត្រូវបានប្រមូលឬចំណាយ និងឆ្លុះបញ្ចាំងអំពីទំហំនៃអត្ថប្រយោជន៍សេដ្ឋកិច្ចរបស់ភូមិសាស្ត្រនីមួយៗដែលទទួលបានឬកើតឡើង តាមរយៈការអនុវត្តថវិកា។

ចំណាត់ថ្នាក់ភូមិសាស្ត្រ ត្រូវបានរៀបចំទៅតាមលេខកូដរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ដែលកំណត់ដោយក្រសួងមហាផ្ទៃ។

ចំណាត់ថ្នាក់ភូមិសាស្ត្រ ត្រូវបានកំណត់ទៅតាមភូមិសាស្ត្ររាជធានី ខេត្តនីមួយៗ ទៅតាមកម្រិតនៃដែនដី ដោយប្រើប្រាស់លេខកូដសម្គាល់សរុបចំនួន៦ខ្ទង់ ដែលក្នុងនោះសម្រាប់សម្គាល់ដែនដីរាជធានី ខេត្ត (២ខ្ទង់) ក្រុង ស្រុក ខណ្ឌ (៤ខ្ទង់) និងឃុំ សង្កាត់ (៦ខ្ទង់) អមដោយឈ្មោះដែនដីភូមិសាស្ត្រនីមួយៗ។ ចំណាត់ថ្នាក់ភូមិសាស្ត្រអាច

បែងចែកលម្អិតជាងនេះ រហូតដល់កម្រិតដែនដីភូមិ និងត្រូវមានលេខកូដសម្គាល់បន្ថែម (អាចមានច្រើនខ្ទង់ អាស្រ័យទៅតាមចំនួនភូមិ នៃភូមិសាស្ត្រនីមួយៗ) អាស្រ័យទៅតាមតម្រូវការព័ត៌មានលម្អិតរបស់អង្គភាពប្រើប្រាស់ និងលទ្ធភាពគាំទ្របានរបស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងត្រូវស្នើសុំការពិនិត្យនិងសម្រេចពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ចំណាត់ថ្នាក់ភូមិសាស្ត្រត្រូវបានដាក់ឱ្យអនុវត្តតាមរយៈប្រកាសលេខ ២៤២ សហវ.ប្រក ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់ភូមិសាស្ត្រនៃមាតិកាថវិកា និងត្រូវបានកែសម្រួលជាបន្តបន្ទាប់ តាមរយៈប្រកាសបំពេញបន្ថែម ឬលុប ឬកែប្រែថ្មី នូវលេខកូដចំណាត់ថ្នាក់ភូមិសាស្ត្រ ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាស្រ័យទៅតាមតម្រូវការចាំបាច់នៃការកត់ត្រាថវិកាទៅតាមភូមិសាស្ត្រនីមួយៗ។ ចំណាត់ថ្នាក់ភូមិសាស្ត្រ ជាកម្មវត្ថុនៃការធ្វើបច្ចុប្បន្នភាព ស្របតាមការប្រែប្រួលនៃបរិការណ៍គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

### ៣.៣.៥ ចំណាត់ថ្នាក់មុខងារ

ចំណាត់ថ្នាក់មុខងារនៃមាតិកាថវិការដ្ឋ មានគោលបំណងបង្ហាញអំពីមុខងារសំខាន់ៗរបស់រាជរដ្ឋាភិបាល អមជាមួយនឹងការពន្យល់អំពីមុខងារនីមួយៗ ដូចជា សេវាសាធារណៈទូទៅ, ការពារជាតិ, សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ, សេដ្ឋកិច្ច, ការគ្រប់គ្រងគុណភាពបរិស្ថាន និងអភិរក្សជីវចម្រុះ, ការរៀបចំលំនៅដ្ឋាន និងការគ្រប់គ្រងសហគមន៍, សុខាភិបាល, ការកម្សាន្ត កីឡា សិល្បៈ វប្បធម៌ ផ្សព្វផ្សាយនិងសាសនា, ការអប់រំ និងការគាំពារពីសង្គម។ ចំណាត់ថ្នាក់មុខងារអនុញ្ញាតឱ្យអ្នកគ្រប់គ្រងថវិកាប្រើប្រាស់ ដើម្បីកត់ត្រានិងរាយការណ៍ថវិកាទៅតាមមុខងារនានាដែលមានការពាក់ព័ន្ធ និងជាលទ្ធផល អាចផ្តល់ព័ត៌មានអំពីការប្រើប្រាស់ថវិកាទៅតាមមុខងារទាំងនោះ សម្រាប់ធ្វើការវិភាគ វិភាជថវិកា និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តថវិកានិងមុខងាររបស់រដ្ឋ។ ចំណាត់ថ្នាក់មុខងារមានសារសំខាន់ដល់ការរាយការណ៍ក្នុងក្របខ័ណ្ឌអន្តរជាតិ ជាមួយនឹងដៃគូអភិវឌ្ឍន៍ និងជាប្រភពទិន្នន័យដ៏សំខាន់ក្នុងការប្រៀបធៀបការអនុវត្តថវិកាជាមួយនឹងមុខងារនានា រវាងប្រទេសនិងប្រទេស ក្នុងសកលលោក។

ចំណាត់ថ្នាក់មុខងារ ត្រូវបានបែងចែកជា៣កម្រិត គឺមុខងារ អនុមុខងារ និងអនុអនុមុខងារ អមដោយសេចក្តីពន្យល់នៃមុខងារទាំងនោះ។ ចំណាត់ថ្នាក់មុខងារ ត្រូវប្រើប្រាស់លេខសម្គាល់សរុបចំនួន៥ខ្ទង់ សម្រាប់សម្គាល់មុខងារ (១ខ្ទង់) អនុមុខងារ (៤ខ្ទង់) និងអនុអនុមុខងារ (៥ខ្ទង់)។ ចំណាត់ថ្នាក់មុខងារអាចបែងចែកលម្អិតជាងនេះ និងត្រូវមានលេខកូដសម្គាល់បន្ថែម (អាចមានច្រើនខ្ទង់ អាស្រ័យទៅតាមចំនួនមុខងារដែលបង្កើតបន្ថែមថ្មី) អាស្រ័យទៅតាមតម្រូវការព័ត៌មានលម្អិតរបស់អង្គភាពប្រើប្រាស់ និងលទ្ធភាពគាំទ្របានរបស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងត្រូវស្នើសុំការពិនិត្យនិងសម្រេចពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ចំណាត់ថ្នាក់មុខងារ ត្រូវបានដាក់ឱ្យអនុវត្តតាមរយៈប្រកាសលេខ ៩៩៦ សហវ.ប្រក ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់មុខងារនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ និងអាចត្រូវបានកែសម្រួលជាបន្តបន្ទាប់ តាមរយៈប្រកាសបំពេញបន្ថែម ឬលុប ឬកែប្រែថ្មី នូវលេខកូដចំណាត់ថ្នាក់មុខងារ ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាស្រ័យទៅតាមតម្រូវការចាំបាច់នៃការកត់ត្រាថវិកាទៅតាមមុខងារនីមួយៗ។ ចំណាត់ថ្នាក់មុខងារ ជាកម្មវត្ថុនៃការធ្វើបច្ចុប្បន្នភាព ស្របតាមការប្រែប្រួលនៃបរិការណ៍គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

### ៣.៣.៦ ចំណាត់ថ្នាក់គម្រោង

ចំណាត់ថ្នាក់គម្រោងនៃមាតិកាថវិការដ្ឋ មានគោលបំណងបង្ហាញអំពីចំនួនគម្រោង ដែលអនុវត្តដោយរាជរដ្ឋាភិបាល និងអនុញ្ញាតឱ្យកត់ត្រាការអនុវត្តថវិកាទៅតាមគម្រោងនីមួយៗរបស់អ្នកគ្រប់គ្រងគម្រោង។

ចំណាត់ថ្នាក់គម្រោង ត្រូវបានបែងចែកជា២ប្រភពហិរញ្ញប្បទាន គឺគម្រោងដែលមានប្រភពហិរញ្ញប្បទានក្រៅប្រទេស ឧទាហរណ៍ គម្រោងជានាហិរញ្ញប្បទានពី ADB ឬ WB ឬ ប្រទេសចិន កូរ៉េ ជាដើម និងគម្រោងដែលមានប្រភពហិរញ្ញប្បទានក្នុងប្រទេស អមដោយលេខ ឈ្មោះ និងសេចក្តីពន្យល់នៃគម្រោងទាំងនោះ។ ចំណាត់ថ្នាក់គម្រោងត្រូវប្រើប្រាស់លេខសម្គាល់សរុបចំនួន៦ខ្ទង់ សម្រាប់សម្គាល់លេខគម្រោងនីមួយៗ ដោយលេខសូន្យ (០) ពីមុខលេខកូដសំដៅដល់ប្រភពហិរញ្ញប្បទានក្រៅប្រទេស និងលេខមួយ (១) ពីមុខលេខកូដ សំដៅដល់ប្រភពហិរញ្ញប្បទានក្នុងប្រទេស។

ចំណាត់ថ្នាក់គម្រោងអាចបែងចែកលម្អិតជាងនេះ និងត្រូវមានលេខកូដសម្គាល់បន្ថែម (អាចមានច្រើនខ្ទង់ អាស្រ័យទៅតាមចំនួនគម្រោងដែលបង្កើតបន្ថែមថ្មី) អាស្រ័យទៅតាមតម្រូវការព័ត៌មានលម្អិតរបស់អង្គភាពប្រើប្រាស់ និងលទ្ធភាពគាំទ្របានរបស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងត្រូវស្នើសុំការពិនិត្យនិងសម្រេចពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ចំណាត់ថ្នាក់គម្រោង ត្រូវបានដាក់ឱ្យអនុវត្តតាមរយៈប្រកាសលេខ ៨៨២ សហវ.ប្រក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់គម្រោងនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ និងអាចត្រូវបានកែសម្រួលជាបន្តបន្ទាប់ តាមរយៈប្រកាសបំពេញបន្ថែម ឬលុប ឬកែប្រែថ្មី នូវលេខកូដចំណាត់ថ្នាក់គម្រោងដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាស្រ័យទៅតាមតម្រូវការចាំបាច់នៃការកត់ត្រាថវិកាទៅតាមគម្រោងនីមួយៗ។ ចំណាត់ថ្នាក់គម្រោង ជាកម្មវត្ថុនៃការធ្វើបច្ចុប្បន្នភាព ស្របតាមការប្រែប្រួលនៃបរិការណ៍គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

**៣.៣.៧ ចំណាត់ថ្នាក់មូលនិធិ**

ចំណាត់ថ្នាក់មូលនិធិនៃមាតិកាថវិការដ្ឋ មានគោលបំណងបង្ហាញអំពីប្រភពមូលនិធិសម្រាប់ធានាដល់ការអនុវត្តថវិការបស់រដ្ឋ ដោយផ្អែកលើប្រភពហិរញ្ញប្បទាននានា មានដូចជាពីប្រភពខ្លួនឯងផ្ទាល់ និងប្រភពពីដៃគូអភិវឌ្ឍន៍នានា។

ចំណាត់ថ្នាក់មូលនិធិ ត្រូវបានរៀបចំឡើងដោយផ្អែកលើប្រភពហិរញ្ញប្បទាន ចំនួន៣ គឺប្រភពហិរញ្ញប្បទានក្នុងស្រុក ហិរញ្ញប្បទានឥតសំណង និងឥណទានសម្បទាន អមដោយការបរិយាយនៃមូលនិធិទាំងនោះ។ ចំណាត់ថ្នាក់មូលនិធិត្រូវប្រើប្រាស់លេខសម្គាល់សរុបចំនួន៥ខ្ទង់ សម្រាប់សម្គាល់មូលនិធិនីមួយៗ ដោយលេខមួយ (១) ពីមុខលេខកូដសម្គាល់ សំដៅដល់ប្រភពហិរញ្ញប្បទានក្នុងស្រុក, លេខពីរ (២) ពីមុខលេខកូដសម្គាល់ សំដៅដល់ប្រភពហិរញ្ញប្បទានឥតសំណង និងលេខបី (៣) ពីមុខលេខកូដសម្គាល់ សំដៅដល់ឥណទានសម្បទាន ។ ចំណាត់ថ្នាក់មូលនិធិអាចបែងចែកលម្អិតជាងនេះ និងត្រូវមានលេខកូដសម្គាល់បន្ថែម (អាចមានច្រើនខ្ទង់ អាស្រ័យទៅតាមចំនួនមូលនិធិដែលបង្កើតបន្ថែមថ្មី) អាស្រ័យទៅតាមតម្រូវការព័ត៌មានលម្អិតរបស់អង្គភាពប្រើប្រាស់ និងលទ្ធភាពគាំទ្របានរបស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងត្រូវស្នើសុំការពិនិត្យនិងសម្រេចពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ចំណាត់ថ្នាក់មូលនិធិ ត្រូវបានដាក់ឱ្យអនុវត្តតាមរយៈប្រកាសលេខ ៧៣២ សហវ.ប្រក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់មូលនិធិនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ និងអាចត្រូវបានកែសម្រួលជាបន្តបន្ទាប់ តាមរយៈប្រកាសបំពេញបន្ថែម ឬលុប ឬកែប្រែថ្មី នូវលេខកូដចំណាត់ថ្នាក់មូលនិធិ ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាស្រ័យទៅតាមតម្រូវការចាំបាច់នៃការកត់ត្រាថវិកាទៅតាមមូលនិធិនីមួយៗ។ ចំណាត់ថ្នាក់មូលនិធិ ជាកម្មវត្ថុនៃការធ្វើបច្ចុប្បន្នភាព ស្របតាមការប្រែប្រួលនៃបរិការណ៍គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

## ៣.៤ ភាពប្រទាក់ក្រឡាគ្នារវាងថវិកានិងចំណាត់ថ្នាក់នៃមាតិកាថវិការដ្ឋ

ថវិកាត្រូវបានបែងចែកទៅតាមប្រភេទនៃចំណូលនិងចំណាយថវិកា ទៅតាមកម្មវិធី និងរដ្ឋបាលនីមួយៗ ឬអាចលម្អិតជាងនេះទៀត ទៅតាមតម្រូវការចាំបាច់នៃការគ្រប់គ្រងថវិកា។ ដើម្បីមានមូលដ្ឋានក្នុងការបែងចែកថវិកានេះ អ្នកគ្រប់គ្រងថវិកានឹងប្រើប្រាស់ចំណាត់ថ្នាក់នៃមាតិកាថវិការដ្ឋ សម្រាប់តាងជាលេខសម្គាល់នៃថវិកាដែលនឹងបែងចែកលម្អិតទៅតាមមុខសញ្ញាថវិកា ឬកម្មវិធី ឬអង្គភាព ជាដើម។ ចំណាត់ថ្នាក់នៃមាតិកាថវិការដ្ឋក្លាយជាឧបករណ៍ដែលយកទៅវាស់វែងនិងតាងជាតម្លៃនៃកញ្ចប់ថវិកាដោយអ្នកគ្រប់គ្រងថវិកា និងជាមធ្យោបាយមួយរបស់អ្នកគ្រប់គ្រងថវិកាក្នុងការកត់ត្រា តាមដាន រាយការណ៍ និងគ្រប់គ្រងថវិកាទាំងនោះទៅតាមមុខសញ្ញាដែលបានបែងចែក។

## ៣.៥ មាតិកាគណនី

មាតិកាគណនីត្រូវបានប្រើប្រាស់នៅក្នុងក្របខ័ណ្ឌនៃគណនេយ្យទូទៅ មូលដ្ឋានបង្គរ សម្រាប់រាយការណ៍អំពីស្ថានភាពហិរញ្ញវត្ថុនិងលទ្ធផលហិរញ្ញវត្ថុ។ មាតិកាគណនី ត្រូវបានបែងចែកចេញជាថ្នាក់ ជំពូក គណនី និងអនុគណនី ឬ អាចលម្អិតដល់អនុគណនីរង តាមតម្រូវការចាំបាច់របស់គណនេយ្យករសាធារណៈ។ មាតិកាគណនីត្រូវបានប្រមូលផ្តុំ

នៅក្នុងតារាងតែមួយ ហៅថាប្លង់គណនេយ្យសាធារណៈ ដែលត្រូវដាក់ចេញដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាតិកាគណនីមានទំនាក់ទំនងគ្នាទៅវិញទៅមកជាមួយមាតិកាថវិកា និងត្រូវមានសង្គតិភាពនឹងគ្នា ជាពិសេសផ្នែកចំណូលនិងចំណាយ។ ក្នុងន័យនេះ លេខកូដសម្គាល់ដែលបានប្រើប្រាស់ក្នុងចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាត្រូវឱ្យដូចគ្នានឹងលេខកូដសម្គាល់ដែលបានប្រើប្រាស់ក្នុងមាតិកាគណនី ដោយហេតុតែជាមុខសញ្ញាសេដ្ឋកិច្ចតែមួយ។ ម្យ៉ាងវិញទៀត ការរៀបចំមាតិកាទាំងពីរឱ្យសង្គតិភាពនឹងគ្នានេះនឹងជួយសម្រួលដល់ការរៀបចំប្រព័ន្ធ FMIS សម្រាប់កត់ត្រានិងរាយការណ៍ ទាំងនៅក្នុងក្របខ័ណ្ឌគណនេយ្យថវិកានិងគណនេយ្យទូទៅ ព្រមទាំងអាចឆ្លើយតបទៅនឹងឧត្តមានុវត្តន៍អន្តរជាតិផងដែរ។

**៣.៦ ប្លង់គណនេយ្យនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

ការរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តម្រូវឱ្យមានប្លង់គណនេយ្យសម្រាប់កត់ត្រាប្រតិបត្តិការថវិកា ហិរញ្ញវត្ថុ និងគណនេយ្យ នៅក្នុងប្រព័ន្ធ។ ប្លង់គណនេយ្យនៃប្រព័ន្ធ FMIS ត្រូវរៀបចំដោយផ្អែកលើមាតិកាថវិកានិងមាតិកាគណនី ដែលបានកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងអាចមានមាតិកាគណនីផ្សេងទៀតនៃប្រព័ន្ធ សម្រាប់បម្រើដល់ការកត់ត្រាប្រតិបត្តិការក្នុងប្រព័ន្ធនិងសមស្របទៅនឹងនីតិវិធីការងារក្នុងប្រព័ន្ធ។ មាតិកាទាំងនេះត្រូវបានបង្កើត ដោយមានការពិគ្រោះយោបល់ជាមួយអគ្គនាយកដ្ឋានជំនាញពាក់ព័ន្ធ និងត្រូវបញ្ចូលទៅក្នុងប្លង់គណនេយ្យសាធារណៈ តាមរយៈប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**៣.៧ ការកំណត់មាតិកាថវិកា**

ចំណាត់ថ្នាក់នៃមាតិកាថវិការដ្ឋត្រូវរៀបចំឡើងដោយអគ្គនាយកដ្ឋានថវិកា និងអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ សហការជាមួយអគ្គនាយកដ្ឋានរតនាគារជាតិនិងអគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ផ្អែកលើតម្រូវការនៃការគ្រប់គ្រងថវិកា ការកត់ត្រា តាមដាន និងរបាយការណ៍អំពីព័ត៌មានថវិកា និងត្រូវដាក់ឱ្យអនុវត្តដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈត្រូវរៀបចំឡើងដោយអគ្គនាយកដ្ឋានរតនាគារជាតិ សហការជាមួយអគ្គនាយកដ្ឋានថវិកា អគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងអគ្គនាយកដ្ឋានជំនាញពាក់ព័ន្ធផ្សេងទៀត ដោយផ្អែកលើតម្រូវការនៃការគ្រប់គ្រងគណនេយ្យ ការកត់ត្រា តាមដាន និងរបាយការណ៍អំពីព័ត៌មានហិរញ្ញវត្ថុនិងគណនេយ្យ និងត្រូវដាក់ឱ្យអនុវត្តដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

# ជំពូកទី៤
# កិច្ចប្រតិបត្តិការថវិកា

កិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិកា ដែលជាលទ្ធផលនៃការអនុវត្តច្បាប់ហិរញ្ញវត្ថុ ប្រចាំឆ្នាំនីមួយៗ ត្រូវចុះកិច្ចបញ្ជិកាទៅក្នុងគណនេយ្យថវិកានិងគណនេយ្យទូទៅ នៅក្នុងប្រព័ន្ធ FMIS ស្របតាមខ្លឹមសារនៃមាត្រា៣៣និងមាត្រា៣៤នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ។ ការកត់ត្រានៅក្នុងគណនេយ្យថវិកាត្រូវគោរពតាមវិធានដែលមានកំណត់ក្នុងគោលការណ៍ណែនាំនេះ។ ដោយឡែក ការកត់ត្រានៅក្នុងគណនេយ្យទូទៅត្រូវគោរពតាមគោលការណ៍ណែនាំដោយឡែក ស្របតាមស្តង់ដាគណនេយ្យសាធារណៈកម្ពុជា ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ បន្ថែមពីលើនេះ ការកត់ត្រាប្រតិបត្តិការណាមួយជាចំណូលនិងចំណាយថវិកាត្រូវផ្អែកទៅលើការកំណត់បាននូវចំណុចទទួលស្គាល់នៃប្រតិបត្តិការទាំងនោះ។ ចំពោះគណនេយ្យថវិកា ការទទួលស្គាល់នៃប្រតិបត្តិការចំណូលនិងចំណាយថវិកា ត្រូវផ្អែកទៅទាំងស្រុងលើមូលដ្ឋានចូលឬចេញសាច់ប្រាក់។ ដោយឡែកគណនេយ្យទូទៅ ការទទួលស្គាល់ប្រតិបត្តិការទាំងនេះ ត្រូវផ្អែកទៅលើការកើតឡើងនៃព្រឹត្តិការណ៍សេដ្ឋកិច្ចដែលនាំឱ្យមានសិទ្ធិនិងកាតព្វកិច្ចពាក់ព័ន្ធនឹងអង្គភាពសាធារណៈ ពោលគឺពុំមានអាស្រ័យទៅនឹងចលនាសាច់ប្រាក់នោះទេ។

ដើម្បីមានមូលដ្ឋានចុះកិច្ចបញ្ជិកាគណនេយ្យថវិកានៃប្រតិបត្តិការចំណូលនិងចំណាយថវិកា ជំពូកទី៤នេះនឹងកំណត់អំពីលក្ខខណ្ឌទូទៅសម្រាប់ការទទួលស្គាល់ប្រតិបត្តិការចំណូលនិងចំណាយថវិកា ដោយលម្អិតទៅតាមប្រភេទចំណូលនិងចំណាយថវិកានីមួយៗ និងកំណត់បន្ថែមអំពីលក្ខខណ្ឌដោយឡែកសម្រាប់អនុវត្តប្រតិបត្តិការចំណូលនិងចំណាយថវិកាមួយចំនួន ព្រមទាំងគូសរំលេចអំពីយន្តការនៃការកែតម្រូវប្រតិបត្តិការថវិកា ក្នុងករណីដែលមានកំហុសឆ្គងកត់ត្រា។

## ៤.១ កិច្ចប្រតិបត្តិការចំណូលថវិកា

ផ្អែកតាមមាត្រា២៤នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០២៣ ធនធានថវិកា រួមមាន ចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធ និងចំណូលផ្សេងៗ។ ជាទូទៅ ចំណូលត្រូវឆ្លងកាត់២ដំណាក់កាលធំៗ ដូចខាងក្រោម៖

- ដំណាក់កាលជម្រះចំណូល៖ ការជម្រះចំណូល គឺជាការកំណត់ចំនួនទឹកប្រាក់នៃឥណទេយ្យ ស្របតាមលក្ខខណ្ឌដែលបានកំណត់ដោយបទប្បញ្ញត្តិជាធរមាន។ ចំណូលត្រូវបានជម្រះជាទឹកប្រាក់ដុលដោយមិនត្រូវកាត់កងជាមួយទឹកប្រាក់ចំណាយឡើយ។ ការកំណត់បាននូវទឹកប្រាក់នៃឥណទេយ្យ ពុំទាន់មានផលប៉ះពាល់ដល់ការកត់ត្រាជាចំណូលថវិកានៅក្នុងគណនេយ្យថវិកាទេ បើទោះបីជាដឹងច្បាស់លាស់អំពីមុខសញ្ញាចំណូលថវិកាណាមួយក៏ដោយ ពីព្រោះក្នុងដំណាក់កាលនេះ ពុំទាន់មានវំហូរសាច់ប្រាក់ចូលទៅក្នុងគណនីធនាគារឬបេឡានៅឡើយទេ។ ផ្ទុយទៅវិញ នៅក្នុងគណនេយ្យទូទៅ ឥណទេយ្យដែលបានកំណត់នេះត្រូវបានយកមកកត់ត្រាទទួលស្គាល់ជាចំណូល ដោយត្រូវបដិភាគនឹងគណនីត្រូវទទួល ដែលរដ្ឋត្រូវប្រមូលជាសាច់ប្រាក់នៅពេលក្រោយទៀត។ ការកត់ត្រាបែបនេះ គឺពឹងផ្អែកទៅលើសិទ្ធិរបស់រដ្ឋដែលមានក្នុងការប្រមូលចំណូលទាំងនេះដោយឈរលើមូលដ្ឋានកិច្ចសន្យាឬលិខិតបទដ្ឋានគតិយុត្តដែលអនុញ្ញាតឱ្យមានចំណូលទាំងនេះ។
- ដំណាក់កាលប្រមូលឥណទេយ្យ៖ ការប្រមូលឥណទេយ្យត្រូវប្រតិបត្តិតាមប្រភេទឥណទេយ្យនីមួយៗ និងឈានដល់ការប្រមូលជាសាច់ប្រាក់ជាក់ស្តែង។ ក្នុងករណីដែលទទួលបានសាច់ប្រាក់លើមុខសញ្ញាចំណូលដែលត្រូវទារ នោះគណនេយ្យករសាធារណៈត្រូវកត់ត្រាទទួលស្គាល់ជាចំណូលថវិកានៅក្នុងគណនេយ្យថវិកា។ នៅក្នុងដំណាក់កាលនេះ ពុំមានការកត់ត្រាជាចំណូលម្តងទៀត នៅក្នុងគណនេយ្យទូទៅនោះទេ គឺមានតែការកត់ត្រាជម្រះគណនីត្រូវទទួល ជាមួយនឹងគណនីសាច់ប្រាក់បានទទួលដោយគណនេយ្យករសាធារណៈ។

### ៤.១.១ លក្ខខណ្ឌទូទៅនៃការទទួលស្គាល់ចំណូលថវិកា

អាស្រ័យទៅតាមប្រភេទចំណូល ពេលវេលា និងការត្រួតពិនិត្យផ្ទាល់របស់គណនេយ្យករសាធារណៈ ប្រតិបត្តិការចំណូលត្រូវបានទទួលស្គាល់ជាចំណូលថវិកា លុះត្រាតែប្រតិបត្តិការទាំងនោះគោរពបានទៅតាមលក្ខខណ្ឌតម្រូវទាំង៤ ជាសារវន្តនៃការទទួលស្គាល់ចំណូលថវិកា ដូចមានកំណត់ខាងក្រោមៈ

- មានលំហូរសាច់ប្រាក់ចូលពិតប្រាកដទៅក្នុងគណនីធនាគារឬបេឡារបស់គណនេយ្យករសាធារណៈ នៃឆ្នាំអនុវត្តថវិកា
- ព្រឹត្តិការណ៍ចំណូលកើតមានឡើងពិតប្រាកដ នៅក្នុងឆ្នាំអនុវត្តថវិកា
- មុខសញ្ញាចំណូលថវិកាត្រូវបានកំណត់ច្បាស់លាស់ ដោយផ្អែកលើកិច្ចសន្យាឬលិខិតបទដ្ឋានគតិយុត្តបង្កើតចំណូល និងត្រូវបានបញ្ជាក់ទទួលស្គាល់ដោយអាណាប័ក និង
- មានការត្រួតពិនិត្យត្រឹមត្រូវនិងបញ្ជាក់ទទួលស្គាល់លើចំណូលថវិកាដោយគណនេយ្យករសាធារណៈ ស្របតាមខ្លឹមសារនៃមាត្រា២៧នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ។

នៅពេលដែលគ្រប់លក្ខខណ្ឌនៃការទទួលស្គាល់ចំណូលថវិកាត្រូវបានបំពេញសម្រាប់ប្រតិបត្តិការមួយ ចំណូលថវិកាត្រូវបានកត់ត្រាទៅតាមប្រភេទនៃចំណូលថវិកានីមួយៗ ដោយផ្អែកលើចំណាត់ថ្នាក់សេដ្ឋកិច្ច (ផ្នែកមាតិកាចំណូលថវិកា) នៃមាតិកាថវិការដ្ឋ នៅក្នុងគណនេយ្យថវិកា និងប្រព័ន្ធ FMIS ដោយកំណត់យកតាមថ្ងៃខែឆ្នាំនៃលំហូរចូលសាច់ប្រាក់ពិតប្រាកដ។ កាលបរិច្ឆេទនៃចំណូលថវិកានេះត្រូវបានកំណត់ជាគោលដោយគណនេយ្យករសាធារណៈ និងជាមូលដ្ឋានសម្រាប់ការរាយការណ៍អំពីការអនុវត្តចំណូលថវិកានៃឆ្នាំអនុវត្តថវិកា។ ការកត់ត្រាចំណូលថវិកានៅក្នុងគណនេយ្យថវិកាត្រូវផ្អែកលើសលាកបត្របង្វែរចំណូល អមដោយសក្ខីបត្រគាំទ្រ ដែលអាស្រ័យទៅតាមប្រភេទនៃចំណូលថវិកានីមួយៗ និងប័ណ្ណបង់ប្រាក់ ឬ ប្រកាសឥណទានធនាគារ ឬ របាយការណ៍ធនាគារ ដែលបញ្ជាក់អំពីការបង់ប្រាក់ចូលគណនីធនាគាររបស់គណនេយ្យករសាធារណៈ ឬសក្ខីបត្រផ្សេងទៀតដែលបង្ហាញអំពីការទទួលបានសាច់ប្រាក់ដោយគណនេយ្យករសាធារណៈ។

<u>**បញ្ជាក់៖**</u>

- អាណាប័កត្រូវរៀបចំសលាកបត្របង្វែរចំណូល ដោយមានភ្ជាប់ជាមួយនឹងសក្ខីបត្រគាំទ្រ ឱ្យបានឆាប់រហ័សនិងទាន់ពេលនៃឆ្នាំអនុវត្តថវិកា ដើម្បីធានាបាននូវការគោរពគោលការណ៍ថវិកាប្រចាំឆ្នាំដូចមានចែងក្នុងមាត្រា១១ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០២៣។
- កាលបរិច្ឆេទនៃការទទួលការទូទាត់ នៅក្នុងប្រព័ន្ធ FMIS ឬ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដទៃទៀត គឺជាមូលដ្ឋាននៃការកំណត់ថ្ងៃខែឆ្នាំនៃលំហូរសាច់ប្រាក់ចូលពិតប្រាកដសម្រាប់ទទួលស្គាល់ជាចំណូលថវិកា។
- ក្នុងករណីដែលការប្រមូលឥណទេយ្យជាសាច់ប្រាក់ត្រូវបានអនុវត្តក្រោយថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំអនុវត្ត និងបើទោះបីជាការគ្រោងចំណូលថវិកា ព្រឹត្តិការណ៍ចំណូល និងការពិនិត្យរបស់អាណាប័កនិងគណនេយ្យករសាធារណៈបានត្រឹមត្រូវ និងរួចរាល់ក្នុងឆ្នាំអនុវត្តថវិកាក៏ដោយ ក៏ប្រតិបត្តិការចំណូលនោះត្រូវទទួលស្គាល់ជាចំណូលថវិកាក្នុងឆ្នាំបន្ទាប់នៅក្នុងគណនេយ្យថវិកាដែរ។ ការណ៍នេះអាចនាំឱ្យមានផលប៉ះពាល់ដល់ការកត់ត្រា និងរាយការណ៍អំពីការអនុវត្តឥណទានចំណូលថវិកា។ ដូច្នេះ អាណាប័កត្រូវខិតខំប្រមូលចំណូលសាច់ប្រាក់ឱ្យបានទាន់ពេលក្នុងឆ្នាំអនុវត្តថវិកា។

<u>ឧទាហរណ៍៖</u>

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានជួលទីតាំងមួយកន្លែងឱ្យធនាគារពាណិជ្ជដៃគូសម្រាប់ដាក់ទូដកសាច់ប្រាក់ដោយស្វ័យប្រវត្តិ ដោយបានប្រាក់ឈ្នួលប្រចាំខែ ចំនួន ១លានរៀល និងបានចុះកិច្ចសន្យារយៈពេលបីឆ្នាំ ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥។ នៅក្នុងកិច្ចសន្យាបានតម្រូវឱ្យធនាគារពាណិជ្ជដៃគូ បង់ប្រាក់ឈ្នួលទីតាំងប្រចាំខែនៅក្នុងសប្តាហ៍ទី១ នៃខែបន្ទាប់។ ជារៀងរាល់ខែ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានទទួលប្រាក់ឈ្នួល

ចំនួន ១លានរៀល និងបានបង់ចូលគណនីទោលរតនាគារនៅថ្ងៃបន្ទាប់ ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានជូនដំណឹងទៅគណនេយ្យករសាធារណៈ តាមរយៈឯកសារចំណូល សម្រាប់ធ្វើការផ្ទៀងផ្ទាត់។ ក្រោយពីបានពិនិត្យគ្រប់ជ្រុងជ្រោយ គណនេយ្យករសាធារណៈត្រូវទទួលស្គាល់ចំណូលនេះជាចំណូលថវិកា (គណនីលេខ ៧៣០៣) ពីការជួលទីតាំង ដោយហេតុតែព្រឹត្តិការណ៍ជួលកើតមានពិតប្រាកដ, គណនេយ្យករសាធារណៈបានទទួលប្រាក់ចូលគណនីទោលរតនាគារ និងបានពិនិត្យថាត្រឹមត្រូវ ព្រមទាំងកំណត់បានមុខសញ្ញាចំណូលពីការជួលទីតាំង។ ដូច្នេះ គណនេយ្យករសាធារណៈត្រូវទទួលស្គាល់ចំណូលសាច់ប្រាក់នេះជាចំណូលថវិកា (ពីការជួលទីតាំង) នៅថ្ងៃខែឆ្នាំដែលទទួលបានសាច់ប្រាក់។ នៅក្នុងប្រព័ន្ធ FMIS គណនេយ្យករសាធារណៈត្រូវកត់ត្រាទទួលស្គាល់ជាចំណូលថវិកា ទាំងនៅក្នុងទិដ្ឋភាពគណនេយ្យថវិកាទាំងក្នុងគណនេយ្យទូទៅ (កត់ត្រាជម្រះ គណនីត្រូវទទួល ជាមួយនឹងគណនីសាច់ប្រាក់) នៅថ្ងៃខែឆ្នាំដែលគណនេយ្យករសាធារណៈបានទទួលសាច់ប្រាក់។

### ៤.១.២ លក្ខខណ្ឌដោយឡែកនៃការទទួលស្គាល់ចំណូលថវិកា

ប្រតិបត្តិការចំណូលមួយចំនួនពុំបានគោរពតាមលក្ខខណ្ឌជាសារវន្តទាំង៤ដូចបានកំណត់ក្នុងចំណុចទី៤.១.១ ខាងលើនេះទេ ដោយសារតែក្របខ័ណ្ឌពេលវេលានិងចរិតនៃការប្រមូលចំណូលទាំងនោះពុំអាចប្រព្រឹត្តទៅបានតាមការគ្រោងទុកនិងពុំអាចអនុវត្តតាមនីតិវិធីជាធម្មតា។ ក្នុងករណីនេះធ្វើឱ្យគណនេយ្យករសាធារណៈពុំអាចកត់ត្រាទទួលស្គាល់ជាចំណូលថវិកាតាមគោលការណ៍គណនេយ្យថវិកាបានទេ ហើយថែមទាំងអាចមានវិបាកជាសារវន្តដល់ការរាយការណ៍អំពីការអនុវត្តចំណូលថវិកាប្រចាំឆ្នាំ ធៀបនឹងផែនការ។ ដើម្បីដោះស្រាយបញ្ហានេះ លក្ខខណ្ឌមួយចំនួនត្រូវបានអនុញ្ញាតឱ្យអនុវត្តដោយឡែក ក្នុងការទទួលស្គាល់ប្រតិបត្តិការមួយចំនួនជាចំណូលថវិកា និងកត់ត្រាក្នុងគណនេយ្យថវិកា។ ជាការពិតណាស់ ការលើកលែងសម្រាប់ប្រតិបត្តិការទាំងនេះអាចមានវិបាកដល់ការវាយតម្លៃលើគុណភាពនៃគណនីចំណូលថវិកា ដោយហេតុតែចំណូលពុំត្រូវបានប្រមូលឱ្យបានទាន់ពេលនិងក្នុងឆ្នាំអនុវត្តថវិកាដែលច្បាប់ហិរញ្ញវត្ថុបានអនុញ្ញាតឱ្យប្រមូលជាប្រចាំឆ្នាំ (មិនស្របតាមគោលការណ៍ថវិកា៖ ប្រចាំឆ្នាំ ឯកត្តភាព និងសកលភាព)។ ហេតុដូច្នេះហើយ ការលើកលែងនេះគឺសម្រាប់តែប្រតិបត្តិការជាក់លាក់ និងត្រូវធ្វើការកែលម្អជាបណ្តើរៗទាំងវិធានទាំងនីតិវិធីការងារបន្ថែមទៀត ដើម្បីឱ្យប្រតិបត្តិការចំណូលទាំងនោះអាចអនុវត្តបានដោយអនុលោមតាមគោលការណ៍រួមនៃគណនេយ្យថវិកា។ ប្រតិបត្តិការចំណូល ដែលអនុញ្ញាតឱ្យគោរពតាមលក្ខខណ្ឌដោយឡែក សម្រាប់ការទទួលស្គាល់ជាចំណូលថវិកា រួមមាន៖

#### ៤.១.២.១ ប្រតិបត្តិការសាច់ប្រាក់បានទទួលនៅក្នុងឆ្នាំអនុវត្តថវិកា ប៉ុន្តែពុំទាន់ដឹងច្បាស់អំពីមុខសញ្ញាចំណូលថវិកា

ចំណូលមួយចំនួនត្រូវបានអតិថិជន ឬ អ្នកជាប់ពន្ធ បង់ជាសាច់ប្រាក់ចូលមកគណនេយ្យករសាធារណៈ ប៉ុន្តែអ្នកបង់ប្រាក់ពុំបានផ្តល់ព័ត៌មានគ្រប់គ្រាន់មកគណនេយ្យករសាធារណៈឬអាណាប័ក ដើម្បីពិនិត្យនិងបញ្ជាក់លើមុខសញ្ញាចំណូល ឬអាចជាករណីដែលកំហុសច្រឡំដោយអ្នកបង់ប្រាក់។ ក្នុងករណីនេះ ប្រតិបត្តិការចំណូលទាំងនេះពុំអាចកត់ត្រានិងទទួលស្គាល់ជាចំណូលថវិកានៃឆ្នាំអនុវត្តថវិកាបានទេនៅក្នុងគណនេយ្យថវិកា បើទោះបីជាមានលំហូរសាច់ប្រាក់ចូលពិតប្រាកដទៅក្នុងគណនីធនាគារឬបេឡារបស់គណនេយ្យករសាធារណៈនៅក្នុងឆ្នាំអនុវត្តថវិកាក៏ដោយ ដោយសារតែប្រតិបត្តិការទាំងនេះមានលក្ខណៈ ដូចខាងក្រោម៖

- ព្រឹត្តិការណ៍ចំណូលពុំមានភាពច្បាស់លាស់
- មុខសញ្ញាចំណូលថវិកាពុំត្រូវបានកំណត់ច្បាស់លាស់ និងពុំមានការបញ្ជាក់ទទួលស្គាល់ពីអាណាប័ក គិតត្រឹមដំណាច់រយៈពេលបំពេញបន្ថែម (យ៉ាងយូរបំផុតត្រឹមថ្ងៃទី៣១ ខែមករា ឆ្នាំបន្ទាប់)
- មានលំហូរសាច់ប្រាក់ចូលពិតប្រាកដទៅក្នុងគណនីធនាគារឬបេឡារបស់គណនេយ្យករសាធារណៈ នៅក្នុងឆ្នាំអនុវត្តថវិកា និង

- មានការត្រួតពិនិត្យផ្ទៀងផ្ទាត់ភាពត្រឹមត្រូវដោយគណនេយ្យករសាធារណៈនិងមិនដឹងអំពីមុខសញ្ញាចំណូលថវិកា ស្របតាមខ្លឹមសារនៃមាត្រា២៧នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ។

ក្នុងករណីដែលអាណាប័កអាចប្រគល់ឯកសារគាំទ្រចំណូល និងអាចបញ្ជាក់ទទួលស្គាល់ជាចំណូលថវិកាមុនពេលបញ្ចប់កាលបរិច្ឆេទរយៈពេលបំពេញបន្ថែម គណនេយ្យករសាធារណៈត្រូវកត់ត្រាទទួលស្គាល់ចំណូលនោះទៅតាមប្រភេទនៃចំណូលថវិកានីមួយៗ ដោយផ្អែកលើចំណាត់ថ្នាក់សេដ្ឋកិច្ច (ផ្នែកមាតិកាចំណូលថវិកា) នៃមាតិកាថវិការដ្ឋ នៅក្នុងគណនេយ្យថវិកា និងប្រព័ន្ធ FMIS ដោយកំណត់យកតាមថ្ងៃខែឆ្នាំនៃសលាកបត្របង្វែរចំណូល (ឬកំណត់យកថ្ងៃទី៣១ ខែធ្នូ ឆ្នាំអនុវត្តថវិកា ករណីគណនេយ្យករសាធារណៈបានទទួលសលាកបត្របង្វែរចំណូល នៅក្នុងអំឡុងរយៈពេលបំពេញបន្ថែម) ដោយមិនយកតាមថ្ងៃខែឆ្នាំនៃវិហរូចូលសាច់ប្រាក់ពិតប្រាកដនោះទេ។ កាលបរិច្ឆេទនៃចំណូលថវិកានេះត្រូវបានកំណត់ជាគោលដោយគណនេយ្យករសាធារណៈ និងជាមូលដ្ឋានសម្រាប់ការរាយការណ៍អំពីការអនុវត្តចំណូលថវិកានៃឆ្នាំអនុវត្តថវិកា។ ការកត់ត្រាចំណូលថវិកានៅក្នុងគណនេយ្យថវិកាត្រូវផ្អែកលើសលាកបត្របង្វែរចំណូល អមដោយសក្ខីបត្រគាំទ្រ ដែលអាស្រ័យទៅតាមប្រភេទនៃចំណូលថវិកានីមួយៗ និងប័ណ្ណបង់ប្រាក់ ឬប្រកាសឥណទានធនាគារ ឬរបាយការណ៍ធនាគារ ដែលបញ្ជាក់អំពីការបង់ប្រាក់ចូលគណនីធនាគាររបស់គណនេយ្យករសាធារណៈ ឬសក្ខីបត្រផ្សេងទៀតដែលបង្ហាញអំពីការទទួលបានសាច់ប្រាក់ដោយគណនេយ្យករសាធារណៈ។

ក្នុងករណីដែលអាណាប័កមិនអាចប្រគល់ឯកសារគាំទ្រចំណូល និងមិនអាចបញ្ជាក់ទទួលស្គាល់ជាចំណូលថវិកាមុនពេលបញ្ចប់កាលបរិច្ឆេទរយៈពេលបំពេញបន្ថែម គណនេយ្យករសាធារណៈពុំកត់ត្រាប្រតិបត្តិការចំណូលទាំងនេះនៅក្នុងគណនេយ្យថវិកាទេ ប៉ុន្តែត្រូវចុះកិច្ចបញ្ជិកាគណនេយ្យទ្វេភាគ នៅក្នុងគណនេយ្យទូទៅ និងប្រព័ន្ធ FMIS សម្រាប់ប្រតិបត្តិការទទួលសាច់ប្រាក់ចំណូលដោយបដិភាគនឹងគណនីចំណូលបណ្ដោះអាសន្ន ដែលមានចរិតលក្ខណៈជាបំណុលត្រូវសងត្រលប់ទៅវិញ។

<u>**បញ្ជាក់៖**</u>

- អាណាប័កត្រូវកំណត់មុខសញ្ញាចំណូលថវិកា ដែលពាក់ព័ន្ធនឹងសាច់ប្រាក់ដែលបានបង់ចូលគណនេយ្យករសាធារណៈ ក្នុងរយៈពេលកំណត់យ៉ាងយូរបំផុតត្រឹម១ឆ្នាំ រាប់ចាប់ពីថ្ងៃដែលសាច់ប្រាក់បានបង់ចូលគណនីធនាគារឬបេឡារបស់គណនេយ្យករសាធារណៈ។ ក្នុងករណីផុតកាលកំណត់នេះ និងពុំមានការបំភ្លឺពីអាណាប័ក គណនេយ្យករសាធារណៈត្រូវបង្វែរសាច់ប្រាក់ចំណូលនេះជាចំណូលថវិកាផ្សេងៗរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬទៅតាមមុខសញ្ញាចំណូលថវិកានីមួយៗ អាស្រ័យទៅតាមព័ត៌មានបឋមនៃវិហរូសាច់ប្រាក់ចូលនោះ ហើយអាណាប័កពុំអាចស្នើសុំបង្វែរទៅជាចំណូលថវិការបស់ខ្លួន និងពុំអាចស្នើសុំប្រាក់រង្វាន់ដែលពាក់ព័ន្ធនឹងចំណូលថវិកានោះវិញបានទេ។
- ក្នុងករណីដែលគណនេយ្យករសាធារណៈបានបង្វែរសាច់ប្រាក់ចំណូលជាចំណូលថវិកាផ្សេងៗរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរួចរាល់ ឬទៅតាមមុខសញ្ញាចំណូលថវិកានានា ហើយមានអតិថិជនបានជូនដំណឹងអំពីការភ័ន្តច្រឡំក្នុងការបង់ប្រាក់ និងស្នើសុំមកគណនេយ្យករសាធារណៈដើម្បីដកប្រាក់ត្រលប់ទៅវិញ គណនេយ្យករសាធារណៈត្រូវរៀបចំស្នើសុំទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឬអាណាប័កពាក់ព័ន្ធ ដើម្បីស្នើសុំគោលការណ៍ឯកភាពក្នុងការផ្ទេរប្រាក់ត្រលប់ទៅអតិថិជនវិញ តាមរយៈការបោះផ្សាយអាណត្តិបើកប្រាក់សងត្រលប់ទៅអតិថិជន (ដោយកំណត់ជាមុខសញ្ញាចំណាយផ្សេងៗ) ដោយផ្អែកលើសំណើសុំរបស់អតិថិជន តាមរយៈគណនេយ្យករសាធារណៈ។

<u>ឧទាហរណ៍៖</u>

ក្រុមហ៊ុន ABC បានបង់ប្រាក់ចំនួន ៥,០០០ ដុល្លារអាម៉េរិក តាមរយៈការបង្វែរចូលគណនីធនាគារ ចូលមកសាលាខេត្តសៀមរាប កាលពីថ្ងៃទី៥ ខែមករា ឆ្នាំ២០២៤ ប៉ុន្តែក្រុមហ៊ុនពុំបានផ្តល់ព័ត៌មានគ្រប់គ្រាន់មកសាលាខេត្ត ដើម្បីពិនិត្យនិងបញ្ជាក់លើមុខសញ្ញាចំណូលទេ។ សាលាខេត្តសៀមរាប ពុំអាចកត់ត្រាប្រតិបត្តិការចំណូលទាំងនេះ និង

ពុំអាចទទួលស្គាល់ជាចំណូលថវិកានៃឆ្នាំអនុវត្តថវិកាបានទេនៅក្នុងគណនេយ្យថវិកា បើទោះបីជាមានរំហូរសាច់ប្រាក់ចូលពិតប្រាកដទៅក្នុងគណនីធនាគាររបស់គណនេយ្យកររតនាគារទទួលបន្ទុកសាលាខេត្តសៀមរាប នៅក្នុងឆ្នាំអនុវត្តថវិកាក៏ដោយ។ ក្រុមហ៊ុនពុំបានផ្តល់ព័ត៌មានមកសាលាខេត្តសៀមរាប អស់រយៈពេល១ឆ្នាំ។ លុះដល់ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៥ ទើបក្រុមហ៊ុនមកសាលាខេត្តដោយបញ្ជាក់អំពីមូលហេតុនៃថវិកាដែលបានចូលគណនីធនាគារ ទឹកប្រាក់ ៥,០០០ ដុល្លារអាម៉េរិក នេះ គឺដើម្បីបង់ថ្លៃសេវាស្នើសុំសិទ្ធិប្រកបអាជីវកម្ម ក្នុងដែនដីសាលាខេត្ត។

ក្នុងករណីខាងលើនេះ៖

ទី១. ពេលបង់សាច់ប្រាក់នៅថ្ងៃទី៥ ខែមករា ឆ្នាំ២០២៤ ដោយសារតែពុំទាន់មានព័ត៌មានអំពីប្រភពចំណូល ដូច្នេះ ពុំមានការទទួលស្គាល់ជាចំណូលថវិកា នៅក្នុងគណនេយ្យថវិកាទេ។ ប៉ុន្តែ ប្រតិបត្តិការនេះត្រូវកត់ត្រាជាសាច់ប្រាក់ចូល ក្នុងកិច្ចបញ្ជិកាគណនេយ្យទូទៅ ដោយកត់ត្រា ឥណពន្ធ គណនី ធនាគារ និងឥណទាន គណនីចំណូលបណ្តោះអាសន្ន ចំនួន ៥,០០០ ដុល្លារអាម៉េរិក។

ទី២. ដោយខ្វះព័ត៌មានអំពីចំណូលសាច់ប្រាក់នេះ ហើយទឹកប្រាក់បានចូលមកជាបណ្តោះអាសន្នអស់រយៈពេលលើសពី១ឆ្នាំ គណនេយ្យកររតនាគារទទួលបន្ទុកសាលាខេត្តសៀមរាបត្រូវកត់ត្រាជាចំណូលថវិកាផ្សេងៗរបស់សាលាខេត្តទាំងនៅក្នុងគណនេយ្យថវិកានិងក្នុងគណនេយ្យទូទៅ។

ទី៣. នៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៥ បើទោះបីជាបានទទួលព័ត៌មានបន្ថែមពីក្រុមហ៊ុនអំពីប្រភពនៃចំណូលសាច់ប្រាក់ ៥,០០០ ដុល្លារអាម៉េរិកនេះក៏ដោយ ក៏គណនេយ្យកររតនាគារទទួលបន្ទុកសាលាខេត្តសៀមរាបពុំត្រូវកត់ត្រាម្តងទៀតនូវមុខសញ្ញាចំណូលថវិកានេះបានទេ ពីព្រោះបានកត់ត្រាម្តងហើយ កាលពីចុងការិយបរិច្ឆេទឆ្នាំ២០២៥។

<u>ឧទាហរណ៍</u>៖

ក្រុមហ៊ុន ABC បានដាក់លិខិតប្រកាសពន្ធ និងបានបង់ប្រាក់ពន្ធទូទាត់ជូនអគ្គនាយកដ្ឋានពន្ធដារ នៅធនាគារពាណិជ្ជដៃគូ នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២៣ ប៉ុន្តែសាច់របស់ក្រុមហ៊ុនដែលបានបង់ ពុំត្រូវបានផ្ទេរចូលគណនីចរន្តរបស់អគ្គនាយកដ្ឋានពន្ធដារនៅធនាគារពាណិជ្ជដៃគូទេ ដោយសារធនាគាពាណិជ្ជដៃគូមានការភាន់ច្រឡំផ្ទេរទៅគណនីចរន្តរបស់រតនាគារខេត្តកណ្តាល។ នៅពេលដែលរតនាគារខេត្ត ទទួលបានសាច់ប្រាក់ រតនាគារពុំមានមូលដ្ឋានកំណត់មុខសញ្ញាចំណូលរបស់អង្គភាពមួយណាទេ ដោយកត់ត្រារក្សាទុកក្នុងគណនីចំណូលបណ្តោះអាសន្ននិងបង្វែរវង់ចាំដោះស្រាយ។ ហូតដល់ខែកុម្ភៈ ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារ បានជូនដំណឹងពីការផ្ទេរចំណូលច្រឡំរបស់ធនាគារពាណិជ្ជដៃគូ មកអគ្គនាយកដ្ឋានរតនាគារជាតិ។ បន្ទាប់ពីបានការជូនដំណឹង អគ្គនាយកដ្ឋានរតនាគារជាតិ បានធ្វើការស្រាវជ្រាវរកព័ត៌មានពាក់ព័ន្ធ ទើបបានរកឃើញចំណូលខាងលើបានបង់ចូលរតនាគារខេត្តកណ្តាល ដូច្នេះ បានធ្វើការផ្ទេរចំណូលខាងលើ នៅខែមីនា ឆ្នាំ២០២៤ មកអគ្គនាយកដ្ឋានរតនាគារជាតិ ដោយកត់ត្រាជាចំណូលបណ្តោះអាសន្នរបស់អគ្គនាយកដ្ឋានពន្ធដារ។ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារ បានរៀបចំសលាកបត្របង្វែរចំណូលមកកាន់អគ្គនាយកដ្ឋានរតនាគារជាតិ ដើម្បីបង្វែរចំណូលនិងកត់ត្រាជាចំណូលថវិកា ក្នុងគណនេយ្យថវិកា នៅឆ្នាំ២០២៤។

### ៤.១.២.២ ប្រតិបត្តិការចំណូលព្រម-ចំណាយព្រម (ករណីទូទាត់រង្វាន់)

មុខសញ្ញាចំណូលមួយចំនួនត្រូវបានទទួលគោលការណ៍លើកទឹកចិត្ត ដើម្បីបង្កើនប្រសិទ្ធភាពនិងជំរុញការប្រមូលចំណូល តាមរយៈការផ្តល់នូវប្រាក់រង្វាន់ កំណត់ដោយប្រកាសអន្តរក្រសួង រវាងក្រសួង ស្ថាប័នសាមីជាមួយនឹងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ សាច់ប្រាក់ចំណូលមួយចំណែកត្រូវបានរក្សាទុក តាមអត្រាបែងចែកប្រាក់រង្វាន់ សម្រាប់បើកប្រាក់រង្វាន់ នៅពេលដែលសាច់ប្រាក់ចំណូលនោះត្រូវបានប្រមូល និងមុនពេលបង់ប្រាក់ចូលគណនីធនាគារឬបេឡារបស់គណនេយ្យករសាធារណៈ។ ស្ថានភាពនេះធ្វើឱ្យគណនេយ្យករសាធារណៈពុំបានទទួលសាច់ប្រាក់ពេញលេញ ប៉ុន្តែមានកាតព្វកិច្ចត្រូវទទួលស្គាល់ជាចំណូលថវិកាពេញលេញ ដោយសារតែចំណូលទាំងនោះត្រូវបានប្រមូលពេញលេញនិងគ្រប់ចំនួនទឹកប្រាក់ពីអតិថិជន។ ក្នុងករណីនេះ ប្រតិបត្តិការចំណូលត្រូវបានកត់ត្រានិងទទួលស្គាល់ជាចំណូលថវិកានៃឆ្នាំអនុវត្តថវិកានៅក្នុងគណនេយ្យថវិកា នៅពេលដែលប្រតិបត្តិការទាំងនោះបំពេញតាមលក្ខខណ្ឌ ដូចខាងក្រោម៖

- មានរំហូរសាច់ប្រាក់ចូលនិងចេញពិតប្រាកដ នៅក្នុងឆ្នាំអនុវត្តថវិកា តាមរយៈរបាយការណ៍សាច់ប្រាក់ដែលមានការបញ្ជាក់ទទួលស្គាល់ដោយអាណាប័ក ប៉ុន្តែសាច់ប្រាក់ទាំងនេះពុំបានចូលគណនីធនាគារឬបេឡារបស់គណនេយ្យករសាធារណៈទេ
- ព្រឹត្តិការណ៍ចំណូលពិតជាបានកើតឡើង នៅក្នុងឆ្នាំកំពុងអនុវត្តថវិកា
- មានការបញ្ជាក់ទទួលស្គាល់ពីអាណាប័កអំពីមុខសញ្ញាចំណូលថវិកា ដោយផ្អែកលើកិច្ចសន្យាឬលិខិតបទដ្ឋានគតិយុត្តបង្កើតចំណូល និង
- មានការត្រួតពិនិត្យផ្ទៀងផ្ទាត់ភាពត្រឹមត្រូវលើចំណូលថវិកានិងចំណាយថវិកាដោយគណនេយ្យករសាធារណៈស្របតាមខ្លឹមសារនៃមាត្រា២៧និងមាត្រា២៨នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ។

ក្នុងករណីដែលអាណាប័កអាចប្រគល់ឯកសារគាំទ្រចំណូល និងអាចបញ្ជាក់ទទួលស្គាល់ជាចំណូលថវិកាព្រមជាមួយនឹងអាណត្តិបើកប្រាក់សម្រាប់ទទួលស្គាល់ជាចំណាយថវិកា មុនថ្ងៃទី៣១ ខែមករា ឆ្នាំបន្ទាប់ (យ៉ាងយូរបំផុតត្រឹមដំណាច់រយៈពេលបំពេញបន្ថែម) គណនេយ្យករសាធារណៈត្រូវកត់ត្រាទទួលស្គាល់ចំណូលនិងចំណាយនោះទៅតាមប្រភេទនៃចំណូលនិងចំណាយថវិកានីមួយៗជាក់ស្តែង ដោយផ្អែកលើចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការដ្ឋនៅក្នុងគណនេយ្យថវិកា និងប្រព័ន្ធ FMIS ដោយកំណត់យកតាមថ្ងៃខែឆ្នាំនៃសលាកបត្របង្វែរចំណូលនិងអាណត្តិបើកប្រាក់ទូទាត់ប្រាក់រង្វាន់ (ឬ កំណត់យកថ្ងៃទី៣១ ខែធ្នូ ឆ្នាំអនុវត្តថវិកា ករណីគណនេយ្យករសាធារណៈបានទទួលឯកសារ នៅក្នុងអំឡុងរយៈពេលបំពេញបន្ថែម) គឺពុំអាស្រ័យទៅនឹងថ្ងៃខែឆ្នាំនៃរំហូរសាច់ប្រាក់ចូលឬចេញពិតប្រាកដនោះទេ។ កាលបរិច្ឆេទនៃចំណូលនិងចំណាយថវិកានេះត្រូវបានកំណត់ជាគោលដោយគណនេយ្យករសាធារណៈ និងជាមូលដ្ឋានសម្រាប់ការរាយការណ៍អំពីការអនុវត្តចំណូលនិងចំណាយថវិកានៃឆ្នាំអនុវត្តថវិកា។

ក្នុងករណីដែលអាណាប័កមិនអាចប្រគល់ឯកសារគាំទ្រចំណូល និងមិនអាចបញ្ជាក់ទទួលស្គាល់ជាចំណូលថវិកាព្រមជាមួយនឹងអាណត្តិបើកប្រាក់សម្រាប់ទទួលស្គាល់ជាចំណាយថវិកា មុនថ្ងៃទី៣១ ខែមករា ឆ្នាំបន្ទាប់ (ក្រោយរយៈពេលបំពេញបន្ថែម) និងបើទោះបីជាសាច់ប្រាក់ចំណូលនិងព្រឹត្តិការណ៍ចំណូលបានកើតឡើងក្នុងឆ្នាំអនុវត្តថវិកាក៏ដោយក៏គណនេយ្យករសាធារណៈត្រូវកត់ត្រាទទួលស្គាល់ជាចំណូលនិងចំណាយថវិកាទាំងនោះនៅឆ្នាំបន្ទាប់ ដោយប្រើប្រាស់ចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការដ្ឋ នៅក្នុងគណនេយ្យថវិកា និងប្រព័ន្ធ FMIS ដោយកំណត់យកតាមថ្ងៃខែឆ្នាំនៃសលាកបត្របង្វែរចំណូលនិងអាណត្តិបើកប្រាក់ទូទាត់ប្រាក់រង្វាន់ គឺពុំអាស្រ័យទៅនឹងថ្ងៃខែឆ្នាំនៃរំហូរសាច់ប្រាក់ចូលឬចេញពិតប្រាកដនោះទេ។ ស្ថានភាពនេះនាំឱ្យគណនេយ្យករសាធារណៈកត់ត្រាចំណូលនិងចំណាយថវិកាលើប្រាក់រង្វាន់នៅឆ្នាំបន្ទាប់ និងត្រូវប្រើប្រាស់ឥណទានថវិកាឆ្នាំបន្ទាប់។ កាលបរិច្ឆេទនៃចំណូលនិងចំណាយថវិកានេះត្រូវបានកំណត់ជាគោលដោយគណនេយ្យករសាធារណៈ និងជាមូលដ្ឋានសម្រាប់ការរាយការណ៍អំពីការអនុវត្តចំណូលនិងចំណាយថវិកានៃឆ្នាំអនុវត្តថវិកា។

ការកត់ត្រាចំណូលថវិកានៅក្នុងគណនេយ្យថវិកា និងប្រព័ន្ធ FMIS ត្រូវផ្អែកលើសលាកបត្របង្វែរចំណូលអមដោយសក្ខីបត្រគាំទ្រ ដែលអាស្រ័យទៅតាមប្រភេទនៃចំណូលថវិកានីមួយៗ និងអាណត្តិបើកប្រាក់ទូទាត់ប្រាក់រង្វាន់អមដោយសក្ខីបត្រគាំទ្រ សម្រាប់មុខសញ្ញាចំណាយជាប្រាក់រង្វាន់ ដោយយកតាមថ្ងៃខែឆ្នាំកត់ត្រាដូចមានកំណត់ក្នុងវាក្យខណ្ឌខាងលើ។

ប្រតិបត្តិការចំណូលព្រម-ចំណាយព្រម(ករណីរង្វាន់)នេះ នឹងមានការកត់ត្រានិងរាយការណ៍ដូចគ្នា ទាំងនៅក្នុងទិដ្ឋភាពគណនេយ្យថវិកានិងក្នុងគណនេយ្យទូទៅ។

**បញ្ជាក់៖** អាណាប័កត្រូវទទួលខុសត្រូវក្នុងការរៀបចំឯកសារសម្រាប់កំណត់មុខសញ្ញាចំណូលថវិកានិងចំណាយថវិកាឱ្យបានទាន់ពេលនៃព្រឹត្តិការណ៍ចំណូលនិងចំណាយដែលបានកើតមានឡើងជាក់ស្តែង នៅក្នុងឆ្នាំអនុវត្តថវិកា។ ការណ៍នេះជានាបាននូវភាពត្រឹមត្រូវនិងពិតប្រាកដនៃព្រឹត្តិការណ៍ ព្រមទាំងអាចឆ្លុះបញ្ចាំងបានត្រឹមត្រូវនៅក្នុងការអនុវត្តថវិកា ដោយគោរពតាមគោលការណ៍ប្រចាំឆ្នាំនៃថវិកា។

ឧទាហរណ៍៖

ក្រសួងសាធារណការនិងដឹកជញ្ជូន បានទូទាត់ចំណាយប្រាក់រង្វាន់លើកទឹកចិត្តជូនមន្ត្រីពាក់ព័ន្ធនឹងការប្រមូលចំណូលពីការផ្តល់សេវាសាធារណៈនិងការផាកពិន័យ ប្រចាំខែធ្នូ ឆ្នាំ២០២២ ដោយបានប្រគល់ឯកសារ មកគណនេយ្យករសាធារណៈ ដែលរួមមានសលាកបត្របង្វែរចំណូលនិងអាណត្តិបើកប្រាក់ទូទាត់ប្រាក់រង្វាន់ អមដោយសក្ខីបត្រ នូវចំនួនទឹកប្រាក់ ១០០ លានរៀល នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៣ ដើម្បីធ្វើការទូទាត់សាច់ប្រាក់ចំណូលដែលបានប្រមូលនិងបានដកប្រាក់ចែកជាប្រាក់រង្វាន់ជូនទៅមន្ត្រីពាក់ព័ន្ធ នៅអំឡុងខែធ្នូ ឆ្នាំ២០២២។ តាមរយៈឧទាហរណ៍នេះគណនេយ្យករសាធារណៈត្រូវកត់ត្រាទទួលស្គាល់ជាចំណូលនិងចំណាយថវិកានោះ ទៅតាមប្រភេទនៃចំណូលថវិកានីមួយៗជាក់ស្តែង និងចំណាយថវិការង្វាន់ (លេខគណនី ៦៤០៣៣) ដោយត្រូវកត់ត្រានៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ទាំងនៅក្នុងគណនេយ្យថវិកានិងក្នុងគណនេយ្យទូទៅ ដោយសារតែឯកសារទូទាត់នេះមកដល់ក្នុងអំឡុងរយៈពេលបំពេញបន្ថែម។ ករណីដែលសលាកបត្របង្វែរចំណូលនិងអាណត្តិបើកប្រាក់ទូទាត់ប្រាក់រង្វាន់ អមដោយសក្ខីបត្រគាំទ្របានប្រគល់មកគណនេយ្យករសាធារណៈ ក្រោយរយៈពេលបំពេញបន្ថែម គណនេយ្យករសាធារណៈពុំអាចកត់ត្រាទទួលស្គាល់ចំណូលនិងចំណាយថវិកានេះនៅក្នុងឆ្នាំ២០២២បានទេ គឺត្រូវកត់ត្រាទទួលស្គាល់ជាចំណូលនិងចំណាយថវិកានៅឆ្នាំ២០២៣ ដោយប្រើប្រាស់ឥណទានថវិកាឆ្នាំ២០២៣ បើទោះបីជាសាច់ប្រាក់ចំណូលនិងព្រឹត្តិការណ៍ចំណូលបានកើតឡើងក្នុងឆ្នាំអនុវត្តថវិកាឆ្នាំ២០២២ក៏ដោយ។

**៤.១.២.៣ ចំណូលពីការកាត់ពន្ធលើអាណត្តិបើកប្រាក់**

មុខសញ្ញាចំណូលមួយចំនួនត្រូវបានជួយប្រមូលនិងកាត់ទុកដោយគណនេយ្យករសាធារណៈ លើចំណែកពន្ធដែលត្រូវបង់ដោយអ្នកជាប់ពន្ធ តាមរយៈអាណត្តិបើកប្រាក់ ដោយពុំមានការប្រមូលជាសាច់ប្រាក់ជាក់ស្តែងនោះទេ។ ក្នុងករណីនេះ ប្រតិបត្តិការចំណូលនេះត្រូវទទួលស្គាល់ជាចំណូលថវិកានៃឆ្នាំអនុវត្តថវិកា បើទោះបីជាពុំមានសាច់ប្រាក់ចូលពិតប្រាកដទៅគណនេយ្យករសាធារណៈក៏ដោយ ដោយសារតែប្រតិបត្តិការទាំងនេះមានលក្ខណៈ ដូចខាងក្រោម៖

- មានការអនុញ្ញាតដោយច្បាប់និងបទប្បញ្ញត្តិជាធរមាន ឱ្យគណនេយ្យករសាធារណៈអាចធ្វើប្រតិបត្តិការនេះបាន
- មុខសញ្ញាចំណូលថវិកាត្រូវបានកំណត់ច្បាស់លាស់ និងមានការបញ្ជាក់ទទួលស្គាល់ពីអាណាប័ក យ៉ាងយូរត្រឹមកាលបរិច្ឆេទបញ្ចប់រយៈពេលបំពេញបន្ថែម និង
- មានការត្រួតពិនិត្យផ្ទៀងផ្ទាត់ភាពត្រឹមត្រូវដោយគណនេយ្យករសាធារណៈ ស្របតាមខ្លឹមសារនៃមាត្រា២៧នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ។

គណនេយ្យករសាធារណៈត្រូវកត់ត្រាជាចំណូលថវិកា ក្នុងឆ្នាំអនុវត្តថវិកា នៅក្នុងគណនេយ្យថវិកា និងប្រព័ន្ធ FMIS ដោយផ្អែកលើសលាកបត្របង្វែរចំណូល អមដោយសក្ខីបត្រគាំទ្រ ដែលអាស្រ័យទៅតាមប្រភេទនៃចំណូលថវិកានីមួយៗ និងអាណត្តិបើកប្រាក់ អមដោយសក្ខីបត្រគាំទ្រ ដោយប្រើប្រាស់ចំណាត់ថ្នាក់សេដ្ឋកិច្ច (ផ្នែកមាតិកាចំណូលថវិកា) នៃមាតិកាថវិការដ្ឋ ដោយកំណត់យកតាមថ្ងៃខែឆ្នាំនៃសលាកបត្របង្វែរចំណូល (ឬ កំណត់យកថ្ងៃទី៣១ ខែធ្នូ ឆ្នាំអនុវត្តថវិកា ករណីគណនេយ្យករសាធារណៈបានទទួលសលាកបត្របង្វែរចំណូល នៅក្នុងអំឡុងរយៈពេលបំពេញបន្ថែម) កាលបរិច្ឆេទនៃចំណូលថវិកានេះត្រូវបានកំណត់ជាគោលដោយគណនេយ្យករសាធារណៈ និងជាមូលដ្ឋានសម្រាប់ការរាយការណ៍អំពីការអនុវត្តចំណូលថវិកានៃឆ្នាំអនុវត្តថវិកា។

ប្រតិបត្តិការប្រភេទនេះនឹងនាំឱ្យមានការកត់ត្រាចំណូលថវិកា និងរបាយការណ៍ដូចគ្នា ទាំងនៅក្នុងគណនេយ្យថវិកានិងគណនេយ្យទូទៅ។

ឧទាហរណ៍៖

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបោះផ្សាយអាណត្តិបើកប្រាក់ទូទាត់ប្រាក់បៀវត្ស ប្រចាំខែកញ្ញា ឆ្នាំ២០២៣ ជូនមន្ត្រីរាជការនិងមន្ត្រីជាប់កិច្ចសន្យា នូវចំនួនទឹកប្រាក់ ១០០ លានរៀល ដែលក្នុងនោះមានប្រាក់ពន្ធលើប្រាក់បៀវត្សចំនួន ៥ លានរៀល រួចបញ្ជូនមកគណនេយ្យករសាធារណៈ ដើម្បីធ្វើការបើកផ្តល់ជូនមន្ត្រីរាជការនិងមន្ត្រីជាប់កិច្ចសន្យា។

ដោយទទួលបានការអនុញ្ញាតក្នុងការកាត់ទុកប្រាក់ពន្ធលើប្រាក់បៀវត្ស គណនេយ្យកររតនាគារកាត់ប្រាក់ពន្ធលើប្រាក់បៀវត្សចំនួន ៥ លានរៀល និងបង្វែរចូលជាចំណូលថវិកាពីការបង់ពន្ធលើប្រាក់បៀវត្ស ក្រោយពីទទួលសលាកបត្របង្វែរចំណូលរបស់អគ្គនាយកដ្ឋានពន្ធដារក្នុងខែតុលា ដោយត្រូវកត់ត្រាតាមថ្ងៃខែឆ្នាំនៃសលាកបត្របង្វែរចំណូល។

### ៤.១.២.៤ ចំណូលឧបត្ថម្ភធនពីរដ្ឋបាលសាធារណៈ ឬប្រភពផ្សេងៗទៀត

ប្រតិបត្តិការទទួលចំណូលឧបត្ថម្ភធនពីរដ្ឋបាលសាធារណៈ ឬពីប្រភពផ្សេងទៀត ដូចជាពីមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានកត់ត្រានិងទទួលស្គាល់ជាចំណូលថវិកាពីឧបត្ថម្ភធន នៅក្នុងឆ្នាំអនុវត្តថវិកា នៅក្នុងគណនេយ្យថវិកា។ ការឧបត្ថម្ភធននេះត្រូវបានចាត់ទុកជាសាច់ប្រាក់ប្រហាក់ប្រហែលរបស់រដ្ឋបាលសាធារណៈបានទទួល ដែលស្ថិតនៅក្នុងគណនីប្រាក់បញ្ញើរបស់រដ្ឋបាលសាធារណៈទាំងនោះ និងអាចប្រើប្រាស់បានសម្រាប់ធានាដល់ការចំណាយថវិកា។ ក្នុងន័យនេះ ប្រតិបត្តិការទទួលឧបត្ថម្ភធនពីរដ្ឋបាលសាធារណៈ ឬប្រភពផ្សេងទៀត ត្រូវចាត់ទុកជាចំណូលថវិកាក្នុងករណី៖

- មានការបោះផ្សាយអាណត្តិបើកប្រាក់ឧបត្ថម្ភធនទៅរដ្ឋបាលទទួលនៅក្នុងឆ្នាំអនុវត្តថវិកា (ឬយ៉ាងយូរត្រឹមដំណាច់រយៈពេលបំពេញបន្ថែម) ដោយអាណាប័កជាអ្នកផ្តល់ឧបត្ថម្ភធន ឬ ប្រកាសបន្ថែមឥណទានថវិកាឱ្យរដ្ឋបាលទទួល
- មានការត្រួតពិនិត្យផ្ទៀងផ្ទាត់ភាពត្រឹមត្រូវលើចំណាយឧបត្ថម្ភធនដោយគណនេយ្យករសាធារណៈ ឬ គោលការណ៍សម្រេចឱ្យប្រើប្រាស់ប្រភពផ្សេងទៀតសម្រាប់ផ្តល់ឧបត្ថម្ភធនទៅរដ្ឋបាលទទួល ស្របតាមខ្លឹមសារនៃមាត្រា២៧ និងមាត្រា២៨នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ និង
- មានការបញ្ជាក់ទទួលស្គាល់ពីគណនេយ្យករសាធារណៈ អំពីការទទួលឧបត្ថម្ភធនចូលគណនីប្រាក់បញ្ញើរបស់រដ្ឋបាលទទួលឧបត្ថម្ភធន។

គណនេយ្យករសាធារណៈត្រូវកត់ត្រាទទួលស្គាល់ចំណូលថវិកានេះទៅតាមប្រភេទនៃចំណូលថវិកានីមួយៗ ដោយផ្អែកលើចំណាត់ថ្នាក់សេដ្ឋកិច្ច (ផ្នែកមាតិកាចំណូលថវិកា) នៃមាតិកាថវិការដ្ឋ នៅក្នុងគណនេយ្យថវិកា និងប្រព័ន្ធ FMIS ដោយកំណត់យកតាមថ្ងៃខែឆ្នាំនៃការទទួលស្គាល់របស់គណនេយ្យករសាធារណៈលើទឹកប្រាក់ដែលបានបញ្ចូលក្នុងគណនីប្រាក់បញ្ញើរបស់រដ្ឋបាលសាធារណៈ។ កាលបរិច្ឆេទនៃចំណូលថវិកានេះត្រូវបានកំណត់ជាគោលដោយគណនេយ្យករសាធារណៈ និងជាមូលដ្ឋានសម្រាប់ការរាយការណ៍អំពីការអនុវត្តចំណូលនិងចំណាយថវិកានៃឆ្នាំអនុវត្តថវិកា។ ទន្ទឹមនេះ ប្រតិបត្តិការខាងលើនេះពុំតម្រូវឱ្យរដ្ឋបាលសាធារណៈដែលទទួលឧបត្ថម្ភធនរៀបចំជាសលាកបត្របង្វែរចំណូលសម្រាប់ការទទួលស្គាល់ជាចំណូលថវិកាទេ។ គណនេយ្យករសាធារណៈទទួលបន្ទុកអង្គភាពសាធារណៈដែលទទួលឧបត្ថម្ភធន ត្រូវផ្អែកលើសក្ខីបត្ររបស់គណនេយ្យកររតនាគារ (លិខិតជូនដំណឹងឥណទាន អមដោយសក្ខីបត្រគាំទ្រ) ដើម្បីកត់ត្រាទទួលស្គាល់ជាចំណូលថវិកាតែម្តង។ ដោយឡែក ចំពោះគណនេយ្យករសាធារណៈដែលទទួលបន្ទុកកត់ត្រាប្រតិបត្តិការចំណាយឧបត្ថម្ភធនទៅរដ្ឋបាលសាធារណៈ នឹងមានកំណត់ក្នុងចំណុចទី៤.២.២.៧ នៃផ្នែកកិច្ចប្រតិបត្តិការចំណាយថវិកា ខាងក្រោម។

ប្រតិបត្តិការចំណូលឧបត្ថម្ភធននេះនឹងនាំឱ្យមានការកត់ត្រាចំណូលថវិកា និងការរាយការណ៍ចំណូលដូចគ្នាទាំងនៅក្នុងគណនេយ្យថវិកានិងក្នុងគណនេយ្យទូទៅ។

**<u>បញ្ជាក់</u>៖** ប្រតិបត្តិការខាងលើនេះត្រូវអនុវត្តនៅក្នុងឆ្នាំថវិកានីមួយៗ ដោយមានការអនុញ្ញាតជារយៈពេលបំពេញបន្ថែម យ៉ាងយូរត្រឹមកាលបរិច្ឆេទបញ្ចប់រយៈពេលបំពេញបន្ថែម។ ក្នុងករណីដែលប្រតិបត្តិការខាងលើនេះត្រូវអនុវត្តក្នុងរយៈពេលបំពេញបន្ថែម ការកត់ត្រាទទួលស្គាល់ជាចំណូលថវិកាត្រូវកំណត់យកថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំអនុវត្តថវិកា។

ឧទាហរណ៍៖

នៅថ្ងៃទី៥ ខែមករា ឆ្នាំ២០២៣ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានបោះផ្សាយអាណត្តិបើកប្រាក់ឧបត្ថម្ភធនជូនរដ្ឋបាលខេត្តកណ្ដាល សម្រាប់ធានាដល់ការចំណាយប្រចាំត្រីមាសទី១ ឆ្នាំ២០២៣ នូវចំនួនទឹកប្រាក់ ១ប៊ី លានរៀល។ គណនេយ្យកររតនាគារកណ្ដាលនឹងផ្ទេរថវិកាឧបត្ថម្ភធននេះទៅរដ្ឋបាលខេត្តកណ្ដាល ដើម្បីឱ្យគណនេយ្យកររតនាគារខេត្តកណ្ដាលកត់ត្រាទទួលថវិកាឧបត្ថម្ភធន ដោយបញ្ចូលថវិកានេះចូលទៅក្នុងគណនីប្រាក់បញ្ញើរបស់រដ្ឋបាលខេត្តកណ្ដាល។ ទន្ទឹមនេះ គណនេយ្យកររតនាគារទទួលបន្ទុករដ្ឋបាលខេត្តកណ្ដាលត្រូវកត់ត្រាទទួលស្គាល់ជាចំណូលថវិកាបានពីឧបត្ថម្ភធនរបស់រដ្ឋ នៅក្នុងគណនេយ្យថវិកា ដោយកំណត់យកតាមថ្ងៃខែឆ្នាំដែលគណនេយ្យកររតនាគារកណ្ដាលបានបញ្ចូលទឹកប្រាក់ឧបត្ថម្ភធនទៅក្នុងគណនីប្រាក់បញ្ញើរបស់ខេត្តកណ្ដាល។

**៤.១.២.៥ ចំណូលពីដៃគូអភិវឌ្ឍន៍ ឬ ពីសប្បុរសជន**

ប្រតិបត្តិការចំណូលពីដៃគូអភិវឌ្ឍន៍ ឬ ពីសប្បុរសជន ត្រូវបានកត់ត្រានិងទទួលស្គាល់ជាចំណូលថវិកា នៅក្នុងឆ្នាំអនុវត្តថវិកានៅក្នុងគណនេយ្យថវិកា ក្នុងករណីដែលប្រតិបត្តិការទាំងនោះបំពេញតាមលក្ខខណ្ឌ ដូចខាងក្រោម៖

- មានលំហូរសាច់ប្រាក់ចូលពិតប្រាកដទៅក្នុងគណនីធនាគាររបស់គណនេយ្យករសាធារណៈនៅក្នុងឆ្នាំអនុវត្តថវិកា
- ព្រឹត្តិការណ៍ចំណូលពិតជាបានកើតឡើងនៅក្នុងឆ្នាំកំពុងអនុវត្តថវិកា
- មានការបញ្ជាក់ទទួលស្គាល់ពីអាណាប័កអំពីមុខសញ្ញាចំណូលថវិកា ដោយផ្អែកលើកិច្ចសន្យាឬកិច្ចព្រមព្រៀង និង
- មានការត្រួតពិនិត្យផ្ទៀងផ្ទាត់ភាពត្រឹមត្រូវដោយគណនេយ្យករសាធារណៈ ស្របតាមខ្លឹមសារនៃមាត្រា២៧នៃអនុក្រឹត្យស្ដីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ។

ផ្អែកលើឯកសារគាំទ្រចំណូលថវិកាពីដៃគូអភិវឌ្ឍន៍ ឬ ពីសប្បុរសជនដែលត្រូវប្រគល់ឱ្យយ៉ាងយូរបំផុតត្រឹមកាលបរិច្ឆេទបញ្ចប់រយៈពេលបំពេញបន្ថែម គណនេយ្យករសាធារណៈត្រូវកត់ត្រាទទួលស្គាល់ចំណូលថវិកានេះទៅតាមប្រភេទនៃចំណូលថវិកានីមួយៗ ដោយផ្អែកលើចំណាត់ថ្នាក់សេដ្ឋកិច្ច (ផ្នែកមាតិកាចំណូលថវិកា) នៃមាតិកាថវិការដ្ឋនៅក្នុងគណនេយ្យថវិកា និងប្រព័ន្ធ FMIS ដោយកំណត់យកតាមថ្ងៃខែឆ្នាំនៃសលាកបត្របង្វែរចំណូល (ករណីមុនរយៈពេលបន្ថែម) ឬ កំណត់យកថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំអនុវត្តថវិកា (ករណីអំឡុងរយៈពេលបំពេញបន្ថែម) គឺពុំអាស្រ័យនឹងលំហូរសាច់ប្រាក់ចូលពិតប្រាកដទៅក្នុងគណនីធនាគាររបស់គណនេយ្យករសាធារណៈទេ។ កាលបរិច្ឆេទនៃចំណូលថវិកានេះត្រូវបានកំណត់ជាគោលដោយគណនេយ្យករសាធារណៈ និងជាមូលដ្ឋានសម្រាប់ការរាយការណ៍អំពីការអនុវត្តចំណូលថវិកាពីដៃគូអភិវឌ្ឍន៍ ឬ ពីសប្បុរសជន នៅក្នុងឆ្នាំអនុវត្តថវិកា។

ក្នុងករណីដែលឯកសារគាំទ្រចំណូលថវិកាពីដៃគូអភិវឌ្ឍន៍ ឬ ពីសប្បុរសជន ត្រូវបានប្រគល់ជូនគណនេយ្យករសាធារណៈ ក្រោយថ្ងៃទី៣១ ខែមករា នៃឆ្នាំបន្ទាប់ (ក្រោយរយៈពេលបំពេញបន្ថែម) គណនេយ្យករសាធារណៈត្រូវកត់ត្រាទទួលស្គាល់ចំណូលថវិកានេះនៅឆ្នាំបន្ទាប់ ដោយកំណត់យកតាមថ្ងៃខែឆ្នាំនៃសលាកបត្របង្វែរចំណូល។

ក្នុងករណីដែលដៃគូអភិវឌ្ឍន៍ ឬ ពីសប្បុរសជន ផ្តល់ជំនួយក្រោមរូបភាពជាទ្រព្យសម្ភារៈ ឬជំនួយបច្ចេកទេសនានា ចំណូលប្រភេទនេះពុំមានការកត់ត្រាទទួលស្គាល់ជាចំណូលថវិកានៅក្នុងគណនេយ្យថវិកាទេ ដោយសារតែពុំមានលំហូរសាច់ប្រាក់ចូលជាក់ស្តែង ប៉ុន្តែករណីនេះ គណនេយ្យសាធារណៈត្រូវធ្វើការកត់ត្រាប្រតិបត្តិការនេះនៅក្នុងគណនេយ្យទូទៅ (មូលដ្ឋានបង្គរ) ដោយទទួលស្គាល់ជាចំណូល ផ្អែកតាមស្មារតីនៃប្រកាសលេខ ៣៥៤ សហវ.ប្រក. ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២២ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីកិច្ចបញ្ជិកាគណនេយ្យនៃទ្រព្យសកម្មរយៈពេលវែង និងស្តង់ដាគណនេយ្យសាធារណៈជាតិនិងអន្តរជាតិ ដើម្បីធានាបាននូវការប្រមូលផ្តុំនៃកិច្ចប្រតិបត្តិការហិរញ្ញវត្ថុនិងគណនេយ្យរបស់រដ្ឋ។

ការកត់ត្រាចំណូលថវិកាពីដៃគូអភិវឌ្ឍន៍ ឬ ពីសប្បុរសជននៅក្នុងគណនេយ្យថវិកា និងប្រព័ន្ធ FMIS ត្រូវផ្អែកលើសលាកបត្របង្វែរចំណូល អមដោយសក្ខីបត្រគាំទ្រ ដែលអាស្រ័យទៅតាមប្រភេទនៃចំណូលថវិកានីមួយៗ ដោយយកតាមថ្ងៃខែឆ្នាំកត់ត្រាដូចមានកំណត់ក្នុងវាក្យខណ្ឌខាងលើ។

**បញ្ជាក់៖** អាណាប័កត្រូវខិតខំរៀបចំសលាកបត្របង្វែរចំណូល អមដោយសក្ខីបត្រគាំទ្រ សម្រាប់កំណត់មុខសញ្ញាចំណូលថវិកាឱ្យបានទាន់ពេលនៃព្រឹត្តិការណ៍ចំណូលបានកើតមានឡើង ដើម្បីធានាបាននូវភាពត្រឹមត្រូវនិងពិតប្រាកដនៃព្រឹត្តិការណ៍ ព្រមទាំងអាចឆ្លុះបញ្ចាំងបានត្រឹមត្រូវនៃការអនុវត្តថវិកា ដោយគោរពតាមគោលការណ៍ប្រចាំឆ្នាំនៃថវិកា។

ឧទាហរណ៍៖

រាជរដ្ឋាភិបាលជប៉ុន តាមរយៈទីភ្នាក់ងារសហប្រតិបត្តិការជប៉ុន បានចុះកិច្ចព្រមព្រៀងផ្តល់ជំនួយឥតសំណងដល់រាជរដ្ឋាភិបាលកម្ពុជាតាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជួយលើគម្រោងស្តារឡើងវិញនូវប្រឡាយទឹក ប្រវែង ១០គីឡូម៉ែត្រ សម្រាប់ប្រព័ន្ធស្រោចស្រពរបស់ប្រជាពលរដ្ឋ ក្នុងឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ដោយផ្តល់ថវិកាទៅក្រសួងសាធារណការនិងដឹកជញ្ជូនជាអ្នកអនុវត្តគម្រោងនេះ។ ទីភ្នាក់ងារសហប្រតិបត្តិការជប៉ុន បានទម្លាក់ថវិកាចំនួន ៥០០,០០០ ដុល្លារអាម៉េរិក នៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ចូលគណនីទោលរតនាគារ ដើម្បីឱ្យអគ្គនាយកដ្ឋានរតនាគារជាតិបើកផ្តល់ប្រាក់បន្តទៅអ្នកអនុវត្តគម្រោង (ក្រសួងសាធារណការនិងដឹកជញ្ជូន)។ អគ្គនាយកដ្ឋានរតនាគារជាតិបានជូនដំណឹងទៅអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុលនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អំពីថវិកាជំនួយឥតសំណងរបស់រាជរដ្ឋាភិបាលជប៉ុន។ អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុលបានរៀបចំសលាកបត្របង្វែរចំណូល (ជំនួយឥតសំណង) នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២៣ ចំពោះទឹកប្រាក់ខាងលើ។

ក្នុងករណីនេះ ក្រោយពីបានពិនិត្យលើភាពត្រឹមត្រូវលើសលាកបត្របង្វែរចំណូល គណនេយ្យកររតនាគារកណ្តាលត្រូវកត់ត្រាទទួលស្គាល់ជាចំណូលថវិកា នៅក្នុងគណនេយ្យថវិកា អនុគណនីលេខ៧៥១៤១ នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៣ នូវទឹកប្រាក់ចំនួន ៥០០,០០០ ដុល្លារអាម៉េរិក ដោយគិតតាមអត្រាប្តូរប្រាក់នៃថ្ងៃខែឆ្នាំដែលបានកត់ត្រាទឹកប្រាក់ចូល។ ប្រតិបត្តិការទទួលស្គាល់ចំណូលថវិកានេះ ពុំអាស្រ័យទៅនឹងថ្ងៃខែឆ្នាំនៃវិហរសាច់ប្រាក់ដែលទីភ្នាក់ងារសហប្រតិបត្តិការជប៉ុនបានបង់ប្រាក់ចូលក្នុងគណនីធនាគាររបស់គណនេយ្យករសាធារណៈទេ។

### ៤.១.២.៦ ការបង់ភាគលាភ ឬ អតិរេកចូលថវិការដ្ឋ

ការបង់ភាគលាភពីសហគ្រាសសាធារណៈ ឬ ធនាគារជាតិនៃកម្ពុជា ឬ អតិរេកពីរដ្ឋបាលសាធារណៈ (ដូចជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ឬ រដ្ឋបាលថ្នាក់ក្រោមជាតិ ជាដើម) ចូលថវិការដ្ឋ ត្រូវបានកត់ត្រានិងទទួលស្គាល់ជាចំណូលថវិកានៃឆ្នាំអនុវត្តថវិកានៅក្នុងគណនេយ្យថវិកា ដោយសារតែប្រតិបត្តិការនោះបំពេញតាមលក្ខខណ្ឌ ដូចខាងក្រោម៖

- មានវិហរសាច់ប្រាក់ចូលពិតប្រាកដទៅក្នុងគណនីធនាគារឬបេឡារបស់គណនេយ្យករសាធារណៈ នៅក្នុងឆ្នាំអនុវត្តថវិកា ឬមានការដកប្រាក់ចេញពីគណនីប្រាក់បញ្ញើរបស់សហគ្រាសសាធារណៈ ឬ រដ្ឋបាលសាធារណៈ សម្រាប់ការបង់ភាគលាភ ឬ អតិរេកទាំងនេះចូលថវិការដ្ឋ
- ព្រឹត្តិការណ៍បង់ចំណូលពិតជាកើតមានឡើង
- មានការបញ្ជាក់ពីសហគ្រាសសាធារណៈ ឬ ធនាគារជាតិនៃកម្ពុជា ឬ រដ្ឋបាលសាធារណៈ អំពីមុខសញ្ញាចំណូលថវិកា មិនឱ្យហួសពីរយៈពេលបំពេញបន្ថែម និង
- មានការត្រួតពិនិត្យផ្ទៀងផ្ទាត់ភាពត្រឹមត្រូវដោយគណនេយ្យករសាធារណៈ ស្របតាមខ្លឹមសារនៃមាត្រា២៧នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ។

ផ្អែកលើឯកសារគាំទ្រប្រតិបត្តិការបង់ភាគលាភ ឬ អតិរេកចូលថវិការដ្ឋ ដែលត្រូវប្រគល់ឱ្យយ៉ាងយូរបំផុតត្រឹមដំណាច់កាលបរិច្ឆេទបញ្ចប់រយៈពេលបំពេញបន្ថែម គណនេយ្យករសាធារណៈត្រូវកត់ត្រាទទួលស្គាល់ជាចំណូលថវិកាពីការបង់ភាគលាភឬអតិរេកចូលថវិការដ្ឋ ដោយប្រើប្រាស់ចំណាត់ថ្នាក់សេដ្ឋកិច្ច (ផ្នែកមាតិកាចំណូលថវិកា) នៃមាតិកាថវិការដ្ឋ នៅក្នុងគណនេយ្យថវិកា និងប្រព័ន្ធ FMIS ដោយកំណត់យកតាមថ្ងៃខែឆ្នាំនៃសលាកបត្របង្វែរចំណូលពីការបង់ភាគលាភ ឬ អតិរេក (ឬ កំណត់យកថ្ងៃទី៣១ ខែធ្នូ ឆ្នាំអនុវត្តថវិកា ករណីគណនេយ្យករសាធារណៈបាន

ទទួលសលាកបត្របង្វែរចំណូល នៅក្នុងអំឡុងរយៈពេលបំពេញបន្ថែម) គឺពុំអាស្រ័យទៅនឹងរំហូរសាច់ប្រាក់ចូលពិតប្រាកដ ឬ ថ្ងៃខែឆ្នាំនៃការដកប្រាក់ពីគណនីប្រាក់បញ្ញើរបស់សហគ្រាសសាធារណៈឬរដ្ឋបាលសាធារណៈបង់ចូលថវិការដ្ឋនោះទេ។ កាលបរិច្ឆេទនៃចំណូលថវិកានេះត្រូវបានកំណត់ជាគោលដោយគណនេយ្យករសាធារណៈ និងជាមូលដ្ឋានសម្រាប់ការរាយការណ៍អំពីការអនុវត្តចំណូលថវិកាពីការបង់ភាគលាភរបស់សហគ្រាសសាធារណៈឬធនាគារជាតិនៃកម្ពុជា ឬការបង់អតិរេករបស់រដ្ឋបាលសាធារណៈ ចូលថវិការដ្ឋ នៅក្នុងឆ្នាំអនុវត្តថវិកា។ ករណីនេះ ប្រតិបត្តិការចំណូលថវិកាពីការបង់ភាគលាភរបស់សហគ្រាសសាធារណៈឬធនាគារជាតិនៃកម្ពុជា ឬ បង់អតិរេករបស់រដ្ឋបាលសាធារណៈ នឹងនាំឱ្យមានការកត់ត្រានិងធ្វើរបាយការណ៍ដូចគ្នា នៅក្នុងគណនេយ្យថវិកានិងគណនេយ្យទូទៅ។

ក្នុងករណីដែលអាណាប័កពុំអាចរៀបចំឯកសារទទួលស្គាល់ចំណូលថវិកានេះបានទាន់ពេល (គឺរៀបចំក្រោយរយៈពេលបំពេញបន្ថែម) ចំណូលថវិកាពីការបង់ភាគលាភរបស់សហគ្រាសសាធារណៈឬធនាគារជាតិនៃកម្ពុជា ឬពីការបង់អតិរេករបស់រដ្ឋបាលសាធារណៈផ្សេងទៀត នឹងត្រូវបានទទួលស្គាល់ជាចំណូលថវិកានៅឆ្នាំបន្ទាប់ ដោយកំណត់យកតាមថ្ងៃខែឆ្នាំនៃសលាកបត្របង្វែរចំណូល នៅក្នុងគណនេយ្យថវិកា និងប្រព័ន្ធ FMIS។

<u>**បញ្ជាក់៖**</u> សហគ្រាសសាធារណៈ ធនាគារជាតិនៃកម្ពុជា និងរដ្ឋបាលសាធារណៈដែលមានការពាក់ព័ន្ធនឹងការបង់ភាគលាភ ឬ អតិរេកជាចំណូលថវិការដ្ឋ ត្រូវទទួលខុសត្រូវក្នុងការរៀបចំសលាកបត្របង្វែរចំណូលអមដោយសក្ខីបត្រគាំទ្រឱ្យបានទាន់ពេលនៃព្រឹត្តិការណ៍ចំណូលដែលបានកើតមានឡើង ដើម្បីធានាបាននូវភាពត្រឹមត្រូវនិងពិតប្រាកដនៃព្រឹត្តិការណ៍ ព្រមទាំងអាចឆ្លុះបញ្ចាំងបានត្រឹមត្រូវនៃការអនុវត្តថវិកា ដោយគោរពតាមគោលការណ៍ប្រចាំឆ្នាំនៃថវិកា។

<u>ឧទាហរណ៍៖</u>

<u>ករណីបង់ភាគលាភ៖</u>

ថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៣ ធនាគារជាតិនៃកម្ពុជាបានបង់ភាគលាភ ប្រចាំឆ្នាំ២០២២ ជូនរាជរដ្ឋាភិបាលកម្ពុជានូវចំនួនទឹកប្រាក់ ២០ប៊ី លានរៀល ចូលក្នុងគណនីទោលរតនាគារ។ ក្រោយពេលទទួលបានសលាកបត្របង្វែរចំណូលពីធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០២៣ គណនេយ្យករសាធារណៈពិនិត្យលើភាពត្រឹមត្រូវនៃព័ត៌មានដែលបានបំពេញលើសលាកបត្របង្វែរចំណូល និងឯកសារគាំទ្រ និងកត់ត្រាជាចំណូលថវិកាពីការបង់ភាគលាភអនុគណនីលេខ៧២០១២ នៅក្នុងគណនេយ្យថវិកា ក្នុងឆ្នាំ២០២៣។

<u>ករណីបង់អតិរេក៖</u>

មន្ទីរពេទ្យព្រះអង្គឌួង បានជូនដំណឹងពីអតិរេកសល់ដែលអាចបង់ចូលថវិការដ្ឋវិញ សម្រាប់ឆ្នាំ២០២៣ នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០២៣ និងបានប្រគល់ឯកសារគាំទ្រនៃប្រតិបត្តិការបង់អតិរេកចូលថវិការដ្ឋនិងបានបង់ចូលថវិការដ្ឋ ដោយរួមមានប័ណ្ណស្នើសុំបង្វែរប្រាក់ពីគណនីប្រាក់បញ្ញើរបស់មន្ទីរពេទ្យព្រះអង្គឌួងនៅរតនាគារ និងសលាកបត្របង្វែរចំណូល ចូលថវិការដ្ឋ នូវទឹកប្រាក់ចំនួន ៥០ លានរៀល នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៤។ ក្រោយពីបានពិនិត្យត្រឹមត្រូវលើឯកសារដែលបានប្រគល់ឱ្យ គណនេយ្យកររតនាគារកណ្តាលបានដកប្រាក់បញ្ញើរបស់មន្ទីរពេទ្យព្រះអង្គឌួងនៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៤ ដោយត្រូវបង្វែរជាចំណូលថវិការដ្ឋ (របស់ក្រសួងសុខាភិបាល)។ ក្នុងករណីនេះគណនេយ្យកររតនាគារកណ្តាលត្រូវកត់ត្រាទទួលស្គាល់ជាចំណូលថវិកាពីការបង់អតិរេករបស់មន្ទីរពេទ្យព្រះអង្គឌួងអនុគណនីលេខ៧៧០១៤ ចំនួនទឹកប្រាក់ ៥០ លានរៀល នៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៤ នៅក្នុងគណនេយ្យថវិកា។

#### ៤.១.២.៧ ការបង្វែរប្រាក់ពីគណនីប្រាក់បញ្ញើ បង់ចូលជាចំណូលថវិកា

អង្គភាពសាធារណៈនិងឯកជនមួយចំនួន បានបើកគណនីប្រាក់បញ្ញើនៅរតនាគារជាតិ សម្រាប់ធ្វើប្រតិបត្តិការចំណូលនិងចំណាយ ព្រមទាំងអាចមានតម្រូវការក្នុងការស្នើសុំបង្វែរប្រាក់សម្រាប់ការបង់ពន្ធ ឬ ទូទាត់ចំណាយផ្សេងៗ។ ក្នុងករណីដែលអង្គភាពទាំងនោះបង្វែរប្រាក់ពីគណនីប្រាក់បញ្ញើសម្រាប់ការបង់ពន្ធ នោះទឹកប្រាក់បង្វែរពីគណនីប្រាក់បញ្ញើនឹងត្រូវកត់ត្រាទទួលស្គាល់ជាចំណូលថវិកាផងដែរ ដោយសារតែ៖

- មានរំហូរសាច់ប្រាក់ចេញពិតប្រាកដ ក្រោមរូបភាពជាការដកប្រាក់ពីគណនីប្រាក់បញ្ញើ សម្រាប់បង់ចូលថវិកា (បង់ចំណូលពន្ធ) នៅក្នុងឆ្នាំអនុវត្តថវិកា
- ព្រឹត្តិការណ៍ចំណូលពិតជាកើតមានឡើង នៅក្នុងឆ្នាំកំពុងអនុវត្តថវិកា
- មានការបញ្ជាក់ពីទទួលស្គាល់ពីអាណាប័ក អំពីមុខសញ្ញាចំណូលថវិកា និង
- មានការត្រួតពិនិត្យផ្ទៀងផ្ទាត់ភាពត្រឹមត្រូវដោយគណនេយ្យករសាធារណៈ ស្របតាមខ្លឹមសារនៃមាត្រា២៧នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ។

ផ្អែកលើឯកសារគាំទ្រនៃប្រតិបត្តិការបង់ពន្ធដោយដកពីគណនីប្រាក់បញ្ញើ ដែលត្រូវប្រគល់ឱ្យយ៉ាងយូរបំផុតត្រឹមកាលបរិច្ឆេទបញ្ចប់រយៈពេលបំពេញបន្ថែម គណនេយ្យករសាធារណៈត្រូវកត់ត្រាទទួលស្គាល់ជាចំណូលថវិកាពីការបង់ពន្ធរបស់អង្គភាពសាធារណៈឬឯកជន ដោយប្រើប្រាស់ចំណាត់ថ្នាក់សេដ្ឋកិច្ច (ផ្នែកមាតិកាចំណូលថវិកា) នៃមាតិកាថវិការដ្ឋ នៅក្នុងគណនេយ្យថវិកា និងប្រព័ន្ធ FMIS ដោយកំណត់យកតាមថ្ងៃខែឆ្នាំនៃសលាកបត្របង្វែរចំណូល (ឬ កំណត់យកថ្ងៃទី៣១ ខែធ្នូ ឆ្នាំអនុវត្តថវិកា ករណីគណនេយ្យករសាធារណៈបានទទួលសលាកបត្របង្វែរចំណូលនៅក្នុងអំឡុងរយៈពេលបំពេញបន្ថែម) គឺពុំអាស្រ័យទៅនឹងថ្ងៃខែឆ្នាំនៃរំហូរសាច់ប្រាក់ចេញពីគណនីប្រាក់បញ្ញើនោះទេ។ កាលបរិច្ឆេទនៃចំណូលថវិកានេះត្រូវបានកំណត់ជាគោលដោយគណនេយ្យករសាធារណៈ និងជាមូលដ្ឋានសម្រាប់ការរាយការណ៍អំពីការអនុវត្តចំណូលថវិកា នៅក្នុងឆ្នាំអនុវត្តថវិកា។ ក្នុងករណីនេះ ប្រតិបត្តិការចំណូលថវិកាពីការបង់ពន្ធដោយដកប្រាក់ពីគណនីប្រាក់បញ្ញើ នឹងនាំឱ្យមានការកត់ត្រានិងរាយការណ៍ដូចគ្នា ទាំងនៅក្នុងគណនេយ្យថវិកានិងគណនេយ្យទូទៅ។

ក្នុងករណីដែលអាណាប័កពុំអាចរៀបចំឯកសារទទួលស្គាល់ចំណូលថវិកានេះបានទាន់ពេល (គឺរៀបចំក្រោយរយៈពេលបំពេញបន្ថែម) ចំណូលថវិកាពីការបង់ពន្ធដោយដកប្រាក់ពីគណនីប្រាក់បញ្ញើរបស់អង្គភាពសាធារណៈឬឯកជន នឹងត្រូវបានទទួលស្គាល់ជាចំណូលថវិកានៅឆ្នាំបន្ទាប់ ដោយកំណត់យកតាមថ្ងៃខែឆ្នាំនៃសលាកបត្របង្វែរចំណូលនៅក្នុងគណនេយ្យថវិកា និងប្រព័ន្ធ FMIS។

**<u>បញ្ជាក់</u>៖** អាណាប័កត្រូវទទួលខុសត្រូវក្នុងការរៀបចំសលាកបត្របង្វែរចំណូល អមដោយឯកសារគាំទ្រសម្រាប់កំណត់មុខសញ្ញាចំណូលថវិកាពីការបង់ពន្ធរបស់អង្គភាពសាធារណៈឬឯកជន ឱ្យបានទាន់ពេលនៃព្រឹត្តិការណ៍ចំណូលដែលបានកើតមានឡើង ដើម្បីធានាបាននូវភាពត្រឹមត្រូវនិងពិតប្រាកដនៃព្រឹត្តិការណ៍ ព្រមទាំងអាចឆ្លុះបញ្ចាំងបានត្រឹមត្រូវនៃការអនុវត្តថវិកា ដោយគោរពតាមគោលការណ៍ប្រចាំឆ្នាំនៃថវិកា។

<u>ឧទាហរណ៍</u>

ក្រុមហ៊ុនតេលា មានគណនីប្រាក់បញ្ញើនៅរតនាគារជាតិ ទុកទទួលប្រាក់ទូទាត់លើថ្លៃប្រេងឥន្ធនៈដែលបានទិញនិងប្រើប្រាស់ដោយក្រសួង ស្ថាប័ន។ ក្រោយពីប្រកបអាជីវកម្មក្នុងឆ្នាំ២០២៣ ក្រុមហ៊ុនតេលាមានសមតុល្យក្នុងគណនីប្រាក់បញ្ញើចំនួន ៥ប៊ី លានរៀល និងក្រោយពីការបិទបញ្ជីគណនេយ្យចប់សព្វគ្រប់ក្នុងឆ្នាំ២០២៣ ក្រុមហ៊ុនតេលាត្រូវធ្វើការបង់ពន្ធលើប្រាក់ចំណេញ ប្រចាំឆ្នាំ២០២៣ ជូនអគ្គនាយកដ្ឋានពន្ធដារ ចំនួន ៥០០ លានរៀល។ ដោយសង្កេតឃើញថាគណនីប្រាក់បញ្ញើនៅរតនាគារជាតិនៅមានសមតុល្យគ្រប់គ្រាន់ ក្រុមហ៊ុនតេលាបានស្នើសុំឱ្យអគ្គនាយកដ្ឋានរតនាគារជាតិ បង្វែរប្រាក់ចំនួន ៥០០ លានរៀល សម្រាប់ការបង់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ២០២៣ ជូនអគ្គនាយកដ្ឋានពន្ធដារតែម្តង។ នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៤ ក្រុមហ៊ុនតេលាបានរៀបចំសំណើសុំផ្ទេរប្រាក់ចំនួន ៥០០ លានរៀល រួចបញ្ជូនសំណើមកអគ្គនាយកដ្ឋានរតនាគារជាតិ។ ក្រោយពីបានពិនិត្យត្រឹមត្រូវលើការស្នើសុំរបស់ក្រុមហ៊ុនតេលា អគ្គនាយកដ្ឋានរតនាគារជាតិបានផ្ទេរប្រាក់ចេញពីគណនីប្រាក់បញ្ញើរបស់ក្រុមហ៊ុនតេលា ចំនួន ៥០០ លានរៀល នៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ និងបានជូនដំណឹងទៅអគ្គនាយកដ្ឋានពន្ធដារអំពីការបង្វែរប្រាក់ចូលគណនីបណ្តោះអាសន្នរបស់អគ្គនាយកដ្ឋានពន្ធដារ លើទឹកប្រាក់បង់ពន្ធលើប្រាក់ចំណេញរបស់ក្រុមហ៊ុនតេលា។ នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបានរៀបចំសលាកបត្របង្វែរចំណូល មកអគ្គនាយកដ្ឋានរតនាគារជាតិ ដោយទទួលស្គាល់

ទឹកប្រាក់បង់ពន្ធរបស់ក្រុមហ៊ុនគេលា ជាចំណូលថវិកាជាតិ។ ក្រោយពីពិនិត្យត្រឹមត្រូវលើឯកសាររបស់អគ្គនាយកដ្ឋានពន្ធដារ គណនេយ្យករសាធារណៈត្រូវកត់ត្រាទទួលស្គាល់ជាចំណូលថវិកា អនុគណនីលេខ៧០០១២ ចំនួនទឹកប្រាក់ ៥០០ លានរៀល នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៤ នៅក្នុងគណនេយ្យថវិកា។

### ៤.១.២.៨ ចំណូលថវិការដ្ឋពីកម្រៃធនាគារ

ផ្អែកតាមលិខិតបទដ្ឋានគតិយុត្តដែលអនុញ្ញាតឱ្យអគ្គនាយកដ្ឋានធនាគារជាតិ គិតកម្រៃសេវាលើការផ្ទេរប្រាក់ពីគណនីប្រាក់បញ្ញើរបស់និក្ខិត្តករធនាគារ ធនាគារកណ្ដាលនិងធនាគាររាជធានី ខេត្ត ទទួលបានប្រាក់ចំណូលពីកម្រៃសេវានេះ តាមរយៈការកាត់ប្រាក់ចេញពីគណនីប្រាក់បញ្ញើរបស់និក្ខិត្តករធនាគារ និងត្រូវធ្វើការបែងចែកកម្រៃធនាគារ មួយចំណែកជាប្រយោជន៍ផ្ទាល់ដល់ធនាគារ និងមួយចំណែកទៀតត្រូវបង់ចូលជាចំណូលថវិការដ្ឋ ស្របតាមបទប្បញ្ញត្តិជាធរមាន។ ក្នុងករណីដែលកម្រៃធនាគារត្រូវទទួលស្គាល់ជាចំណូលថវិកានូវចំណែកដែលត្រូវបង់ចូលថវិការដ្ឋ គណនេយ្យករសាធារណៈត្រូវកត់ត្រាទទួលស្គាល់ប្រតិបត្តិការនេះ ជាចំណូលថវិការដ្ឋរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយសារតែ៖

- មានរំហូរសាច់ប្រាក់ចេញពិតប្រាកដពីគណនីប្រាក់បញ្ញើរបស់អង្គភាពស្នើសុំបង្វែរប្រាក់
- ព្រឹត្តិការណ៍ចំណូលពិតជាកើតមានឡើងនៅក្នុងឆ្នាំកំពុងអនុវត្តថវិកាតាមរយៈការបង្វែរប្រាក់នេះ
- មានការទទួលស្គាល់ពីនិក្ខិត្តករធនាគារ ដែលជាម្ចាស់គណនីប្រាក់បញ្ញើ អំពីកម្រៃសេវាដែលបានកាត់ និង
- មានការត្រួតពិនិត្យផ្ទៀងផ្ទាត់ភាពត្រឹមត្រូវដោយគណនេយ្យករសាធារណៈ ស្របតាមខ្លឹមសារនៃមាត្រា២៧នៃអនុក្រឹត្យស្ដីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ។

ផ្អែកលើសក្ខីបត្រគាំទ្រនៃប្រតិបត្តិការកម្រៃធនាគារនេះ (ដូចជា លិខិតជូនដំណឹងអំពីការកាត់កម្រៃសេវាពីគណនីប្រាក់បញ្ញើ និងលិខិតគតិយុត្តតម្រូវឱ្យបង់ចូលជាចំណូលថវិការដ្ឋ ជាដើម) គណនេយ្យករសាធារណៈត្រូវកត់ត្រាទទួលស្គាល់ប្រតិបត្តិការនេះជាចំណូលថវិការដ្ឋ ដោយផ្អែកលើចំណាត់ថ្នាក់សេដ្ឋកិច្ច (ផ្នែកមាតិកាចំណូលថវិកា) នៃមាតិកាថវិការដ្ឋ នៅក្នុងគណនេយ្យថវិកា និងប្រព័ន្ធ FMIS ព្រមទាំងត្រូវកំណត់យកតាមថ្ងៃខែឆ្នាំនៃកិច្ចប្រតិបត្តិការបង្វែរជាចំណូលថវិការដ្ឋ (មិនប្រើប្រាស់សលាកបត្របង្វែរចំណូលទេ) ដោយពុំអាស្រ័យទៅនឹងថ្ងៃខែឆ្នាំនៃការដកប្រាក់ចេញពីគណនីប្រាក់បញ្ញើរបស់អង្គភាពស្នើសុំនោះទេ។ កាលបរិច្ឆេទនៃចំណូលថវិកានេះត្រូវបានកំណត់ជាគោលដោយគណនេយ្យករសាធារណៈ និងជាមូលដ្ឋានសម្រាប់ការរាយការណ៍អំពីការអនុវត្តចំណូលថវិកាពីប្រតិបត្តិការកាត់កម្រៃសេវាធនាគារ នៅក្នុងឆ្នាំអនុវត្តថវិកា។

ប្រតិបត្តិការចំណូលថវិការដ្ឋពីកម្រៃធនាគារ នឹងនាំឱ្យមានការកត់ត្រានិងរាយការណ៍ដូចគ្នា ទាំងនៅក្នុងគណនេយ្យថវិកានិងគណនេយ្យទូទៅ។

<u>ឧទាហរណ៍</u>៖

រដ្ឋាករអគ្គិសនីខេត្តបាត់ដំបង បានស្នើសុំទៅធនាគារខេត្តបាត់ដំបង ផ្ទេរប្រាក់ចេញពីគណនីប្រាក់បញ្ញើចំនួន ២០ លានរៀល សម្រាប់ការទូទាត់ជូនអាជ្ញាធរអគ្គិសនីកម្ពុជា លើថ្លៃសេវាអាជ្ញាបណ្ណប្រកបអាជីវកម្មប្រចាំឆ្នាំ២០២៣។ ផ្អែកលើគោលការណ៍ដែលបានអនុញ្ញាតឱ្យធនាគារគិតកម្រៃសេវាផ្ទេរប្រាក់ពីគណនីប្រាក់បញ្ញើ ធនាគារខេត្តបាត់ដំបងបានផ្ទេរប្រាក់ ២០ លានរៀល ជូនអាជ្ញាធរអគ្គិសនីកម្ពុជា និងបានគិតកម្រៃសេវាផ្ទេរប្រាក់ ចំនួន ២០,០០០ រៀល។ កម្រៃសេវាធនាគារនេះនឹងត្រូវបង់ចូលជាចំណូលថវិកាមួយចំណែក ឧទាហរណ៍ ២០% នៃកម្រៃសេវា ស្មើនឹង ៤,០០០ រៀល រីឯមួយចំណែកទៀត ត្រូវទុកជាគុណប្រយោជន៍នៃការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានធនាគារជាតិ។ ទឹកប្រាក់ ៤,០០០ រៀលដែលបានដកចេញពីគណនីប្រាក់បញ្ញើរបស់រដ្ឋាករអគ្គិសនីខេត្តបាត់ដំបងនឹងត្រូវបង្វែរចូលជាចំណូលថវិការដ្ឋ (ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ)។ គណនេយ្យករសាធារណៈត្រូវកត់ត្រាទឹកប្រាក់បានបង្វែរចំនួន ៤,០០០ រៀល ចូលជាចំណូលថវិការដ្ឋ អនុគណនីលេខ៧៧០១៣ នៅក្នុងគណនេយ្យថវិកា ដោយផ្អែកលើឯកសារជូនដំណឹងអំពីការដកប្រាក់ពីគណនីប្រាក់បញ្ញើ។ ប្រតិបត្តិការនេះពុំចាំបាច់មានសលាកបត្របង្វែរចំណូលឡើយ។

### ៤.១.២.៩ ចំណេញពិតពីអត្រាប្តូរប្រាក់

ចំណេញពិតពីអត្រាប្តូរប្រាក់កើតឡើង នៅពេលដែលមានការទិញ ឬ លក់ ឬ ប្តូររូបិយបណ្ណដែលអត្រាប្តូរប្រាក់មានតម្លៃល្អជាងមុន (ឬធំជាងមុន) ធៀបនឹងតម្លៃដែលបានកត់ត្រាមុននៃរូបិយបណ្ណ។ ប្រតិបត្តិការចំណេញពិតពីអត្រាប្តូរប្រាក់នេះត្រូវទទួលស្គាល់ជាចំណូលថវិកា ដោយសារតែ៖

- មានលំហូរសាច់ប្រាក់ចូលពិតប្រាកដ ទៅក្នុងគណនីធនាគាររបស់គណនេយ្យករសាធារណៈ ដែលកើតចេញពីការប្តូរប្រាក់ជាក់ស្តែង តាមអត្រាប្តូរប្រាក់នៅថ្ងៃប្រតិបត្តិការ
- ព្រឹត្តិការណ៍ចំណូលពិតជាកើតមានឡើង នៅក្នុងឆ្នាំកំពុងអនុវត្តថវិកា និង
- មានការត្រួតពិនិត្យត្រឹមត្រូវនិងបញ្ជាក់ទទួលស្គាល់លើចំណូលថវិកា (ចំណេញពិតពីអត្រាប្តូរប្រាក់) ដោយគណនេយ្យករសាធារណៈ។

ផ្អែកលើសក្ខីបត្រគាំទ្រនៃប្រតិបត្តិការប្តូរប្រាក់នេះ (ដូចជារបាយការណ៍ធនាគារជាដើម) គណនេយ្យករសាធារណៈត្រូវកត់ត្រាទទួលស្គាល់ប្រតិបត្តិការនេះជាចំណូលថវិកា (ចំណេញពិតពីអត្រាប្តូរប្រាក់) ដោយប្រើប្រាស់ចំណាត់ថ្នាក់សេដ្ឋកិច្ច (ផ្នែកមាតិកាចំណូលថវិកា) នៃមាតិកាថវិកាជាតិ នៅក្នុងគណនេយ្យថវិកា និងប្រព័ន្ធ FMIS ព្រមទាំងកំណត់យកតាមថ្ងៃខែឆ្នាំនៃប្រតិបត្តិការប្តូរប្រាក់ដែលបានកើតឡើង ឬ កំណត់យកថ្ងៃទី៣១ ខែធ្នូ ឆ្នាំអនុវត្តថវិកា ករណីគណនេយ្យករសាធារណៈកត់ត្រាទទួលស្គាល់ប្រតិបត្តិការនេះនៅក្នុងអំឡុងរយៈពេលបំពេញបន្ថែម។ កាលបរិច្ឆេទនៃចំណូលថវិកានេះត្រូវបានកំណត់ជាគោលដោយគណនេយ្យករសាធារណៈ និងជាមូលដ្ឋានសម្រាប់ការរាយការណ៍អំពីការអនុវត្តចំណូលថវិកាពីប្រតិបត្តិការចំណេញពិតពីអត្រាប្តូរប្រាក់ នៅក្នុងឆ្នាំអនុវត្តថវិកា។

ប្រតិបត្តិការចំណេញពិតពីអត្រាប្តូរប្រាក់នេះ នឹងនាំឱ្យមានការកត់ត្រានិងរាយការណ៍ដូចគ្នា ទាំងនៅក្នុងគណនេយ្យថវិកានិងគណនេយ្យទូទៅ។

**<u>បញ្ជាក់៖</u>**

- ការកត់ត្រាប្រតិបត្តិការចំណេញពិតពីអត្រាប្តូរប្រាក់ពុំតម្រូវឱ្យមានសលាកបត្របង្វែរចំណូលថវិកាទេ។
- នៅក្នុងក្របខ័ណ្ឌគណនេយ្យទូទៅ មូលដ្ឋានបង្គរ គោលការណ៍ណែនាំសម្រាប់កិច្ចបញ្ជិកាគណនេយ្យទ្វេភាគនៃប្រតិបត្តិការចំណេញឬខាតពីអត្រាប្តូរប្រាក់ នឹងត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្របតាមស្តង់ដាគណនេយ្យសាធារណៈជាតិនិងអន្តរជាតិ។

<u>ឧទាហរណ៍៖</u>

សាលារាជធានីភ្នំពេញបានចុះកិច្ចសន្យាផ្គត់ផ្គង់សេវាបំភ្លឺសាធារណៈជាមួយក្រុមហ៊ុន ABC ដោយតម្រូវឱ្យបង់ថ្លៃសេវាប្រចាំខែជូនក្រុមហ៊ុន ចំនួន ១០,០០០ ដុល្លារអាមេរិក នៅអំឡុងសប្តាហ៍ទី២ នៃខែបន្ទាប់។ នៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២៣ ក្រុមហ៊ុនបានចេញវិក្កយបត្រជាប្រាក់ដុល្លារអាមេរិកជូនសាលារាជធានីភ្នំពេញ ដែលមានទឹកប្រាក់ ១០,០០០ ដុល្លារអាមេរិក ស្មើនឹង ៤០,៥០០,០០០ រៀល (អត្រា ១ ដុល្លារអាមេរិកស្មើនឹង ៤,០៥០ រៀល តាមការកំណត់របស់ធនាគារជាតិនៃកម្ពុជា)។ នៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២៣ សាលារាជធានីភ្នំពេញបានបោះផ្សាយអាណត្តិបើកប្រាក់ជាប្រាក់រៀលចំនួនទឹកប្រាក់ ៤០,៥០០,០០០ រៀល សមមូលដុល្លារអាមេរិកចំនួន ១០,០០០ ដុល្លារអាមេរិក ដើម្បីទូទាត់ជូនក្រុមហ៊ុន រួចបញ្ជូនឯកសារមកគណនេយ្យកររតនាគារទទួលបន្ទុកសាលារាជធានីភ្នំពេញ ដើម្បីធ្វើការពិនិត្យនិងផ្ទៀងផ្ទាត់។ ក្រោយពីបានពិនិត្យត្រឹមត្រូវ គណនេយ្យកររតនាគារទទួលបន្ទុកសាលារាជធានីភ្នំពេញបានទូទាត់ជូនក្រុមហ៊ុន នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២៣ នូវទឹកប្រាក់ចំនួន ៤០ លានរៀល សមមូលជាប្រាក់ដុល្លារអាមេរិកចំនួន ១០,០០០ ដុល្លារអាមេរិក តាមអត្រាប្តូរប្រាក់ ១ ដុល្លារអាមេរិកស្មើនឹង ៤,០០០ រៀល របស់ធនាគារជាតិនៃកម្ពុជា តាមរយៈគណនីប្រាក់បញ្ញើរបស់សាលារាជធានីភ្នំពេញ។ ក្នុងករណីនេះ សាលារាជធានីភ្នំពេញបានចំណេញពិតពីអត្រាប្តូរប្រាក់ចំនួន ៥០០,០០០ រៀល។ សាលារាជធានីភ្នំពេញ ត្រូវកត់ត្រាចំណេញពិតពីអត្រាប្តូរប្រាក់នេះ ជាចំណូលថវិការបស់

សាលារាជធានីភ្នំពេញ នៅក្នុងគណនេយ្យថវិកា ដោយកំណត់យកតាមថ្ងៃខែឆ្នាំនៃការទូទាត់ប្រាក់ទៅក្រុមហ៊ុន និងពុំចាំបាច់មានសលាកបត្របង្វែរចំណូលទេ។

**៤.១.២.១០ ចំណូលមិនឆ្លងកាត់រតនាគារជាតិ**

ប្រតិបត្តិការចំណូលមិនឆ្លងកាត់រតនាគារជាតិ ពុំអាចកត់ត្រានិងទទួលស្គាល់ជាចំណូលថវិកានៃឆ្នាំអនុវត្តថវិកានៅក្នុងគណនេយ្យថវិកាបានទេ ដោយសារតែប្រតិបត្តិការនេះពុំមានលំហូរសាច់ប្រាក់ចូលទៅក្នុងគណនីធនាគារឬបេឡារបស់គណនេយ្យករសាធារណៈ និងពុំបានឆ្លងកាត់ការត្រួតពិនិត្យនិងបញ្ជាក់ទទួលស្គាល់លើចំណូលថវិកាដោយគណនេយ្យករសាធារណៈ ស្របតាមខ្លឹមសារនៃមាត្រា២៧នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ។ ប្រតិបត្តិការនេះពុំមែនជាកម្មវត្ថុនៃការកត់ត្រាក្នុងទិដ្ឋភាពនៃការអនុវត្តថវិកាទេ ប៉ុន្តែជាកម្មវត្ថុនៃការរាយការណ៍បន្ថែមអំពីការអនុវត្តថវិកា នៅក្រៅប្រព័ន្ធរតនាគារជាតិ។ ដោយឡែក គណនេយ្យករសាធារណៈត្រូវធ្វើមជ្ឈការនិងកត់ត្រាប្រតិបត្តិការនេះ នៅក្នុងប្រព័ន្ធគណនេយ្យទូទៅ (មូលដ្ឋានបង្គរ) ដើម្បីឆ្លុះបញ្ចាំងគ្រប់ប្រតិបត្តិការហិរញ្ញវត្ថុនិងគណនេយ្យនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល។ របៀបនៃការធ្វើសមាហរណកម្មប្រតិបត្តិការនេះនៅក្នុងគណនេយ្យទូទៅនឹងមានកំណត់ដោយឡែក និងត្រូវអនុវត្តដោយអនុលោមតាមស្តង់ដាគណនេយ្យសាធារណៈជាតិនិងអន្តរជាតិមូលដ្ឋានបង្គរ។

**៤.១.២.១១ បុរេប្រទានបានទទួល**

ក្នុងករណីដែលរដ្ឋបាលសាធារណៈមួយចំនួនបានទទួលប្រាក់បុរេប្រទានពីរដ្ឋបាលសាធារណៈដទៃទៀត សម្រាប់ធានាដល់សមតុល្យនៃគណនីប្រាក់បញ្ញើឬគណនីធនាគារ ដើម្បីមានលទ្ធភាពទូទាត់ចំណាយថវិកាចាំបាច់និងបន្ទាន់ ប្រាក់ចំណូលទាំងនោះពុំត្រូវបានកត់ត្រាទទួលស្គាល់ជាចំណូលថវិកានៅក្នុងគណនេយ្យថវិកា និងប្រព័ន្ធ FMIS នោះទេ បើទោះបីជាមានលំហូរចូលសាច់ប្រាក់ឬសាច់ប្រាក់សមមូលក៏ដោយ ដោយហេតុតែសាច់ប្រាក់ចំណូលទាំងនេះត្រូវបានចាត់ទុកជាបុរេប្រទានបានទទួល ក្រោមរូបភាពជាបំណុលដែលត្រូវសងត្រលប់វិញ និងជាក់ស្តែង ពុំមានព្រឹត្តិការណ៍ដែលជាហេតុនាំឱ្យមានចំណូលថវិកានោះទេ។ ប្រតិបត្តិការប្រភេទនេះពុំមាននាំឱ្យមានការកត់ត្រានៅក្នុងគណនេយ្យថវិកាទេ ប៉ុន្តែ គណនេយ្យករសាធារណៈត្រូវកត់ត្រានិងរាយការណ៍នៅក្នុងគណនេយ្យទូទៅ ដែលកំណត់ក្នុងគោលការណ៍ណែនាំដោយឡែក។

**៤.១.២.១២ ប្រតិបត្តិការចំណូលផ្សេងទៀត**

ប្រតិបត្តិការចំណូលផ្សេងទៀត សំដៅដល់ប្រតិបត្តិការទាំងឡាយណាក្រៅពីប្រតិបត្តិការដែលបានកំណត់ក្នុងចំណុចទី៤.១.១ និងចំណុចទី៤.១.២.១ ដល់ចំណុចទី៤.១.២.១២ ហើយអាចកើតមានឡើងដោយថាហេតុ ព្រមទាំងពុំទាន់មានលទ្ធភាពកំណត់ចូលក្នុងលក្ខខណ្ឌនៃការទទួលស្គាល់ជាចំណូលថវិកា នៅក្នុងគណនេយ្យថវិកា និងប្រព័ន្ធ FMIS តាមគោលការណ៍ណែនាំនេះ។ ក្នុងករណីនេះ អាណាប័កនិងគណនេយ្យករសាធារណៈត្រូវទាក់ទងមកអគ្គនាយកដ្ឋានរតនាគារជាតិ និងអគ្គនាយកដ្ឋានពាក់ព័ន្ធ ដើម្បីពិភាក្សា វិភាគ និងកំណត់អំពីលទ្ធភាពនៃការកត់ត្រាចូលក្នុងគណនេយ្យថវិកា និងប្រព័ន្ធ FMIS។

**៤.១.៣ ធនធានហិរញ្ញប្បទាន**

ធនធានហិរញ្ញប្បទានមានការពាក់ព័ន្ធនឹងលំហូរចូលសាច់ប្រាក់ហិរញ្ញប្បទានមករាជរដ្ឋាភិបាល ក្រោមរូបភាពជាការខ្ចីបុល ទាំងក្នុងស្រុកទាំងក្រៅស្រុក, ការដាក់ប្រាក់ចូលគណនីប្រាក់បញ្ញើ, ការបង់ប្រាក់ចូលគណនីទោលរតនាគារ ឬ ប្រតិបត្តិការសាច់ប្រាក់ផ្សេងទៀត ដែលមានចរិតលក្ខណៈជាបណ្តោះអាសន្ន (មិនស្ថាពរ) និងត្រូវបង្វិលសងត្រលប់ទៅម្ចាស់ដើមវិញ។ ធនធានហិរញ្ញប្បទានមិនមែនជាធនធានថវិកា ដែលត្រូវកត់ត្រាទទួលស្គាល់ជាចំណូលថវិកានោះទេ ដោយហេតុតែធនធានទាំងនេះពុំបានគោរពតាមលក្ខខណ្ឌនៃការទទួលស្គាល់ជាចំណូលថវិកា (ដូចមានកំណត់ក្នុងចំណុចទី៤.១.១ នៃជំពូកនេះ) ជាពិសេស លក្ខខណ្ឌនៃការកើតឡើងជាក់ស្តែងឬជាស្ថាពរនៃព្រឹត្តិការណ៍ចំណូល។ ដូច្នេះ ធនធានហិរញ្ញប្បទានពុំតម្រូវឱ្យធ្វើការកត់ត្រានៅក្នុងគណនេយ្យថវិកា នោះទេ។ ជាមួយគ្នានេះ នៅក្នុងគណនេយ្យទូទៅ

និងប្រព័ន្ធ FMIS ធនធានហិរញ្ញប្បទានត្រូវបានចុះកិច្ចបញ្ជិកាគណនេយ្យទ្វេភាគ ស្របតាមស្តង់ដាគណនេយ្យសាធារណៈកម្ពុជា ដោយសារតែ ប្រតិបត្តិការនេះក៏ជាប្រតិបត្តិការហិរញ្ញវត្ថុនិងគណនេយ្យរបស់រដ្ឋ ដែលត្រូវកត់ត្រា បូកសរុប និងរាយការណ៍ទៅរដ្ឋសភាដែរ ក្នុងក្របខ័ណ្ឌនៃរបាយការណ៍ហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល។

ប៉ុន្តែ នៅក្នុងកាលៈទេសៈខ្លះ ធនធានហិរញ្ញប្បទានត្រូវចាត់ទុកនិងទទួលស្គាល់ជាចំណូលថវិកា ដោយហេតុតែធនធានទាំងនោះត្រូវបានរឹបអូស (ករណីការរឹបអូសប្រាក់កក់), លើកលែង (ការលើកលែងសងបំណុលតទៅទៀតពីប្រទេសសហប្រតិបត្តិការឬដៃគូអភិវឌ្ឍន៍) និងមិនត្រូវសងត្រលប់ទៅម្ចាស់ដើមវិញទេ។ ក្នុងករណីនេះ ធនធានហិរញ្ញប្បទានត្រូវកត់ត្រាជាចំណូលថវិកា ដោយប្រើប្រាស់ចំណាត់ថ្នាក់សេដ្ឋកិច្ច (ផ្នែកមាតិកាចំណូលថវិកា) នៃមាតិកាថវិការដ្ឋ នៅក្នុងគណនេយ្យថវិកា និងប្រព័ន្ធ FMIS ដោយកំណត់យកតាមថ្ងៃខែឆ្នាំនៃសលាកបត្របង្វែរចំណូលដែលរៀបចំដោយអាណាប័ក គឺពុំអាស្រ័យទៅនឹងថ្ងៃខែឆ្នាំនៃលំហូរសាច់ប្រាក់ចូលពិតប្រាកដនោះទេ។ កាលបរិច្ឆេទនៃចំណូលថវិកានេះត្រូវបានកំណត់ជាគោលដោយគណនេយ្យករសាធារណៈ និងជាមូលដ្ឋានសម្រាប់ការរាយការណ៍អំពីការអនុវត្តចំណូលថវិកានៃឆ្នាំអនុវត្តថវិកា។ ការកត់ត្រាចំណូលថវិការបស់គណនេយ្យករសាធារណៈនៅក្នុងគណនេយ្យថវិកា និងប្រព័ន្ធ FMIS ត្រូវពឹងផ្អែកលើសលាកបត្របង្វែរចំណូល អមដោយសក្ខីបត្រគាំទ្រ ដែលអាស្រ័យទៅតាមប្រភេទនៃចំណូលថវិកានីមួយៗ។ ប្រតិបត្តិការប្រភេទនេះនឹងនាំឱ្យមានការកត់ត្រានិងរបាយការណ៍ដូចគ្នា ទាំងនៅក្នុងគណនេយ្យថវិកានិងគណនេយ្យទូទៅ។

<u>ឧទាហរណ៍៖</u>

កាលពីថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ក្រុមហ៊ុន ABC បានឈ្នះការដេញថ្លៃផ្គត់ផ្គង់ម៉ាស៊ីនភ្លើងមួយគ្រឿងជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងបានតម្កល់ប្រាក់សម្រាប់ធានាសកម្មភាពអាជីវកម្ម ចំនួន ១០ លានរៀល។ ក្រោយពេលប្រើប្រាស់ម៉ាស៊ីនភ្លើងមួយរយៈ (ក្នុងអំឡុងពេលធានាសុពលភាព) ម៉ាស៊ីនភ្លើងក៏មានបញ្ហាមិនអាចដំណើរការបានដោយសារតែម៉ូទ័របូមសាំងមិនដំណើរការ ហើយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានឱ្យក្រុមហ៊ុនមកពិនិត្យនិងផ្លាស់ប្តូរគ្រឿងបន្លាស់នេះចេញ។ ប៉ុន្តែ ក្រុមហ៊ុនមិនឆ្លើយតបនិងមិនគោរពតាមកិច្ចសន្យាដែលបានព្រមព្រៀង។ ជាលទ្ធផលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសម្រេចរឹបអូសប្រាក់តម្កល់ធានាចំនួន ១០ លានរៀលរបស់ក្រុមហ៊ុន នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៤ ចំពោះការមិនគោរពតាមកិច្ចសន្យា។ នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៤ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានរៀបចំសលាកបត្របង្វែរចំណូល ពីការរឹបអូសប្រាក់កក់នេះ ជាចំណូលថវិការដ្ឋ។

តាមរយៈឧទាហរណ៍នេះ នៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ប្រតិបត្តិការបង់ប្រាក់តម្កល់ធានាសកម្មភាពអាជីវកម្ម ចំនួន ១០ លានរៀល ដែលប្រតិបត្តិការនេះជាប្រភេទប្រតិបត្តិការសាច់ប្រាក់ (ធនធានហិរញ្ញប្បទាន) ដែលជាបំណុលដែលរដ្ឋត្រូវសងត្រលប់ទៅក្រុមហ៊ុនវិញ ហើយសាច់ប្រាក់នេះអាចបង្វិលប្រើប្រាស់ជាហិរញ្ញប្បទានបណ្តោះអាសន្ន។ នៅក្នុងកិច្ចបញ្ជិកាគណនេយ្យទូទៅ នឹងមានការកត់ត្រាជាសាច់ប្រាក់ចូល ជាមួយនឹងគណនីបំណុលត្រូវសងវិញ (ប្រាក់តម្កល់ធានាសកម្មភាពអាជីវកម្ម)។ រីឯ នៅក្នុងកិច្ចបញ្ជិកាគណនេយ្យថវិកា ពុំមានការកត់ត្រាទេ។ នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៤ ក្រោយពីទទួលបានសលាកបត្របង្វែរចំណូលរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលបញ្ជាក់អំពីការរឹបអូសប្រាក់កក់នេះ និងបានពិនិត្យត្រឹមត្រូវ គណនេយ្យករសាធារណៈនឹងកត់ត្រាទទួលស្គាល់ទឹកប្រាក់តម្កល់ចំនួន ១០ លានរៀល ជាចំណូលថវិការបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងត្រូវកត់ត្រានៅក្នុងគណនេយ្យថវិកាព្រមទាំងគណនេយ្យទូទៅ។

### ៤.១.៤ រយៈពេលនៃការទទួលសលាកបត្របង្វែរចំណូល សម្រាប់ការទទួលស្គាល់ចំណូលថវិកា

សលាកបត្របង្វែរចំណូល សម្រាប់ការទទួលស្គាល់ជាចំណូលថវិកា នៅក្នុងការិយបរិច្ឆេទនៃឆ្នាំអនុវត្តថវិកា អាចត្រូវបានបន្តទទួលយ៉ាងយូរត្រឹមកាលបរិច្ឆេទបញ្ចប់រយៈពេលបំពេញបន្ថែម ដោយត្រូវចុះកិច្ចបញ្ជិកានៅក្នុងគណនេយ្យថវិកា និងប្រព័ន្ធ FMIS នៅថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំអនុវត្តថវិកា ក្នុងករណីដែលលក្ខខណ្ឌនៃការទទួលស្គាល់ជាចំណូលថវិកា ដូចមានកំណត់ក្នុងចំណុចទី៤.១.១ និងចំណុចទី៤.១.២ ត្រូវបានគោរព។ បើទោះបីជាមានការអនុញ្ញាត

យ៉ាងនេះក៏ដោយ ក៏អាណាប័កត្រូវខិតខំរៀបចំសលាកបត្របង្វែរចំណូល និងត្រូវបញ្ជូនមកគណនេយ្យករសាធារណៈឱ្យបានទាន់ពេល នៃឆ្នាំអនុវត្តថវិកា (ត្រឹមថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំអនុវត្តថវិកា) ដើម្បីឱ្យដំណើរការនៃការបិទបញ្ជីគណនេយ្យថវិកានិងការរៀបចំរបាយការណ៍ថវិកាអាចប្រព្រឹត្តទៅដោយរលូននិងទាន់ពេល។

**៤.១.៥ ការសងប្រាក់ចំណូល**

ចំណូលថវិកាមួយចំនួន ក្រោយពីបានបង់ប្រាក់ចូលគណនេយ្យករសាធារណៈរួចរាល់ និងក្រោយពីអង្គភាពសាធារណៈបានទទួលស្គាល់ជាចំណូលថវិការួចរាល់ហើយ អាចមានករណីដែលអាណាប័កស្នើសុំទៅគណនេយ្យករសាធារណៈដកប្រាក់ចំណូលថវិកាដោយត្រូវសងត្រលប់ទៅអតិថិជនវិញ (មូលហេតុ អាចមានការភ័ន្តច្រឡំក្នុងការកំណត់ជាចំណូលថវិកានិងតម្រូវឱ្យសងទៅអតិថិជនវិញ) នឹងត្រូវដកជាសាច់ប្រាក់ចេញពីគណនីធនាគារឬបេឡារបស់គណនេយ្យករសាធារណៈ ដើម្បីសងត្រលប់ទៅវិញ។

ក្នុងករណីដែលការសងប្រាក់ត្រលប់វិញប្រព្រឹត្តទៅនៅក្នុងឆ្នាំអនុវត្តថវិកា គណនេយ្យករសាធារណៈត្រូវកត់ត្រានៅក្នុងគណនេយ្យថវិកា និងប្រព័ន្ធ FMIS ដោយកាត់បន្ថយពីចំណូលថវិកាដែលបានទទួលស្គាល់ពីមុន ដោយផ្អែកលើគោលការណ៍ឯកភាពអនុញ្ញាតឱ្យបន្ថយចំណូលថវិការបស់អាណាប័កអមដោយឯកសារគាំទ្រ ដោយកំណត់យកតាមថ្ងៃខែឆ្នាំនៃរំហូរសាច់ប្រាក់ចេញរបស់គណនេយ្យករសាធារណៈ។

ក្នុងករណីដែលការសងប្រាក់ត្រលប់វិញប្រព្រឹត្តទៅនៅឆ្នាំបន្តបន្ទាប់ គណនេយ្យករសាធារណៈត្រូវកត់ត្រានៅក្នុងគណនេយ្យថវិកា និងប្រព័ន្ធ FMIS ដោយចាត់ទុកជាចំណាយថវិកាផ្សេងៗ ដោយផ្អែកលើអាណត្តិបើកប្រាក់ និងឯកសារគាំទ្រ ដោយកំណត់យកតាមថ្ងៃខែឆ្នាំនៃរំហូរសាច់ប្រាក់ចេញរបស់គណនេយ្យករសាធារណៈ។

## ៤.២ កិច្ចប្រតិបត្តិការចំណាយថវិកា

ផ្អែកតាមមាត្រា៤៣នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ ចំណាយថវិកាត្រូវឆ្លងកាត់៥ដំណាក់កាលធំៗ ដូចខាងក្រោម៖

- ដំណាក់កាល ការធានាចំណាយ
- ដំណាក់កាល ការអនុវត្តកិច្ចលទ្ធកម្ម
- ដំណាក់កាល ការជម្រះបញ្ជីចំណាយ
- ដំណាក់កាល អាណាប័ណ្ណ និង
- ដំណាក់កាល ការទូទាត់។

មានតែប្រតិបត្តិការនៃការទូទាត់ក្នុងដំណាក់កាលការទូទាត់ទេ ដែលនាំឱ្យមានការទទួលស្គាល់ជាចំណាយថវិកាស្ថាពរនៅក្នុងកិច្ចបញ្ជិកាគណនេយ្យនៃគណនេយ្យថវិកា និងប្រព័ន្ធ FMIS។ ការទូទាត់សាច់ប្រាក់នៅក្នុងដំណាក់កាលការទូទាត់នឹងនាំឱ្យមានរំហូរសាច់ប្រាក់ចេញ ដែលជាលក្ខខណ្ឌចាំបាច់សម្រាប់ការទទួលស្គាល់ជាចំណាយថវិកា។ ការទទួលស្គាល់ជាចំណាយថវិកានឹងនាំឱ្យមានការប្រើប្រាស់ឥណទានចំណាយថវិកាជាស្ថាពររបស់អ្នកគ្រប់គ្រងថវិកា និងជាមូលដ្ឋានទិន្នន័យស្ថាពរនៃការរាយការណ៍អំពីការអនុវត្តចំណាយថវិការបស់រដ្ឋ។ ដូច្នេះ ឥណទានថវិកាគឺជាបុរេលក្ខខណ្ឌនៃការកត់ត្រាទទួលស្គាល់ជាចំណាយថវិការបស់រដ្ឋ។ រីឯ ដំណាក់កាលផ្សេងទៀត អាចមានជាការកត់ត្រាតាមដានការអនុវត្តឥណទានថវិកានៅក្នុងប្រព័ន្ធ FMIS ប៉ុន្តែ ពុំទាន់អាចជាការកត់ត្រាការប្រើប្រាស់ឥណទានចំណាយថវិកាជាស្ថាពរនោះទេ។ ប្រតិបត្តិការចំណាយដែលកើតមានក្នុងដំណាក់កាលនៃចំណាយថវិកាដែលមិនទាន់ឆ្លងកាត់ការទូទាត់ អាចនាំឱ្យមានការកត់ត្រាក្នុងគណនេយ្យទូទៅ (តាមគោលការណ៍ទ្វេភាគ និងមូលដ្ឋានបង្គរ) និងប្រព័ន្ធ FMIS ដោយផ្អែកទៅតាមប្រភេទនិងមុខសញ្ញានៃចំណាយនីមួយៗ។ នៅក្នុងក្របខ័ណ្ឌនៃការកត់ត្រាគណនេយ្យទូទៅនេះ នឹងមានគោលការណ៍ណែនាំដោយឡែក សម្រាប់ការទទួលស្គាល់ចំណាយ តាមមូលដ្ឋានបង្គរ ដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

អាស្រ័យទៅតាមប្រភេទចំណាយ ពេលវេលា និងការត្រួតពិនិត្យផ្ទាល់របស់គណនេយ្យករសាធារណៈ ប្រតិបត្តិការចំណាយត្រូវបានទទួលស្គាល់ជាចំណាយថវិកា លុះត្រាតែប្រតិបត្តិការទាំងនោះគោរពបានទៅតាមលក្ខខណ្ឌនៃការទទួលស្គាល់ចំណាយថវិកា ដូចមានកំណត់ខាងក្រោម៖

**៤.២.១ លក្ខខណ្ឌទូទៅនៃការទទួលស្គាល់ចំណាយថវិកា**

គណនេយ្យករសាធារណៈ ត្រូវទទួលស្គាល់ប្រតិបត្តិការចំណាយណាមួយជាចំណាយថវិកានៃឆ្នាំអនុវត្តថវិកា ដោយត្រូវកត់ត្រាចូលក្នុងគណនេយ្យថវិកា លុះត្រាតែប្រតិបត្តិការទាំងនោះបំពេញតាមលក្ខខណ្ឌតម្រូវទាំង៤ជាសារវន្ត ដូចខាងក្រោម៖

- មានវិហរសាច់ប្រាក់ចេញពិតប្រាកដពីគណនេយ្យករសាធារណៈនៅក្នុងឆ្នាំអនុវត្តថវិកា
- ព្រឹត្តិការណ៍ចំណាយកើតមានឡើងពិតប្រាកដនៅក្នុងឆ្នាំអនុវត្តថវិកា
- មុខសញ្ញាចំណាយថវិកាត្រូវបានកំណត់ច្បាស់លាស់ដោយផ្អែកលើកិច្ចសន្យាផ្គត់ផ្គង់ កិច្ចព្រមព្រៀង ឬឯកសារគាំទ្រចំណាយផ្សេងទៀត និងត្រូវមានការបញ្ជាក់ទទួលស្គាល់ដោយអាណាប័ក និង
- មានការត្រួតពិនិត្យផ្ទៀងផ្ទាត់ភាពត្រឹមត្រូវដោយគណនេយ្យករសាធារណៈ ស្របតាមខ្លឹមសារនៃមាត្រា២៧និងមាត្រា២៨នៃអនុក្រឹត្យស្ដីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ។

នៅពេលដែលគ្រប់លក្ខខណ្ឌនៃការទទួលស្គាល់ចំណាយថវិកាត្រូវបានបំពេញសម្រាប់ប្រតិបត្តិការមួយ ចំណាយថវិកាត្រូវបានកត់ត្រាទៅតាមប្រភេទនិងមុខសញ្ញានៃចំណាយថវិកានីមួយៗ ដោយផ្អែកលើចំណាត់ថ្នាក់សេដ្ឋកិច្ច (ផ្នែកមាតិកាចំណាយថវិកា) នៃមាតិកាថវិការដ្ឋ នៅក្នុងគណនេយ្យថវិកា និងប្រព័ន្ធ FMIS ដោយកំណត់យកតាមថ្ងៃខែឆ្នាំនៃវិហរចេញសាច់ប្រាក់ពិតប្រាកដរបស់គណនេយ្យករសាធារណៈ។ កាលបរិច្ឆេទនៃចំណាយថវិកានេះត្រូវបានកំណត់ជាគោលដោយគណនេយ្យករសាធារណៈ និងជាមូលដ្ឋានសម្រាប់ការរាយការណ៍អំពីការអនុវត្តចំណាយថវិកានៃឆ្នាំអនុវត្តថវិកា។ ការកត់ត្រាចំណាយថវិកានៅក្នុងគណនេយ្យថវិកាត្រូវផ្អែកលើអាណត្តិបើកប្រាក់ អមដោយសក្ខីបត្រគាំទ្រ ដែលអាស្រ័យទៅតាមប្រភេទនិងមុខសញ្ញានៃចំណាយថវិកានីមួយៗ និងឯកសារទូទាត់ឬបង្វែរប្រាក់ ឬ ប្រកាសឥណពន្ធធនាគារ ឬ របាយការណ៍ធនាគារ ឬសក្ខីបត្រផ្សេងទៀត ដែលបញ្ជាក់អំពីការទូទាត់ប្រាក់ចេញពីគណនេយ្យករសាធារណៈ។ ប្រតិបត្តិការនេះនាំឱ្យមានការកត់ត្រានិងរាយការណ៍ដូចគ្នាទាំងនៅក្នុងគណនេយ្យថវិកានិងគណនេយ្យទូទៅ។

<u>**បញ្ជាក់៖**</u>

- នៅក្នុងការអនុវត្តការងារជាក់ស្ដែង ថ្ងៃខែឆ្នាំនៃវិហរចេញសាច់ប្រាក់ពិតប្រាកដរបស់គណនេយ្យករសាធារណៈត្រូវកំណត់យកតាមកាលបរិច្ឆេទនៃការទូទាត់សាច់ប្រាក់ (Payment date) នៅក្នុងប្រព័ន្ធ FMIS។ ក្នុងករណីនេះ ដែលប្រព័ន្ធ FMIS ពុំទាន់ទៅដល់អង្គភាពសាធារណៈ គណនេយ្យករសាធារណៈត្រូវយកតាមថ្ងៃខែឆ្នាំនៃការចេញមូលប្បទានបត្រ ឬការបើកផ្ដល់ប្រាក់។
- អាណាប័កត្រូវរៀបចំអាណត្តិបើកប្រាក់ ឬ សំណើសុំទូទាត់ ដោយមានភ្ជាប់សក្ខីបត្រគាំទ្រ ឱ្យបានទាប់រហ័ស និងទាន់ពេល នៃឆ្នាំអនុវត្តថវិកា ដើម្បីធានាបាននូវការគោរពគោលការណ៍ថវិកាប្រចាំឆ្នាំ ដូចមានចែងក្នុងមាត្រា១១នៃច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០២៣។
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងចេញការណែនាំដោយឡែកសម្រាប់កំណត់លិខិតយុត្តិការចំណាយថវិកា ទៅតាមមុខសញ្ញាចំណាយថវិកា។

<u>ឧទាហរណ៍៖</u>

ក្រសួងបរិស្ថាន បានបោះផ្សាយអាណត្តិបើកប្រាក់សម្រាប់ទូទាត់ថ្លៃផ្គត់ផ្គង់សម្ភារៈការិយាល័យ ដែលក្រុមហ៊ុន ABC បានផ្គត់ផ្គង់សម្ភារៈរួចរាល់និងបានប្រគល់វិក្កយបត្រជូនក្រសួង កាលពីថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៣ ចំនួនទឹកប្រាក់ ៤០ លានរៀល។ ក្រសួងបរិស្ថានបានបញ្ជូនឯកសារទូទាត់មកអ្នកត្រួតពិនិត្យថវិកាដើម្បីត្រួតពិនិត្យនិងផ្ដល់

ទិដ្ឋាការនិងបញ្ជូនមកគណនេយ្យករសាធារណៈ នៅថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២៣ ដើម្បីធ្វើការទូទាត់។ ក្រោយពីបានពិនិត្យត្រឹមត្រូវ គណនេយ្យករសាធារណៈបានបើកផ្តល់ទៅក្រុមហ៊ុន ABC ដោយបង្វែរប្រាក់ចូលគណនីធនាគាររបស់ក្រុមហ៊ុន នៅថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២៣។

តាមរយៈឧទាហរណ៍ខាងលើនេះ គណនេយ្យករសាធារណៈនឹងកត់ត្រាទទួលស្គាល់ចំណាយថវិកាលើការទិញសម្ភារការិយាល័យ គណនី ចំណាយទិញសម្ភារការិយាល័យ គណនីលេខ ៦០០២១ នៅក្នុងគណនេយ្យថវិកា នៅថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២៣។ រីឯ នៅក្នុងគណនេយ្យទូទៅ គណនេយ្យករសាធារណៈទទួលស្គាល់ការកត់ត្រាចំណាយនៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៣ ដោយត្រូវចុះឥណពន្ធ គណនីចំណាយ និងឥណទាន គណនីត្រូវសង ចំនួនទឹកប្រាក់ ៤០ លានរៀល។

**៤.២.២ លក្ខខណ្ឌដោយឡែកនៃការទទួលស្គាល់ចំណាយថវិកា**

ប្រតិបត្តិការចំណាយមួយចំនួន ពុំបានគោរពតាមលក្ខខណ្ឌជាសារវន្តទាំង៤ ដែលបានកំណត់ក្នុងចំណុចទី ៤.២.១ ខាងលើនេះទេ ដោយសារតែក្របខ័ណ្ឌពេលវេលា ចរិតចំណាយ និងនីតិវិធីការងារនៃការអនុវត្តចំណាយទាំងនោះពុំអាចប្រព្រឹត្តទៅបានតាមការគ្រោងទុក។ ករណីនេះធ្វើឱ្យគណនេយ្យករសាធារណៈពុំអាចកត់ត្រាទទួលស្គាល់ជាចំណាយថវិកា តាមគោលការណ៍គណនេយ្យថវិកាបានទេ ហើយអាចមានផលប៉ះពាល់ជាសារវន្តថែមទៀតផង ដល់ការរាយការណ៍អំពីការអនុវត្តចំណាយថវិកាប្រចាំឆ្នាំ បើធៀបនឹងផែនការ។ ដើម្បីដោះស្រាយបញ្ហានេះ លក្ខខណ្ឌមួយចំនួនត្រូវបានអនុញ្ញាតឱ្យអនុវត្តដោយឡែក ក្នុងការទទួលស្គាល់ប្រតិបត្តិការមួយចំនួនជាចំណាយថវិកា និងត្រូវកត់ត្រាក្នុងគណនេយ្យថវិកា។ ជាការពិតណាស់ ការលើកលែងសម្រាប់ប្រតិបត្តិការទាំងនេះអាចមានវិបាកដល់ការវាយតម្លៃលើគុណភាពនៃគណនីចំណាយថវិកា ដោយហេតុតែចំណាយពុំត្រូវបានអនុវត្តឱ្យទាន់ពេលនិងក្នុងឆ្នាំអនុវត្តថវិកាដែលច្បាប់ហិរញ្ញវត្ថុបានអនុញ្ញាតឱ្យចំណាយជាប្រចាំឆ្នាំ (មិនស្របតាមគោលការណ៍ថវិកា៖ ប្រចាំឆ្នាំ ឯកត្តភាព និងសកលភាព)។ ហេតុដូច្នេះហើយ ការលើកលែងនេះគឺសម្រាប់តែប្រតិបត្តិការជាក់លាក់ និងត្រូវធ្វើការកែលម្អជាបណ្តើរៗទាំងវិធាននិងនីតិវិធីការងារបន្ថែមទៀត ដើម្បីឱ្យប្រតិបត្តិការចំណាយទាំងនោះអាចអនុវត្តបាន ដោយអនុលោមតាមគោលការណ៍គ្រឹះនៃថវិកាដែលបានកំណត់ដោយច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០២៣ និងគោរពតាមគោលការណ៍រួមនៃគណនេយ្យថវិកា។ ប្រតិបត្តិការចំណាយដែលគោរពតាមលក្ខខណ្ឌដោយឡែក សម្រាប់ការទទួលស្គាល់ជាចំណាយថវិកា រួមមាន៖

**៤.២.២.១ ប្រតិបត្តិការចំណាយកើតមាននៅក្នុងឆ្នាំអនុវត្តថវិកា ប៉ុន្តែសាច់ប្រាក់ចំណាយត្រូវបានទូទាត់នៅក្នុងឆ្នាំបន្ទាប់**

ប្រតិបត្តិការចំណាយមួយចំនួនបានកើតឡើងនៅក្នុងឆ្នាំអនុវត្តថវិកាឬអំឡុងរយៈពេលបំពេញបន្ថែម និងការទូទាត់សាច់ប្រាក់ត្រូវបានអនុវត្តចប់សព្វគ្រប់ គិតយ៉ាងយូរត្រឹមកាលបរិច្ឆេទបញ្ចប់រយៈពេលបំពេញបន្ថែម ប្រតិបត្តិការចំណាយទាំងនោះត្រូវកត់ត្រានិងទទួលស្គាល់ជាចំណាយថវិកានៃឆ្នាំអនុវត្តថវិកា នៅក្នុងគណនេយ្យថវិកា ដោយសារតែប្រតិបត្តិការទាំងនោះបំពេញតាមលក្ខខណ្ឌ ដូចខាងក្រោម៖

- ព្រឹត្តិការណ៍ចំណាយពិតជាបានកើតមានឡើង នៅក្នុងឆ្នាំអនុវត្តថវិកា ឬ អំឡុងរយៈពេលបំពេញបន្ថែម
- មុខសញ្ញាចំណាយថវិកាត្រូវបានកំណត់ច្បាស់លាស់ និងមានការបញ្ជាក់ទទួលស្គាល់ពីអាណាប័ក
- មានលំហូរសាច់ប្រាក់ចេញពិតប្រាកដពីគណនេយ្យករសាធារណៈនៅក្នុងឆ្នាំបន្ទាប់ ប៉ុន្តែគិតយ៉ាងយូរត្រឹមកាលបរិច្ឆេទបញ្ចប់រយៈពេលបំពេញបន្ថែម ដែលត្រូវកំណត់ដោយសារាចរណែនាំបន្ថែមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង
- មានការត្រួតពិនិត្យផ្ទៀងផ្ទាត់ភាពត្រឹមត្រូវដោយគណនេយ្យករសាធារណៈ ស្របតាមខ្លឹមសារនៃមាត្រា២៧និងមាត្រា២៨នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ។

នៅពេលដែលគ្រប់លក្ខខណ្ឌនៃការទទួលស្គាល់ចំណាយថវិកាត្រូវបានបំពេញសម្រាប់ប្រតិបត្តិការខាងលើ ចំណាយថវិកាត្រូវបានកត់ត្រាទៅតាមប្រភេទនិងមុខសញ្ញានៃចំណាយថវិកានីមួយៗ ដោយផ្អែកលើចំណាត់ថ្នាក់សេដ្ឋកិច្ច (ផ្នែកមាតិកាចំណាយថវិកា) នៃមាតិកាថវិការដ្ឋ នៅក្នុងគណនេយ្យថវិកា និងប្រព័ន្ធ FMIS ដោយកំណត់យកថ្ងៃទី៣១ ខែធ្នូ ឆ្នាំអនុវត្តថវិកា គឺពុំអាស្រ័យទៅនឹងថ្ងៃខែឆ្នាំនៃរំហូរចេញសាច់ប្រាក់ពិតប្រាកដនោះទេ។ កាលបរិច្ឆេទនៃចំណាយថវិកានេះត្រូវបានកំណត់ជាគោលដោយគណនេយ្យករសាធារណៈ និងជាមូលដ្ឋានសម្រាប់ការរាយការណ៍អំពីការអនុវត្តចំណាយថវិកានៃឆ្នាំអនុវត្តថវិកា។ ការកត់ត្រាចំណាយថវិកានៅក្នុងគណនេយ្យថវិកាត្រូវផ្អែកលើអាណត្តិបើកប្រាក់ អមដោយសក្ខីបត្រគាំទ្រ អាស្រ័យទៅតាមប្រភេទនិងមុខសញ្ញានៃចំណាយថវិកានីមួយៗ ដែលត្រូវប្រគល់ឱ្យគណនេយ្យករសាធារណៈយ៉ាងយូរត្រឹមកាលបរិច្ឆេទបញ្ចប់រយៈពេលបំពេញបន្ថែម និងឯកសារទូទាត់ឬបង្វែរប្រាក់ ឬ ប្រកាសឥណពន្ធធនាគារ ឬ របាយការណ៍ធនាគារ ឬសក្ខីបត្រផ្សេងទៀត ដែលបញ្ជាក់អំពីការទូទាត់ប្រាក់ចេញពីគណនេយ្យករសាធារណៈ។

<u>ឧទាហរណ៍៖</u>

ក្រសួងយុត្តិធម៌ បានប្រើប្រាស់បណ្តាញសេវាអ៊ីនធើណែតពីក្រុមហ៊ុនស៊ីធីលីង ប្រចាំខែវិច្ឆិកា ឆ្នាំ២០២៣ ហើយក្រុមហ៊ុនបានផ្ញើវិក្កយបត្រស្នើសុំទូទាត់ មកក្រសួង នៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២៣ ដែលមានទឹកប្រាក់ចំនួន ១០ លានរៀល។ ក្រសួងបានរៀបចំឯកសារនិងបោះផ្សាយអាណត្តិបើកប្រាក់ នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២៣ និងបានបញ្ជូនឯកសារមកអ្នកត្រួតពិនិត្យថវិកា ព្រមទាំងគណនេយ្យករសាធារណៈ នៅថ្ងៃទី២ ខែមករា ឆ្នាំ២០២៤។ ក្រោយពីបានពិនិត្យត្រឹមត្រូវ គណនេយ្យករសាធារណៈបានទូទាត់ជូនក្រុមហ៊ុន ដោយបង្វែរប្រាក់ចូលគណនីធនាគាររបស់ក្រុមហ៊ុន ចំនួន ១០ លានរៀល នៅថ្ងៃទី៥ ខែមករា ឆ្នាំ២០២៤។

តាមរយៈឧទាហរណ៍ខាងលើនេះ ការទូទាត់ប្រាក់ជូនក្រុមហ៊ុនបានប្រព្រឹត្តទៅនៅក្នុងអំឡុងពេលបំពេញបន្ថែម គណនេយ្យករសាធារណៈត្រូវទទួលស្គាល់ជាចំណាយថវិកា នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ នៅក្នុងគណនេយ្យថវិកា។ រីឯ នៅក្នុងគណនេយ្យទូទៅ គណនេយ្យករសាធារណៈត្រូវទទួលស្គាល់ជាចំណាយ នៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២៣ ដោយត្រូវកត់ត្រាឥណពន្ធ គណនី ចំណាយលើសេវាអ៊ីនធើណែត និងឥណទាន គណនីត្រូវសង ទឹកប្រាក់ចំនួន ១០ លានរៀល។

**៤.២.២.២ ប្រតិបត្តិការសាច់ប្រាក់បានចំណាយមុន និងដឹងច្បាស់ថាជាមុខសញ្ញាចំណាយថវិកា នៅក្នុងឆ្នាំអនុវត្ត**

ប្រតិបត្តិការចំណាយមួយចំនួនមានភាពចាំបាច់ដែលត្រូវបើកផ្តល់ឬទូទាត់ជាសាច់ប្រាក់មុន មានដូចជាចំណាយមុនអាណត្តិកិច្ច ឬចំណាយតាមនីតិវិធីបើកផ្តល់មុន ឬបុរេប្រទានសាច់ប្រាក់ ជាដើម។ ក្នុងករណីនេះ ប្រតិបត្តិការបុរេប្រទានសាច់ប្រាក់ ឬ ការបើកផ្តល់សាច់ប្រាក់មុន ត្រូវបានកត់ត្រានិងទទួលស្គាល់ជាចំណាយថវិកា នៅក្នុងឆ្នាំអនុវត្តថវិកា នៅក្នុងគណនេយ្យថវិកា ទៅតាមមុខសញ្ញាចំណាយថវិកាដែលបានស្នើសុំបើកប្រាក់មុន ដោយសារតែប្រតិបត្តិការទាំងនោះបំពេញតាមលក្ខខណ្ឌ ដូចខាងក្រោម៖

- មានរំហូរសាច់ប្រាក់ចេញពិតប្រាកដពីគណនេយ្យករសាធារណៈ នៅក្នុងឆ្នាំអនុវត្តថវិកា
- មុខសញ្ញាចំណាយថវិកា ត្រូវបានកំណត់ច្បាស់លាស់ និងមានការបញ្ជាក់ទទួលស្គាល់ពីអាណាប័ក តាមរយៈលិខិតស្នើសុំបុរេប្រទានឬបើកផ្តល់ប្រាក់មុន និង
- មានការត្រួតពិនិត្យផ្ទៀងផ្ទាត់ភាពត្រឹមត្រូវដោយគណនេយ្យករសាធារណៈ ស្របតាមបទដ្ឋានគតិយុត្តជាធរមាន។

នៅពេលដែលគ្រប់លក្ខខណ្ឌនៃការទទួលស្គាល់ចំណាយថវិកាត្រូវបានបំពេញសម្រាប់ប្រតិបត្តិការខាងលើ ចំណាយថវិកាត្រូវបានកត់ត្រាទៅតាមប្រភេទនិងមុខសញ្ញានៃចំណាយថវិកានីមួយៗ ដោយផ្អែកលើចំណាត់ថ្នាក់សេដ្ឋកិច្ច (ផ្នែកមាតិកាចំណាយថវិកា) នៃមាតិកាថវិការដ្ឋ នៅក្នុងគណនេយ្យថវិកា និងប្រព័ន្ធ FMIS ដោយកំណត់យកតាមថ្ងៃខែឆ្នាំនៃរំហូរសាច់ប្រាក់ចេញពិតប្រាកដពីគណនេយ្យករសាធារណៈ។ កាលបរិច្ឆេទនៃចំណាយថវិកានេះត្រូវបានកំណត់ជាគោលដោយគណនេយ្យករសាធារណៈ និងជាមូលដ្ឋានសម្រាប់ការរាយការណ៍អំពីការអនុវត្តចំណាយថវិកា នៃឆ្នាំអនុវត្តថវិកា។ ការកត់ត្រាចំណាយថវិកានៅក្នុងគណនេយ្យថវិកាត្រូវផ្អែកលើលិខិតស្នើសុំបុរេប្រទានឬបើកផ្តល់ប្រាក់មុន អមដោយសក្ខីបត្រគាំទ្រ ដោយមានបញ្ជាក់អំពីប្រភេទនិងមុខសញ្ញានៃចំណាយថវិកានីមួយៗ និងឯកសារទូទាត់ឬ

បង្វែរប្រាក់ ឬ ប្រកាសឥណពន្ធធនាគារ ឬ របាយការណ៍ធនាគារ ឬសក្ខីបត្រផ្សេងទៀត ដែលបញ្ជាក់អំពីការទូទាត់ប្រាក់ចេញពីគណនេយ្យករសាធារណៈ។

អាណាប័កត្រូវស្រូតរូតរៀបចំឯកសារទូទាត់ចំណាយ ដោយមានភ្ជាប់សក្ខីបត្រទូទាត់ រួចបញ្ជូនមកអ្នកត្រួតពិនិត្យថវិកា ស្របតាមបទប្បញ្ញត្តិជាធរមាន មុននឹងបញ្ជូនមកគណនេយ្យករសាធារណៈ ដើម្បីធ្វើការទូទាត់ចំណាយឱ្យបានទាន់ពេល យ៉ាងយូរបំផុតត្រឹមកាលបរិច្ឆេទបញ្ចប់រយៈពេលបំពេញបន្ថែម។ រីឯ សាច់ប្រាក់ដែលនៅសល់ពីការចំណាយ ត្រូវបង់ចូលគណនេយ្យករសាធារណៈ និងត្រូវកត់ត្រាបន្ថយចំណាយថវិកាក្នុងករណីបង់ទាន់ក្នុងឆ្នាំអនុវត្តថវិកា ឬ ត្រូវកត់ត្រាជាចំណូលថវិកាក្នុងករណីបង់នៅឆ្នាំបន្ទាប់។

<u>ឧទាហរណ៍ទី១៖</u>

នៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២៣ ក្រសួងអធិការកិច្ចបានស្នើសុំបើកផ្តល់ប្រាក់មុន ចំនួន ៦០ លានរៀល សម្រាប់ការរៀបចំសិក្ខាសាលាស្តីពីវិធីសាស្ត្រនៃការធ្វើអធិការកិច្ចរបស់រាជរដ្ឋាភិបាល នៅសណ្ឋាគារភ្នំពេញ ដែលគ្រោងនៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៣។ លិខិតស្នើសុំបើកប្រាក់មុន បានមកដល់គណនេយ្យកររតនាគារកណ្តាល នៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២៣។ ក្រោយពេលពិនិត្យត្រឹមត្រូវនិងផ្ទៀងផ្ទាត់ជាមួយនឹងឥណទានថវិការបស់ក្រសួងអធិការកិច្ច គណនេយ្យកររតនាគារកណ្តាលបានបើកផ្តល់ប្រាក់ទៅរជ្ជទេយ្យករបុរេប្រទានរបស់ក្រសួងអធិការកិច្ច ចំនួន ៦០ លានរៀល នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២៣ និងបានកត់ត្រាជាចំណាយថវិកាក្នុងគណនេយ្យថវិកាសម្រាប់ការរៀបចំសិក្ខាសាលា អនុគណនីលេខ៦១១០៣ ទឹកប្រាក់ចំនួន ៦០ លានរៀល នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២៣។ ក្រោយពីបានបញ្ចប់សិក្ខាសាលា នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ក្រសួងអធិការកិច្ចបានរៀបចំអាណត្តិបើកប្រាក់ទូទាត់ប្រាក់បើកផ្តល់មុន អមដោយវិក្កយបត្រនិងសក្ខីបត្រចំណាយផ្សេងៗ ដើម្បីទូទាត់ជម្រះសាច់ប្រាក់ដែលបានបើកផ្តល់មុន និងបានបញ្ជូនឯកសារទូទាត់មកអ្នកត្រួតពិនិត្យថវិកា និងគណនេយ្យករសាធារណៈ ដើម្បីទទួលស្គាល់ការចំណាយនៅក្នុងក្របខ័ណ្ឌគណនេយ្យទូទៅ។

<u>ឧទាហរណ៍ទី២៖</u>

នៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២២ ក្រសួងព្រះបរមរាជវាំងបានបើកសាច់ប្រាក់បុរេប្រទានចរន្តសម្រាប់ការងារជួសជុលបន្ទាន់អគាររាជដំណាក់ ចំនួន ២៤០ លានរៀល ត្រូវជា៦០%នៃទឹកប្រាក់សរុបចំនួន ៤០០ លានរៀល។ គណនេយ្យករសាធារណៈត្រូវកត់ត្រាទទួលស្គាល់ជាចំណាយថវិការបស់ក្រសួងព្រះបរមរាជវាំង នៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២២ ចំនួន ២៤០ លានរៀល។ នៅថ្ងៃទី៥ ខែមករា ឆ្នាំ២០២៣ (រយៈពេលបំពេញបន្ថែម) ក្រសួងបានបោះផ្សាយអាណត្តិនិយ័តកម្ម ជម្រះបុរេប្រទាន៦០% និងបោះផ្សាយអាណត្តិបើកប្រាក់បង្គ្រប់ចំនួន ១៦០ លានរៀល រួចបញ្ជូនមកអ្នកត្រួតពិនិត្យថវិកា ដើម្បីទទួលបានទិដ្ឋាការ និងបានបញ្ជូនអាណត្តិនិយ័តកម្ម/អាណត្តិបើកប្រាក់ មកគណនេយ្យករសាធារណៈដើម្បីធ្វើការត្រួតពិនិត្យ និងទូទាត់ជម្រះបំណុលបុរេប្រទាន នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០២៣។ ក្រោយពីបានពិនិត្យត្រឹមត្រូវលើសំណើសុំទូទាត់ គណនេយ្យករសាធារណៈកត់ត្រាទទួលស្គាល់ជាចំណាយនៅក្នុងគណនេយ្យថវិកាបន្ថែមចំនួន ១៦០ លានរៀល សម្រាប់កាលបរិច្ឆេទក្នុងឆ្នាំអនុវត្តថវិកា ២០២២។ រីឯ នៅក្នុងគណនេយ្យទូទៅ គណនេយ្យករសាធារណៈកត់ត្រាទទួលស្គាល់ជាចំណាយចរន្តទឹកប្រាក់ចំនួន ៤០០ លានរៀល សម្រាប់កាលបរិច្ឆេទក្នុងឆ្នាំអនុវត្តថវិកា ២០២២។

**៤.២.២.៣ ប្រតិបត្តិការរំហូរសាច់ប្រាក់ចេញ មុនពេលមានឥណទានថវិកា និងដឹងច្បាស់ថាជាមុខសញ្ញាចំណាយថវិកា នៅពេលក្រោយ**

ប្រតិបត្តិការចំណាយមួយចំនួនមានភាពចាំបាច់ បន្ទាន់ និងពិសេសបំផុត ព្រមទាំងពុំមានឥណទានថវិកានៅពេលចេញសាច់ប្រាក់ដូចជា ចំណាយបន្ទាន់លើគ្រោះទឹកជំនន់ឬរញ្ជួយដី ឬចំណាយលើព្រឹត្តិការណ៍មួយចំនួនដែលពុំបានគ្រោងទុកមុន ដូចជាសង្គ្រាមជាដើម។ ប្រតិបត្តិការចំណាយពិសេសប្រភេទនេះតម្រូវឱ្យមានការទូទាត់សាច់ប្រាក់ជាមុននៅក្នុងឆ្នាំអនុវត្ត និងត្រូវធ្វើការទូទាត់ជម្រះ ទទួលស្គាល់ជាចំណាយថវិកានៅពេលក្រោយ ក្រោយពីបាន

ដោះស្រាយឥណទានថវិកា។ ក្នុងករណីនេះ បើទោះបីជាសាច់ប្រាក់បានចំណាយមុននៅក្នុងឆ្នាំអនុវត្តថវិកាក៏ដោយ ក៏ប្រតិបត្តិការចំណាយត្រូវបានកត់ត្រានិងទទួលស្គាល់ជាចំណាយថវិកាពេលក្រោយ (ក្នុងឆ្នាំអនុវត្តថវិកាឬអាចនៅក្នុងឆ្នាំបន្ទាប់) ក្នុងគណនេយ្យថវិកា នៅពេលដែលមានឥណទានគ្រប់គ្រាន់ ដោយសារតែប្រតិបត្តិការទាំងនោះបំពេញតាមលក្ខខណ្ឌ ដូចខាងក្រោម៖

- ព្រឹត្តិការណ៍ចំណាយពិតជាកើតមានឡើង នៅក្នុងឆ្នាំកំពុងអនុវត្តថវិកាឬអាចនៅក្នុងឆ្នាំបន្ទាប់
- មុខសញ្ញាចំណាយថវិកា ត្រូវបានកំណត់ច្បាស់លាស់ និងមានការបញ្ជាក់ទទួលស្គាល់ពីអាណាប័ក
- មានរំហូរសាច់ប្រាក់ចេញពិតប្រាកដពីគណនេយ្យករសាធារណៈ នៅក្នុងឆ្នាំអនុវត្តថវិកា និង
- មានការត្រួតពិនិត្យផ្ទៀងផ្ទាត់ភាពត្រឹមត្រូវដោយគណនេយ្យករសាធារណៈ ស្របតាមខ្លឹមសារនៃមាត្រា២៧និងមាត្រា២៨នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ។

នៅពេលដែលគ្រប់លក្ខខណ្ឌនៃការទទួលស្គាល់ចំណាយថវិកាត្រូវបានបំពេញសម្រាប់ប្រតិបត្តិការខាងលើ ចំណាយថវិកាត្រូវបានកត់ត្រាទៅតាមប្រភេទនិងមុខសញ្ញានៃចំណាយថវិកានីមួយៗ ដោយផ្អែកលើចំណាត់ថ្នាក់សេដ្ឋកិច្ច (ផ្នែកមាតិកាចំណាយថវិកា) នៃមាតិកាថវិការដ្ឋ នៅក្នុងគណនេយ្យថវិកា និងប្រព័ន្ធ FMIS ដោយកំណត់យកតាមថ្ងៃខែឆ្នាំនៃអាណត្តិបើកប្រាក់និយ័តកម្ម គឺពុំបានពឹងផ្អែកលើថ្ងៃខែឆ្នាំនៃរំហូរចេញសាច់ប្រាក់ពិតប្រាកដនោះទេ។ កាលបរិច្ឆេទនៃចំណាយថវិកានេះត្រូវបានកំណត់ជាគោលដោយគណនេយ្យករសាធារណៈ និងជាមូលដ្ឋានសម្រាប់ការរាយការណ៍អំពីការអនុវត្តចំណាយថវិកានៃឆ្នាំអនុវត្តថវិកា។ ការកត់ត្រាចំណាយថវិកានៅក្នុងគណនេយ្យថវិកាត្រូវផ្អែកលើអាណត្តិបើកប្រាក់ អមដោយសក្ខីបត្រគាំទ្រ ដែលអាស្រ័យទៅតាមប្រភេទនិងមុខសញ្ញានៃចំណាយថវិកានីមួយៗ និងឯកសារទូទាត់ឬបង្វែរប្រាក់ ឬ ប្រកាសឥណពន្ធធនាគារ ឬ របាយការណ៍ធនាគារ ឬសក្ខីបត្រផ្សេងទៀត ដែលបញ្ជាក់អំពីការទូទាត់ប្រាក់ចេញពីគណនេយ្យករសាធារណៈ។ ប្រតិបត្តិការខាងលើនេះ ពុំនាំឱ្យមានភាពខុសគ្នារវាងតួលេខនៃការអនុវត្តចំណាយ ទាំងក្នុងគណនេយ្យថវិកានិងគណនេយ្យទូទៅនោះទេ។

**<u>បញ្ជាក់</u>៖** អាណាប័កត្រូវស្រូតរូតរៀបចំអាណត្តិបើកប្រាក់និយ័តកម្ម ដោយមានភ្ជាប់ជាមួយឯកសារគាំទ្រសម្រាប់ប្រតិបត្តិការចំណាយដែលកើតមាន រួចបញ្ជូនមកអ្នកត្រួតពិនិត្យថវិកា ស្របតាមបទប្បញ្ញត្តិជាធរមាន មុននឹងបញ្ជូនមកគណនេយ្យករសាធារណៈ ដើម្បីធ្វើការកត់ត្រាជម្រះឱ្យបានទាន់ពេល។

<u>ឧទាហរណ៍</u>៖

អំឡុងខែធ្នូ ឆ្នាំ២០២៣ នៅកម្ពុជាមានកើតជំងឺកាចសាហាវ ដែលទាមទារឱ្យមានវិធានការសុខាភិបាលបន្ទាន់ ដូចជាការទិញវ៉ាក់សាំង ការត្រៀមបម្រុងស្បៀងអាហារជួយឧបត្ថម្ភដល់ប្រជាពលរដ្ឋដែលត្រូវបិទខ្ទប់ ជាដើម។ ដោយសារតែព្រឹត្តិការណ៍កើតឡើងភ្លាមៗនិងបន្ទាន់ រាជរដ្ឋាភិបាល តាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រេចផ្តល់ប្រាក់មុនជូនក្រសួងសុខាភិបាលសម្រាប់យកទៅចំណាយបន្ទាន់នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៣ ទឹកប្រាក់ចំនួន ១០០ លានដុល្លារអាម៉េរិក និងត្រូវទូទាត់មកវិញ ដោយប្រើប្រាស់ឥណទានថវិកាឆ្នាំ២០២៤។ ក្រោយពីបានបំពេញបេសកកម្មការងារចប់សព្វគ្រប់ ក្រសួងសុខាភិបាលរៀបចំបោះផ្សាយអាណត្តិបើកប្រាក់ នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៤ សម្រាប់ធ្វើការទូទាត់ទឹកប្រាក់ដែលបានចំណាយមុនក្នុងឆ្នាំ២០២៣ ដោយប្រើប្រាស់ឥណទានថវិកាឆ្នាំ២០២៤។ អាណត្តិបើកប្រាក់អមដោយសក្ខីបត្រគាំទ្របានបញ្ជូនមកអ្នកត្រួតពិនិត្យថវិកា ដើម្បីពិនិត្យនិងទទួលបានទិដ្ឋាការ និងបញ្ជូនអាណត្តិបើកប្រាក់ មកគណនេយ្យករសាធារណៈ នៅថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២៤ ដើម្បីធ្វើការត្រួតពិនិត្យនិងទូទាត់។ ក្រោយពីបានពិនិត្យឃើញថាត្រឹមត្រូវ នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២៤ គណនេយ្យករសាធារណៈអនុម័តទទួលស្គាល់ជាចំណាយថវិកា នៅក្នុងគណនេយ្យថវិកា នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២៤។ រីឯ ការកត់ត្រានៅក្នុងគណនេយ្យទូទៅក៏ប្រព្រឹត្តទៅដូចគ្នាផងដែរ។

### ៤.២.២.៤ ប្រតិបត្តិការចំណូលព្រម-ចំណាយព្រម (ករណីទូទាត់រង្វាន់)

មុខសញ្ញាចំណាយមួយចំនួនត្រូវបានទូទាត់ជាមុនជាមួយនឹងសាច់ប្រាក់ចំណូលដែលប្រមូលបាន ដូចជាការទូទាត់ចំណាយប្រាក់រង្វាន់ ដែលប្រភពសាច់ប្រាក់ត្រូវបានកាត់ចេញពីការប្រមូលចំណូលផ្ទាល់តែម្តង។ ទោះបីជាមានការអនុញ្ញាតឱ្យប្រើប្រាស់សាច់ប្រាក់មុនសម្រាប់ការទូទាត់ប្រាក់រង្វាន់នេះ និងគ្មានវិហូរសាច់ប្រាក់ចូលនិងចេញពីគណនីធនាគារឬបេឡារបស់គណនេយ្យករសាធារណៈក៏ដោយ ក៏មុខសញ្ញាចំណូលនិងចំណាយថវិកាត្រូវធ្វើការកត់ត្រានិងបង្ហាញឱ្យបានពេញលេញនិងត្រឹមត្រូវទៅតាមព្រឹត្តិការណ៍សេដ្ឋកិច្ចដែលបានកើតឡើង ដើម្បីឆ្លុះបញ្ចាំងពីភាពត្រឹមត្រូវពិតប្រាកដ តម្លាភាព និងភាពគ្រប់ជ្រុងជ្រោយនៃព័ត៌មានហិរញ្ញវត្ថុ។ ក្នុងស្ថានភាពនេះ ទាំងចំណូលទាំងចំណាយត្រូវទទួលស្គាល់និងលាតត្រដាងក្នុងរបាយការណ៍ថវិកានិងហិរញ្ញវត្ថុរបស់រដ្ឋ។ ការទទួលស្គាល់ចំណូលថវិកាក្នុងករណីនេះត្រូវបានកំណត់ក្នុងចំណុចទី៤.១.២.៣ ខាងលើ។ រីឯប្រតិបត្តិការចំណាយក្នុងករណីនេះត្រូវបានកត់ត្រានិងទទួលស្គាល់ជាចំណាយថវិកានៃឆ្នាំអនុវត្តថវិកា នៅក្នុងគណនេយ្យថវិកា នៅពេលដែលប្រតិបត្តិការទាំងនោះ បំពេញតាមលក្ខខណ្ឌដូចខាងក្រោម៖

- មានវិហូរសាច់ប្រាក់ចូលនិងចេញពិតប្រាកដ នៅក្នុងឆ្នាំអនុវត្តថវិកា តាមរយៈរបាយការណ៍សាច់ប្រាក់ដែលមានការបញ្ជាក់ទទួលស្គាល់ដោយអាណាប័ក ប៉ុន្តែសាច់ប្រាក់ទាំងនេះពុំបានហូរចូល ឬ ហូរចេញពីគណនេយ្យករសាធារណៈទេ
- ព្រឹត្តិការណ៍ចំណាយពិតជាបានកើតមានឡើងនៅក្នុងឆ្នាំអនុវត្តថវិកា
- មានការបញ្ជាក់ទទួលស្គាល់អំពីមុខសញ្ញាចំណាយថវិកាដោយអាណាប័ក និង
- មានការត្រួតពិនិត្យផ្ទៀងផ្ទាត់ភាពត្រឹមត្រូវលើចំណូលថវិកានិងចំណាយថវិកាដោយគណនេយ្យករសាធារណៈស្របតាមខ្លឹមសារនៃមាត្រា២៧និងមាត្រា២៨នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ។

ក្នុងករណីដែលអាណាប័កអាចបញ្ជូនអាណត្តិបើកប្រាក់និងឯកសារគាំទ្រចំណាយ និងអាចបញ្ជាក់ទទួលស្គាល់ជាចំណាយថវិកា ព្រមជាមួយនឹងសលាកបត្របង្វែរចំណូល ដើម្បីទទួលស្គាល់ជាចំណូលថវិកាទន្ទឹមគ្នា យ៉ាងយូរត្រឹមកាលបរិច្ឆេទបញ្ចប់រយៈពេលបំពេញបន្ថែម (ត្រឹមថ្ងៃទី៣១ ខែមករា ឆ្នាំបន្ទាប់) គណនេយ្យករសាធារណៈត្រូវកត់ត្រាទទួលស្គាល់ចំណូលនិងចំណាយថវិកានោះទៅតាមប្រភេទនិងមុខសញ្ញានៃចំណូលនិងចំណាយថវិកានីមួយៗ ដោយផ្អែកលើចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការដ្ឋ នៅក្នុងគណនេយ្យថវិកា និងប្រព័ន្ធ FMIS ដោយកំណត់យកតាមថ្ងៃខែឆ្នាំនៃអាណត្តិបើកប្រាក់និងសលាកបត្របង្វែរចំណូល គឺពុំអាស្រ័យទៅនឹងថ្ងៃខែឆ្នាំនៃវិហូរសាច់ប្រាក់ចូលឬចេញពិតប្រាកដនោះទេ។ កាលបរិច្ឆេទនៃចំណូលនិងចំណាយថវិកានេះត្រូវបានកំណត់ជាគោលដោយគណនេយ្យករសាធារណៈ និងជាមូលដ្ឋានសម្រាប់ការរាយការណ៍អំពីការអនុវត្តចំណូលនិងចំណាយថវិកានៃឆ្នាំអនុវត្តថវិកា។

ក្នុងករណីដែលអាណាប័កមិនអាចបញ្ជូនអាណត្តិបើកប្រាក់និងឯកសារគាំទ្រចំណាយ និងមិនអាចបញ្ជាក់ទទួលស្គាល់ជាចំណាយថវិកា ព្រមជាមួយនឹងសលាកបត្របង្វែរចំណូល ដើម្បីទទួលស្គាល់ជាចំណូលថវិកាទន្ទឹមគ្នា យ៉ាងយូរត្រឹមកាលបរិច្ឆេទបញ្ចប់រយៈពេលបំពេញបន្ថែម (ត្រឹមថ្ងៃទី៣១ ខែមករា ឆ្នាំបន្ទាប់) ទោះបីជាសាច់ប្រាក់ចំណូល-ចំណាយ និងព្រឹត្តិការណ៍ចំណូល-ចំណាយបានកើតឡើងក្នុងឆ្នាំអនុវត្តថវិកាក៏ដោយ ក៏គណនេយ្យករសាធារណៈត្រូវកត់ត្រាទទួលស្គាល់ជាចំណូលនិងចំណាយថវិកាទាំងនោះនៅឆ្នាំបន្ទាប់ ដោយប្រើប្រាស់ចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការដ្ឋ នៅក្នុងគណនេយ្យថវិកា និងប្រព័ន្ធ FMIS ដោយកំណត់យកតាមថ្ងៃខែឆ្នាំនៃសលាកបត្របង្វែរចំណូល និងអាណត្តិបើកប្រាក់ គឺពុំអាស្រ័យទៅនឹងថ្ងៃខែឆ្នាំនៃវិហូរសាច់ប្រាក់ចូលឬចេញពិតប្រាកដនោះទេ។ ស្ថានភាពនេះនាំឱ្យគណនេយ្យករសាធារណៈកត់ត្រាចំណូលនិងចំណាយថវិកាលើការទូទាត់ប្រាក់រង្វាន់នៅឆ្នាំបន្ទាប់។ កាលបរិច្ឆេទនៃចំណូលនិងចំណាយថវិកានេះត្រូវបានកំណត់ជាគោលដោយគណនេយ្យករសាធារណៈ និងជាមូលដ្ឋានសម្រាប់ការរាយការណ៍អំពីការអនុវត្តចំណូលនិងចំណាយថវិកានៃឆ្នាំអនុវត្តថវិកា។

ប្រតិបត្តិការចំណូលព្រម-ចំណាយព្រម (ករណីវង្វាន់) នេះ នឹងនាំឱ្យមានការកត់ត្រាចំណូលនិងចំណាយ និងរបាយការណ៍ដូចគ្នា ទាំងនៅក្នុងគណនេយ្យថវិកានិងគណនេយ្យទូទៅ។

**<u>បញ្ជាក់</u>៖** អាណាប័កត្រូវទទួលខុសត្រូវក្នុងការរៀបចំឯកសារសម្រាប់កំណត់មុខសញ្ញាចំណូលថវិកានិងចំណាយថវិកា ឱ្យបានទាន់ពេល នៃព្រឹត្តិការណ៍ចំណូលនិងចំណាយដែលបានកើតមានឡើងជាក់ស្តែងនៅក្នុងឆ្នាំអនុវត្តថវិកា។ ការណ៍នេះធានាបាននូវភាពត្រឹមត្រូវនិងពិតប្រាកដនៃព្រឹត្តិការណ៍ ព្រមទាំងអាចឆ្លុះបញ្ចាំងបានត្រឹមត្រូវនៅក្នុងការអនុវត្តថវិកា ដោយគោរពតាមគោលការណ៍ប្រចាំឆ្នាំនៃថវិកា។

<u>ឧទាហរណ៍</u>៖

នៅថ្ងៃទី៥ ខែមករា ឆ្នាំ២០២៣ ក្រសួងរ៉ែនិងថាមពលបានបោះផ្សាយអាណត្តិបើកប្រាក់និយ័តកម្មទូទាត់ប្រាក់វង្វាន់ ប្រចាំឆ្នាំ២០២២ និងសលាកបត្របង្វែរចំណូល ដោយមានភ្ជាប់សក្ខីបត្រគាំទ្រ មានទឹកប្រាក់សរុបចំនួន ៣០០ លានរៀល រួចបញ្ជូនមកអ្នកត្រួតពិនិត្យថវិកា ដើម្បីទទួលបានទិដ្ឋាការ។ អាណត្តិបើកប្រាក់និយ័តកម្មនិងសលាកបត្របង្វែរចំណូល បានបញ្ជូនមកគណនេយ្យករសាធារណៈ ដើម្បីធ្វើការត្រួតពិនិត្យនិងទូទាត់ នៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៣។ ក្រោយពីពិនិត្យត្រឹមត្រូវ គណនេយ្យករសាធារណៈអនុម័តទទួលស្គាល់ជាចំណាយថវិកា នៅក្នុងគណនេយ្យថវិកា នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ចំពោះទឹកប្រាក់ទូទាត់វង្វាន់ ចំនួន ៣០០ លានរៀល។

### ៤.២.២.៥ ការកាត់ពន្ធលើអាណត្តិបើកប្រាក់

មុខសញ្ញាចំណាយមួយចំនួនត្រូវធ្វើការទូទាត់ដោយរួមបញ្ចូលនូវប្រាក់ពន្ធ អាស្រ័យទៅតាមការកំណត់ដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ដែលគណនេយ្យករសាធារណៈត្រូវធ្វើការកាត់ពន្ធទុក សម្រាប់ការទទួលស្គាល់ជាចំណូលថវិកា ដូចមានកំណត់ក្នុងចំណុចទី៤.១.២.៤ ដូចជាអាណត្តិបើកប្រាក់បៀវត្ស ឬ ការទូទាត់ជូនអ្នកផ្គត់ផ្គង់។ ក្នុងករណីនេះ ចំនួនប្រាក់ពន្ធដែលត្រូវទូទាត់តាមរយៈអាណត្តិបើកប្រាក់ ពុំបានបើកផ្តល់ជាសាច់ប្រាក់ទៅអ្នកជាប់ពន្ធនោះទេ ប៉ុន្តែប្រតិបត្តិការនេះត្រូវទទួលស្គាល់ជាចំណាយថវិកានៃឆ្នាំអនុវត្តថវិកាដែរ ទោះបីជាពុំមានសាច់ប្រាក់ចេញពិតប្រាកដពីគណនេយ្យករសាធារណៈក៏ដោយ ដោយសារតែប្រតិបត្តិការទាំងនេះមានលក្ខណៈ ដូចខាងក្រោម៖

- មានការអនុញ្ញាតដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តឱ្យគណនេយ្យករសាធារណៈអាចធ្វើការកាត់ពន្ធទុកមុនសម្រាប់ការបង្វែរជាចំណូលថវិកា
- មុខសញ្ញាចំណាយថវិកា ត្រូវបានកំណត់ច្បាស់លាស់ និងមានការបញ្ជាក់ទទួលស្គាល់ពីអាណាប័ក គិតត្រឹមដំណាច់រយៈពេលបំពេញបន្ថែម (យ៉ាងយូរបំផុតត្រឹមថ្ងៃទី៣១ ខែមករា ឆ្នាំបន្ទាប់) និង
- មានការត្រួតពិនិត្យផ្ទៀងផ្ទាត់ភាពត្រឹមត្រូវដោយគណនេយ្យករសាធារណៈ ស្របតាមខ្លឹមសារនៃមាត្រា២៧និងមាត្រា២៨នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ។

ការកត់ត្រាចំណាយថវិកានូវចំនួនប្រាក់ពន្ធ ដើម្បីទទួលស្គាល់ជាចំណូលថវិកា នៅក្នុងគណនេយ្យថវិកា និងប្រព័ន្ធ FMIS ត្រូវផ្អែកលើអាណត្តិបើកប្រាក់ អមដោយសក្ខីបត្រគាំទ្រ ដោយប្រើប្រាស់ចំណាត់ថ្នាក់សេដ្ឋកិច្ច (ផ្នែកមាតិកាចំណាយថវិកា) នៃមាតិកាថវិការដ្ឋ ដោយកំណត់យកតាមថ្ងៃខែឆ្នាំនៃការបើកផ្តល់ប្រាក់លើអាណត្តិបើកប្រាក់។ កាលបរិច្ឆេទនៃចំណាយថវិកាលើប្រាក់ពន្ធនេះត្រូវបានកំណត់ជាគោលដោយគណនេយ្យករសាធារណៈ និងជាមូលដ្ឋានសម្រាប់ការរាយការណ៍អំពីការអនុវត្តចំណាយថវិកានៃឆ្នាំអនុវត្តថវិកា។

ប្រតិបត្តិការប្រភេទនេះនឹងនាំឱ្យមានការកត់ត្រាចំណាយថវិកា និងរបាយការណ៍ដូចគ្នា ទាំងនៅក្នុងគណនេយ្យថវិកានិងគណនេយ្យទូទៅ។

**<u>បញ្ជាក់</u>៖** គណនេយ្យករសាធារណៈត្រូវកាត់ប្រាក់ពន្ធលើសំណើសុំទូទាត់ ក្នុងទំហំទឹកប្រាក់ពេញ (មិនគណនាតាមសមាមាត្រនៃទឹកប្រាក់បើកផ្តល់) តាមអត្រាកំណត់ដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ដើម្បីបង្វែរជាចំណូលបណ្តោះអាសន្ន រង់ចាំកំណត់មុខសញ្ញាជាចំណូលថវិកា។

ឧទាហរណ៍ទី១៖ អាណត្តិបើកប្រាក់បៀវត្សមន្ត្រីរាជការស៊ីវិល

នៅថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២៣ ក្រសួងទេសចរណ៍បានបោះផ្សាយអាណត្តិបើកប្រាក់បៀវត្ស ប្រចាំខែធ្នូ មានទឹកប្រាក់សរុបចំនួន ៨៥០ លានរៀល មានភ្ជាប់ព័ត៌មានប្រាក់កាត់ពន្ធលើមន្ត្រីរាជកាស៊ីវិលចំនួន ៤,៥៦០,០០០ រៀល រួចបញ្ជូនមកអ្នកត្រួតពិនិត្យថវិកា ដើម្បីទទួលបានទិដ្ឋាការ រួចបញ្ជូនអាណត្តិបើកប្រាក់មកគណនេយ្យករសាធារណៈ ដើម្បីធ្វើការត្រួតពិនិត្យ កាត់ពន្ធ និងបើកផ្តល់ជូនមន្ត្រីរាជការ នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៣។

- ការទទួលស្គាល់ចំណាយថវិកាក្នុងឆ្នាំថវិកា២០២៣ ចំនួន ៨៥០,០០០,០០០រៀល
- ចំណូលថវិកាពីការដកហូតពន្ធបៀវត្សក្នុងឆ្នាំថវិកា២០២៣ ចំនួន ៤,៥៦០,០០០រៀល
- ចំណាយជាសាច់ប្រាក់បើកផ្តល់ជូនមន្ត្រីរាជការ ចំនួន ៨៤៥,៤០០,០០០រៀល។

គណនេយ្យករសាធារណៈកត់ត្រាទទួលស្គាល់ជាចំណាយថវិកានូវទឹកប្រាក់ពេញ រួមបញ្ចូលទាំងប្រាក់ពន្ធដែលត្រូវបង្វែរជាចំណូលថវិការដ្ឋ នៅក្នុងគណនេយ្យថវិកា។

ឧទាហរណ៍ទី២៖ អាណត្តិបើកប្រាក់អ្នកផ្គត់ផ្គង់ខាងក្រៅជាប់កាតព្វកិច្ច

នៅថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២៣ ក្រសួងព័ត៌មានបានបោះផ្សាយអាណត្តិបើកប្រាក់ទូទាត់ជូនក្រុមហ៊ុន ABC ដែលបានផ្គត់ផ្គង់ម៉ាស៊ីនបំពងសំលេងចំនួន១០គ្រឿង មានទឹកប្រាក់សរុបចំនួន ៤៤០ លានរៀល ដោយមានភ្ជាប់លិខិតយុត្តិការចំណាយ ដែលបញ្ជាក់ថាក្រុមហ៊ុន ABC ជាក្រុមហ៊ុនជាប់កាតព្វកិច្ចអ្នកបង់ពន្ធធំ រួចបញ្ជូនមកអ្នកត្រួតពិនិត្យថវិកា ដើម្បីទទួលបានទិដ្ឋាការ រួចបញ្ជូនអាណត្តិបើកប្រាក់មកគណនេយ្យករសាធារណៈ ដើម្បីធ្វើការត្រួតពិនិត្យ កាត់ពន្ធ និងបើកផ្តល់ជូនក្រុមហ៊ុន នៅថ្ងៃទី៥ ខែមករា ឆ្នាំ២០២៤។

- ការទទួលស្គាល់ចំណាយថវិកាក្នុងឆ្នាំថវិកា២០២៣ ចំនួន ៤៤០,០០០,០០០រៀល
- ចំណូលថវិកា ពីការកាត់ទុកពន្ធVAT ក្នុងឆ្នាំថវិកា២០២៣ ចំនួន ៤០,០០០,០០០រៀល
- ចំណាយជាសាច់ប្រាក់បើកជូនក្រុមហ៊ុន ABC ចំនួន ៤០០,០០០,០០០រៀល។

គណនេយ្យករសាធារណៈកត់ត្រាទទួលស្គាល់ជាចំណាយថវិកានូវទឹកប្រាក់ពេញ រួមបញ្ចូលទាំងប្រាក់ពន្ធ ដែលត្រូវបង្វែរជាចំណូលថវិការដ្ឋ នៅក្នុងគណនេយ្យថវិកា។

### ៤.២.២.៦ ការទូទាត់ទឹកប្រាក់តម្កល់ធានាសុពលភាព

ផ្អែកតាមគោលការណ៍និងបទប្បញ្ញត្តិជាធរមាន និងកិច្ចសន្យា ក្រោយបញ្ចប់ការងារផ្គត់ផ្គង់ទំនិញ ការងារសាងសង់ជួសជុល និងសេវាកម្មដែលអនុវត្តដោយអង្គភាពរដ្ឋ គណនេយ្យករសាធារណៈត្រូវធ្វើការទូទាត់ជូនអង្គភាពរដ្ឋនោះ នូវទឹកប្រាក់១០០%នៃតម្លៃកិច្ចសន្យា ចំពោះករណីការអនុវត្តចំណាយថវិកាចរន្ត និងចំពោះករណីការអនុវត្តចំណាយថវិកាមូលធន ត្រូវទូទាត់ទឹកប្រាក់៩០%នៃតម្លៃកិច្ចសន្យា និងទូទាត់១០%ទៀត ក្រោយផុតរយៈពេលធានាសុពលភាព និងបានគោរពតាមលក្ខខណ្ឌតម្រូវនានានៃកិច្ចសន្យា។ ចំពោះចំណាយថវិកាចរន្ត អង្គភាពរដ្ឋមិនតម្រូវឱ្យមានប្រាក់តម្កល់ធានាសុពលភាពនោះទេ។ ក្នុងដំណាក់កាលធានាសុពលភាពដែលត្រូវមានការពិនិត្យវាយតម្លៃចុងក្រោយដោយគណៈកម្មការអន្តរក្រសួង អង្គភាពរដ្ឋជាអ្នកទទួលការត្រូវទទួលខុសត្រូវលើការធានាសុពលភាពនេះ។ ករណីអង្គភាពរដ្ឋណាមិនអនុវត្តការកិច្ចទទួលខុសត្រូវនៅដំណាក់កាលធានាសុពលភាពនេះ នោះនឹងទទួលរងវិធានការផ្នែករដ្ឋបាល ឬវិធានការផ្សេងទៀត ស្របតាមបទប្បញ្ញត្តិជាធរមាន។ រីឯ ករណីការអនុវត្តថវិកាមូលធន ដោយសារតែការទូទាត់សាច់ប្រាក់ប្រព្រឹត្តទៅជា២ដំណាក់ គឺដំណាក់ទី១ ទឹកប្រាក់៩០% និងដំណាក់ទី២ ទឹកប្រាក់១០% សម្រាប់ទូទាត់ប្រាក់ធានាសុពលភាព ការទទួលស្គាល់ជាចំណាយថវិកានៃប្រតិបត្តិការប្រភេទនេះត្រូវធ្វើជា២ដំណាក់ដូចគ្នា ដោយដំណាក់ទី១ គឺការស្នើសុំទូទាត់ប្រាក់និងទទួលស្គាល់ជាចំណាយថវិកា ចំនួន៩០% រីឯ ដំណាក់ទី២ គឺទឹកប្រាក់ធានាសុពលភាព១០% ទៀត។ ការណ៍នេះធ្វើឱ្យការគ្រោងឥណទានចំណាយថវិកាមូលធន និងការបោះផ្សាយអាណត្តិបើកប្រាក់ ត្រូវធ្វើឡើងចំនួន២លើកដូចគ្នា។ ប្រតិបត្តិការទូទាត់ទឹកប្រាក់តម្កល់ធានាសុពលភាព១០%នេះត្រូវទទួលស្គាល់ជាចំណាយថវិកានៃឆ្នាំបន្ទាប់ ដោយសារតែប្រតិបត្តិការនេះមានលក្ខណៈ ដូចខាងក្រោម៖

- រំហូរសាច់ប្រាក់ចេញសម្រាប់ទូទាត់ប្រាក់តម្កល់ធានាសុពលភាព ពីគណនេយ្យករសាធារណៈ កើតមានឡើង នៅក្នុងឆ្នាំបន្ទាប់
- ព្រឹត្តិការណ៍ដែលនាំឱ្យកើតមានការទូទាត់ប្រាក់តម្កល់ធានាសុពលភាពនេះ ពិតជាបានកើតឡើង
- មុខសញ្ញាចំណាយថវិកា ត្រូវបានកំណត់ច្បាស់លាស់ និងមានការបញ្ជាក់ទទួលស្គាល់ពីអាណាប័ក គិតត្រឹម កាលបរិច្ឆេទបញ្ចប់រយៈពេលបំពេញបន្ថែម និង
- មានការត្រួតពិនិត្យផ្ទៀងផ្ទាត់ភាពត្រឹមត្រូវដោយគណនេយ្យករសាធារណៈ ស្របតាមខ្លឹមសារនៃមាត្រា២៧ និងមាត្រា២៨នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ។

ការកត់ត្រាប្រតិបត្តិការប្រាក់តម្កល់ធានាសុពលភាពជាចំណាយថវិកានៅក្នុងគណនេយ្យថវិកា និងប្រព័ន្ធ FMIS ត្រូវផ្អែកលើអាណត្តិបើកប្រាក់ អមដោយសក្ខីបត្រគាំទ្រ ដោយប្រើប្រាស់ចំណាត់ថ្នាក់សេដ្ឋកិច្ច (ផ្នែកមាតិកាចំណាយថវិកា) នៃមាតិកាថវិការដ្ឋ ដោយកំណត់យកតាមថ្ងៃខែឆ្នាំនៃការបើកប្រាក់តម្កល់ធានាសុពលភាពជូនអង្គភាពរដ្ឋ។ កាលបរិច្ឆេទនៃចំណាយថវិកានេះត្រូវបានកំណត់ជាគោលដោយគណនេយ្យករសាធារណៈ និងជាមូលដ្ឋានសម្រាប់ការរាយការណ៍អំពីការអនុវត្តចំណាយថវិកានៃឆ្នាំអនុវត្តថវិកា។ ការកត់ត្រានៅក្នុងគណនេយ្យទូទៅ មូលដ្ឋានបង្ករ ចំពោះប្រតិបត្តិការនេះនឹងមានកំណត់ដោយឡែក តាមរយៈប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយអនុលោមតាមស្តង់ដាគណនេយ្យសាធារណៈកម្ពុជា។

<u>**បញ្ជាក់៖**</u>

- ការគ្រោងឥណទានទូទាត់ចំណាយថវិកាមូលធន ត្រូវធ្វើជា២ជំហាន គឺជំហានទី១ ទុកសម្រាប់ទូទាត់ចំណាយថវិកាទឹកប្រាក់៩០% និងជំហានទី២ ទុកសម្រាប់ទូទាត់ប្រាក់តម្កល់ធានាសុពលភាព១០%។
- អាណត្តិបើកប្រាក់ជូនអង្គភាពរដ្ឋ ត្រូវធ្វើជា២ដំណាក់កាល ទៅតាមការស្នើសុំបើកប្រាក់។

ចំពោះការផ្គត់ផ្គង់ទំនិញនិងសេវាកម្មដោយក្រុមហ៊ុនឯកជន ប្រាក់តម្កល់ធានាសុពលភាពការងារ ត្រូវអនុវត្តតាមយន្តការប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា។ ដូច្នេះ កិច្ចសន្យាផ្គត់ផ្គង់ទំនិញនិងសេវាកម្មដោយក្រុមហ៊ុនឯកជន មិនតម្រូវឱ្យមានប្រាក់តម្កល់ធានាសុពលភាព១០%ទេ។ អាណាប័កត្រូវស្នើសុំទូទាត់១០០%នៃទឹកប្រាក់ក្នុងកិច្ចសន្យាតាមរយៈអាណត្តិបើកប្រាក់និងសក្ខីបត្រគាំទ្រ ស្របតាមបទប្បញ្ញត្តិជាធរមាន ហើយគណនេយ្យករសាធារណៈត្រូវទូទាត់ទឹកប្រាក់ពេញនៃការស្នើសុំទូទាត់។ ដោយឡែក ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា ត្រូវប្រគល់ជូនអ្នកផ្គត់ផ្គង់វិញ ក្រោយផុតរយៈពេលធានាសុពលភាពនិងបានគោរពតាមលក្ខខណ្ឌតម្រូវនានានៃកិច្ចសន្យា។

<u>ឧទាហរណ៍៖</u>

នាយកដ្ឋានផ្លូវថ្នល់(អគ្គនាយកដ្ឋានបច្ចេកទេស) នៃក្រសួងសាធារណការនិងដឹកជញ្ជូន ទទួលបានកិច្ចសន្យាជួលជុលផ្លូវលំមួយខ្សែ ដែលមានតម្លៃ ១០០ លានរៀល ក្នុងឃុំស៊ីធរ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល។ ផ្អែកតាមកិច្ចសន្យា ក្រោយការជួសជុលផ្លូវលំចប់សព្វគ្រប់ នាយកដ្ឋានអាចស្នើសុំទូទាត់ថវិកាពីសាលាខេត្តកណ្ដាល និងត្រូវទទួលការទូទាត់ចំនួន៩០%នៃតម្លៃព្រមព្រៀងគ្នា រីឯការទូទាត់១០%ទៀត នឹងត្រូវធ្វើឡើងក្រោយបញ្ចប់ការធានាសុពលភាពលើផ្លូវលំដែលបានជួសជុល។ នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៣ នាយកដ្ឋានផ្លូវថ្នល់បានបញ្ចប់ការដ្ឋានជាស្ថាពរ និងបានស្នើសុំការទូទាត់ថវិកាពីសាលាខេត្ត។ នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៣ សាលាខេត្តកណ្ដាលបានបោះផ្សាយអាណត្តិបើកប្រាក់ ទឹកប្រាក់ចំនួន ៩០ លានរៀល និងបានបញ្ជូនឯកសារទៅអ្នកត្រួតពិនិត្យថវិកា មុននឹងបញ្ជូនទៅគណនេយ្យកររតនាគារខេត្តកណ្ដាល ដើម្បីពិនិត្យនិងបើកផ្ដល់។ នៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្រោយពីបានពិនិត្យត្រឹមត្រូវ គណនេយ្យកររតនាគារខេត្តកណ្ដាល ត្រូវទូទាត់ប្រាក់ទៅនាយកដ្ឋានផ្លូវថ្នល់ ចំនួន ៩០ លានរៀល និងត្រូវទទួលស្គាល់ជាចំណាយថវិកា អនុគណនីលេខ២១០៤១។ នៅក្នុងឆ្នាំ២០២៤ខាងមុខ នៅពេលបញ្ចប់ធានាសុពលភាព សាលាខេត្តកណ្ដាលនឹងស្នើសុំទូទាត់ប្រាក់១០% តាមរយៈអាណត្តិបើកប្រាក់ ដែលជាទឹកប្រាក់តម្កល់ធានាសុពលភាពជូន

នាយកដ្ឋានផ្លូវថ្នល់ ហើយគណនេយ្យករសាធារណៈត្រូវទទួលស្គាល់ទឹកប្រាក់១០% នេះជាចំណាយថវិកាដែលពាក់ព័ន្ធនឹងការជួសជុលផ្លូវលំខាងលើ និងបើកផ្ដល់សាច់ប្រាក់ជូនអ្នកផ្គត់ផ្គង់។

**៤.២.២.៧ ចំណាយឧបត្ថម្ភធនទៅរដ្ឋបាលផ្សេងៗ**

ប្រតិបត្តិការចំណាយឧបត្ថម្ភធនទៅរដ្ឋបាលសាធារណៈផ្សេងៗ ត្រូវបានកត់ត្រានិងទទួលស្គាល់ជាចំណាយថវិកាលើការឧបត្ថម្ភធនក្នុងឆ្នាំអនុវត្តថវិកា នៅក្នុងគណនេយ្យថវិកា ទោះបីជាពុំមានចលនាសាច់ប្រាក់ចេញពីគណនីធនាគារឬបេឡារបស់គណនេយ្យករសាធារណៈនៃរដ្ឋបាលផ្ដល់ឧបត្ថម្ភធនទាំងនោះក៏ដោយ។ ការឧបត្ថម្ភធននេះត្រូវបានចាត់ទុកជាសាច់ប្រាក់ប្រហាក់ប្រហែលរបស់រដ្ឋបាលសាធារណៈបានចំណាយទៅឱ្យរដ្ឋបាលផ្សេងទៀតសម្រាប់យកទៅប្រើប្រាស់ឬទទួលស្គាល់ជាចំណូលថវិការបស់ខ្លួន ដើម្បីធានាដល់ការចំណាយថវិកា ដែលប្រភពចំណូលទាំងនេះនឹងរក្សាទុកនៅក្នុងគណនីប្រាក់បញ្ញើរបស់រដ្ឋបាលសាធារណៈទទួលឧបត្ថម្ភធន។ ការទទួលស្គាល់ជាចំណូលថវិការបស់រដ្ឋបាលសាធារណៈទទួលឧបត្ថម្ភធន មានកំណត់ក្នុងចំណុចទី៤.១.២.៥។ ក្នុងន័យនេះ ប្រតិបត្តិការចំណាយឧបត្ថម្ភធនទៅរដ្ឋបាលសាធារណៈ ត្រូវចាត់ទុកជាចំណាយថវិកានៃឆ្នាំអនុវត្តថវិកា ដោយសារតែះ

- មានការបោះផ្សាយអាណត្តិបើកប្រាក់ឧបត្ថម្ភធនទៅរដ្ឋបាលទទួលនៅក្នុងឆ្នាំអនុវត្តថវិកា ដោយអាណាប័កជាអ្នកផ្ដល់ឱ្យ និង
- មានការត្រួតពិនិត្យផ្ទៀងផ្ទាត់ភាពត្រឹមត្រូវលើចំណាយឧបត្ថម្ភធនដោយគណនេយ្យករសាធារណៈ ស្របតាមខ្លឹមសារនៃមាត្រា២៧និងមាត្រា២៨នៃអនុក្រឹត្យស្ដីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ។

គណនេយ្យករសាធារណៈត្រូវកត់ត្រាទទួលស្គាល់ចំណាយថវិកានេះ ទៅតាមប្រភេទនិងមុខសញ្ញានៃចំណាយថវិកាឧបត្ថម្ភធននីមួយៗ ដោយផ្អែកលើចំណាត់ថ្នាក់សេដ្ឋកិច្ច (ផ្នែកមាតិកាចំណាយថវិកា) នៃមាតិកាថវិការដ្ឋ នៅក្នុងគណនេយ្យថវិកា និងប្រព័ន្ធ FMIS ដោយកំណត់យកតាមថ្ងៃខែឆ្នាំនៃការបញ្ចូលប្រាក់ឧបត្ថម្ភធនចូលក្នុងគណនីប្រាក់បញ្ញើរបស់អង្គភាពទទួលឧបត្ថម្ភធន។ ក្នុងករណីដែលមានការបង្វែរជាសាច់ប្រាក់ឧបត្ថម្ភចេញពីគណនេយ្យករសាធារណៈ ការកត់ត្រាទទួលស្គាល់ជាចំណាយថវិកាត្រូវយកតាមថ្ងៃខែឆ្នាំនៃរំហូរសាច់ប្រាក់ចេញពិតប្រាកដរបស់គណនេយ្យករសាធារណៈ។ កាលបរិច្ឆេទនៃចំណាយថវិកានេះត្រូវបានកំណត់ជាគោលដោយគណនេយ្យករសាធារណៈ និងជាមូលដ្ឋានសម្រាប់ការរាយការណ៍អំពីការអនុវត្តចំណាយថវិកានៃឆ្នាំអនុវត្តថវិកា។

ប្រតិបត្តិការចំណាយឧបត្ថម្ភធននេះ នឹងនាំឱ្យមានការកត់ត្រាចំណាយនិងរបាយការណ៍ដូចគ្នា ទាំងនៅក្នុងគណនេយ្យថវិកានិងគណនេយ្យទូទៅ។

<u>បញ្ជាក់</u>៖ ប្រតិបត្តិការខាងលើនេះត្រូវអនុវត្តនៅក្នុងឆ្នាំថវិកានីមួយៗ ដោយមានការអនុញ្ញាតជារយៈពេលបំពេញបន្ថែម យ៉ាងយូរត្រឹមថ្ងៃទី៣១ ខែមករា នៃឆ្នាំបន្ទាប់។ ក្នុងករណីដែលប្រតិបត្តិការខាងលើនេះអនុវត្តនៅក្នុងរយៈពេលបំពេញបន្ថែម ការកត់ត្រាទទួលស្គាល់ជាចំណាយថវិកាត្រូវកំណត់យកថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំអនុវត្តថវិកា។

<u>ឧទាហរណ៍</u>៖

នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២៣ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបោះផ្សាយអាណត្តិបើកប្រាក់ឧបត្ថម្ភតុល្យភាពត្រីមាសទី៤ ឆ្នាំ២០២៣ ជូនសាលាខេត្តកំពត ដែលមានទឹកប្រាក់ចំនួន ២ ប៊ីលានរៀល រួចបានបញ្ជូនឯកសារមកអ្នកត្រួតពិនិត្យថវិកា ដើម្បីពិនិត្យនិងផ្ដល់ទិដ្ឋាការ។ នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៣ អាណត្តិបើកប្រាក់បានបញ្ជូនបន្តមកគណនេយ្យករសាធារណៈ ដើម្បីធ្វើការត្រួតពិនិត្យនិងបង្វែរថវិកាទៅសាលាខេត្តកំពត។ ក្រោយពីបានពិនិត្យត្រឹមត្រូវគណនេយ្យកររតនាគារកណ្ដាលបានបញ្ជូនថវិកាទៅរតនាគារខេត្តកំពត ដើម្បីឱ្យគណនេយ្យកររតនាគារខេត្តកំពតកត់ត្រាចូលទៅក្នុងគណនីប្រាក់បញ្ញើរបស់សាលាខេត្តកំពតនៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២៣។ ទន្ទឹមនេះ គណនេយ្យកររតនាគារទទួលបន្ទុកសាលាខេត្តកំពតនឹងកត់ត្រាចូលគណនីប្រាក់បញ្ញើរបស់សាលាខេត្តកំពត នៅរតនាគារ និងទទួលស្គាល់ជាចំណូលថវិកាឧបត្ថម្ភពីថវិការដ្ឋ។

តាមរយៈឧទាហរណ៍ខាងលើនេះ គណនេយ្យករធនាគារកណ្ដាលត្រូវទទួលស្គាល់ជាចំណាយថវិកា នៅក្នុងគណនេយ្យថវិកា ចំនួនទឹកប្រាក់ ២ប៊ី លានរៀល នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២៣។ រីឯការកត់ត្រានៅក្នុងគណនេយ្យទូទៅ គណនេយ្យករធនាគារកណ្ដាលត្រូវទទួលស្គាល់ជាចំណាយ នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២៣។

### ៤.២.២.៨ ការទូទាត់ចំណាយចូលគណនីប្រាក់បញ្ញើ

ប្រតិបត្តិការចំណាយមួយចំនួនត្រូវធ្វើការទូទាត់ជូនអត្ថគាហកៈដែលមានគណនីប្រាក់បញ្ញើនៅរតនាគារ។ គណនេយ្យករសាធារណៈត្រូវបានកត់ត្រាទទួលស្គាល់ជាចំណាយថវិកានៃឆ្នាំអនុវត្តថវិកា នៅក្នុងគណនេយ្យថវិកា និងប្រព័ន្ធ FMIS ទោះបីជាពុំមានលំហូរសាច់ប្រាក់ចេញពិតប្រាកដពីគណនេយ្យករសាធារណៈ ដោយសារតែប្រតិបត្តិការនេះបំពេញតាមលក្ខខណ្ឌ ដូចខាងក្រោម៖

- មានលំហូរសាច់ប្រាក់ចូលពិតប្រាកដ ទៅក្នុងគណនីប្រាក់បញ្ញើ នៅក្នុងឆ្នាំអនុវត្តថវិកា
- ព្រឹត្តិការណ៍ចំណាយពិតជាបានកើតមានឡើង នៅក្នុងឆ្នាំអនុវត្តថវិកា
- មានការបញ្ជាក់ទទួលស្គាល់អំពីមុខសញ្ញាចំណាយថវិកាដោយអាណាប័ក និង
- មានការត្រួតពិនិត្យផ្ទៀងផ្ទាត់ភាពត្រឹមត្រូវដោយគណនេយ្យករសាធារណៈ ស្របតាមខ្លឹមសារនៃមាត្រា២៧ និងមាត្រា២៨នៃអនុក្រឹត្យស្ដីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ។

ផ្អែកលើអាណត្តិបើកប្រាក់ និងឯកសារគាំទ្រចំណាយថវិកាដែលត្រូវប្រគល់ឱ្យយ៉ាងយូរបំផុតត្រឹមកាលបរិច្ឆេទបញ្ចប់រយៈពេលបំពេញបន្ថែម គណនេយ្យករសាធារណៈត្រូវកត់ត្រាទទួលស្គាល់ចំណាយថវិកានេះទៅតាមប្រភេទនិងមុខសញ្ញានៃចំណាយថវិកានីមួយៗ ដោយផ្អែកលើចំណាត់ថ្នាក់សេដ្ឋកិច្ច (ផ្នែកមាតិកាចំណាយថវិកា) នៃមាតិកាថវិការដ្ឋ នៅក្នុងគណនេយ្យថវិកា និងប្រព័ន្ធ FMIS ដោយកំណត់យកតាមថ្ងៃខែឆ្នាំនៃលំហូរសាច់ប្រាក់ចូលពិតប្រាកដក្នុងគណនីប្រាក់បញ្ញើ (ករណីមុនរយៈពេលបំពេញបន្ថែម) ឬ កំណត់យកថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំអនុវត្តថវិកា (ករណីអំឡុងពេលបំពេញបន្ថែម)។ កាលបរិច្ឆេទនៃចំណាយថវិកានេះត្រូវបានកំណត់ជាគោលដោយគណនេយ្យករសាធារណៈ និងជាមូលដ្ឋានសម្រាប់ការរាយការណ៍អំពីការអនុវត្តចំណាយថវិកាប្រភេទនេះ នៅក្នុងឆ្នាំអនុវត្តថវិកា។

<u>ឧទាហរណ៍</u>៖

ក្រសួងអប់រំ យុវជន និងកីឡា បានបោះផ្សាយអាណត្តិបើកប្រាក់ នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ ដោយផ្អែកលើវិក្កយបត្ររបស់អគ្គិសនីកម្ពុជាដែលទទួលបាន នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៣ សម្រាប់ទូទាត់ថ្លៃប្រើប្រាស់ថាមពលអគ្គិសនី ចំនួនទឹកប្រាក់ ២០ លានរៀល និងបានបញ្ជូនឯកសារមកដល់គណនេយ្យករសាធារណៈ នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៣ ដើម្បីត្រួតពិនិត្យនិងបើកផ្ដល់។ ដោយសារតែអគ្គិសនីកម្ពុជាបានបើកគណនីប្រាក់បញ្ញើនៅអគ្គនាយកដ្ឋានរតនាគារជាតិ និងក្រោយពីបានពិនិត្យត្រឹមត្រូវលើឯកសារដែលបានបញ្ជូនមកដោយក្រសួង គណនេយ្យកររតនាគារកណ្ដាលត្រូវទទួលស្គាល់ជាចំណាយថវិកាលើការប្រើប្រាស់ថាមពលអគ្គិសនីរបស់ក្រសួង ដោយទូទាត់ចូលទៅគណនីប្រាក់បញ្ញើរបស់អគ្គិសនីកម្ពុជា នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៣។

តាមរយៈឧទាហរណ៍ខាងលើនេះ គណនេយ្យករសាធារណៈបានកត់ត្រាទទួលស្គាល់ជាចំណាយថវិកា នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៣ នៅក្នុងគណនេយ្យថវិកា ដោយផ្អែកលើថ្ងៃខែដែលបានបញ្ចូលប្រាក់ក្នុងគណនីប្រាក់បញ្ញើរបស់អគ្គិសនីកម្ពុជា ទឹកប្រាក់ចំនួន ២០ លានរៀល។ រីឯនៅក្នុងគណនេយ្យទូទៅ ការទទួលស្គាល់ចំណាយលើការប្រើប្រាស់ថាមពលអគ្គិសនី គឺត្រូវកត់ត្រានៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៣ ដោយផ្អែកលើវិក្កយបត្របានទទួល ដោយកត់ត្រាឥណពន្ធ គណនី ចំណាយ និងឥណទាន គណនី គណនីត្រូវសង ទឹកប្រាក់ ២០ លានរៀល។

### ៤.២.២.៩ ចំណាយថវិកាប្រភពពីដៃគូអភិវឌ្ឍន៍ ឬ ថវិកាសប្បុរសជន

ចំណាយមួយចំនួនរបស់រដ្ឋត្រូវបាន គាំទ្រដោយថវិការបស់ដៃគូអភិវឌ្ឍន៍ ឬមានការចូលរួមថវិកា ពីសប្បុរសជនដែលបានដាក់ប្រាក់ចូលគណនីទោលរតនាគារ ឬ ប្រើប្រាស់ក្រោមរូបភាពជាអនុគណនីទោលរតនាគារ (បើកគណនីធនាគារដោយឡែក ប៉ុន្តែគណនេយ្យករសាធារណៈកត់ត្រានិងតាមដាន) ឬ ចូលក្នុងគណនីធនាគាររបស់គណនេយ្យករ

សាធារណៈ។ ក្នុងករណីនេះ ប្រតិបត្តិការចំណាយថវិកាប្រភពពីដៃគូអភិវឌ្ឍន៍ ឬ ពីសប្បុរសជន ត្រូវបានកត់ត្រានិងទទួលស្គាល់ជាចំណាយថវិកានៃឆ្នាំអនុវត្តថវិកានៅក្នុងគណនេយ្យថវិកា ក្នុងករណីដែលប្រតិបត្តិការទាំងនោះបំពេញតាមលក្ខខណ្ឌ ដូចខាងក្រោម៖

- មានលំហូរសាច់ប្រាក់ចេញពីគណនីធនាគារឬបេឡាររបស់គណនេយ្យករសាធារណៈ នៅក្នុងឆ្នាំអនុវត្តថវិកា
- ព្រឹត្តិការណ៍ចំណាយពិតជាបានកើតមានឡើង នៅក្នុងឆ្នាំអនុវត្តថវិកា
- មានការបញ្ជាក់ទទួលស្គាល់អំពីមុខសញ្ញាចំណាយថវិកាដោយអាណាប័ក និង
- មានការត្រួតពិនិត្យផ្ទៀងផ្ទាត់ភាពត្រឹមត្រូវដោយគណនេយ្យករសាធារណៈ ស្របតាមខ្លឹមសារនៃមាត្រា២៧ និងមាត្រា២៨នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ។

ផ្អែកលើអាណត្តិបើកប្រាក់ និងឯកសារគាំទ្រចំណាយថវិកាប្រភពពីដៃគូអភិវឌ្ឍន៍ឬពីសប្បុរជន ដែលត្រូវប្រគល់ឱ្យយ៉ាងយូរបំផុតត្រឹមការិយបរិច្ឆេទបញ្ចប់រយៈពេលបំពេញបន្ថែម គណនេយ្យករសាធារណៈត្រូវកត់ត្រាទទួលស្គាល់ចំណាយថវិកានេះទៅតាមប្រភេទនិងមុខសញ្ញានៃចំណាយថវិកានីមួយៗ ដោយផ្អែកលើចំណាត់ថ្នាក់សេដ្ឋកិច្ច (ផ្នែកមាតិកាចំណាយថវិកា) នៃមាតិកាថវិការដ្ឋ នៅក្នុងគណនេយ្យថវិកា និងប្រព័ន្ធ FMIS ដោយកំណត់យកតាមថ្ងៃខែឆ្នាំនៃលំហូរសាច់ប្រាក់ចេញពិតប្រាកដ (ករណីមុនរយៈពេលបំពេញបន្ថែម) ឬ កំណត់យកថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំអនុវត្តថវិកា (ករណីអំឡុងរយៈពេលបំពេញបន្ថែម)។ កាលបរិច្ឆេទនៃចំណាយថវិកានេះត្រូវបានកំណត់ជាគោលដោយគណនេយ្យករសាធារណៈ និងជាមូលដ្ឋានសម្រាប់ការរាយការណ៍អំពីការអនុវត្តចំណាយថវិកាពីដៃគូអភិវឌ្ឍន៍ ឬ ពីសប្បុរសជននៅក្នុងឆ្នាំអនុវត្តថវិកា។

ក្នុងករណីដែលថវិកាប្រភពដៃគូអភិវឌ្ឍន៍ ឬ ពីសប្បុរសជន ស្ថិតនៅក្រៅប្រព័ន្ធគណនីទោលរតនាគារ ឬ ក្រៅគណនីធនាគាររបស់គណនេយ្យករសាធារណៈ (អាចក្រោមរូបភាពជាទព្វសម្ភារៈ ឬជំនួយបច្ចេកទេសនានា ឬ ការទូទាត់ផ្ទាល់ពីដៃគូអភិវឌ្ឍន៍ ឬ សប្បុរសជនទៅអ្នកផ្គត់ផ្គង់) ចំណាយប្រភេទនេះពុំមានការកត់ត្រាទទួលស្គាល់ជាចំណាយថវិកានៅក្នុងគណនេយ្យថវិកាទេ ដោយសារតែពុំមានលំហូរសាច់ប្រាក់ចេញជាក់ស្តែង ដែលទទួលស្គាល់ដោយគណនេយ្យករសាធារណៈ។ ករណីនេះ គណនេយ្យករសាធារណៈត្រូវធ្វើការកត់ត្រាប្រតិបត្តិការនេះនៅក្នុងគណនេយ្យទូទៅ (មូលដ្ឋានបង្គរ) ដោយទទួលស្គាល់ជាចំណាយ ផ្អែកតាមស្មារតីនៃប្រកាសលេខ ៣៥៤ សហវ.ប្រក. ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២២ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីកិច្ចបញ្ជិកាគណនេយ្យនៃទ្រព្យសកម្មរយៈពេលវែង និងស្តង់ដាគណនេយ្យសាធារណៈជាតិនិងអន្តរជាតិ ដើម្បីធានាបាននូវការប្រមូលផ្តុំនៃកិច្ចប្រតិបត្តិការហិរញ្ញវត្ថុនិងគណនេយ្យរបស់រដ្ឋ។

<u>**បញ្ជាក់៖**</u>

- អាណាប័កត្រូវខិតខំរៀបចំអាណត្តិបើកប្រាក់ អមដោយសក្ខីបត្រគាំទ្រ រួចបញ្ជូនមកអ្នកត្រួតពិនិត្យថវិកា ស្របតាមបទប្បញ្ញត្តិជាធរមាន មុននឹងបញ្ជូនមកគណនេយ្យករសាធារណៈ សម្រាប់ចុះកិច្ចបញ្ជិកាគណនេយ្យនៃចំណាយថវិកា ដើម្បីធានាដល់ការបិទបញ្ជីគណនេយ្យ និងរៀបចំរបាយការណ៍ថវិកានិងហិរញ្ញវត្ថុប្រចាំឆ្នាំឱ្យបានទាន់ពេល។
- ក្នុងករណីដែលថវិកាដៃគូអភិវឌ្ឍន៍ ឬ ថវិកាសប្បុរសជន ឆ្លងកាត់តាមប្រព័ន្ធការងាររបស់គណនេយ្យករសាធារណៈ ឬប្រព័ន្ធគ្រប់គ្រងរដ្ឋ (ឆ្លងសាច់ប្រាក់ ឆ្លងការត្រួតពិនិត្យ និងអនុវត្តនីតិវិធីហិរញ្ញវត្ថុរបស់រដ្ឋ) ថវិកានោះត្រូវកត់ត្រាជាចំណូលនិងចំណាយថវិកា។
- ក្នុងករណីដែលថវិកាដៃគូអភិវឌ្ឍន៍ ឬ ថវិកាសប្បុរសជន គ្រាន់តែឆ្លងលំហូរសាច់ប្រាក់តាមរយៈគណនីដែលបានបើកនៅគណនេយ្យករសាធារណៈ នោះគណនេយ្យករសាធារណៈពុំត្រូវកត់ត្រាប្រតិបត្តិការថវិកា ជាចំណូលនិងចំណាយថវិកា នៅក្នុងគណនេយ្យថវិកា នោះទេ ដោយសារតែពុំបានធ្វើការត្រួតពិនិត្យត្រឹមត្រូវ។ ប៉ុន្តែគណនេយ្យករសាធារណៈត្រូវរាយការណ៍អំពីចំណូលនិងចំណាយសាច់ប្រាក់ដែលពាក់ព័ន្ធនឹងការប្រើប្រាស់

ថវិកាដៃគូអភិវឌ្ឍន៍ ឬ ថវិកាសប្បុរសជន និងក្នុងករណីដែលមានគោលការណ៍ណែនាំដោយឡែក ត្រូវសមាហរណកម្មតួលេខចូលទៅក្នុងគណនេយ្យទូទៅសម្រាប់ការរាយការណ៍ហិរញ្ញវត្ថុរួមរបស់អង្គភាព។

ឧទាហរណ៍ទី១៖

គម្រោងលើកស្ទួយ និងស្តារអាងទំនប់ទឹក ក្នុងឆ្នាំ២០២៣ នៅខេត្តបន្ទាយមានជ័យ ដែលត្រូវប្រើប្រាស់ថវិកាចំនួន ២ប៊ី លានរៀល ក្នុងនោះរាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានឯកភាពជាមួយដៃគូអភិវឌ្ឍន៍ធ្វើបដិភាគកម្មចំនួន៥០%នៃថវិកាដើម្បីទ្រទ្រង់គម្រោងនេះ។ ដៃគូអភិវឌ្ឍន៍បានបង្វែរថវិកាចូលថវិការដ្ឋសម្រាប់អនុវត្តគម្រោងនេះ តាមរយៈក្រសួងធនធានទឹកនិងឧតុនិយម។ ក្រសួងធនធានទឹកនិងឧតុនិយម តាមរយៈមន្ទីរធនធានទឹកនិងឧតុនិយមខេត្តបន្ទាយមានជ័យ បានអនុវត្តគម្រោងនេះចប់សព្វគ្រប់ និងបានស្នើសុំទូទាត់ថវិកាពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ដោយមានការឯកភាពគ្នាពីដៃគូអភិវឌ្ឍន៍ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានបោះផ្សាយអាណត្តិបើកប្រាក់ នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២៣ ទឹកប្រាក់ចំនួន ២ប៊ី លានរៀល ដែលក្នុងនោះថវិកាដៃគូអភិវឌ្ឍន៍មានចំនួន ១ប៊ី លានរៀល ដើម្បីទូទាត់ជូនមន្ទីរធនធានទឹកនិងឧតុនិយមខេត្តបន្ទាយមានជ័យ ដោយត្រូវបង្វែរប្រាក់ចូលគណនីធនាគាររបស់មន្ទីរ។ នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៣ អាណត្តិបើកប្រាក់បានបញ្ជូនដល់អ្នកត្រួតពិនិត្យថវិកាដើម្បីពិនិត្យនិងផ្តល់ទិដ្ឋាការ និងនៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៣ បានមកដល់គណនេយ្យករសាធារណៈ ដើម្បីពិនិត្យភាពត្រឹមត្រូវនិងបើកផ្តល់។ ក្រោយពីបានពិនិត្យចប់សព្វគ្រប់ នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២៣ គណនេយ្យករសាធារណៈកត់ត្រាទទួលស្គាល់ជាចំណាយថវិកា នៅក្នុងគណនេយ្យថវិកា ទឹកប្រាក់សរុបចំនួន ២ប៊ី លានរៀល។

ឧទាហរណ៍ទី២៖

គម្រោងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលអនុវត្តដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានទទួលជំនួយពីសហភាពអឺរ៉ុប តាមយន្តការថវិកាទ្រទ្រង់ (Budget Support) ចំនួន ៥ លានអឺរ៉ូ ក្នុងឆ្នាំ២០២៣។ សហភាពអឺរ៉ុបបានបង្វែរថវិកានេះចូលគណនីធនាគារ ដែលបានបើកដោយគណនេយ្យករ និងអ្នកគ្រប់គ្រងគម្រោង។ ការគ្រប់គ្រងនិងអនុវត្តថវិកានេះពុំបានឆ្លងកាត់នីតិវិធីហិរញ្ញវត្ថុរបស់រដ្ឋនោះទេ ពោលគឺត្រូវអនុវត្តតាមនីតិវិធីរួមសម្រាប់គ្រប់គ្រង ការរៀបចំ និងតាមដានការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍។ គណនេយ្យករសាធារណៈពុំបានត្រួតពិនិត្យផ្ទៀងផ្ទាត់ភាពត្រឹមត្រូវតាមនីតិវិធីហិរញ្ញវត្ថុរបស់រដ្ឋ ក៏ដូចជាពុំបានដឹងអំពីការចាត់ចែងសាច់ប្រាក់របស់គម្រោងនេះទេ។ ក្នុងករណីនេះ គណនេយ្យករសាធារណៈពុំអាចកត់ត្រាប្រតិបត្តិការចំណូលនិងចំណាយថវិការបស់ថវិកាដៃគូអភិវឌ្ឍន៍ នៅក្នុងគណនេយ្យថវិកាទេ។ ប៉ុន្តែ គណនេយ្យករសាធារណៈត្រូវប្រមូលផ្តុំប្រតិបត្តិការអនុវត្តថវិកាទាំងអស់ តាមរយៈរបាយការណ៍អនុវត្តថវិកាដៃគូអភិវឌ្ឍន៍ដែលបានផ្ញើមកអគ្គនាយកដ្ឋានរតនាគារជាតិ ដើម្បីធ្វើសម្រង់តួលេខ សម្រាប់ការរាយការណ៍ហិរញ្ញវត្ថុរបស់រដ្ឋ។

### ៤.២.២.១០ ខាតពិតពីអត្រាប្តូរប្រាក់

ខាតពិតពីអត្រាប្តូរប្រាក់កើតឡើង នៅពេលដែលមានការទិញឬលក់រូបិយបណ្ណដែលអត្រាប្តូរប្រាក់មានតម្លៃទាបជាងមុន ធៀបនឹងតម្លៃដែលបានកត់ត្រាមុននៃរូបិយបណ្ណ។ ប្រតិបត្តិការខាតពិតពីអត្រាប្តូរប្រាក់នេះត្រូវទទួលស្គាល់ជាចំណាយថវិកា ដោយសារតែ៖

- មានលំហូរសាច់ប្រាក់ចេញពិតប្រាកដពីគណនេយ្យករសាធារណៈ ដែលកើតចេញពីការប្តូរប្រាក់ជាក់ស្តែង តាមអត្រាប្តូរប្រាក់នៅថ្ងៃប្រតិបត្តិការ
- ព្រឹត្តិការណ៍ចំណាយពិតជាកើតមានឡើងនៅក្នុងឆ្នាំកំពុងអនុវត្តថវិកា និង
- មានការត្រួតពិនិត្យត្រឹមត្រូវនិងបញ្ជាក់ទទួលស្គាល់លើចំណាយថវិកា (ខាតពិតពីអត្រាប្តូរប្រាក់) ដោយគណនេយ្យករសាធារណៈ។

ផ្អែកលើសក្ខីបត្រគាំទ្រនៃប្រតិបត្តិការប្តូរប្រាក់នេះ (ដូចជារបាយការណ៍ធនាគារជាដើម) គណនេយ្យករសាធារណៈត្រូវកត់ត្រាទទួលស្គាល់ប្រតិបត្តិការនេះជាចំណាយថវិកា (ខាតពិតពីអត្រាប្តូរប្រាក់) ដោយប្រើប្រាស់ចំណាត់ថ្នាក់សេដ្ឋកិច្ច

(ផ្នែកមាតិកាចំណាយថវិកា) នៃមាតិកាថវិការដ្ឋ នៅក្នុងគណនេយ្យថវិកា និងប្រព័ន្ធ FMIS និងត្រូវកំណត់យកតាមថ្ងៃខែឆ្នាំនៃប្រតិបត្តិការប្តូរប្រាក់ដែលបានកើតឡើង ពោលគឺយកតាមថ្ងៃខែឆ្នាំនៃរំហូរសាច់ប្រាក់ចេញពិតប្រាកដពីគណនេយ្យករសាធារណៈ។ កាលបរិច្ឆេទនៃចំណាយថវិកានេះត្រូវបានកំណត់ជាគោលដោយគណនេយ្យករសាធារណៈ និងជាមូលដ្ឋានសម្រាប់ការរាយការណ៍អំពីការអនុវត្តចំណាយថវិកាពីប្រតិបត្តិការខាតពិតពីអត្រាប្តូរប្រាក់ នៅក្នុងឆ្នាំអនុវត្តថវិកា។

ប្រតិបត្តិការខាតពីអត្រាប្តូរប្រាក់នេះ នឹងនាំឱ្យមានការកត់ត្រានិងរបាយការណ៍ដូចគ្នា ទាំងនៅក្នុងគណនេយ្យថវិកានិងគណនេយ្យទូទៅ។

<u>**បញ្ជាក់៖**</u>

- ការកត់ត្រាប្រតិបត្តិការខាតពិតពីអត្រាប្តូរប្រាក់ពុំតម្រូវឱ្យមានអាណត្តិបើកប្រាក់ចំណាយថវិកាទេ។
- នៅក្នុងក្របខ័ណ្ឌគណនេយ្យទូទៅ មូលដ្ឋានបង្គរ គោលការណ៍ណែនាំសម្រាប់កិច្ចបញ្ជិកាគណនេយ្យទ្វេភាគនៃប្រតិបត្តិការចំណេញឬខាតពីអត្រាប្តូរប្រាក់ នឹងត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្របតាមស្តង់ដាគណនេយ្យសាធារណៈជាតិនិងអន្តរជាតិ។

<u>ឧទាហរណ៍៖</u>

សាលារាជធានីភ្នំពេញបានចុះកិច្ចសន្យាផ្គត់ផ្គង់សេវាបំភ្លឺសាធារណៈជាមួយក្រុមហ៊ុន ABC ដោយតម្រូវឱ្យបង់ថ្លៃសេវាប្រចាំខែជូនក្រុមហ៊ុន ចំនួន ១០,០០០ ដុល្លារអាមេរិក នៅអំឡុងសប្តាហ៍ទី២ នៃខែបន្ទាប់។ នៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២៣ ក្រុមហ៊ុនបានចេញវិក្កយបត្រជាប្រាក់ដុល្លារអាមេរិកជូនសាលារាជធានីភ្នំពេញ ដែលមានទឹកប្រាក់ ១០,០០០ ដុល្លារអាមេរិក ស្មើនឹង ៤០,៥០០,០០០ រៀល (អត្រា ១ ដុល្លារអាមេរិកស្មើនឹង ៤,០៥០ រៀល)។ នៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២៣ សាលារាជធានីភ្នំពេញបានបោះផ្សាយអាណត្តិបើកប្រាក់ ទឹកប្រាក់ចំនួន ១០,០០០ ដុល្លារអាមេរិក ស្មើនឹង ៤០,៥០០,០០០ រៀល ដើម្បីទូទាត់ជូនក្រុមហ៊ុន រួចបញ្ជូនឯកសារមកគណនេយ្យកររតនាគារទទួលបន្ទុកសាលារាជធានីភ្នំពេញ ដើម្បីធ្វើការពិនិត្យនិងផ្ទៀងផ្ទាត់។ ក្រោយពីបានពិនិត្យត្រឹមត្រូវ គណនេយ្យកររតនាគារបានទូទាត់ជូនក្រុមហ៊ុន នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២៣ ជាប្រាក់រៀល ចំនួន ៤១,០០០,០០០ រៀល តាមអត្រាប្តូរប្រាក់ជាក់ស្តែង ១ ដុល្លារអាមេរិកស្មើនឹង ៤,១០០ រៀល តាមរយៈគណនីប្រាក់បញ្ញើរបស់សាលារាជធានីភ្នំពេញ ។ ក្នុងករណីនេះ សាលារាជធានីបានខាតពិតពីអាត្រាប្តូរប្រាក់ ចំនួន ៥០០,០០០ រៀល គណនេយ្យកររតនាគារទទួលបន្ទុកសាលារាជធានីភ្នំពេញ ត្រូវកត់ត្រាខាតពិតពីអត្រាប្តូរប្រាក់នេះ ជាចំណាយថវិការបស់សាលារាជធានីភ្នំពេញ នៅក្នុងគណនេយ្យថវិកា ដោយកំណត់យកតាមថ្ងៃខែឆ្នាំនៃការទូទាត់ប្រាក់ទៅក្រុមហ៊ុន និងពុំចាំបាច់មានអាណត្តិបើកប្រាក់ទទួលស្គាល់ជាចំណាយថវិកា ខាតពីអត្រាប្តូរប្រាក់ទេ។

### ៤.២.២.១១ ចំណាយមិនឆ្លងកាត់រតនាគារជាតិ

ប្រតិបត្តិការចំណាយមិនឆ្លងកាត់រតនាគារជាតិ ពុំអាចកត់ត្រានិងទទួលស្គាល់ជាចំណាយថវិកានៃឆ្នាំអនុវត្តថវិកានៅក្នុងគណនេយ្យថវិកាបានទេ ដោយសារតែប្រតិបត្តិការនេះពុំមានរំហូរសាច់ប្រាក់ចេញពីគណនីធនាគាររបស់គណនេយ្យករសាធារណៈ និងពុំបានឆ្លងការត្រួតពិនិត្យនិងបញ្ជាក់ទទួលស្គាល់លើចំណាយថវិកាដោយគណនេយ្យករសាធារណៈ ស្របតាមខ្លឹមសារនៃមាត្រា២៧និងមាត្រា២៨នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ។ នៅក្នុងគណនេយ្យថវិកា ប្រតិបត្តិការនេះពុំមែនជាកម្មវត្ថុនៃការកត់ត្រាក្នុងទិដ្ឋភាពនៃការអនុវត្តថវិកាទេ ប៉ុន្តែជាកម្មវត្ថុនៃការរាយការណ៍បន្ថែមអំពីការអនុវត្តថវិកានៅក្រៅប្រព័ន្ធរតនាគារជាតិ។ ដោយឡែក គណនេយ្យករសាធារណៈត្រូវធ្វើមជ្ឈការនិងកត់ត្រាប្រតិបត្តិការនេះ នៅក្នុងប្រព័ន្ធគណនេយ្យទូទៅ (មូលដ្ឋានបង្គរ) ដើម្បីឆ្លុះបញ្ចាំងគ្រប់ប្រតិបត្តិការហិរញ្ញវត្ថុនិងគណនេយ្យនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល។ របៀបនៃការកត់ត្រាប្រតិបត្តិការនេះនៅក្នុងគណនេយ្យទូទៅនឹងមានកំណត់ដោយឡែក និងត្រូវអនុវត្តដោយអនុលោមតាមស្តង់ដាគណនេយ្យសាធារណៈតម្កល់ជាមូលដ្ឋានបង្គរ។

### ៤.២.២.១២ ប្រតិបត្តិការចំណាយផ្សេងទៀត

ប្រតិបត្តិការចំណាយផ្សេងទៀត សំដៅដល់ប្រតិបត្តិការទាំងឡាយណាក្រៅពីប្រតិបត្តិការដែលបានកំណត់ក្នុងចំណុចទី៤.២.១និងចំណុចទី៤.២.២.១ដល់ទី៤.២.២.១១ ហើយអាចកើតមានឡើងជាយថាហេតុ ព្រមទាំងពុំទាន់មានលទ្ធភាពកំណត់ចូលក្នុងលក្ខខណ្ឌខាងលើនៃការទទួលស្គាល់ជាចំណាយថវិកា នៅក្នុងគណនេយ្យថវិកា និងប្រព័ន្ធ FMIS តាមគោលការណ៍ណែនាំនេះ។ ក្នុងករណីនេះ អាណាប័កនិងគណនេយ្យករសាធារណៈត្រូវទំនាក់ទំនងមកអគ្គនាយកដ្ឋានរតនាគារជាតិ និងអគ្គនាយកដ្ឋានពាក់ព័ន្ធ ដើម្បីពិភាក្សា វិភាគ និងកំណត់អំពីលទ្ធភាពនៃការកត់ត្រាចូលគណនេយ្យថវិកា និងប្រព័ន្ធ FMIS។

### ៤.២.៣ បន្ទុកហិរញ្ញប្បទាន

បន្ទុកហិរញ្ញប្បទានពាក់ព័ន្ធនឹងលំហូរចេញសាច់ប្រាក់របស់រាជរដ្ឋាភិបាល ក្រោមរូបភាពជាការសងបំណុលទាំងក្នុងស្រុកទាំងក្រៅស្រុក ការបង្វិលសងប្រាក់ចេញពីគណនីប្រាក់បញ្ញើ ការបង់ប្រាក់តម្កល់ឬប្រាក់កក់សម្រាប់ធានាការផ្គត់ផ្គង់ទំនិញ និងសេវាកម្ម ឬ ប្រតិបត្តិការសាច់ប្រាក់ផ្សេងទៀត ដែលមានចរិតលក្ខណៈជាបណ្ដោះអាសន្ន (មិនស្ថាពរ) និងត្រូវបង្វិលសងត្រលប់មករដ្ឋវិញ។ បន្ទុកហិរញ្ញប្បទានមិនមែនជាបន្ទុកថវិកាដែលត្រូវកត់ត្រាទទួលស្គាល់ជាចំណាយថវិកាទេ ដោយហេតុតែបន្ទុកទាំងនេះពុំបានគោរពតាមលក្ខខណ្ឌនៃការទទួលស្គាល់ជាចំណាយថវិកា (ដូចមានកំណត់ខាងលើ) ជាពិសេស នៅត្រង់លក្ខខណ្ឌនៃការកើតឡើងជាក់ស្តែងឬជាស្ថាពរនៃព្រឹត្តិការណ៍ចំណាយ។ ដូច្នេះ បន្ទុកហិរញ្ញប្បទានពុំតម្រូវឱ្យធ្វើការកត់ត្រានៅក្នុងគណនេយ្យថវិកា នោះទេ។ ផ្ទុយទៅវិញ នៅក្នុងគណនេយ្យទូទៅ និងប្រព័ន្ធ FMIS បន្ទុកហិរញ្ញប្បទានត្រូវបានចុះកិច្ចបញ្ជិកាគណនេយ្យទ្វេភាគ ស្របតាមស្តង់ដាគណនេយ្យសាធារណៈកម្ពុជា ដោយសារតែ ប្រតិបត្តិការនេះក៏ជាប្រតិបត្តិការហិរញ្ញវត្ថុនិងគណនេយ្យរបស់រដ្ឋ ដែលត្រូវកត់ត្រាបូកសរុប និងរាយការណ៍ទៅរដ្ឋសភាដែរ ក្នុងក្របខ័ណ្ឌនៃរបាយការណ៍ហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល។

ទោះជាយ៉ាងនេះក្តី នៅក្នុងកាលៈទេសៈខ្លះ បន្ទុកហិរញ្ញប្បទានត្រូវចាត់ទុកនិងទទួលស្គាល់ជាចំណាយថវិកា ដោយហេតុតែបន្ទុកហិរញ្ញប្បទានទាំងនោះត្រូវបានចំណាយជាស្ថាពរដោយអាណាប័ក ដូចជាករណីដែលអ្នកផ្គត់ផ្គង់រឹបអូសយកប្រាក់តម្កល់ជាដើម ដែលការណ៍នេះនាំឱ្យក្លាយជាបន្ទុកថវិការបស់រដ្ឋ និងត្រូវទទួលស្គាល់ជាចំណាយថវិកា។ ក្នុងករណីនេះ បន្ទុកហិរញ្ញប្បទានត្រូវកត់ត្រាជាចំណាយថវិកា ដោយប្រើប្រាស់ចំណាត់ថ្នាក់សេដ្ឋកិច្ច (ផ្នែកមាតិកាចំណាយថវិកា) នៃមាតិកាថវិការដ្ឋ នៅក្នុងគណនេយ្យថវិកា និងប្រព័ន្ធ FMIS ដោយកំណត់យកតាមថ្ងៃខែឆ្នាំនៃអាណត្តិបើកប្រាក់ គឺពុំអាស្រ័យទៅនឹងថ្ងៃខែឆ្នាំនៃលំហូរសាច់ប្រាក់ចេញពិតប្រាកដទៀតនោះទេ។ កាលបរិច្ឆេទនៃចំណាយថវិកានេះត្រូវបានកំណត់ជាគោលដោយគណនេយ្យករសាធារណៈ និងជាមូលដ្ឋានសម្រាប់ការរាយការណ៍អំពីការអនុវត្តចំណាយថវិកានៃឆ្នាំអនុវត្តថវិកា។ ការកត់ត្រាចំណាយថវិការបស់គណនេយ្យករសាធារណៈនៅក្នុងគណនេយ្យថវិកា និងប្រព័ន្ធ FMIS ត្រូវផ្អែកលើអាណត្តិបើកប្រាក់ អមដោយសក្ខីបត្រគាំទ្រ ដែលអាស្រ័យទៅតាមប្រភេទនិងមុខសញ្ញានៃចំណាយថវិកានីមួយៗ។ ប្រតិបត្តិការប្រភេទនេះនឹងនាំឱ្យមានការកត់ត្រាចំណាយថវិកានិងរបាយការណ៍ដូចគ្នា ទាំងនៅក្នុងគណនេយ្យថវិកានិងគណនេយ្យទូទៅ។

<u>ឧទាហរណ៍៖</u>

អគ្គនាយកដ្ឋានរតនាគារជាតិបានជួលទីតាំងមួយកន្លែងនៅខណ្ឌទួលគោក រាជធានីភ្នំពេញ ពីសហគ្រិន តារា ដើម្បីធ្វើជាកន្លែងរក្សាទុកឯកសារគណនេយ្យរបស់គណនេយ្យករសាធារណៈ ដោយបានចុះកិច្ចសន្យាជួល សម្រាប់រយៈពេល៣ឆ្នាំ ចាប់ថ្ងៃទី១ ខែមករា ឆ្នាំ២០២២ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ដោយត្រូវបង់ប្រាក់ឈ្នួលប្រចាំខែ ចំនួន ១,០០០ ដុល្លារអាមេរិក និងត្រូវតម្កល់ប្រាក់ធានា ចំនួន២ខែ។ នៅថ្ងៃទី៣ ខែមករា ឆ្នាំ២០២២ អគ្គនាយកដ្ឋានរតនាគារជាតិបានស្នើសុំទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីរៀបចំសំណើសុំដកប្រាក់ចំនួន ២,០០០ ដុល្លារអាមេរិក យកទៅបង់ជាប្រាក់តម្កល់លើការជួលផ្ទះពីសហគ្រិន តារា។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានរៀបចំសំណើសុំដកប្រាក់ពីគណនេយ្យករសាធារណៈ ដើម្បីបង្វែរប្រាក់ទៅសហគ្រិន តារា ចំនួន ២,០០០ ដុល្លារអាមេរិក។ ក្រោយពីបានពិនិត្យ

ត្រឹមត្រូវ នៅថ្ងៃទី៥ ខែមករា ឆ្នាំ២០២២ គណនេយ្យករសាធារណៈបានបង្វែរប្រាក់ចំនួន ២,០០០ ដុល្លារអាមេរិក ទៅគណនីធនាគាររបស់សហគ្រិន តារា។ ប្រតិបត្តិការនេះពុំមែនជាប្រតិបត្តិការចំណាយថវិកាទេ ដោយសារតែប្រាក់កក់នេះនឹងត្រូវបង្វិលសងវិញមកគណនេយ្យករសាធារណៈដោយសហគ្រិនតារានៅពេលចប់កិច្ចសន្យា។ ប្រតិបត្តិការនេះជាបន្ទុកហិរញ្ញប្បទានរបស់គណនេយ្យករសាធារណៈ ដែលចេញជាសាច់ប្រាក់ ហើយត្រូវកត់ត្រានៅក្នុងគណនេយ្យទូទៅ ប៉ុន្តែពុំមានការកត់ត្រានៅក្នុងគណនេយ្យថវិកាទេ។ ក្រោយពេលចប់កិច្ចសន្យានៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ សហគ្រិនតារាបានរឹបអូសយកប្រាក់តម្កល់នេះ ដោយសារតែផ្ទះដែលបានជួលបានខូចខាតមួយចំនួន ដូចជា ការប្រេះឡាក់ជញ្ជាំង, ការបែកបាក់កញ្ចក់បង្អួច, ការខូចខាតលើទ្វារ ជាដើម។ ករណីនេះ ប្រាក់កក់ពុំបានសងត្រលប់មកគណនេយ្យករសាធារណៈវិញទេ ហើយគណនេយ្យករសាធារណៈត្រូវទទួលស្គាល់ការខាតបង់ប្រាក់នេះជាចំណាយថវិកា និងត្រូវកត់ត្រានៅក្នុងគណនេយ្យថវិកាផងដែរ តាមរយៈអាណត្តិបើកប្រាក់ ទទួលស្គាល់លើមុខសញ្ញាចំណាយថវិកា និងត្រូវប្រើប្រាស់ឥណទានថវិកា។

### ៤.២.៤ រយៈពេលនៃការទទួលអាណត្តិបើកប្រាក់ សម្រាប់ការទទួលស្គាល់ចំណាយថវិកា

អាណត្តិបើកប្រាក់ចំណាយថវិកាសម្រាប់ការទទួលស្គាល់ជាចំណាយថវិកា នៅក្នុងការិយបរិច្ឆេទនៃឆ្នាំអនុវត្តថវិកា អាចត្រូវបានបន្តទទួលយ៉ាងយូរត្រឹមថ្ងៃទី៣១ ខែមករា នៃឆ្នាំបន្ទាប់ ដោយត្រូវចុះកិច្ចបញ្ជីកានៅក្នុងគណនេយ្យថវិកា និងប្រព័ន្ធ FMIS នៅថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំអនុវត្តថវិកា ក្នុងករណីបំពេញបាននូវលក្ខខណ្ឌនៃការទទួលស្គាល់ជាចំណាយថវិកា ដូចមានកំណត់ក្នុងចំណុចទី៤.២.១និងចំណុចទី៤.២.២ ខាងលើ។ ទោះបីជាមានការអនុញ្ញាតយ៉ាងនេះក៏ដោយ ក៏អាណាប័កត្រូវខិតខំរៀបចំអាណត្តិបើកប្រាក់ អមដោយសក្ខីបត្រគាំទ្រ និងត្រូវបញ្ជូនមកអ្នកត្រួតពិនិត្យថវិកា ស្របតាមបទប្បញ្ញត្តិជាធរមានមុននឹងបញ្ជូនមកគណនេយ្យករសាធារណៈឱ្យបានទាន់ពេល នៃឆ្នាំអនុវត្តថវិកា (ត្រឹមថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំអនុវត្តថវិកា) ដើម្បីឱ្យដំណើរការនៃការបិទបញ្ជីគណនេយ្យនិងរៀបចំរបាយការណ៍ថវិកាអាចប្រព្រឹត្តទៅដោយរលូន និងទាន់ពេល។

### ៤.២.៥ សំណែសចំណាយ

ចំណាយមួយចំនួន ក្រោយពីបានបើកផ្តល់សាច់ប្រាក់រួចរាល់ដោយគណនេយ្យករសាធារណៈ និងក្រោយពីអង្គភាពសាធារណៈបានយកទៅចំណាយរួចរាល់ ហើយអាចនៅសល់ជាសាច់ប្រាក់ពីការចំណាយ នឹងត្រូវបង់ចូលគណនេយ្យករសាធារណៈវិញ។ ប្រាក់សល់ពីការចំណាយនេះ ហៅថា សំណែសចំណាយ។

ក្នុងករណីដែលការបង់សំណែសចំណាយប្រព្រឹត្តទៅនៅក្នុងឆ្នាំអនុវត្តថវិកា គណនេយ្យករសាធារណៈត្រូវកត់ត្រានៅក្នុងគណនេយ្យថវិកា និងប្រព័ន្ធ FMIS ដោយកាត់បន្ថយចំណាយថវិកា ដែលបានទទួលស្គាល់ពីមុន ដោយផ្អែកលើសលាកបត្របង់សំណែសចំណាយ និងឯកសារគាំទ្រ ដោយកំណត់យកតាមថ្ងៃខែឆ្នាំនៃសលាកបត្របង់សំណែសចំណាយ និងពុំអាស្រ័យទៅនឹងថ្ងៃខែឆ្នាំនៃវិហ្វូរចូលសាច់ប្រាក់ពិតប្រាកដទេ។

ក្នុងករណីដែលការបង់សំណែសចំណាយប្រព្រឹត្តទៅនៅឆ្នាំបន្តបន្ទាប់ គណនេយ្យករសាធារណៈត្រូវកត់ត្រានៅក្នុងគណនេយ្យថវិកា និងប្រព័ន្ធ FMIS ដោយចាត់ទុកជាចំណូលថវិកាផ្សេងៗ ដោយផ្អែកលើសលាកបត្របង្វែរចំណូលពីសំណែសចំណាយ និងឯកសារគាំទ្រ ដោយកំណត់យកតាមថ្ងៃខែឆ្នាំនៃសលាកបត្របង្វែរចំណូលពីសំណែសចំណាយ និងពុំអាស្រ័យទៅនឹងថ្ងៃខែឆ្នាំនៃវិហ្វូរចូលសាច់ប្រាក់ពិតប្រាកដនោះទេ។

## ៤.៣ ការចុះកិច្ចបញ្ជិកាគណនេយ្យថវិកា

### ៤.៣.១ ការកត់ត្រាប្រតិបត្តិការចំណូលនិងចំណាយថវិកា

ការកត់ត្រានៅក្នុងគណនេយ្យថវិកាត្រូវប្រព្រឹត្តទៅតាមវិធីសាស្ត្រសាមញ្ញ ដោយត្រូវប្រើសញ្ញាបូក (+) ឬ ដក (-) នៃចំនួនទឹកប្រាក់ដែលត្រូវកត់ត្រា ផ្អែកលើការទទួលស្គាល់ប្រតិបត្តិការថវិកាដោយគណនេយ្យករសាធារណៈ។ គណនេយ្យករសាធារណៈត្រូវកត់ត្រា៖

*ចំពោះចំណូលថវិកា៖*

- កត់ត្រាបូកបន្ថែម (+) នៅពេលដែលមានចំណូលថវិកាកើនឡើង
- កត់ត្រាបន្ថយ (-) នៅពេលដែលមានការបង្វិលសងចំណូលថវិកា ឬ និយ័តកម្មចំណូលថវិកាដែលបានកត់ត្រារួចម្តងហើយ និង
- គណនារកទឹកប្រាក់ចំណូលថវិកា ដែលបានបូកបន្តនិងបានអនុវត្ត ធៀបទៅនឹងផែនការថវិកា។

*ចំពោះចំណាយថវិកា៖*

- កត់ត្រាបូកបន្ថែម (+) នៅពេលដែលមានចំណាយថវិកាកើតឡើង
- កត់ត្រាបន្ថយ (-) នៅពេលដែលមានការបង់សំណែសចំណាយ ឬ និយ័តកម្មចំណាយថវិកាដែលបានកត់ត្រារួចម្តងហើយ និង
- គណនារកទឹកប្រាក់ចំណាយថវិកា ដែលបានបូកបន្តនិងបានអនុវត្ត ធៀបទៅនឹងផែនការថវិកា។

ការកត់ត្រាទាំងនេះត្រូវអនុវត្តលើសលាកបត្រតាមដានចំណូលថវិកា និងសលាកបត្រតាមដានចំណាយថវិកាដោយផ្អែកលើសក្ខីបត្រដើមដែលផ្តល់ដោយអាណាប័ក។ ការកត់ត្រានេះត្រូវធ្វើឡើង តាមរយៈប្រព័ន្ធ FMIS។

### ៤.៣.២ ការកែតម្រូវលើកិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិកា

នៅពេលដែលចំណូលនិងចំណាយថវិកាត្រូវបានទទួលស្គាល់នៅក្នុងគណនេយ្យថវិកា និងប្រព័ន្ធ FMIS រួចរាល់ ប៉ុន្តែក្រោយមក អាណាប័ក ឬគណនេយ្យករសាធារណៈ ឬភាគីទី៣ (សវនករជាដើម) បានពិនិត្យនិងរកឃើញថា មានកំហុសឆ្គងនៃការកត់ត្រាប្រតិបត្តិការចំណូលនិងចំណាយថវិកាទាំងនោះ អាណាប័កនិងគណនេយ្យករសាធារណៈត្រូវធ្វើការកែតម្រូវប្រតិបត្តិការទាំងនោះឡើងវិញ ដូចខាងក្រោម៖

- ករណីរកឃើញកំហុសឆ្គងនៅក្នុងឆ្នាំអនុវត្តប្រតិបត្តិការចំណូលនិងចំណាយថវិកា៖ ត្រូវធ្វើការកែតម្រូវប្រតិបត្តិការនៅក្នុងខែដែលរកឃើញកំហុសឆ្គង ដោយមិនត្រូវប្រតិសកម្មដល់ប្រតិបត្តិការដែលបានកត់ត្រារួចរាល់នោះទេ និងត្រូវកត់ត្រាបន្ថែមឬបន្ថយប្រតិបត្តិការកែតម្រូវ ដើម្បីឱ្យប្រតិបត្តិការដើម ត្រឹមត្រូវវិញ និង
- ករណីរកឃើញកំហុសឆ្គងក្រោយឆ្នាំអនុវត្តប្រតិបត្តិការចំណូលនិងចំណាយថវិកា៖
  - អំឡុងពេលបិទបញ្ជី៖ អនុញ្ញាតឱ្យកែតម្រូវ ដោយកំណត់យកថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំអនុវត្ត និង
  - ក្រោយពេលបិទបញ្ជីចប់សព្វគ្រប់៖ មិនអនុញ្ញាតឱ្យកែតម្រូវឡើងវិញទេ បន្ទាប់ពីច្បាប់ទូទាត់ថវិកាត្រូវបានបញ្ជូនដល់រដ្ឋសភា។

ការកែតម្រូវប្រតិបត្តិការទាំងនេះត្រូវធ្វើឡើងទាំងនៅក្នុងក្របខ័ណ្ឌនៃគណនេយ្យថវិកានិងគណនេយ្យទូទៅ។ វិធីសាស្ត្រនៃការកែតម្រូវប្រតិបត្តិការថវិកានៅក្នុងក្របខ័ណ្ឌគណនេយ្យទូទៅត្រូវអនុវត្តតាមស្តង់ដាគណនេយ្យសាធារណៈកម្ពុជា ដែលនឹងត្រូវកំណត់ដោយឡែកតាមរយៈប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

### ៤.៣.៣ រយៈពេលបំពេញបន្ថែម សម្រាប់ការអនុវត្តចំណូលនិងចំណាយថវិកា

ក្នុងករណីដែលមានច្បាប់ហិរញ្ញវត្ថុកែតម្រូវ ត្រូវបានអនុម័តនៅក្នុងឆ្នាំអនុវត្តថវិកា ឬមានអនុក្រឹត្យបន្ថែមឥណទានថវិកា ស្របតាមមាត្រា៧១នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០២៣ ចំណូលនិងចំណាយថវិកាដែលបានគ្រោងក្នុងច្បាប់ហិរញ្ញវត្ថុកែតម្រូវ ឬអនុក្រឹត្យនេះ អាចអនុវត្តបានក្នុងអំឡុងនៃរយៈពេលបំពេញបន្ថែម និងត្រូវចុះកិច្ចបញ្ជិកាគណនេយ្យនៅក្នុងការិយបរិច្ឆេទអនុវត្តថវិកាប្រចាំឆ្នាំ ដោយកំណត់យកថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំអនុវត្តថវិកាដោយមិនអាស្រ័យទៅនឹងការហូរចូលឬចេញសាច់ប្រាក់របស់គណនេយ្យករសាធារណៈនោះទេ។ រយៈពេលបំពេញបន្ថែមនៃការអនុវត្តថវិកាសម្រាប់ករណីនេះត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ អាណាប័កនិងគណនេយ្យករសាធារណៈត្រូវកំណត់ឱ្យបាននូវមុខសញ្ញានៃប្រតិបត្តិការថវិកា ដែលកើតមានក្នុងរយៈពេលបំពេញបន្ថែមខាងលើនេះ។

## ជំពូកទី៥

## ការបិទបញ្ជីគណនេយ្យថវិកា និងការរៀបចំរបាយការណ៍ថវិកា

អនុលោមតាមមាត្រា១១នៃច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០២៣ ការិយបរិច្ឆេទនៃឆ្នាំថវិកាចាប់ផ្ដើមនៅថ្ងៃទី១ ខែមករា ហើយបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ និងមាត្រា៨៦ ការិយបរិច្ឆេទគណនេយ្យថវិកាត្រូវកំណត់រយៈពេលចំនួន១២(ដប់ពីរ)ខែ ដោយគិតចាប់ពីថ្ងៃទី១ ខែមករា រហូតដល់កាលបរិច្ឆេទបិទបញ្ជីគណនេយ្យនៅថ្ងៃទី៣១ ខែធ្នូនៃឆ្នាំដដែល។ ការបិទបញ្ជីគណនេយ្យថវិកាគឺជាកិច្ចដំណើរការនៃការបញ្ឈប់ បញ្ចប់ និងបិទប្រតិបត្តិការចំណូលនិងចំណាយថវិកា និងអាចកំណត់បាននូវស្ថានភាពពិតប្រាកដនិងស្ដាពរអំពីការអនុវត្តថវិកា ការប្រើប្រាស់ឥណទានថវិកាជាស្ថាពរ ឬឥណទានថវិកានៅសល់ នៅក្នុងឆ្នាំថវិកា ព្រមទាំងអាចកំណត់បាននិងបញ្ចប់នូវសមតុល្យថវិកា (អតិរេកថវិកា ឬ ឱនភាពថវិកា) ផងដែរ។ ការបិទបញ្ជីគណនេយ្យគឺជាដំណាក់កាលមួយដ៏សំខាន់ មិនត្រឹមតែជាកិច្ចដំណើរការការងារក្នុងពេលកំណត់ណាមួយនោះទេ ប៉ុន្តែទាមទារឱ្យមានការគិតគូរប្រមូលផ្ដុំនិងផ្ទៀងផ្ទាត់រាល់ប្រតិបត្តិការសេសសល់ទាំងអស់ នាចុងការិយបរិច្ឆេទនៃឆ្នាំអនុវត្តថវិកា។ ទន្ទឹមនេះ ភាពយឺតយ៉ាវនៃការបិទបញ្ជីគណនេយ្យអាចនាំឱ្យមានផលប៉ះពាល់ដល់ការរៀបចំរបាយការណ៍ស្ដីពីការអនុវត្តថវិកា ដែលត្រូវភ្ជាប់ជាឧបសម្ព័ន្ធនៃច្បាប់ទូទាត់ថវិកាប្រចាំឆ្នាំទៅរដ្ឋសភា និងព្រឹទ្ធសភា ស្របតាមពេលជាក់លាក់កំណត់ដោយច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០២៣។ ជាមួយគ្នានេះ អាណាប័កត្រូវពន្យល់និងបញ្ជាក់អំពីមូលហេតុនានាដែលនាំឱ្យមានគម្លាតនៃការប្រើប្រាស់ថវិកាដែលអនុញ្ញាតដោយច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំនិងការអនុវត្តជាក់ស្ដែង នៅក្នុងរបាយការណ៍សមិទ្ធកម្មរបស់ខ្លួន។

ដើម្បីមានជាមូលដ្ឋានរឹងមាំដល់ការបិទបញ្ជីគណនេយ្យថវិកានិងការរៀបចំរបាយការណ៍ថវិកា ជំពូកទី៥នេះនឹងកំណត់អំពីគោលការណ៍សំខាន់ៗមួយចំនួនសម្រាប់អនុវត្តចំពោះប្រតិបត្តិការថវិកានៅចុងការិយបរិច្ឆេទ, ក្របខ័ណ្ឌពេលវេលានៃការបិទបញ្ជីគណនេយ្យ, កិច្ចដំណើរការបិទបញ្ជី, ការគណនាលទ្ធផលនៃការអនុវត្តថវិកា, តួអង្គពាក់ព័ន្ធព្រមទាំងការរៀបចំរបាយការណ៍ថវិកាប្រចាំឆ្នាំ។

### ៥.១ ការត្រៀមលក្ខណៈមុននឹងបិទបញ្ជីគណនេយ្យថវិកានៅចុងការិយបរិច្ឆេទថវិកា

ជាគោលការណ៍ ការបិទបញ្ជីគណនេយ្យថវិកាត្រូវប្រព្រឹត្តទៅយ៉ាងយូរបំផុតត្រឹមថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំអនុវត្តថវិកានីមួយៗ។ ប៉ុន្តែ ដោយហេតុតែជារឿយៗប្រតិបត្តិការថវិកាមួយចំនួនកើតមានឡើងជាគំហុក នៅត្រីមាសទី៤នៃឆ្នាំអនុវត្តថវិកា ហើយជាពិសេសនៅចុងការិយបរិច្ឆេទថវិកា ការបិទបញ្ជីគណនេយ្យថវិកាក៏ពុំអាចដំណើរការទៅតាមកាលកំណត់យ៉ាងយូរបំផុតត្រឹមថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំអនុវត្តថវិកានីមួយៗបានទេ។ ការណ៍នេះតោងមានការកំណត់ជាផ្លូវការនូវកាលវេលាជាក់លាក់ទៅតាមប្រភេទនៃប្រតិបត្តិការថវិកានីមួយៗ ដើម្បីអនុញ្ញាតឱ្យអាណាប័ក អ្នកត្រួតពិនិត្យថវិកា និងគណនេយ្យករសាធារណៈអាចត្រៀមលក្ខណៈជាមុន តាមតួនាទីរៀងៗខ្លួន ក្នុងការអនុវត្តថវិកានិងបិទបញ្ជីគណនេយ្យថវិកា ស្របទៅតាមពេលកំណត់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

#### ៥.១.១ ក្របខ័ណ្ឌពេលវេលា

ការគោរពបាននូវពេលកំណត់នៃប្រតិបត្តិការថវិកានៃឆ្នាំអនុវត្តថវិកានីមួយៗ ដោយអាណាប័ក អ្នកត្រួតពិនិត្យថវិកា និងគណនេយ្យករសាធារណៈ គឺជាកត្តាសំខាន់ដែលនាំឱ្យទទួលបានជោគជ័យនៃកិច្ចដំណើរការបិទបញ្ជីគណនេយ្យ និងការរៀបចំរបាយការណ៍ថវិកាបានទាន់ពេល ស្របតាមការតម្រូវដោយច្បាប់និងបទប្បញ្ញត្តិជាធរមាន។

ជាទូទៅ នៅត្រីមាសទី៤ នៃឆ្នាំអនុវត្តថវិកានីមួយៗ និងជាពិសេស នៅចុងការិយបរិច្ឆេទថវិកា អាណាប័កត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវប្រតិបត្តិការចំណូលនិងចំណាយថវិកានីមួយៗ ស្របតាមប្រតិទិននៃការបិទបញ្ជីគណនេយ្យដែលកំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ អាស្រ័យទៅតាមប្រភេទនិងមុខសញ្ញានៃប្រតិបត្តិការថវិកានីមួយៗ កាលបរិច្ឆេទកំណត់ក្នុងការអនុវត្តនិងបញ្ចប់ប្រតិបត្តិការថវិកា ព្រមទាំងការបញ្ជូនសលាកបត្របង្វែរចំណូល អាណត្តិបើកប្រាក់ អមដោយឯកសារគាំទ្រដែលមានការពាក់ព័ន្ធ ត្រូវកំណត់ជាប្រចាំឆ្នាំ ដោយសារាចរណែនាំរបស់ក្រសួង

សេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីការបិទបញ្ជីចំណូល-ចំណាយថវិកានិងការធ្វើរបាយការណ៍បូកសរុបការអនុវត្តចំណូល-ចំណាយថវិកា ។

អាណាប័កមានកាតព្វកិច្ចបញ្ជូនឯកសារនានាពាក់ព័ន្ធនឹងប្រតិបត្តិការថវិកា ទៅអ្នកត្រួតពិនិត្យថវិកា ស្របតាមនីតិវិធីជាធរមាន មុននឹងបញ្ជូនទៅគណនេយ្យករសាធារណៈ។ គណនេយ្យករសាធារណៈមានពេលយ៉ាងយូរបំផុតត្រឹមថ្ងៃទី៣១ ខែមករា នៃឆ្នាំបន្ទាប់ ដើម្បីបន្តទទួលសលាកបត្របង្វែរចំណូលនិងអាណត្តិបើកប្រាក់ អមដោយសក្ខីបត្រគាំទ្រ ដើម្បីធ្វើការត្រួតពិនិត្យ ដោះស្រាយ និងកត់ត្រាជាលេខនាគណនេយ្យបន្ថែមនៅត្រឹមថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំអនុវត្ត មុននឹងបិទបញ្ជីគណនេយ្យថវិកា និងរៀបចំរបាយការណ៍ថវិកា។ មុននឹងធ្វើការបិទបញ្ជីគណនេយ្យជាស្ថាពរ អាណាប័កដោយសហការជាមួយអ្នកត្រួតពិនិត្យថវិកា និងគណនេយ្យករសាធារណៈ ដើម្បីកំណត់ឱ្យបានអំពីស្ថានភាពពិតប្រាកដនៃការអនុវត្តថវិការបស់ខ្លួន និងក្នុងករណីចាំបាច់ ត្រូវធ្វើនិយ័តកម្មឥណទានថវិកា ឬការកែតម្រូវចាំបាច់នានានៃកិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិការបស់ខ្លួន ដើម្បីចៀសវាងបញ្ហានៃការប្រើប្រាស់លើសឥណទានថវិកា។

### ៥.១.២ ការគ្រប់គ្រងឥណទានថវិកា

អាណាប័កត្រូវមានភាពជាម្ចាស់លើការត្រួតពិនិត្យ តាមដានការប្រើប្រាស់ និងគ្រប់គ្រងឥណទានថវិការបស់ខ្លួន ដើម្បីធានាបានថា ថវិកាត្រូវបានប្រើប្រាស់ចំគោលដៅ និងមានប្រសិទ្ធភាពខ្ពស់។

ទន្ទឹមនេះ អាណាប័ក អ្នកត្រួតពិនិត្យថវិកា និងគណនេយ្យករសាធារណៈ ត្រូវមានការទទួលខុសត្រូវខ្ពស់ និងចូលរួមសហការឱ្យបានខ្ជាប់ខ្ជួន ក្នុងការពិនិត្យតាមដានការប្រើប្រាស់ឥណទានថវិកា ដើម្បីធានាថា ថវិកាដែលបានផ្តល់ឱ្យទៅអាណាប័កត្រូវបានអនុវត្តដោយរលូន, មិនមានបញ្ហាអនុវត្តលើសឥណទានថវិកា ឬអនុវត្តខុសមុខសញ្ញា ជាដើម។

<u>**ចំណាំ៖**</u> ឥណទានថវិកានៅសល់ដែលពុំបានប្រើប្រាស់ក្នុងឆ្នាំអនុវត្តថវិកា ជាកម្មវត្ថុនៃការធ្វើមោឃភាពដោយច្បាប់ទូទាត់ថវិកាប្រចាំឆ្នាំ លើកលែងតែមានការអនុញ្ញាតឱ្យយោងឥណទានថវិកាទាំងនោះ ស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

### ៥.១.៣ ការកែប្រែចំណាត់ថ្នាក់ថវិកា

ជារៀងរាល់ឆ្នាំ ថវិកាត្រូវបានគ្រោងនិងអនុវត្តទៅតាមចំណាត់ថ្នាក់នៃមាតិកាថវិការដ្ឋ និងបានបញ្ចូលទៅក្នុងប្រព័ន្ធ FMIS។ ក្នុងអំឡុងពេលនៃការអនុវត្តថវិកា អាណាប័កអាចមានតម្រូវការក្នុងការកែសម្រួលមុខសញ្ញាចំណូលនិងចំណាយថវិកា ដើម្បីឆ្លើយតបទៅនឹងតម្រូវការឬស្ថានភាពអនុវត្តថវិកាជាក់ស្តែង។ ការណ៍នេះអាចនាំឱ្យមានការផ្លាស់ប្តូរចំណាត់ថ្នាក់នៃមាតិកាថវិការដ្ឋ ទាំងក្រៅនិងក្នុងប្រព័ន្ធ FMIS ដែលតម្រូវឱ្យមានការកំណត់ជាវិធាននិងនីតិវិធីច្បាស់លាស់។ ការកែប្រែលេខកូដនៃចំណាត់ថ្នាក់ថវិកាត្រូវមានការពិនិត្យ ផ្ទៀងផ្ទាត់ និងផ្តល់យោបល់ពីអគ្គនាយកដ្ឋានថវិកា អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ អគ្គនាយកដ្ឋានរតនាគារជាតិ ទៅតាមផ្នែកដែលមានការពាក់ព័ន្ធនឹងសមត្ថកិច្ចរៀងៗខ្លួន និងជូនដំណឹងទៅអគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីកែសម្រួលក្នុងប្រព័ន្ធ FMIS។ ការកែប្រែលេខកូដនៃចំណាត់ថ្នាក់ថវិកានេះ ត្រូវធានាថា ពុំមានការបាត់បង់ឬមានគម្លាតខ្លាំងរវាងទិន្នន័យចំណូលនិងចំណាយនានាដែលបានចុះបញ្ជីដោយប្រើប្រាស់លេខកូដចាស់និងលេខកូដថ្មីនៃចំណាត់ថ្នាក់ថវិកា ដើម្បីធានានិរន្តរភាពនិងសង្គតិភាពនៃតម្លៃដែលបានចុះបញ្ជីជាមួយលេខកូដចាស់និងតម្លៃថ្មីដែលនឹងប្រើប្រាស់លេខកូដថ្មី ព្រមទាំងធានាឱ្យបានថា ការរាយការណ៍អាចប្រព្រឹត្តទៅដោយរលូន គ្រប់ជ្រុងជ្រោយ ពេញលេញ ប្រទាក់ក្រឡាគ្នា និងមានតម្លាភាព។ ការកែប្រែលេខកូដនៃចំណាត់ថ្នាក់ថវិកានេះត្រូវប្រព្រឹត្តទៅក្នុងក្របខ័ណ្ឌពេលវេលាជាក់លាក់ និងអាស្រ័យទៅតាមប្រភេទនៃប្រតិបត្តិការថវិកាដែលបានស្នើសុំកែសម្រួល។

### ៥.១.៤ ការផ្ទៀងផ្ទាត់ប្រតិបត្តិការថវិកា

មុននឹងឈានដល់ការបិទបញ្ជីគណនេយ្យថវិកាជាស្ថាពរ នៅចុងការិយបរិច្ឆេទនៃឆ្នាំអនុវត្តថវិកា គណនេយ្យករសាធារណៈត្រូវធ្វើការពិនិត្យនិងផ្ទៀងផ្ទាត់ឡើងវិញនូវប្រតិបត្តិការថវិកាដែលបានកត់ត្រាកន្លងមក ដោយសហការជាមួយអាណាប័ក និង/ឬ អ្នកត្រួតពិនិត្យថវិកា តាមការចាំបាច់ ដើម្បីធានាបានថាប្រតិបត្តិការថវិកាទាំងនោះពុំមានកំហុសឆ្គង។

យន្តការនេះធានាដល់ភាពត្រឹមត្រូវ គ្រប់ជ្រុងជ្រោយ និងគុណភាពនៃទិន្នន័យចំណូលនិងចំណាយថវិកាសម្រាប់ការរាយការណ៍។ ក្នុងករណីដែលរកឃើញថាមានកំហុសឆ្គងលើការកត់ត្រាប្រតិបត្តិការថវិកា អាណាប័កនិងគណនេយ្យករសាធារណៈត្រូវធ្វើការកែតម្រូវប្រតិបត្តិការទាំងនោះឱ្យបានរួចរាល់ មុននឹងដំណើរការបិទបញ្ជីគណនេយ្យ។ ការកែតម្រូវប្រតិបត្តិការថវិកាត្រូវអនុលោមតាមការណែនាំ ដូចមានកំណត់ក្នុងគោលការណ៍ណែនាំនេះ។ គណនេយ្យករសាធារណៈត្រូវដំណើរការពិនិត្យនិងផ្ទៀងផ្ទាត់ប្រតិបត្តិការថវិកា ដូចខាងក្រោម៖

- ត្រូវផ្ទៀងផ្ទាត់ឡើងវិញនូវរាល់ប្រតិបត្តិការចំណូលនិងចំណាយថវិកាដែលបានទទួលស្គាល់រួចរាល់ហើយឱ្យដល់ខែធ្នូ
- ត្រូវពិនិត្យអំពីប្រតិបត្តិការថវិកាដែលនៅសេសសល់និងពុំទាន់ទទួលស្គាល់ជាចំណូលឬចំណាយថវិកា
- ត្រូវកំណត់ឱ្យបាននូវប្រតិបត្តិការថវិកាដែលចប់សព្វគ្រប់ត្រឹមថ្ងៃទី៣១ ខែធ្នូ និងប្រតិបត្តិការថវិកាដែលកើតមានក្នុងអំឡុងរយៈពេលបំពេញបន្ថែម ដែលបានកត់ត្រាជាលេខនាគណនេយ្យបន្ថែមនៅថ្ងៃទី៣១ ខែធ្នូ
- ត្រូវញែកឱ្យបាននូវចំណូលនិងចំណាយថវិកាដែលបានទទួលស្គាល់តាមលក្ខខណ្ឌទូទៅ និងចំណូលនិងចំណាយថវិកាដែលបានទទួលស្គាល់តាមលក្ខខណ្ឌដោយឡែក សម្រាប់ជាមូលដ្ឋានក្នុងការពន្យល់អំពីភាពខុសគ្នានៃលទ្ធផលថវិកា លទ្ធផលសាច់ប្រាក់ និងលទ្ធផលគណនេយ្យ
- ត្រូវធ្វើការប្រៀបធៀបគ្នាឡើងវិញរវាងសលាកបត្របង្វែរចំណូល និងចំណូលសាច់ប្រាក់ជាក់ស្តែងក្នុងឆ្នាំ ព្រមទាំងពន្យល់អំពីភាពខុសគ្នា (ករណីបើមាន)
- ត្រូវធ្វើការប្រៀបធៀបគ្នាឡើងវិញរវាងអាណត្តិបើកប្រាក់ចំណាយថវិកា និងចំណាយសាច់ប្រាក់ជាក់ស្តែងក្នុងឆ្នាំ ព្រមទាំងពន្យល់អំពីភាពខុសគ្នា (ករណីបើមាន)
- ត្រូវសហការខ្ពស់ជាមួយនឹងអាណាប័ក និង/ឬ អ្នកត្រួតពិនិត្យថវិកា ក្នុងការស្វែងរកឯកសារគាំទ្រដល់ប្រតិបត្តិការថវិកាណាដែលពុំទាន់បានបញ្ចប់សព្វគ្រប់
- ត្រូវសម្អាតប្រតិបត្តិការថវិកាដែលនៅសេសសល់ចុងក្រោយ ដោយលុបចេញ កែតម្រូវ ធ្វើប្រតិក្រាន្ត ឬដោយវិធីសាស្ត្រផ្សេងទៀត ក្នុងករណីដែលប្រតិបត្តិការទាំងនោះកើតមានឡើងដោយអចេតនា មានភាពមិនប្រក្រតី មិនមានឯកសារគាំទ្រច្បាស់លាស់ និងត្រូវសុំការសម្រេចពីថ្នាក់ដឹកនាំ ព្រមទាំងត្រូវសហការជាមួយនឹងអាណាប័ក និង/ឬ អ្នកត្រួតពិនិត្យថវិកា និង
- ត្រូវធ្វើការប្រៀបធៀបនិងផ្ទៀងផ្ទាត់ទៅវិញទៅមករវាងប្រតិបត្តិការចំណូលនិងចំណាយថវិកាដែលបានទទួលស្គាល់ក្នុងគណនេយ្យថវិកា និងប្រតិបត្តិការដែលបានចុះបញ្ជីគណនេយ្យតាមទ្វេភាគក្នុងគណនេយ្យទូទៅ ដើម្បីធានាសង្គតិភាពនៃប្រតិបត្តិការ និងធានាថាគ្រប់ប្រតិបត្តិការថវិកាត្រូវបានកត់ត្រាទាំងនៅក្នុងគណនេយ្យថវិកានិងគណនេយ្យទូទៅ ព្រមទាំងបង្ការគម្លាតទិន្នន័យចំណូលនិងចំណាយរបស់រដ្ឋ ក្នុងក្របខណ្ឌនៃការរាយការណ៍ថវិកានិងហិរញ្ញវត្ថុ។

### ៥.១.៥ ការកំណត់អំពីទឹកប្រាក់ត្រូវទូទាត់នៅឆ្នាំបន្ទាប់

ក្រោយពីបានធ្វើការសន្យាចំណាយរួចរាល់ (តាមរយៈការចុះកិច្ចសន្យាផ្គត់ផ្គង់ជាដើម) ចំណាយមួយចំនួនពុំអាចអនុវត្តបានទាន់ពេលតាមនីតិវិធីហិរញ្ញវត្ថុសម្រាប់ការទូទាត់ឱ្យបានមុនចុងការិយបរិច្ឆេទនៃឆ្នាំអនុវត្តថវិកា ការណ៍នេះអាចនាំឱ្យមានការប្រើប្រាស់ឥណទានថវិកាឆ្នាំអនុវត្ត (ឥណទានថវិកាមិនប្រើប្រាស់) និងការប្រើប្រាស់ឥណទានថវិកាឆ្នាំបន្ទាប់។ ដូច្នេះ អាណាប័កត្រូវធ្វើការគណនាឱ្យបានច្បាស់លាស់អំពីចំណាយកាតព្វកិច្ច និងចំណាយមិនអាចចៀសវាងបាន ដើម្បីជាមូលដ្ឋានក្នុងការពន្យល់អំពីមុខសញ្ញាឥណទានចំណាយថវិកាដែលមិនបានប្រើប្រាស់ឬទូទាត់ និងជាមូលដ្ឋានក្នុងការសម្រេចចិត្តថា គួរលុបចោលការចំណាយទាំងនោះ ឬស្នើសុំយោងឥណទានថវិកាដែលមិនបានប្រើប្រាស់ទៅឆ្នាំបន្ទាប់ ឬស្នើសុំប្រើប្រាស់ឥណទានថវិកាឆ្នាំបន្ទាប់ ស្របតាមបទប្បញ្ញត្តិជាធរមាន។ ចំណាយកាតព្វកិច្ច សំដៅដល់ចំណាយលើសេវាដែលបានទទួលស្គាល់រួចហើយនៅឆ្នាំថវិកាមុន ហើយមិនទាន់បានទូទាត់រួច។ ចំណាយមិនអាច

បៀសវាងបាន សំដៅដល់ចំណាយដែលនៅជំពាក់មិនទាន់បានទូទាត់នៅក្នុងឆ្នាំថវិកា ចំណាយបន្ទុកបុគ្គលិក និងចំណាយទាក់ទងនឹងការអនុវត្តច្បាប់ និងកិច្ចព្រមព្រៀងជាតិនិងអន្តរជាតិ។

## ៥.២ ការបិទបញ្ជីគណនេយ្យថវិកា

ក្រោយពីបានចាត់ចែងនិងផ្ទៀងផ្ទាត់ត្រឹមត្រូវនូវប្រតិបត្តិការថវិការួចរាល់ហើយ ការបិទបញ្ជីចំណូលនិងចំណាយថវិកានឹងដំណើរការនៅដំណាក់កាលចុងក្រោយបង្អស់។ ការបិទបញ្ជីគណនេយ្យថវិកាមានលក្ខណៈសាមញ្ញជាងការបិទបញ្ជីគណនេយ្យទូទៅ ដោយសារតែប្រតិបត្តិការមានចំនួនតិច ការកត់ត្រាតាមបែបសាមញ្ញ (បូក ដក ឬសល់) និងពាក់ព័ន្ធតែនឹងចំណូលនិងចំណាយថវិកា។ រីឯ ការបិទបញ្ជីគណនេយ្យទូទៅត្រូវគិតដល់គ្រប់ប្រតិបត្តិការផ្សេងទៀត ដូចជា ប្រតិបត្តិការសន្និធិ ទ្រព្យសកម្ម បំណុល រំលស់ ជាដើម ដើម្បីឱ្យការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុអាចឆ្លុះបញ្ចាំងគ្រប់ជ្រុងជ្រោយអំពីស្ថានភាពហិរញ្ញវត្ថុរបស់រដ្ឋ។ ការបិទបញ្ជីគណនេយ្យថវិកាមានលក្ខណៈខុសគ្នាពីការបិទបញ្ជីគណនេយ្យទូទៅ ដោយសារតែ៖

- ជាដំណើរការបញ្ឈប់ បញ្ចប់ និងបិទប្រតិបត្តិការចំណូលនិងចំណាយថវិកា នៅក្នុងបញ្ជីចំណូលនិងចំណាយថវិកា តាមរយៈសលាកបត្រតាមដានចំណូលនិងចំណាយថវិកា ដោយមានការបញ្ជាក់ត្រឹមត្រូវពីគណនេយ្យករសាធារណៈនិងផ្ទៀងផ្ទាត់ជាមួយអាណាប័ក
- មិនមានការផ្ទេរតួលេខចំណូលនិងចំណាយថវិកាទៅគណនីលទ្ធផលថវិកា ដូចការអនុវត្តនៅក្នុងគណនេយ្យទូទៅហើយត្រូវកត់ត្រាទ្វេភាគនោះទេ
- គ្រាន់តែជាការគណនាតួលេខនៅសល់ ឬបូកយោងបន្ត ឬសរុប នៃសលាកបត្រតាមដានចំណូលនិងចំណាយថវិកានីមួយៗ និងបិទសលាកបត្រតាមដាននីមួយៗ នៅត្រឹមថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំអនុវត្ត។

ក៏ប៉ុន្តែ ការបិទបញ្ជីគណនេយ្យថវិកាមានភាពប្រទាក់ក្រឡាគ្នាទៅវិញទៅមកជាមួយនឹងការបិទបញ្ជីគណនេយ្យទូទៅ ដោយសារតែប្រតិបត្តិការថវិកាក៏ជាប្រតិបត្តិការហិរញ្ញវត្ថុនិងគណនេយ្យដែលបានកត់ត្រានៅក្នុងគណនេយ្យទូទៅ មូលដ្ឋានបង្គរផងដែរ។ ដូច្នេះ មុននឹងធ្វើការបិទបញ្ជីគណនេយ្យថវិកា គណនេយ្យករសាធារណៈត្រូវផ្ទៀងផ្ទាត់ឡើងវិញជាមួយនឹងបញ្ជីគណនេយ្យទូទៅផងដែរ និងត្រូវធ្វើការកត់សម្គាល់អំពីភាពខុសគ្នានៃគណនីចំណូលនិងចំណាយថវិកានីមួយៗ។

### ៥.២.១ ក្របខ័ណ្ឌពេលវេលា

ការបិទបញ្ជីគណនេយ្យថវិកាត្រូវអនុវត្តទៅតាមក្របខ័ណ្ឌពេលវេលា ដូចខាងក្រោម៖

- យ៉ាងយូរត្រឹមដំណាច់ខែមករា នៃឆ្នាំបន្ទាប់ក្នុងរយៈពេលបំពេញបន្ថែម ដែលអនុញ្ញាតឱ្យបន្តទទួលសលាកបត្របង្វែរចំណូលនិងអាណត្តិបើកប្រាក់ ឬប្រតិបត្តិការចំណាយក្នុងប្រព័ន្ធ អមដោយសក្ខីបត្រគាំទ្រ
- យ៉ាងយូរត្រឹមដំណាច់ខែកុម្ភៈ នៃឆ្នាំបន្ទាប់ ការបិទបញ្ជីចំណូលនិងចំណាយថវិកា និងរៀបចំរបាយការណ៍ថវិកាដោយគណនេយ្យករសាធារណៈ និង
- យ៉ាងយូរត្រឹមដំណាច់ខែមីនា នៃឆ្នាំបន្ទាប់ ការបូកសរុបរបាយការណ៍ថវិការបស់គណនេយ្យកររតនាគារ។

### ៥.២.២ កិច្ចដំណើរការបិទបញ្ជីគណនេយ្យថវិកា

គណនេយ្យករសាធារណៈត្រូវទទួលខុសត្រូវលើការងារបិទបញ្ជីគណនេយ្យចំណូលនិងចំណាយថវិកា ដោយត្រូវអនុវត្តការងារនេះ តាមយន្តការដូចខាងក្រោម៖

- ត្រូវបិទបញ្ជីចំណូលនិងចំណាយថវិកា តាមមុខសញ្ញានិងគណនីនីមួយៗ ដែលបានកត់ត្រានៅក្នុងសលាកបត្រតាមដានចំណូលថវិកានិងសលាកបត្រតាមដានចំណាយថវិកា ដោយគូសបន្ទាត់បញ្ចប់ និងសរសេរការបញ្ជាក់អំពីទឹកប្រាក់ដែលបានបញ្ចប់ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំអនុវត្តថវិកា ព្រមទាំងចុះហត្ថលេខាលើបញ្ជីនីមួយៗឱ្យបានត្រឹមត្រូវនិងដាក់ថ្ងៃខែឆ្នាំចុះហត្ថលេខាដោយគណនេយ្យករសាធារណៈ
- ត្រូវបិទបញ្ជីចំណូលនិងចំណាយថវិកា ចាប់ពីខែមករា រហូតដល់ខែធ្នូ នៃឆ្នាំអនុវត្តថវិកា

- ក្នុងករណីដែលប្រើប្រាស់ប្រព័ន្ធ FMIS សម្រាប់កត់ត្រាប្រតិបត្តិការថវិកាក្នុងក្របខ័ណ្ឌគណនេយ្យថវិកា គណនេយ្យករសាធារណៈត្រូវអនុវត្តតាមនីតិវិធីដោយឡែកនៅក្នុងប្រព័ន្ធ FMIS សម្រាប់ធ្វើការបិទបញ្ជីគណនេយ្យក្នុងប្រព័ន្ធ FMIS
- ត្រូវស្រង់តួលេខសមតុល្យចុងគ្រា (គិតត្រឹមថ្ងៃទី៣១ ខែធ្នូ) នៃចំណូលនិងចំណាយថវិកាដែលបានបិទនៅក្នុងបញ្ជីគណនេយ្យថវិកា ដាក់ចូលទៅក្នុងរបាយការណ៍ថវិកា។ ជាធម្មតា ប្រព័ន្ធ FMIS នឹងជួយទាញទិន្នន័យនេះដោយស្វ័យប្រវត្តិចូលទៅក្នុងរបាយការណ៍ថវិកា និង
- ត្រូវប្រមូលផ្តុំនិងចងក្រងឯកសារនៃកិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិកាជាប្រចាំថ្ងៃ ខែ និងឆ្នាំ សម្រាប់ការងារសវនកម្ម។

#### ៥.២.៣ តួអង្គពាក់ព័ន្ធ

ការបិទបញ្ជីគណនេយ្យថវិកា មានការពាក់ព័ន្ធនឹងតួអង្គ ដូចខាងក្រោម៖

- គណនេយ្យករសាធារណៈ ដែលទទួលបន្ទុកលើការងារចំណូលនិងចំណាយថវិការបស់អង្គភាពសាធារណៈ
- អាណាប័ក ដែលតាមរយៈប្រធានអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ ឬមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុ ត្រូវផ្តល់កិច្ចសហការខ្ពស់ក្នុងការផ្តល់ឯកសារគាំទ្រនានា និងការផ្ទៀងផ្ទាត់តួលេខចំណូលនិងចំណាយថវិកាជាមួយគណនេយ្យករសាធារណៈ និង
- អ្នកត្រួតពិនិត្យថវិកា ដែលត្រូវសហការផ្តល់ព័ត៌មាន ឬ ឯកសារ (ករណីចាំបាច់) និងសហការផ្ទៀងផ្ទាត់តួលេខចំណូលនិងចំណាយថវិកា ជាមួយគណនេយ្យករសាធារណៈ។

ក្នុងករណីដែលមានការមិនយល់ស្របគ្នាលើការផ្ទៀងផ្ទាត់តួលេខចំណូលនិងចំណាយថវិការវាងអាណាប័ក និង/ឬអ្នកត្រួតពិនិត្យថវិកា និងគណនេយ្យករសាធារណៈ តួលេខចំណូលនិងចំណាយថវិកាដែលបានកត់ត្រានិងរាយការណ៍ដោយគណនេយ្យករសាធារណៈត្រូវចាត់ទុកជាបានការ។

អាណាប័ក អ្នកត្រួតពិនិត្យថវិកា និងគណនេយ្យករសាធារណៈ ត្រូវចូលរួមសហការខ្ពស់ជាអតិបរមា ក្នុងការដោះស្រាយបញ្ហាប្រឈមនានានៃការអនុវត្តថវិកា និងការបិទបញ្ជីគណនេយ្យថវិកា ឱ្យបានទទួលលទ្ធផលល្អប្រសើរនិងទាន់ពេល។ ក្នុងករណីមិនអាចដោះស្រាយបញ្ហាបាន គណនេយ្យករសាធារណៈ និង/ឬអ្នកត្រួតពិនិត្យថវិកា ត្រូវរាយការណ៍ដើម្បីសុំការពិនិត្យនិងសម្រេចពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ការងារបិទបញ្ជីគណនេយ្យថវិកា ទាមទារឱ្យមានការយកចិត្តទុកដាក់ខ្ពស់ ពីតួអង្គពាក់ព័ន្ធ ទាំងក្របខ័ណ្ឌពេលវេលានិងក្រឹត្យក្រមការងារ។ បើមិនដូច្នោះទេ ការងារបិទបញ្ជីគណនេយ្យនឹងពុំអាចសម្រេចបានតាមពេលកំណត់ និងមានផលប៉ះពាល់ដល់ការរាយការណ៍ទៅរដ្ឋសភា តាមរយៈច្បាប់ទូទាត់ថវិកាប្រចាំឆ្នាំ។

### ៥.៣ ការរៀបចំរបាយការណ៍ថវិកា

របាយការណ៍ថវិកាសំដៅដល់របាយការណ៍ចំណូលនិងចំណាយថវិការដ្ឋ ដែលឆ្លុះបញ្ចាំងអំពីការអនុវត្តថវិកាប្រចាំឆ្នាំ ដោយធ្វើការប្រៀបធៀបទៅនឹងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ព្រមទាំងរំលេចឱ្យឃើញនូវឥណទានថវិកាមិនបានប្រើប្រាស់ និងឥណទានថវិកាត្រូវយោងទៅឆ្នាំបន្ទាប់ (ករណីបើមាន)។ របាយការណ៍ថវិកាគឺជាសមាសធាតុមួយដ៏សំខាន់នៃរបាយការណ៍របស់រដ្ឋ ក្នុងក្របខ័ណ្ឌនៃការអនុវត្តហិរញ្ញវត្ថុសាធារណៈ។ របាយការណ៍ថវិកាមានគោលបំណងផ្តល់នូវព័ត៌មានស្តីពីលទ្ធផលនៃការអនុវត្តចំណូលនិងចំណាយថវិកាដោយអាណាប័ក ក្នុងក្របខ័ណ្ឌនៃគម្រោងថវិកាដែលបានផ្តល់ជូន សម្រាប់ជាមូលដ្ឋានរាយការណ៍ដល់ស្ថាប័ននីតិប្បញ្ញត្តិនិងសាធារណជន។

#### ៥.៣.១ មូលដ្ឋាននៃការរៀបចំរបាយការណ៍ថវិកា

របាយការណ៍ថវិកាត្រូវបានរៀបចំដោយផ្អែកលើទិន្នន័យ ដែលទាញចេញពីគណនេយ្យថវិកា តាមមូលដ្ឋានសាច់ប្រាក់ និងទាញចេញពីប្រព័ន្ធ FMIS។

របាយការណ៍ថវិកាត្រូវផ្អែកលើតួលេខនៃសលាកបត្រតាមដានចំណូលនិងចំណាយថវិកា។

### ៥.៣.២ ប្រភេទរបាយការណ៍ថវិកា

របាយការណ៍ថវិកា រួមមាន៖

១. របាយការណ៍ចំណូលថវិកា និង

២. របាយការណ៍ចំណាយថវិកា។

ទម្រង់នៃរបាយការណ៍ចំណូលថវិកា មានភ្ជាប់ជាឧបសម្ព័ន្ធជាមួយនឹងគោលការណ៍ណែនាំនេះ។

របាយការណ៍ថវិកាអាចរៀបចំលម្អិតបន្ថែមទៅតាមចំណាត់ថ្នាក់នៃមាតិកាថវិការដ្ឋ តាមតម្រូវការព័ត៌មានចាំបាច់នានា សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការរាយការណ៍ជូនរដ្ឋសភា ដូចជា របាយការណ៍ចំណាយថវិកាតាមមុខសញ្ញាចំណាយ និងតាមកម្មវិធី ជាដើម។ ទម្រង់នៃរបាយការណ៍លម្អិតទាំងនេះត្រូវកំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយផ្អែកតាមតម្រូវការចាំបាច់។

### ៥.៣.៣ អ្នករៀបចំរបាយការណ៍ថវិកា

របាយការណ៍ថវិកាត្រូវបានរៀបចំឡើងដោយគណនេយ្យករសាធារណៈ ដោយត្រូវសហការផ្ទៀងផ្ទាត់ជាមួយនឹងអាណាប័ក និង/ឬ អ្នកត្រួតពិនិត្យថវិកា។ របាយការណ៍ថវិកាត្រូវបានចុះហត្ថលេខានិងបញ្ជាក់ទទួលស្គាល់ដោយអាណាប័ក និងក្នុងករណីដែលមិនមានចុះហត្ថលេខាបញ្ជាក់របស់អាណាប័កលើរបាយការណ៍ថវិកា គណនេយ្យករសាធារណៈមានសិទ្ធិប្រើប្រាស់របាយការណ៍ថវិកាដែលបានរៀបចំរួចរាល់ សម្រាប់ជាមូលដ្ឋានក្នុងការរាយការណ៍ផ្លូវការអំពីការអនុវត្តថវិការបស់អាណាប័ក។

អគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវរៀបចំប្រព័ន្ធ FMIS ដោយសហការជាមួយអង្គភាពពាក់ព័ន្ធ ដើម្បីផលិតនិងទាញរបាយការណ៍ថវិកាដោយស្វ័យប្រវត្តិពីប្រព័ន្ធ FMIS ឱ្យបានត្រឹមត្រូវនិងមានគុណភាព។

### ៥.៣.៤ កាលកំណត់នៃការរៀបចំរបាយការណ៍ថវិកា

របាយការណ៍ថវិកាប្រចាំខែ ត្រូវរៀបចំឱ្យបានរួចរាល់យ៉ាងយូរបំផុតត្រឹមដំណាច់សប្តាហ៍ទី២ នៃខែបន្ទាប់។

របាយការណ៍ថវិកាប្រចាំឆ្នាំ ត្រូវរៀបចំឱ្យបានរួចរាល់យ៉ាងយូរបំផុតត្រឹមដំណាច់ខែកុម្ភៈ នៃឆ្នាំបន្ទាប់។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងកំណត់លម្អិតបន្ថែមអំពីក្របខ័ណ្ឌពេលវេលានៃការរៀបចំរបាយការណ៍ថវិកាទៅតាមប្រភេទរដ្ឋបាលសាធារណៈនីមួយៗ ដើម្បីធានាដល់ការធ្វើមជ្ឈការតួលេខនិងបូកសរុបរបាយការណ៍ថវិការបស់គណនេយ្យកររតនាគារកណ្តាលបានទាន់ពេល។

### ៥.៣.៥ ការបញ្ជូនរបាយការណ៍ថវិកា៖

ក្រោយពីបានរៀបចំរួចរាល់ គណនេយ្យករសាធារណៈត្រូវបញ្ជូនរបាយការណ៍ថវិកាទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកានិងអគ្គនាយកដ្ឋានរតនាគារជាតិ) ដើម្បីបូកសរុបនិងមុខការបន្ត។

របាយការណ៍ថវិកាត្រូវបានបញ្ជូនទៅអាជ្ញាធរសវនកម្មជាតិ ដើម្បីពិនិត្យនិងផ្តល់មតិសវនកម្ម ក្នុងក្របខ័ណ្ឌនៃការធ្វើសវនកម្មនៃការគ្រប់គ្រងថវិការដ្ឋប្រចាំឆ្នាំ ស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

របាយការណ៍ថវិកាត្រូវភ្ជាប់ជាឧបសម្ព័ន្ធនៃសេចក្តីព្រាងច្បាប់ទូទាត់ថវិកាប្រចាំឆ្នាំ ដែលត្រូវដាក់ឆ្លងគណៈរដ្ឋមន្ត្រីពិនិត្យនិងសម្រេច មុននឹងបញ្ជូនទៅរដ្ឋសភានិងព្រឹទ្ធសភា ដើម្បីពិនិត្យនិងអនុម័ត។

## ៥.៤ ការគណនាលទ្ធផល

ក្រោយពីការអនុវត្តថវិកាបានចប់សព្វគ្រប់ពេញមួយឆ្នាំ គណនេយ្យករសាធារណៈត្រូវគណនារកលទ្ធផលដែលកើតចេញពីការអនុវត្តថវិកា រួមមានលទ្ធផលថវិកា, លទ្ធផលសាច់ប្រាក់ និងលទ្ធផលគណនេយ្យ។ លទ្ធផលដែលទទួលបានអាចជាអតិរេក ឬ ឱនភាព និងអាស្រ័យទៅតាមប្រភេទនៃលទ្ធផលនីមួយៗ។ ភាពខុសគ្នានៃប្រភេទលទ្ធផលនេះបណ្តាលមកពីមូលដ្ឋានគិតនៃប្រព័ន្ធគណនេយ្យសាធារណៈនីមួយៗ (មូលដ្ឋានសាច់ប្រាក់សម្រាប់គណនេយ្យថវិកា និងមូលដ្ឋានបង្គរសម្រាប់គណនេយ្យទូទៅ) និងលក្ខខណ្ឌនានាដែលបានអនុញ្ញាតដោយបទដ្ឋានជាធរមាន (ឧទាហរណ៍៖

ចំណូលមួយចំនួនទទួលស្គាល់ បើទោះបីជាពុំមានសាច់ប្រាក់ចូលក្នុងឆ្នាំ ដូចជាករណីឧបត្ថម្ភធន ជាដើម)។ ការគណនាកេលទ្ធផលមានសារសំខាន់ក្នុងការពិនិត្យ តាមដាន និងវាយតម្លៃអំពីប្រសិទ្ធភាពនៃការអនុវត្តថវិកា, ការវាស់វែងអំពីសមិទ្ធផលនៃការអនុវត្តថវិការបស់អាណាប័ក, ការប្រើប្រាស់អតិរេកថវិកានៅឆ្នាំបន្ទាប់, ការវិភាគ ជាដើម។ អាណាប័កអាចគណនាលម្អិតបន្ថែមទៀតអំពីលទ្ធផលនៃការអនុវត្តថវិកា អាស្រ័យទៅតាមតម្រូវការគ្រប់គ្រងការងារហិរញ្ញវត្ថុរបស់ខ្លួន ដោយអាចលម្អិតជាលទ្ធផលចរន្ត ឬ លទ្ធផលវិនិយោគ។

### ៥.៤.១ លទ្ធផលថវិកា

លទ្ធផលថវិកាគឺជាផលដករវាងទឹកប្រាក់ចំណូលថវិកានិងចំណាយថវិកា ដែលបានកត់ត្រាទទួលស្គាល់នៅក្នុងកិច្ចបញ្ជិកាគណនេយ្យថវិកា តាមមូលដ្ឋានសាច់ប្រាក់។

លទ្ធផលថវិកាអាចជាអតិរេកថវិកា (ចំណូលថវិកាធំជាងចំណាយថវិកា) ឬឱនភាពថវិកា (ចំណូលថវិកាតូចជាងចំណាយថវិកា)។

លទ្ធផលថវិកាអាចលម្អិតជាលទ្ធផលថវិកាចរន្ត និងលទ្ធផលថវិកាវិនិយោគ ។

លទ្ធផលថវិកាចរន្តគឺជាផលដករវាងចំណូលថវិកាចរន្តនិងចំណាយថវិកាចរន្ត។ លទ្ធផលទទួលបានអាចជាអតិរេកថវិកាចរន្ត ឬ ឱនភាពថវិកាចរន្ត។

លទ្ធផលថវិកាវិនិយោគគឺជាផលដករវាងចំណូលថវិកាវិនិយោគនិងចំណាយថវិកាវិនិយោគ។ លទ្ធផលទទួលបានអាចជាអតិរេកថវិកាវិនិយោគ ឬ ឱនភាពថវិកាវិនិយោគ។

### ៥.៤.២ លទ្ធផលសាច់ប្រាក់

លទ្ធផលសាច់ប្រាក់គឺជាផលដករវាងទឹកប្រាក់ចំណូលសាច់ប្រាក់សរុបនិងចំណាយសាច់ប្រាក់សរុប ដែលកើតមាននៅក្នុងឆ្នាំអនុវត្តថវិកា និងបានចុះកិច្ចបញ្ជិកានៅក្នុងគណនេយ្យទូទៅ។

លទ្ធផលសាច់ប្រាក់អាចជាអតិរេកសាច់ប្រាក់ (ចំណូលសាច់ប្រាក់ធំជាងចំណាយសាច់ប្រាក់) ឬ ឱនភាពសាច់ប្រាក់ (ចំណូលសាច់ប្រាក់តូចជាងចំណាយសាច់ប្រាក់)។

លទ្ធផលសាច់ប្រាក់អាចលម្អិតជាលទ្ធផលសាច់ប្រាក់ចរន្តនិងលទ្ធផលសាច់ប្រាក់វិនិយោគ។

លទ្ធផលសាច់ប្រាក់ចរន្តគឺជាផលដករវាងចំណូលសាច់ប្រាក់ចរន្តនិងចំណាយសាច់ប្រាក់ចរន្ត។ លទ្ធផលទទួលបានអាចជាអតិរេកសាច់ប្រាក់ចរន្ត ឬ ឱនភាពសាច់ប្រាក់ចរន្ត។

លទ្ធផលសាច់ប្រាក់វិនិយោគគឺជាផលដករវាងចំណូលសាច់ប្រាក់វិនិយោគនិងចំណាយសាច់ប្រាក់វិនិយោគ។ លទ្ធផលទទួលបានអាចជាអតិរេកសាច់ប្រាក់វិនិយោគ ឬ ឱនភាពសាច់ប្រាក់វិនិយោគ។

### ៥.៤.៣ លទ្ធផលគណនេយ្យ

លទ្ធផលគណនេយ្យគឺជាផលដករវាងទឹកប្រាក់ចំណូលនិងចំណាយ ដែលបានកត់ត្រាទទួលស្គាល់នៅក្នុងកិច្ចបញ្ជិកាគណនេយ្យទូទៅ មូលដ្ឋានបង្គរ។

លទ្ធផលគណនេយ្យ អាចជាអតិរេកគណនេយ្យ (ចំណូលធំជាងចំណាយ) ឬ ឱនភាពគណនេយ្យ (ចំណូលតូចជាងចំណាយ)។

លទ្ធផលគណនេយ្យអាចលម្អិតជាលទ្ធផលគណនេយ្យចរន្ត និងលទ្ធផលគណនេយ្យវិនិយោគ។

លទ្ធផលគណនេយ្យចរន្តគឺជាផលដករវាងចំណូលចរន្តនិងចំណាយចរន្ត។ លទ្ធផលទទួលបានអាចជាអតិរេកគណនេយ្យចរន្ត ឬ ឱនភាពគណនេយ្យចរន្ត។

លទ្ធផលគណនេយ្យវិនិយោគគឺជាផលដករវាងចំណូលវិនិយោគនិងចំណាយវិនិយោគ។ លទ្ធផលទទួលបានអាចជាអតិរេកគណនេយ្យវិនិយោគ ឬ ឱនភាពគណនេយ្យវិនិយោគ។

### ៥.៤.៤ អតិរេកដែលអាចប្រើប្រាស់បាន

ក្នុងករណីដែលមាន អតិរេកថវិកា ហើយអាណាប័កមានបំណងចង់ប្រើប្រាស់ដើម្បីគោលដៅអភិវឌ្ឍន៍ និង/ឬ រ៉ាប់រងតម្រូវការចាំបាច់ដោយថាហេតុ អាណាប័កពុំអាចយកតួលេខអតិរេកថវិកាដែលបានគណនាតាមរូបមន្តខាងលើមកប្រើប្រាស់បានទេ ដោយសារតែតួលេខអតិរេកថវិកានេះ គឺជាតួលេខដុលដែលរួមបញ្ចូលទាំងសមាសធាតុផ្សេងៗ ដូចជាបំណុលត្រូវសង ការចំណាយលើសន្និធិ ជាដើម និងមិនប្រាកដថាមានសាច់ប្រាក់គ្រប់គ្រាន់ដែលធានាដល់ការប្រើប្រាស់អតិរេកថវិកានេះទេ។ ដូច្នេះ អាណាប័កត្រូវសហការជាមួយគណនេយ្យករសាធារណៈ ដើម្បីពិនិត្យនិងគណនារកអតិរេកដែលអាចប្រើប្រាស់បានពិតប្រាកដ ដើម្បីធានាថា មានសាច់ប្រាក់គ្រប់គ្រាន់សម្រាប់ការទូទាត់ចំណាយដែលអាចកើតចេញពីការប្រើប្រាស់អតិរេក និងអាចដោះស្រាយការជំពាក់បំណុលនានាដោយប្រក្រតីភាព។

អតិរេកថវិកាត្រូវចាត់ចែងស្របតាមច្បាប់បទប្បញ្ញត្តិ និងនីតិវិធីហិរញ្ញវត្ថុជាធរមាន ។ ការប្រើប្រាស់និងចាត់ចែងអតិរេកថវិការបស់រដ្ឋ ជាកម្មវត្ថុនៃការត្រួតពិនិត្យនិងសម្រេចពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

# ជំពូកទី៦

# ការត្រួតពិនិត្យនិងសវនកម្ម

ការត្រួតពិនិត្យនិងសវនកម្មលើការងារគណនេយ្យថវិកាដែលបានអនុវត្តដោយអាណាប័កនិងគណនេយ្យករសាធារណៈ និងអ្នកត្រួតពិនិត្យថវិកា ជួយធានាដល់ភាពត្រឹមត្រូវ គ្រប់ជ្រុងជ្រោយ និងគុណភាពនៃទិន្នន័យចំណូលនិងចំណាយថវិកា ព្រមទាំងការរាយការណ៍ថវិកា ក្នុងក្របខ័ណ្ឌនៃការអនុវត្តគណនេយ្យថវិកា។

## ៦.១ តួអង្គពាក់ព័ន្ធ

អាណាប័កត្រូវរៀបចំនិងដាក់ឱ្យអនុវត្តនូវប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ខ្លួន រួមទាំងសវនកម្មផ្ទៃក្នុង ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តកិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិកា ដែលមានការពាក់ព័ន្ធផ្ទាល់ទៅនឹងសមត្ថកិច្ចនិងការទទួលខុសត្រូវរបស់ខ្លួន។ អាណាប័កត្រូវទទួលរងនូវការធ្វើសវនកម្មពីស្ថាប័នមានសមត្ថកិច្ច ស្របតាមបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

ការត្រួតពិនិត្យលើការងារអនុវត្តគណនេយ្យថវិការបស់គណនេយ្យករសាធារណៈត្រូវអនុវត្តដោយអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង និង/ឬអគ្គាធិការដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងស្ថាប័នមានសមត្ថកិច្ច ស្របតាមបទប្បញ្ញត្តិជាធរមាន បន្ទាប់ពីមានការអនុញ្ញាតរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

អាណាប័ក គណនេយ្យករសាធារណៈ និងអ្នកត្រួតពិនិត្យថវិកា មានកាតព្វកិច្ចផ្តល់កិច្ចសហការខ្ពស់ និងឯកសារឬព័ត៌មាននានា ពាក់ព័ន្ធនឹងកិច្ចប្រតិបត្តិការថវិកា និងការអនុវត្តគណនេយ្យថវិកា ដល់អង្គភាពធ្វើសវនកម្ម ស្របតាមបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

អាណាប័ក គណនេយ្យករសាធារណៈ និងអ្នកត្រួតពិនិត្យថវិកា ត្រូវពិនិត្យនិងកែលម្អតាមមតិសវនកម្ម ដើម្បីធានាដល់ប្រសិទ្ធភាពនៃការអនុវត្តគណនេយ្យថវិកា ស្របតាមបទប្បញ្ញត្តិជាធរមាន។

មន្ត្រីគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ត្រូវសហការសម្របសម្រួលជាមួយអ្នកត្រួតពិនិត្យ និង/ឬអង្គភាពធ្វើសវនកម្មឱ្យបានទាន់ពេល ដើម្បីគាំទ្រដល់ការធ្វើសវនកម្ម/ត្រួតពិនិត្យស្របតាមបទប្បញ្ញត្តិជាធរមាន។

## ៦.២ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

ការត្រួតពិនិត្យនិងសវនកម្មលើការអនុវត្តគណនេយ្យថវិកា អាចប្រព្រឹត្តទៅតាមរយៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

## ឧបសម្ព័ន្ធ

### ឧបសម្ព័ន្ធ១៖ សទ្ទានុក្រម

វាក្យស័ព្ទដែលប្រើប្រាស់នៅក្នុងគោលការណ៍ណែនាំនេះត្រូវបានកំណត់និយមន័យ ដូចខាងក្រោម៖

**កិច្ចបញ្ជិកាគណនេយ្យ** សំដៅដល់ការកត់ត្រាប្រតិបត្តិការហិរញ្ញវត្ថុនិងគណនេយ្យដោយអនុលោមតាមគោលការណ៍ទ្វេភាគ ឬគោលការណ៍ឯកភាគ និងតាមគោលកាណ៍ណែនាំជាធរមាន ព្រមទាំងស្តង់ដាគណនេយ្យសាធារណៈជាតិនិងអន្តរជាតិ។

**គណនីត្រូវទទួល** សំដៅដល់គណនីសម្រាប់កត់ត្រាចំនួនទឹកប្រាក់ ដែលអតិថិជនឬឥណាយិកជំពាក់រដ្ឋពីការផ្គត់ផ្គង់ទំនិញឬសេវាកម្ម បំណុលពន្ធ ចំណូលដែលបានពីចំណូលសារពើពន្ធ ការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ និងការផាកពិន័យ ឬចំណូលផ្សេងទៀត ប៉ុន្តែអតិថិជនឬឥណាយិកមិនទាន់បានទូទាត់ជូនរដ្ឋនៅឡើយ។ គណនីត្រូវទទួលកើតចេញពីការផ្គត់ផ្គង់ទំនិញឬសេវាកម្មដោយជំពាក់ ឬមុខសញ្ញាចំណូលដែលមិនទាន់បានទូទាត់ និងដឹងអំពីទំហំទឹកប្រាក់ជាក់លាក់និងកាលបរិច្ឆេទទទួលសាច់ប្រាក់ត្រលប់មកវិញពីអតិថិជនឬឥណាយិក។ គណនីត្រូវទទួល ត្រូវរាយការណ៍ក្នុងតារាងតុល្យការជាទ្រព្យសកម្មរយៈពេលខ្លី។

**គណនេយ្យថវិកា** សំដៅដល់ការកត់ត្រា តាមដាន និងរាយការណ៍អំពីការប្រើប្រាស់ឥណទានថវិកា ទាំងចំណូលនិងចំណាយថវិកាដែលបានកំណត់ដោយច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ និងត្រូវឆ្លុះបញ្ចាំងអំពីការគ្រោងនិងការប្រើប្រាស់ឥណទានភ្ជាប់សន្យានិងឥណទានទូទាត់ និងឥណទានថវិកានៃចំណាយចរន្ត ព្រមទាំងកត់ត្រានូវចំណូលដែលបានប្រមូល។

**គណនេយ្យទូទៅ** សំដៅដល់ការកត់ត្រាគ្រប់ប្រតិបត្តិការហិរញ្ញវត្ថុនិងគណនេយ្យ និងរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដែលឆ្លុះបញ្ចាំងអំពីភាពពិតប្រាកដនិងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុ និងលទ្ធផលហិរញ្ញវត្ថុ។

**គោលការណ៍ទ្វេភាគ** សំដៅដល់វិធីសាស្ត្រនៃការចុះកិច្ចបញ្ជិកាគណនេយ្យមួយ ដែលការកត់ត្រាសកម្មភាពគណនេយ្យទាមទារឱ្យមានការកត់ត្រាគណនីមួយឬច្រើននៅផ្នែកឥណពន្ធ និងមួយឬច្រើននៅផ្នែកឥណទាន ដើម្បីឱ្យកំណត់ត្រាមានសមតុល្យ ឬមានលំនឹង។

**គោលការណ៍ឯកភាគ** សំដៅដល់វិធីសាស្ត្រនៃការចុះកិច្ចបញ្ជិកាគណនេយ្យសាមញ្ញមួយ ដោយការកត់ត្រាចំនួនទឹកប្រាក់ដែលបានចំណាយ ឬ បានទទួលនៅក្នុងគណនីតែមួយឬទទួលស្គាល់តែផ្នែកម្ខាងនៃប្រតិបត្តិការ។

**ថវិកាកម្មវិធី** សំដៅដល់ការរៀបចំថវិកាដោយផ្អែកលើកម្មវិធីច្បាស់លាស់ ដើម្បីឈានទៅសម្រេចគោលបំណងគោលនយោបាយរបស់អង្គភាពសាធារណៈ ស្របតាមគោលនយោបាយដែលបានកំណត់ក្នុងវិស័យនីមួយៗ។ ថវិកាកម្មវិធីត្រូវមានសូចនាករសមិទ្ធកម្មសម្រាប់ជាយន្តការតាមដាន ដើម្បីវាស់វែង ធ្វើរបាយការណ៍លទ្ធផលក្នុងឆ្នាំ និងលទ្ធផលចុងក្រោយទៅតាមកម្មវិធីនីមួយៗ ព្រមទាំងត្រូវកំណត់ឱ្យបានច្បាស់លាស់នូវថ្លៃជាតុចូលសម្រាប់អនុវត្តកម្មវិធី ដែលរួមមាន ទាំងចំណាយចរន្ត និងចំណាយមូលធន។

**ថវិកាសមិទ្ធកម្ម** សំដៅដល់ការរៀបចំកញ្ចប់ថវិកា ដោយមានការផ្សារភ្ជាប់ទៅនឹងសមិទ្ធកម្ម ដែលក្រសួង ស្ថាប័នបានស្នើឡើង ឬសម្រេចកន្លងមក។

**ទឹកប្រាក់ដុល** សំដៅដល់ចំនួនទឹកប្រាក់សរុបដែលរដ្ឋប្រមូលបានតាមរយៈចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធ និងចំណូលផ្សេងៗ មុនពេលដកចេញឬមិនទាន់កាត់កងជាមួយទឹកប្រាក់ចំណាយណាមួយ។

**ប្រតិក្រាន្ត** សំដៅដល់វិធីសាស្ត្រនៃការកត់ត្រាត្រឡប់ឬបញ្ច្រាសវិញនូវលេខនាគណនេយ្យដែលបានកត់ត្រាក្នុងការិយបរិច្ឆេទឬមុនពេលបិទបញ្ជីគណនេយ្យ។

**ព្រឹត្តិការណ៍ចំណាយ** សំដៅដល់ហេតុឬដំណើរប្រព្រឹត្តទៅទាំងឡាយណាដែលបង្កើតឱ្យមានលំហូរសាច់ប្រាក់ចេញ /បង្កើតបន្ទុកជាស្ពាតរបស់រដ្ឋ។

**ព្រឹត្តិការណ៍ចំណូល** សំដៅដល់ហេតុឬដំណើរប្រព្រឹត្តទៅទាំងឡាយណាដែលបង្កើតឱ្យមានលំហូរសាច់ប្រាក់ចូល/បង្កើតធនធានជាស្ពាតរបស់រដ្ឋ។

**មូលដ្ឋានបង្គរ** សំដៅដល់មូលដ្ឋានគណនេយ្យមួយដែលប្រតិបត្តិការឬព្រឹត្តិការណ៍មួយត្រូវបានទទួលស្គាល់នៅពេលដែលព្រឹត្តិការណ៍បានកើតឡើង (មិនកំណត់ត្រឹមតែនៅពេលដែលសាច់ប្រាក់ ឬសមមូលសាច់ប្រាក់ត្រូវបានទទួល ឬ ត្រូវបានទូទាត់)។

**មូលដ្ឋានសាច់ប្រាក់** សំដៅដល់មូលដ្ឋានគណនេយ្យមួយដែលទទួលស្គាល់ប្រតិបត្តិការ និងព្រឹត្តិការណ៍ដទៃទៀតតែនៅពេលដែលសាច់ប្រាក់ត្រូវបានទទួល ឬត្រូវបានទូទាត់តែប៉ុណ្ណោះ។

**សាច់ប្រាក់និងសាច់ប្រាក់សមមូល** សំដៅដល់សាច់ប្រាក់ក្នុងដៃ សមតុល្យគណនីធនាគារផ្សេងៗ ឬទ្រព្យសកម្មផ្សេងទៀត ដែលងាយស្រួលក្នុងការបំប្លែងជាសាច់ប្រាក់ជាក់លាក់ និងប្រឈមនឹងហានិភ័យនៃការផ្លាស់ប្តូរតម្លៃឬការប្រែប្រួលតម្លៃតិចតួចបំផុត។

**អង្គភាពសាធារណៈ** សំដៅដល់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពរដ្ឋដទៃទៀតដែលទទួលបានថវិការដ្ឋ។

**ឥណទានគ្រោង** សំដៅដល់ចំនួនឥណទានដែលក្រសួង ស្ថាប័នបានគ្រោង និងស្នើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលជាកម្មវត្ថុនៃកិច្ចប្រជុំការពារគម្រោងថវិកាប្រចាំឆ្នាំ។

**ឥណទានថវិកា** សំដៅដល់ថវិការដ្ឋ ដែលអនុម័តដោយរដ្ឋសភា ពិនិត្យឱ្យយោបល់ដោយព្រឹទ្ធសភា និងប្រកាសឱ្យប្រើដោយព្រះរាជក្រមអនុញ្ញាតឱ្យប្រមូលចំណូលបង់ចូលថវិកាជាតិ និងចំណាយថវិកាជាតិ សម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ តាមមាតិកាថវិកា។ ឥណទានថវិកានេះ ត្រូវបានបែងចែកតាមក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែលនីមួយៗ រដ្ឋបាលថ្នាក់ក្រោមជាតិ និងតាមប្រភេទចំណាយ។

**ឥណទានទូទាត់** ត្រូវប្រើសម្រាប់ចេញបញ្ជាចំណាយដែលជាបន្ទុករបស់រដ្ឋទៅតាមលក្ខខណ្ឌទូទាត់នៃកិច្ចសន្យាគម្រោងវិនិយោគ និងនៅក្នុងកម្រិតនៃឥណទានភ្ជាប់សន្យា។ ឥណទានទូទាត់ ត្រូវដាក់នៅក្រោមអាណាប័កសម្រាប់ចំណាយចាំបាច់ក្នុងការអនុវត្តគម្រោងវិនិយោគ ដែលបានកំណត់នៅក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ។

**ឥណទានភ្ជាប់សន្យា** សំដៅដល់ឥណទានកំហិតកំណត់ដែលត្រូវបានអនុញ្ញាតនៅក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំសម្រាប់ឱ្យរាជរដ្ឋាភិបាលធ្វើការធានាចំណាយសម្រាប់ប្រតិបត្តិការទាំងស្រុងនៃគម្រោងឬកម្មវិធីវិនិយោគដែលបានគ្រោងដោយមិនអនុញ្ញាតឱ្យមានការគ្រោងឥណទានបន្ថែមសម្រាប់បញ្ចប់នោះទេ។ ឥណទានភ្ជាប់សន្យានេះត្រូវមានសង្គតិភាពទៅនឹងក្របខ័ណ្ឌថវិការយៈពេលមធ្យម និងធានាបាននូវចីរភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។ ឥណទានភ្ជាប់សន្យា ត្រូវដាក់នៅក្រោមអាណាប័កសម្រាប់ចំណាយចាំបាច់ក្នុងការអនុវត្តគម្រោងវិនិយោគដែលបានកំណត់នៅក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ។

**ឥណទានអនុវត្ត** សំដៅដល់ឥណទានដែលបានអនុម័តក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ សម្រាប់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិ យកទៅប្រើប្រាស់ក្នុងការអនុវត្តសកម្មភាពការងារដោយមានទំនួលខុសត្រូវលើការអនុវត្តរបស់ខ្លួន ដើម្បីរួមចំណែកសម្រេចបាននូវគោលបំណង គោលនយោបាយរួម។

**ឥណទេយ្យ** សំដៅដល់សិទ្ធិដែលអង្គភាពសាធារណៈមាន ក្នុងការទាមទារឬប្រមូលយកអ្វីមួយពីអ្នកជាប់បំណុល។

**ឧបសម្ព័ន្ធ២៖ ទម្រង់ឯកសារគណនេយ្យថវិកា**

២.១. គំរូសលាកបត្របង្វែរចំណូល

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

{Logo}
**{ឈ្មោះក្រសួង ស្ថាប័ន}**
**{ឈ្មោះអង្គភាព}**
លេខ...........................

ថ្ងៃ..............ខែ..............ឆ្នាំ..........ស័ក ព.ស................
ធ្វើនៅ............ថ្ងៃទី........ខែ.........ឆ្នាំ...........................

## សលាកបត្របង្វែរចំណូល

-លេខសម្គាល់៖ {លេខកូដក្រសួងឬអង្គភាព}
-ឥណពន្ធ ៖ ..............................
-ឥណទាន ៖..............................

-ឈ្មោះនិងអាសយដ្ឋាននៃអង្គភាពបង្វែរចំណូលចូលថវិកាជាតិ៖.............................
-ឈ្មោះនិងអាសយដ្ឋាននៃអង្គភាពជាម្ចាស់គ្រប់គ្រង៖..........................................
-ធនាគារជាតិ៖................................................................................................
-ដកចេញពីគណនី៖...........................................................................................................
របស់យើងខ្ញុំដើម្បីបង្វែរចូលថវិកាជាតិ

| អនុគណនី | អត្ថន័យខ្ទង់ចំណូល | ចំនួនទឹកប្រាក់ | | | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ដុល្លារអាមេរិកទៅជារៀល | រៀល | សរុបទឹកប្រាក់ជារៀល |
| | | | | | |
| | | | | | |
| | សរុបរួម | | | | |

ចំនួនទឹកប្រាក់សរសេរជាអក្សរ៖...........................................................................................................។

**ផ្នែកខាងអាណាប័ក រដ្ឋបាលថ្នាក់ជាតិ ឬ រដ្ឋបាលថ្នាក់ក្រោមជាតិ ឬ គ្រឹះស្ថានសាធារណៈរដ្ឋបាល**

**ផ្នែកខាងគណនេយ្យករសាធារណៈ**

ថ្ងៃ......... ខែ.......ឆ្នាំ......ស័ក ព.ស........
ធ្វើនៅ.........ថ្ងៃទី....ខែ......ឆ្នាំ................

## ២.២. គំរូអាណត្តិបើកប្រាក់ចំណាយថវិកា


ព្រះរាជាណាចក្រកម្ពុជា

ក្រសួង: ..............................

កងថវិកា លេខ: ..............................

# អាណត្តិបើកប្រាក់

ការគ្រប់គ្រងឆ្នាំ ២០២៤

លេខចុះបញ្ជីកិច្ច: 

លេខអាណត្តិ: 

| រដ្ឋបាល | ភូមិសាស្ត្រ | មុខងារ | មូលនិធិ | កម្មវិធី-អនុកម្មវិធី-ចង្កោមសកម្មភាព | គម្រោង |
|---|---|---|---|---|---|
| | | | | | |

| ជំពូក-គណនី-អនុគណនី | ចំនួនទឹកប្រាក់ | កម្មវត្ថុចំណាយ/ឈ្មោះសកម្មភាព |
|---|---|---|
| | | |
| សរុបរួម | | ឈ្មោះអត្ថគាហកចំណាយ: |

ឈ្មោះ និងអាសយដ្ឋានអត្ថគាហក:

វិធីទូទាត់: ☐ មូលប្បទានបត្រ ☐ សាច់ប្រាក់

លេខគណនី:

អាសយដ្ឋានធនាគារ ឬរតនាគារ:

អាណត្តិនេះកំណត់ត្រឹមទឹកប្រាក់ចំនួន ..............................

ហត្ថលេខា និងត្រា របស់អាណាប័ក

កាលបរិច្ឆេទ:

**ទិដ្ឋាការអភិបាលហិរញ្ញវត្ថុ**

លេខសលាកបត្រ:

ហត្ថលេខា និងត្រា

កាលបរិច្ឆេទ:

**កន្លែងសម្រាប់គណនេយ្យករ**

ចំនួនទឹកប្រាក់នៃអាណត្តិ: ..............................

ការដកហូត និងការឃាត់ទុក: ..............................

ចំនួនទឹកប្រាក់ពិតប្រាកដត្រូវបើក: ..............................

ការត្រួតពិនិត្យ និងអនុញ្ញាតឱ្យបើកផ្តល់

ហត្ថលេខា និងត្រា

កាលបរិច្ឆេទ:

ក្រសួង: ..............................

កងថវិកា លេខ: ..............................

# អាណត្តិបើកប្រាក់

លេខចុះបញ្ជីកិច្ច: 

លេខអាណត្តិ: 

កាលបរិច្ឆេទ:

| រដ្ឋបាល | ភូមិសាស្ត្រ | មុខងារ | មូលនិធិ | កម្មវិធី-អនុកម្មវិធី-ចង្កោមសកម្មភាព | គម្រោង |
|---|---|---|---|---|---|
| | | | | | |

| ជំពូក-គណនី-អនុគណនី | ចំនួនទឹកប្រាក់ | កម្មវត្ថុចំណាយ/ឈ្មោះសកម្មភាព |
|---|---|---|
| | | |
| សរុបរួម | | ឈ្មោះអត្ថគាហកចំណាយ: |

អាណត្តិនេះកំណត់ត្រឹមទឹកប្រាក់ចំនួន ..............................

ឈ្មោះ និងអាសយដ្ឋានអត្ថគាហក:

**កន្លែងសម្រាប់គណនេយ្យករ**

ចំនួនទឹកប្រាក់នៃអាណត្តិ: ..............................

ការដកហូត និងការឃាត់ទុក: ..............................

ចំនួនទឹកប្រាក់ពិតប្រាកដត្រូវបើក: ..............................

វិធីទូទាត់: ☐ មូលប្បទានបត្រ ☐ សាច់ប្រាក់

លេខគណនី:

អាសយដ្ឋានធនាគារ ឬរតនាគារ:

អត្ថគាហក: (ទទួលសាច់ប្រាក់)

បានទទួល

កាលបរិច្ឆេទ:

ការត្រួតពិនិត្យ និងអនុញ្ញាតឱ្យបើកផ្តល់

ហត្ថលេខា និងត្រា

កាលបរិច្ឆេទ:

២.៣. គំរូសលាកបត្រតាមដានចំណូលថវិកា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

{Logo}
{ឈ្មោះក្រសួង ស្ថាប័ន}/{ឈ្មោះរដ្ឋបាលថ្នាក់ក្រោមជាតិ}
{ឈ្មោះអង្គភាព}
{លេខកូដក្នុងប្រព័ន្ធ FMIS:…………}

ថ្ងៃ.............ខែ.............ឆ្នាំ..........ស័ក ព.ស................
ធ្វើនៅ............ថ្ងៃទី........ខែ.........ឆ្នាំ...........................

**សលាកបត្រតាមដានចំណូលថវិកា**
**ប្រចាំខែ............ឆ្នាំ...........**

| ល.រ | លេខសលាកបត្រ | កាលបរិច្ឆេទចុះបញ្ជី | សរុបទឹកប្រាក់ | អនុគណនី | | |
|---|---|---|---|---|---|---|
| ក.ច្បាប់ហិរញ្ញវត្ថុ | | | | ៧៣០២៣ | ៧៣០... | ៧៣០... |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| ខ.សរុបក្នុងគ្រា | | | | | | |
| គ.យោងគ្រាមុន/ដើមគ្រា | | | | | | |
| ឃ.សរុបចុងគ្រា (ខ+គ) | | | | | | |
| %ធៀបច្បាប់ហិរញ្ញវត្ថុ (ឃ/ក) | | | | | | |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

{Logo}
{ឈ្មោះគ្រឹះស្ថានសាធារណៈរដ្ឋបាល}

# សលាកបត្រតាមដានចំណូលថវិកា
## ប្រចាំខែ............ឆ្នាំ...........

-ឈ្មោះគណនី/អនុគណនី៖.................................................................................................
-លេខគណនី/អនុគណនី៖...................................................................................................
-ឥណទានអនុម័ត៖.........................................................................................................

| ល.រ | កាលបរិច្ឆេទ | បរិយាយ | យោង | ចលនា | | សមតុល្យ | %ច្បាប់ |
|---|---|---|---|---|---|---|---|
| | | | | កើន (+) | ថយ (-) | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| សរុបប្រចាំខែ | | | | | | | |
| សរុបបូកបន្ត | | | | | | | |
| សរុបប្រចាំឆ្នាំ | | | | | | | |

ថ្ងៃ......... ខែ.......ឆ្នាំ......ស័ក ព.ស........
ធ្វើនៅ.........ថ្ងៃទី....ខែ......ឆ្នាំ................

គណនេយ្យករប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល

២.៤. គំរូសលាកបត្រតាមដានចំណាយថវិកា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

{Logo}
**{ឈ្មោះក្រសួង ស្ថាប័ន}**
**{ឈ្មោះអង្គភាព}**
លេខ...........................

# សលាកបត្រតាមដានចំណាយថវិកា
## ប្រចាំខែ............ឆ្នាំ...........

-លេខសម្គាល់៖ {លេខកូដក្រសួងឬអង្គភាព}

-ឈ្មោះគណនី/អនុគណនី៖.........................................................................................
-លេខគណនី/អនុគណនី៖.........................................................................................................
-ឥណទានអនុម័ត៖.........................................................................................................................
-ឥណទានកែតម្រូវ៖.........................................................................................................................
-ការតាមដានចលនា/និយ័តភាពឥណទានថវិកា៖

| ល.រ | កាលបរិច្ឆេទ | បរិយាយ | យោង | ចលនា/និយ័តភាពឥណទាន | | | | | ឥណទានកែតម្រូវ |
|---|---|---|---|---|---|---|---|---|---|
| | | | | កើន (+) | | | | ថយ (-) | |
| | | | | កើនផ្ទៃក្នុង | មិនបានគ្រោង | បន្ថែម | សរុប | | |
| | | | | | | | | | |
| | | | | | | | | | |

-ការតាមដានការអនុវត្តចំណាយ

| ល.រ | កាលបរិច្ឆេទ | បរិយាយ | យោង | អនុវត្តចំណាយ | | | ឥណទាននៅសល់ *(ឥណទានកែតម្រូវ-អនុវត្តចំណាយចុងគ្រា)* |
|---|---|---|---|---|---|---|---|
| | | | | ដើមគ្រា | ក្នុងគ្រា | ចុងគ្រា | |
| | | | | | | | |
| | | | | | | | |
| សរុបប្រចាំខែ | | | | | | | |
| សរុបបូកបន្ត | | | | | | | |
| សរុបប្រចាំឆ្នាំ | | | | | | | |

ថ្ងៃ......... ខែ.......ឆ្នាំ......ស័ក ព.ស........
ធ្វើនៅ.........ថ្ងៃទី....ខែ......ឆ្នាំ................

២.៥. គំរូសលាកបត្របង់សំណៃសចំណាយ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង ស្ថាប័ន មន្ទីរ.....
អង្គភាព........
លេខ...........

| |
|---|
| លេខសម្គាល់ : |
| លេខគណនីឥណពន្ធ : |
| លេខគណនីឥណទាន : |

## សលាកបត្របង់សំណៃសចំណាយ

-ឈ្មោះ និងអាសយដ្ឋាននៃអង្គភាពគ្រប់គ្រង ៖.......................................................................................

-ឈ្មោះ និងអាសយដ្ឋាននៃអង្គភាពបង់សំណៃសចំណាយ ៖..........................................................................

-ស្នើរធនាគារកណ្តាល កត់ត្រាបន្ថយទឹកប្រាក់ចំណាយថវិកានៅក្នុងជំពូក គណនី អនុគណនី ដូចខាងក្រោម៖

| ល.រ | អត្ថន័យនៃការបង់ប្រាក់ | ជំពូក | គណនី | អនុគណនី | ចំនួនទឹកប្រាក់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | | | | | |
| សរុប | | | | | | |

សរុបទឹកប្រាក់ជាអក្សរ៖(......................................)

ផ្នែកខាងអាណាប័ក រដ្ឋបាលថ្នាក់ជាតិ ឬ រដ្ឋបាលថ្នាក់ក្រោមជាតិ ឬ គ្រឹះស្ថានសាធារណៈរដ្ឋបាល

ថ្ងៃ........ខែ....ឆ្នាំ.....ស័ក ព.ស.........
ធ្វើនៅ.......... ថ្ងៃទី......ខែ.......ឆ្នាំ.....

ផ្នែកខាងគណនេយ្យករសាធារណៈ

ថ្ងៃ........ខែ....ឆ្នាំ.....ស័ក ព.ស.........
ធ្វើនៅ.......... ថ្ងៃទី......ខែ.......ឆ្នាំ.....

**ឧបសម្ព័ន្ធ៣៖ ទម្រង់របាយការណ៍ថវិកា**

៣.១. ទម្រង់របាយការណ៍ចំណូលថវិកា

(តារាងទី១)

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

{Logo}

{ឈ្មោះក្រសួង ស្ថាប័ន}

{ឈ្មោះអង្គភាព}

# របាយការណ៍ចំណូលថវិកា

**ចាប់ពីថ្ងៃទី.......ខែ.......ឆ្នាំ....... ដល់ថ្ងៃទី.......ខែ.......ឆ្នាំ........**

ឯកតា៖ រៀល

| មាតិកា | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | ដើមគ្រា | | | ក្នុងគ្រា | | | ចុងគ្រា | | | អនុវត្ត/ច្បាប់ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | រតនាគារកណ្ដាល | រតនាគាររាជធានី ខេត្ត | សរុប | រតនាគារកណ្ដាល | រតនាគាររាជធានី ខេត្ត | សរុប | រតនាគារកណ្ដាល | រតនាគាររាជធានី ខេត្ត | សរុប | %ច្បាប់ |
| 1 | 2 | 3 | 4 | 5 | 6=4+5 | 7 | 8 | 9=7+8 | 10=4+7 | 11=5+8 | 12=10+11 | 13=12/3 |
| សរុបរួម | | | | | | | | | | | | |
| សរុប (លេខកូដ-ក្រសួង ស្ថាប័ន) | | | | | | | | | | | | |
| លេខអនុគណនី | | | | | | | | | | | | |
| ........... | | | | | | | | | | | | |
| សរុប (លេខកូដ-ក្រសួង ស្ថាប័ន) | | | | | | | | | | | | |
| លេខអនុគណនី | | | | | | | | | | | | |
| ........... | | | | | | | | | | | | |
| សរុប (លេខកូដ-ក្រសួង ស្ថាប័ន) | | | | | | | | | | | | |
| លេខអនុគណនី | | | | | | | | | | | | |
| ........... | | | | | | | | | | | | |

**ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា**
**អគ្គនាយក នៃអគ្គនាយកដ្ឋានរតនាគារជាតិ**

**ប្រធាននាយកដ្ឋាន**

**ប្រធានការិយាល័យ**

ភ្នំពេញ ថ្ងៃទី......... ខែ............ឆ្នាំ...............
**អ្នកធ្វើតារាង**

(តារាងទី២)

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

{Logo}

{ឈ្មោះក្រសួង ស្ថាប័ន}

{ឈ្មោះអង្គភាព}

# របាយការណ៍ចំណូលថវិកា (ថ្នាក់ជាតិ)

## ចាប់ពីថ្ងៃទី......ខែ.......ឆ្នាំ...... ដល់ថ្ងៃទី......ខែ......ឆ្នាំ........

ឯកតា៖ រៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ឆ្នាំ២០XX | | អនុវត្ត/ច្បាប់ហិរញ្ញវត្ថុ | | ឈ្មោះក្រសួង ស្ថាប័ន<br>អង្គភាពសាធារណៈប្រហាក់ប្រហែល |
|---|---|---|---|---|---|---|---|---|
| | | | | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | %ច្បាប់ | លើស (+) /ខ្វះ (-) | |
| សរុបរួមចំណូលថវិកាថ្នាក់ជាតិ (ប្រភេទ១+ប្រភេទ២+ប្រភេទ៣) | | | | | | | | |
| ចំណូលក្នុងប្រទេស (ប្រភេទ១+ប្រភេទ២+៣.១) | | | | | | | | |
| ចំណូលចរន្ត (ប្រភេទ១+ប្រភេទ២) | | | | | | | | |
| ប្រភេទ១: ចំណូលសារពើពន្ធ | | | | | | | | |
| | | | | | | | | |
| ប្រភេទ២: ចំណូលមិនមែនសារពើពន្ធ | | | | | | | | |
| | | | | | | | | |
| ប្រភេទ៣: ចំណូលផ្សេងៗ (៣.១+៣.២) | | | | | | | | |
| ៣.១ ចំណូលផ្សេងៗក្នុងប្រទេស | | | | | | | | |
| | | | | | | | | |
| ៣.២ ហិរញ្ញប្បទានឥតសំណង | | | | | | | | |
| | | | | | | | | |

{Logo}

{ឈ្មោះគ្រឹះស្ថានសាធារណៈរដ្ឋបាល}

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍ចំណូលថវិកា (គ្រឹះស្ថានសាធារណៈរដ្ឋបាល)

## ចាប់ពីថ្ងៃទី......ខែ........ឆ្នាំ....... ដល់ថ្ងៃទី......ខែ......ឆ្នាំ........

ឯកតា៖ រៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | | អនុវត្តជាក់ស្តែង | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣=២/១ | |
| | | | សរុបរួម(I+II)<br><br>I-ផ្នែករដ្ឋបាលកណ្តាល<br><br>II-ផ្នែកមន្ទីរជំនាញរាជធានី ខេត្ត | | | | |
| | | | សរុបរួម | | | | |

នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល

គណនេយ្យករសាធារណៈ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

{Logo}
{ឈ្មោះរដ្ឋបាលរាជធានី ខេត្ត}

# របាយការណ៍ចំណូលថវិកា (រដ្ឋបាលរាជធានី ខេត្ត)
## ចាប់ពីថ្ងៃទី......ខែ.......ឆ្នាំ...... ដល់ថ្ងៃទី......ខែ......ឆ្នាំ........

ឯកតា៖ រៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ឆ្នាំ | | អនុវត្ត/ច្បាប់ហិរញ្ញវត្ថុ | | ឈ្មោះរាជធានី ខេត្ត |
|---|---|---|---|---|---|---|---|---|
| | | | | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | %ច្បាប់ | លើស (+) /ខ្វះ (-) | |
| សរុបរួមចំណូលថវិការដ្ឋបាលរាជធានី ខេត្ត (ប្រភេទ១+ប្រភេទ២+ប្រភេទ៣) | | | | | | | | |
| ប្រភេទ១: ចំណូលសារពើពន្ធ | | | | | | | | |
| | | | | | | | | |
| ប្រភេទ២: ចំណូលមិនមែនសារពើពន្ធ | | | | | | | | |
| | | | | | | | | |
| ប្រភេទ៣: ចំណូលផ្សេងៗ (៣.១+៣.២) | | | | | | | | |
| ៣.១ ចំណូលផ្សេងៗក្នុងប្រទេស | | | | | | | | |
| | | | | | | | | |
| ៣.២ ហិរញ្ញប្បទានឥតសំណង | | | | | | | | |
| | | | | | | | | |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

{Logo}

**ឈ្មោះរដ្ឋបាលក្រុង/ ស្រុក/ ខណ្ឌ**

# របាយការណ៍ចំណូលថវិកា (រដ្ឋបាលក្រុង/ ស្រុក/ ខណ្ឌ)

## ចាប់ពីថ្ងៃទី......ខែ.......ឆ្នាំ...... ដល់ថ្ងៃទី......ខែ......ឆ្នាំ.........

ឯកតា៖ រៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | ចលនាឥណទាន | | | | | ច្បាប់ហិរញ្ញវត្ថុ កែតម្រូវ | សមតុល្យ ដើមគ្រា | អនុវត្ត | សមតុល្យចុងគ្រា | អនុវត្តលើស(+)/ខ្វះ(-) | %ប្រៀបធៀប | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | កើន | | | | ថយ | | | | | | | |
| | | | | | កើន ផ្ទៃក្នុង | មិនបាន គ្រោងទុក | បំពេញ បន្ថែម | សរុប | | | | | | | %ច្បាប់ | %ច្បាប់ កែតម្រូវ |
| | | | 1 | 2 | 3 | 4 | 5 | 6 = 3+4+5 | 7 | 8 = 2+6-7 | 9 | 10 | 11 = 9+10 | 12 = 8-11 | 13 = 11/2 % | 14 = 11/8 % |
| សរុបរួមចំណូលថវិការដ្ឋបាលក្រុង ស្រុក ខណ្ឌ (ប្រភេទ១+ប្រភេទ២+ប្រភេទ៣) | | | | | | | | | | | | | | | | |
| ប្រភេទ១ : ចំណូលសារពើពន្ធ | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | |
| ប្រភេទ២ : ចំណូលមិនមែនសារពើពន្ធ | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | |
| ប្រភេទ៣ : ចំណូលផ្សេងៗ (៣.១+៣.២) | | | | | | | | | | | | | | | | |
| ៣.១ ចំណូលផ្សេងៗក្នុងប្រទេស | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | |
| ៣.២ ហិរញ្ញប្បទានឥតសំណង | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

{Logo}

**ឈ្មោះរដ្ឋបាលឃុំ/ សង្កាត់**

# របាយការណ៍ចំណូលថវិកា (រដ្ឋបាលឃុំ/ សង្កាត់)

## ចាប់ពីថ្ងៃទី......ខែ.......ឆ្នាំ...... ដល់ថ្ងៃទី......ខែ......ឆ្នាំ.........

ឯកតា៖ រៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | ចលនាឥណទាន | | | | | ច្បាប់ហិរញ្ញវត្ថុកែតម្រូវ | សមតុល្យដើមគ្រា | អនុវត្ត | សមតុល្យចុងគ្រា | អនុវត្តលើស(+) / ខ្វះ(-) | %ប្រៀបធៀប | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | កើន | | | | ថយ | | | | | | %ច្បាប់ | %ច្បាប់កែតម្រូវ |
| | | | | | កើនផ្ទៃក្នុង | មិនបានគ្រោងទុក | បំពេញបន្ថែម | សរុប | | | | | | | | |
| | | | 1 | 2 | 3 | 4 | 5 | 6 = 3+4+5 | 7 | 8 = 2+6-7 | 9 | 10 | 11 = 9+10 | 12 = 8-11 | 13 = 11/2 % | 14 = 11/8 % |
| សរុបរួមចំណូលថវិការដ្ឋបាលឃុំ/សង្កាត់ (ប្រភេទ១+ប្រភេទ២+ប្រភេទ៣) | | | | | | | | | | | | | | | | |
| ប្រភេទ១ : ចំណូលសារពើពន្ធ | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | |
| ប្រភេទ២ : ចំណូលមិនមែនសារពើពន្ធ | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | |
| ប្រភេទ៣ : ចំណូលផ្សេងៗ (៣.១+៣.២) | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | |
| ៣.១ ចំណូលផ្សេងៗក្នុងប្រទេស | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | |
| ៣.២ ហិរញ្ញប្បទានឥតសំណង | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | |

៣.២. ទម្រង់របាយការណ៍ចំណាយថវិកា
(តារាងទី១)

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

{Logo}
{ឈ្មោះក្រសួង ស្ថាប័ន}
{ឈ្មោះអង្គភាព}
លេខ............................

# របាយការណ៍ចំណាយថវិកា

## ចាប់ពីថ្ងៃទី....ខែ....ឆ្នាំ.......ដល់ ថ្ងៃទី.......ខែ......ឆ្នាំ........

ឯកតា៖ រៀល

<table>
<tr><th rowspan="3">ជំពូក</th><th rowspan="3">គណនី</th><th rowspan="3">អនុគណនី</th><th rowspan="3">បរិយាយ</th><th rowspan="3">ច្បាប់ហិរញ្ញវត្ថុ</th><th colspan="5">ចលនាឥណទាន</th><th rowspan="2">ច្បាប់ហិរញ្ញវត្ថុកែតម្រូវ</th><th colspan="3">អនុវត្ត</th><th rowspan="2">ឥណទាននៅសល់</th><th colspan="2">%ប្រៀបធៀប</th></tr>
<tr><th colspan="4">កើន</th><th rowspan="2">ថយ</th><th>ដើមគ្រា</th><th>ក្នុងគ្រា</th><th>ចុងគ្រា</th><th>%ច្បាប់</th><th>%ច្បាប់កែតម្រូវ</th></tr>
<tr><th>កើនផ្ទៃក្នុង</th><th>មិនបានគ្រោង</th><th>បំពេញបន្ថែម</th><th>សរុប</th><th></th><th></th><th></th><th></th><th></th><th></th><th></th></tr>
<tr><td colspan="4">1</td><td>2</td><td>3</td><td>4</td><td>5</td><td>6=3+4+5</td><td>7</td><td>8=2+6-7</td><td>9</td><td>10</td><td>11=9+10</td><td>12=8-11</td><td>13=11/2%</td><td>14=11/8%</td></tr>
<tr><td colspan="4">សរុបរួមចំណាយថវិកា (ក+ខ)</td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td></tr>
<tr><td colspan="4">ក.សរុបចំណាយចរន្ត</td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td></tr>
<tr><td colspan="4">ខ.សរុបចំណាយវិនិយោគ</td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td></tr>
</table>

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| I.ផ្នែករដ្ឋបាលកណ្តាល | | | | | | | | | | | | | |
| II.ផ្នែកមន្ទីរជំនាញរាជធានី ខេត្ត | | | | | | | | | | | | | |
| ប្រភេទ១: បន្ទុកបុគ្គលិក | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| ប្រភេទ២: ចំណាយប្រតិបត្តិការ | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| ប្រភេទ៣: បន្ទុកហិរញ្ញវត្ថុ | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| ប្រភេទ៥: ការផ្ទេរ | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| ប្រភេទ៦: ចំណាយផ្សេងៗ | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| ខ.សរុបចំណាយមូលធន | | | | | | | | | | | | | |
| ប្រភេទ៤: ចំណាយវិនិយោគ | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| I.ផ្នែករដ្ឋបាលកណ្តាល (ក+ខ) | | | | | | | | | | | | | |
| ក.ចំណាយចរន្ត | | | | | | | | | | | | | |
| ខ.ចំណាយវិនិយោគ | | | | | | | | | | | | | |
| ប្រភេទ១: បន្ទុកបុគ្គលិក | | | | | | | | | | | | | |

| | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | |
| ប្រភេទ២: ចំណាយប្រតិបត្តិការ | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | |
| ប្រភេទ៣: បន្ទុកហិរញ្ញវត្ថុ | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | |
| ប្រភេទ៥: ការផ្ទេរ | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | |
| ប្រភេទ៦: ចំណាយផ្សេងៗ | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | |
| ខ.សរុបចំណាយមូលធន | | | | | | | | | | | | | | | | | |
| ប្រភេទ៤: ចំណាយវិនិយោគ | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | |
| II.ផ្នែកមន្ទីរជំនាញរាជធានី ខេត្ត (ក+ខ) | | | | | | | | | | | | | | | | | |
| ក.ចំណាយចរន្ត | | | | | | | | | | | | | | | | | |
| ខ.ចំណាយវិនិយោគ | | | | | | | | | | | | | | | | | |
| ប្រភេទ១: បន្ទុកបុគ្គលិក | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | |
| ប្រភេទ២: ចំណាយប្រតិបត្តិការ | | | | | | | | | | | | | | | | | |

| | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | | | | | | | | |
| ប្រភេទ៣: បន្ទុកហិរញ្ញវត្ថុ | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | |
| ប្រភេទ៥: ការផ្ទេរ | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | |
| ប្រភេទ៦: ចំណាយផ្សេងៗ | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | |
| ខ.សរុបចំណាយមូលធន | | | | | | | | | | | | | | | | | |
| ប្រភេទ៤: ចំណាយវិនិយោគ | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | |

ផ្នែកខាងអាណាប័ក រដ្ឋបាលថ្នាក់ជាតិ ឬ គ្រឹះស្ថានសាធារណៈរដ្ឋបាល

ផ្នែកខាងគណនេយ្យករសាធារណៈ

(តារាងទី២)

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

{Logo}
{ឈ្មោះក្រសួង ស្ថាប័ន}
{ឈ្មោះអង្គភាព}
លេខ............................

# របាយការណ៍ចំណាយថវិកា (ថ្នាក់ជាតិ)
## ចាប់ពីថ្ងៃទី....ខែ....ឆ្នាំ.......ដល់ ថ្ងៃទី.......ខែ......ឆ្នាំ........

ឯកតា៖ រៀល

| វិស័យ ក្រសួង ស្ថាប័ន ប្រភេទចំណាយ | ឆ្នាំ.... | | អនុវត្ត/ច្បាប់ហិរញ្ញវត្ថុ | |
|---|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ(*) | អនុវត្ត | %ច្បាប់ | កើន (+)/ថយ (-) |
| | 1 | 2 | 3=2/1 | 4=2-1 |
| **សរុបរួមចំណាយថវិកា** | | | | |
| ប្រភេទ១៖ បន្ទុកបុគ្គលិក | | | | |
| ប្រភេទ២៖ ចំណាយប្រតិបត្តិការ | | | | |
| ប្រភេទ៣៖ បន្ទុកហិរញ្ញវត្ថុ | | | | |
| ប្រភេទ៥៖ ការផ្ទេរ | | | | |
| ប្រភេទ៦៖ ចំណាយផ្សេងៗ | | | | |
| **សរុបចំណាយឆ្លងកាត់រតនាគារជាតិ (១+២)** | | | | |
| ១.ចំណាយចរន្ត | | | | |

| | | | | |
|---|---|---|---|---|
| ប្រភេទ១៖ បន្ទុកបុគ្គលិក | | | | |
| ប្រភេទ២៖ ចំណាយប្រតិបត្តិការ | | | | |
| ប្រភេទ៣៖ បន្ទុកហិរញ្ញវត្ថុ | | | | |
| ប្រភេទ៥៖ ការផ្ទេរ | | | | |
| ប្រភេទ៦៖ ចំណាយផ្សេងៗ | | | | |
| **ក.រដ្ឋបាលកណ្ដាល** | | | | |
| **ក.១.ចំណាយចរន្ត** | | | | |
| ប្រភេទ១៖ បន្ទុកបុគ្គលិក | | | | |
| ប្រភេទ២៖ ចំណាយប្រតិបត្តិការ | | | | |
| ប្រភេទ៣៖ បន្ទុកហិរញ្ញវត្ថុ | | | | |
| ប្រភេទ៥៖ ការផ្ទេរ | | | | |
| ប្រភេទ៦៖ ចំណាយផ្សេងៗ | | | | |
| **ខ.មន្ទីរជំនាញក្រោមឱវាទ** | | | | |
| **ខ.១ ចំណាយចរន្ត** | | | | |
| ប្រភេទ១៖ បន្ទុកបុគ្គលិក | | | | |
| ប្រភេទ២៖ ចំណាយប្រតិបត្តិការ | | | | |
| ប្រភេទ៣៖ បន្ទុកហិរញ្ញវត្ថុ | | | | |
| ប្រភេទ៥៖ ការផ្ទេរ | | | | |
| ប្រភេទ៦៖ ចំណាយផ្សេងៗ | | | | |
| **គ.វិស័យ....** | | | | |

| | | | | |
|---|---|---|---|---|
| **ចំណាយចរន្ត** | | | | |
| ប្រភេទ១៖ បន្ទុកបុគ្គលិក | | | | |
| ប្រភេទ២៖ ចំណាយប្រតិបត្តិការ | | | | |
| ប្រភេទ៣៖ បន្ទុកហិរញ្ញវត្ថុ | | | | |
| ប្រភេទ៥៖ ការផ្ទេរ | | | | |
| ប្រភេទ៦៖ ចំណាយផ្សេងៗ | | | | |
| **០១-ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល** | | | | |
| **ចំណាយចរន្ត** | | | | |
| ប្រភេទ១៖ បន្ទុកបុគ្គលិក | | | | |
| ប្រភេទ២៖ ចំណាយប្រតិបត្តិការ | | | | |
| ប្រភេទ៣៖ បន្ទុកហិរញ្ញវត្ថុ | | | | |
| ប្រភេទ៥៖ ការផ្ទេរ | | | | |
| ប្រភេទ៦៖ ចំណាយផ្សេងៗ | | | | |
| **ខ. ចំណាយមិនទាន់បែងចែក** | | | | |
| ជំពូក៦៥៖ ចំណាយចរន្តក្នុងការអនុវត្តគម្រោង | | | | |
| ជំពូក៦៦៖ បន្ទុកហិរញ្ញវត្ថុ (ការប្រាក់) | | | | |
| ប្រភេទ៥៖ ចំណាយផ្សេងៗ(ឧបត្ថម្ភរាជធានី-ខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់) | | | | |
| ជំពូក៦៥៖ ការប្រគល់មុខងារអប់រំ និងសុខាភិបាល | | | | |
| ជំពូក៦៩៖ ចំណាយមិនបានគ្រោងទុក | | | | |
| -ចំណាយត្រៀមបំរុង | | | | |

| | | | | |
|---|---|---|---|---|
| -ចំណាយផ្សេងៗ | | | | |
| **២. ចំណាយមូលធន** | | | | |
| **វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស(១+២+៣)** | | | | |
| **១.គម្រោងវិនិយោគផ្ទាល់** | | | | |
| -គម្រោងវិនិយោគតាមក្រសួង ស្ថាប័ន | | | | |
| (ឈ្មោះក្រសួង ស្ថាប័ន...) | | | | |
| -គម្រោងវិនិយោគក្នុងចំណាយមិនទាន់បែងចែក | | | | |
| • គម្រោងវិនិយោគ | | | | |
| • ជំពូក២៦៖ ការវិនិយោគ | | | | |
| • ជំពូក២៧៖ អចលកម្មហិរញ្ញវត្ថុផ្សេងៗ | | | | |
| **២.បដិភាគវិនិយោគ** | | | | |
| -ចំណាយមិនទាន់បែងចែក | | | | |
| **៣.មូលនិធិទ្រទ្រង់ថវិកា** | | | | |
| -ចំណាយមិនទាន់បែងចែក | | | | |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

{Logo}
{ឈ្មោះរដ្ឋបាលរាជធានី ខេត្ត}
លេខ............................

# របាយការណ៍ចំណាយថវិកា (រដ្ឋបាលរាជធានី ខេត្ត)
# ចាប់ពីថ្ងៃទី....ខែ....ឆ្នាំ.......ដល់ ថ្ងៃទី.......ខែ......ឆ្នាំ........

ឯកតា៖ រៀល

| បរិយាយ | ឆ្នាំ.... | | អនុវត្ត/ច្បាប់ហិរញ្ញវត្ថុ | |
|---|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ(*) | អនុវត្ត | %ច្បាប់ | កើន (+)/ ថយ (-) |
| | 1 | 2 | 3=2/1 | 4=2-1 |
| សរុបរួម | | | | |
| ក- ចំណាយចរន្ត | | | | |
| ប្រភេទ១៖ បន្ទុកបុគ្គលិក | | | | |
| ប្រភេទ២៖ ចំណាយប្រតិបត្តិការ | | | | |
| ប្រភេទ៥៖ ការផ្ទេរ | | | | |
| ប្រភេទ៦៖ ចំណាយផ្សេងៗ | | | | |
| ខ.ចំណាយមូលធន | | | | |
| ប្រភេទ៤៖ ចំណាយវិនិយោគ | | | | |
| ០១- ឈ្មោះ រាជធានី ខេត្ត | | | | |
| ក.ចំណាយចរន្ត | | | | |

| | | | | |
|---|---|---|---|---|
| ប្រភេទ១៖ បន្ទុកបុគ្គលិក | | | | |
| ប្រភេទ២៖ ចំណាយប្រតិបត្តិការ | | | | |
| ប្រភេទ៥៖ ការផ្ទេរ | | | | |
| ប្រភេទ៦៖ ចំណាយផ្សេងៗ | | | | |
| **ខ.ចំណាយមូលធន** | | | | |
| ប្រភេទ៤៖ ចំណាយវិនិយោគ | | | | |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

{Logo}

{ឈ្មោះរដ្ឋបាលក្រុង/ ស្រុក}

លេខ.............................

# របាយការណ៍ចំណាយថវិកា (រដ្ឋបាលក្រុង/ ស្រុក)

## ចាប់ពីថ្ងៃទី.......ខែ........ឆ្នាំ...... ដល់ថ្ងៃទី.......ខែ.......ឆ្នាំ.........

ឯកតា៖ រៀល

| បរិយាយ | ឆ្នាំ... | | អនុវត្ត/ច្បាប់ហិរញ្ញវត្ថុ | |
|---|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ(*) | អនុវត្ត | %ច្បាប់ | កើន(+)/ថយ(-) |
| | 1 | 2 | 3=2/1 | 4=2-1 |
| សរុបរួម | | | | |
| ក-ចំណាយចរន្ត | | | | |
| ប្រភេទ១៖ បន្ទុកបុគ្គលិក | | | | |
| ប្រភេទ២៖ ចំណាយប្រតិបត្តិការ | | | | |
| ប្រភេទ៣៖ បន្ទុកហិរញ្ញវត្ថុ | | | | |
| ប្រភេទ៥៖ ការផ្ទេរ | | | | |
| ប្រភេទ៦៖ ចំណាយផ្សេងៗ | | | | |
| ខ-ចំណាយមូលធន | | | | |
| ប្រភេទ៤៖ ចំណាយវិនិយោគ | | | | |
| ០១-ឈ្មោះ ខេត្ត | | | | |
| ក-ចំណាយចរន្ត | | | | |

| | | | | |
|---|---|---|---|---|
| ប្រភេទ១៖ បន្ទុកបុគ្គលិក | | | | |
| ប្រភេទ២៖ ចំណាយប្រតិបត្តិការ | | | | |
| ប្រភេទ៣៖ បន្ទុកហិរញ្ញវត្ថុ | | | | |
| ប្រភេទ៥៖ ការផ្ទេរ | | | | |
| ប្រភេទ៦៖ ចំណាយផ្សេងៗ | | | | |
| **ខ-ចំណាយមូលធន** | | | | |
| ប្រភេទ៤៖ ចំណាយវិនិយោគ | | | | |

{Logo}

{ឈ្មោះរដ្ឋបាលឃុំ/ សង្កាត់}

លេខ............................

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

## របាយការណ៍ចំណាយថវិកា (រដ្ឋបាលឃុំ/ សង្កាត់)

ចាប់ពីថ្ងៃទី.......ខែ........ឆ្នាំ....... ដល់ថ្ងៃទី.......ខែ.......ឆ្នាំ.........

ឯកតា៖ រៀល

| បរិយាយ | ឆ្នាំ... | | អនុវត្ត/ច្បាប់ហិរញ្ញវត្ថុ | |
|---|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ( * ) | អនុវត្ត | %ច្បាប់ | កើន(+)/ថយ(-) |
| | 1 | 2 | 3=2/1 | 4=2-1 |
| សរុបរួម | | | | |
| ក-ចំណាយចរន្ត | | | | |
| ប្រភេទ១៖ បន្ទុកបុគ្គលិក | | | | |
| ប្រភេទ២៖ ចំណាយប្រតិបត្តិការ | | | | |
| ប្រភេទ៣៖ បន្ទុកហិរញ្ញវត្ថុ | | | | |
| ប្រភេទ៥៖ ការផ្ទេរ | | | | |
| ប្រភេទ៦៖ ចំណាយផ្សេងៗ | | | | |
| ខ-ចំណាយមូលធន | | | | |
| ប្រភេទ៤៖ ចំណាយវិនិយោគ | | | | |
| ០១-ឈ្មោះ ខេត្ត | | | | |
| ក-ចំណាយចរន្ត | | | | |
| ប្រភេទ១៖ បន្ទុកបុគ្គលិក | | | | |

| | | | | |
|---|---|---|---|---|
| ប្រភេទ២៖ ចំណាយប្រតិបត្តិការ | | | | |
| ប្រភេទ៣៖ បន្ទុកហិរញ្ញវត្ថុ | | | | |
| ប្រភេទ៥៖ ការផ្ទេរ | | | | |
| ប្រភេទ៦៖ ចំណាយផ្សេងៗ | | | | |
| **ខ-ចំណាយមូលធន** | | | | |
| ប្រភេទ៤៖ ចំណាយវិនិយោគ | | | | |

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋានរតនាគារជាតិ**

អគារលេខ១៩ វុក្ខវិថីព្រះមហាក្សត្រីយានីកុសមៈ
(ផ្លូវលេខ១០៦) សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
អ៊ីម៉ែល៖ info@treasury.gov.kh
វេបសាយ៖ www.treasury.gov.kh